# មេរៀន

## សម្រាប់ការបណ្តុះបណ្តាលលើការងារមហាជន រាជធានី-ខេត្ត

រៀបចំដោយ៖ គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល

ឆ្នាំ២០២៥

# មាតិកា

បុព្វកថា
អារម្ភកថា
មេរៀនទី១ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ គណៈចលនាមហាជន ........ ១
I. បុព្វកថា ........ ២
II. ប្រវត្តិនៃការងារចលនាមហាជនរបស់គណបក្ស ........ ៥
III. តួនាទី ភារកិច្ច រចនាសម្ព័ន្ធគណៈចលនាមហាជន ........ ១១
IV. របៀបរបបធ្វើការរបស់គណៈចលនាមហាជនគ្រប់ថ្នាក់ ........ ២២
V. វិធីសាស្ត្រ ចរិត អតិក្រម ការងារចលនាមហាជន ........ ២៣
មេរៀនទី២ វិធីសាស្ត្រគោលក្នុងការប្រឈម និងការគ្រប់គ្រង សមរភូមិសតិអារម្មណ៍ "ព័ត៌មាន សាធារណមតិ សតិ អារម្មណ៍មហាជន" ........ ២៥
I- សេចក្តីផ្តើម ........ ២៦
II- ភាពទាក់ទងគ្នារវាងកិច្ចការព័ត៌មាន សាធារណមតិ និងសតិអារម្មណ៍មហាជន ........ ២៨
III- មធ្យោបាយនានាប្រើប្រាស់ជាឧបករណ៍ក្នុងការងារព័ត៌មាននិងសាធារណមតិ ........ ២៩
IV- ការកំណត់វាយតម្លៃប្រធានបទសំខាន់ៗ ក្នុងការងារព័ត៌មាន និងសាធារណមតិ ........ ៣២
V- សាធារណមតិ និង សតិអារម្មណ៍មហាជន ........ ៣៥
VI- វិធីសាស្ត្រគោលក្នុងការប្រឈមនិងការគ្រប់គ្រងសមរភូមិសតិអារម្មណ៍ ........ ៣៦
VII- ឥទ្ធិពលបណ្តាញព័ត៌មានសង្គមលើការបោះឆ្នោត ........ ៣៨
VIII- សេចក្តីសន្និដ្ឋាន ÷ ការត្រិះរិះពិចារណា តើអ្វីជាមធ្យោបាយអំណាច? ........ ៣៩
មេរៀនទី៣ ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និង វិធីសាស្ត្រផ្សព្វផ្សាយ ........ ៤២
I. សេចក្តីផ្តើម ........ ៤៣
II. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យាព័ត៌មាន ........ ៤៣
III. ការរៀបចំខ្លឹមសារ ........ ៤៨
មេរៀនទី៤ ឯកសារជំនួយស្មារតី ស្តីពី យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងសមិទ្ធផលរបស់រាជរដ្ឋាភិបាល ........ ៦២
I. សេចក្តីផ្តើម ........ ៦៣
II. អំពីយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ........ ៦៥
III. សមិទ្ធផលរបស់រាជរដ្ឋាភិបាល ........ ៧២
IV. ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ៨៩
V. សេចក្តីសន្និដ្ឋាន ........ ៩៨
បរិសិដ្ឋ ........ ១០០

# បុព្វកថា

**គណបក្សប្រជាជនកម្ពុជា** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា បានបន្តថែរក្សាយ៉ាងខ្ជាប់ខ្ជួន ឥតប្រែប្រួល នូវគោលបំណង និងឧត្តមគតិរបស់ខ្លួន គឺប្រមូលកម្លាំងប្រជាជាតិទាំងមូលដែលមានឧត្តមគតិស្នេហាជាតិមាតុភូមិ ស្រឡាញ់លទ្ធិប្រជាធិបតេយ្យ និងសន្តិភាព ដោយមិនប្រកាន់ឋានៈ ជីវភាព ជនជាតិ ជំនឿសាសនា អតីតកាល ដើម្បីរួបរួមគ្នា កសាង អភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ក្នុងនោះ គណបក្សប្រជាជនកម្ពុជា បានដាក់ចេញកម្មវិធីនយោបាយជាបន្តបន្ទាប់ សំដៅកសាង ស្តារសន្តិភាព ស្ថិរភាពនយោបាយ អភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងពង្រឹងពង្រីកសក្តានុពល និងកិត្យានុភាពកម្ពុជាទាំងកម្រិតជាតិ និងអន្តរជាតិ។

ក្នុងរយៈពេលជាង៧ទសវត្សរ៍កន្លងមក គណបក្សប្រជាជនកម្ពុជា បានឆ្លងកាត់ដំណាក់កាលសាកល្បងជាច្រើន និងសម្រេចបានសមិទ្ធផលរាប់មិនអស់ រួមមាន ការចូលរួមប្រឆាំងនឹងពួកអាណានិគម ដើម្បីទាមទារឯករាជ្យជាតិ ការរំដោះប្រជាជាតិចេញពីរបបប្រល័យពូជសាសន៍ និងការបង្រួបបង្រួមឯកភាពទឹកដីកម្ពុជាទាំងមូលក្នុងឆ្នាំ១៩៩៨ ក្រោមគោលនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា ព្រមទាំងការដឹកនាំកសាងអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើនមកដល់សព្វថ្ងៃ។ ការណ៍នេះ បានសបញ្ជាក់ថា គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សតែមួយគត់ ដែលមានវ័យចំណាស់ជាងគេ ពោរពេញដោយបទពិសោធ ភាពចាស់ទុំ និងសមត្ថភាពខ្ពស់ ក្នុងការដឹកនាំប្រទេសជាតិប្រកបដោយភាពឆ្នៃប្រឌិត និងជាក់ស្តែង ស្របតាមបរិបទនៃសង្គមកម្ពុជា។

ក្នុងស្ថានភាពបរិបទនៃការបន្តវេនរបស់ថ្នាក់ដឹកនាំជំនាន់ថ្មី រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា បាននិងកំពុងដឹកនាំប្រទេសជាតិប្រកបដោយការទទួលខុសត្រូវខ្ពស់ និងក្នុងល្បឿនលឿន ឈានទៅមុខ សំដៅបន្តរក្សាឱ្យបាននូវ សន្តិភាព ស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់នូវអតិផរណា និងលើកកម្ពស់ជីវភាពប្រជាជនកម្ពុជាកាន់តែមានភាពល្អប្រសើរ។ ក្នុងរយៈពេលជាង២ឆ្នាំនេះ កម្ពុជាបានជួបប្រទះនូវវិញ្ញាសារ និងបញ្ហាប្រឈមជាច្រើន ពីកត្តាខាងក្រៅដោយរងឥទ្ធិពលពីបំរែបំរួលស្ថានភាពនយោបាយពិភពលោក សង្គ្រាមពាណិជ្ជកម្ម ការប្រទាញប្រទង់រវាងប្រទេសមហាអំណាច ការវិវត្តនៃបច្ចេកវិទ្យាថ្មីៗ ការតម្លើងពន្ធបដិការពើសហរដ្ឋអាមេរិចជាដើម ជាពិសេសការឈ្លានពានពីប្រទេសជិតខាង ជាមួយនឹងការវាយប្រហារជាបន្តបន្ទាប់របស់មជ្ឈដ្ឋានប្រឆាំង មកលើរាជរដ្ឋាភិបាលក្នុងចេតនាញុះញង់ បង្កចលាចល បង្កើតភាពមន្ទិលសង្ស័យ មកលើឆន្ទៈ ជំហរ និងសមត្ថភាពដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា។ តែទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលកម្ពុជាប្រកាន់ខ្ជាប់ស្មារតីនឹងនរ ដោះស្រាយបញ្ហា ដោយសន្តិវិធី ប្រកបដោយភាពវៃឆ្លាត បត់បែន និងប៉ិនប្រសប់ ដោយឈរលើមូលដ្ឋានច្បាប់

និងអត្ថប្រយោជន៍ជាតិ និងប្រជាជនជាគោល។ ទាំងអស់នេះ បានបង្ហាញអំពី ចក្ខុវិស័យនិងសមត្ថភាពដឹកនាំ ដោយមានភាពចាស់ទុំ គតិបណ្ឌិត និងភាពប្រាកដប្រជាតាមបរិបទកម្ពុជាស្របតាមទិសស្លោករបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា «ក្មេងមានកម្លាំង និងស្គាល់ផ្លូវ ឯចាស់មានបទពិសោធ»។

ក្នុងស្ថានភាពប្រឈមមុខនឹងវិបត្តិពីក្រៅប្រទេស និងត្រូវបន្តដឹកនាំអភិវឌ្ឍប្រទេសជាតិ ឱ្យកាន់តែមានភាពរឹងមាំ ធន់ និងបន្តរីកចម្រើន ការគ្រប់គ្រងឱ្យបាននូវស្ថានការណ៍ផ្ទៃក្នុង ជាពិសេស **ការងារគ្រប់គ្រងសតិអារម្មណ៍មហាជន និងការងារសមរភូមិសាធារណមតិ** គឺជាការងារចាំបាច់ ដើម្បីធានាការរួបរួម សាមគ្គីរវាងប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ដើម្បីគាំទ្រគ្នាទៅវិញមក និងជាខែលដ៏រឹងមាំសម្រាប់រាជរដ្ឋាភិបាល ក្នុងការបន្តដំណើរដឹកនាំប្រទេសជាតិឆ្ពោះទៅវិបុលភាព ដូចដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា បានលើកឡើងក្នុងពិធីបិទសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤៥ អាណត្តិទី៥ នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៥ ថា រចនាសម្ព័ន្ធគណបក្សទាំងអស់ ត្រូវធានាឱ្យបាននូវ **«សាមគ្គីភាព និងឯកភាព ផ្ទៃក្នុងបក្សឱ្យបានរឹងមាំ ទាំងទស្សនៈ នយោបាយ សតិអារម្មណ៍ គោលជំហរ និងសកម្មភាព ត្រូវស្រុះដៃ ស្មើគ្នា ប្រទាក់ក្រឡាគ្នា ជាអង្គតែមួយពីលើមកក្រោម ទាំងខ្សែបណ្តោយ និងខ្សែទទឹង មិនត្រឹមតែរូបភាព តែខ្លឹមសារស៊ីជម្រៅ»** ដែលជាកត្តាគន្លឹះនៃភាពជោគជ័យ និងប្រៀបឈ្នះរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការបន្តដឹកនាំប្រទេស។ ស្របជាមួយគ្នានេះ ដើម្បីពង្រឹងសតិអារម្មណ៍ និងលើកកម្ពស់សមត្ថភាពបន្ថែមនៃមន្ត្រីបក្ស ក្នុងការអនុវត្តទិសដៅខាងលើឱ្យល្អប្រសើរ ក្នុងសន្និបាតបូកសរុបការងារឆ្នាំ២០២៤ របស់គណៈចលនាមហាជន នាថ្ងៃទី១៧-១៨ ខែធ្នូ ឆ្នាំ២០២៤ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា ក៏បានណែនាំឱ្យគណៈចលនាមហាជន ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំ *«វគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីបក្សលើការងារមហាជន ទាំងគ្រូបង្គោល និងជនបង្គោលរបស់គណបក្សរាជធានី-ខេត្ត ដើម្បីធានានិរន្តរភាព និងប្រសិទ្ធភាព នៃការអនុវត្តការងារ និងការបំពេញតួនាទី ភារកិច្ច ឆ្លើយតប និងសំណូមពរ និងតម្រូវការជាក់ស្តែងរបស់ប្រជាជន និងប្រទេសជាតិ នៅគ្រប់ដំណាក់កាលឱ្យបានទាន់ពេលវេលា»* ។

គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល មានតួនាទី ភារកិច្ច ក្នុងការគ្រប់គ្រងការងារចលនាមហាជន ដោយត្រូវកសាងយន្តការសមស្របសំដៅអនុវត្តឱ្យបានជោគជ័យនូវកម្មវិធីនយោបាយ និងគោលនយោបាយរបស់គណបក្ស ព្រមទាំងត្រូវសហការជាមួយគណៈឃោសនាអប់រំ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល វគ្គបំពាក់បំប៉ននានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងសតិអារម្មណ៍ និងការងារសាធារណមតិរបស់មន្ត្រីបក្ស។

ស្របក្នុងស្មារតីនេះ គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល បានរៀបចំនូវវគ្គបណ្តុះបណ្តាលគ្រូបង្គោលលើការងារមហាជន សម្រាប់រាជធានី-ខេត្ត ដែលនេះគឺជាការងារដែលមានសារៈសំខាន់ និងចាំបាច់ ដែលមិនត្រឹមតែជួយលើកកម្ពស់សមត្ថភាពមន្ត្រីគណបក្សឱ្យមានមូលដ្ឋានច្បាស់លាស់ អំពី ឫសគល់ ប្រវត្តិ

ស្នាដៃ លក្ខន្តិកៈ កម្មវិធីនយោបាយ គោលនយោបាយ សេចក្ដីសម្រេចចិត្តនានារបស់គណបក្សប៉ុណ្ណោះទេ តែក៏ជាយន្តការបន្ថែម ក្នុងការពង្រឹងការងារមហាជន តាមរយៈការបំពាក់បំប៉នស្មារតី ដល់មន្ត្រីគណបក្សយើងឱ្យមានគោលជំហរតែមួយដូចគ្នាលើទិដ្ឋភាព ខ្លឹមសារ ទស្សនៈនយោបាយ និងសារនយោបាយ ព្រមទាំងរបៀបរបបការងារពីថ្នាក់កណ្ដាល រហូតដល់ថ្នាក់មូលដ្ឋាន សំដៅធ្វើសកម្មភាពការងារប្រកបដោយភាពស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងជាពិសេស ជាស្ពានផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋ ដ៏មានប្រសិទ្ធភាព ក្នុងការផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹង អំពីគោលនយោបាយ សមិទ្ធផលនានារបស់គណបក្ស និងរាជរដ្ឋាភិបាល ការជួយដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋតាមលទ្ធភាពជាក់ស្ដែង ក៏ដូចជាការទទួលស្ដាប់នូវ បញ្ហាប្រឈម សំណូមពរផ្សេងៗ ដើម្បីមានវិធានការដោះស្រាយនានាជាបន្តបន្ទាប់។

ក្នុងស្មារតីនេះ តាងនាមគណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ខ្ញុំសូមសម្ដែងការកោតសរសើរជូនចំពោះ **ឯកឧត្តម ហ៊ុន ម៉ានី** អគ្គលេខាធិការនៃគណៈចលនាមហាជន និងក្រុមការងាររៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលលើការងារមហាជន ដែលបានរៀបចំ **វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលលើការងារមហាជន សម្រាប់រាជធានី-ខេត្ត ជំនាន់ទី១** ឱ្យប្រព្រឹត្តទៅដោយរលូន ជោគជ័យ និងទទួលផ្លែផ្កាល្អប្រសើរ។ ជាមួយគ្នានេះ ក៏សូមលើកទឹកចិត្តឱ្យបន្តរៀបចំការបណ្ដុះបណ្ដាលនេះ ឱ្យដល់ថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់-ភូមិ ក្នុងជំហានបន្តបន្ទាប់ទៀត និងឱ្យជាប់ជាប្រចាំ ដើម្បីជាធាតុចូលថ្មីៗបន្ថែមទៀតសម្រាប់កម្មាភិបាលបក្សថ្នាក់ក្រោមជាតិ ដែលសកម្មភាពនេះ ក៏នឹងចូលរួមជាផ្នែកមួយសំខាន់ ក្នុងការបន្តថែរក្សា សាមគ្គីភាព ឯកភាពនៃរចនាសម្ព័ន្ធបក្សឱ្យកាន់តែរឹងមាំ កាន់តែប្រទាក់ក្រឡា សំដៅអនុវត្តតួនាទីឱ្យកាន់តែប្រសើរ ក្នុងការផ្សារភ្ជាប់ និងឆ្លើយតបជាមួយប្រជាពលរដ្ឋ ស្របតាមការណែនាំរបស់ **សម្ដេចតេជោ** គឺ **«ប្រជាជនជាកត្តាកំណត់ក្នុងការតស៊ូរំដោះជាតិ ការកសាង ការពារប្រទេស និងជាមូលដ្ឋានគ្រឹះ សម្រាប់ទ្រទ្រង់ដល់ការដឹកនាំខាងនយោបាយក្នុងសង្គមជាតិ។ គណបក្ស ត្រូវតែប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងយកប្រជាជនធ្វើជាគោលដៅនៃការបម្រើរបស់ខ្លួន»**។

ថ្ងៃ ច័ន្ទ ៩កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥

**គណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាល**

**ប្រធាន**

**សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន**

# អារម្ភកថា

ក្នុងសន្និបាតគណៈចលនាមហាជនកាលពីថ្ងៃទី១៧-១៨ ខែធ្នូ ឆ្នាំ២០២៤ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា បានណែនាំឱ្យគណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល *«រៀបចំវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីបក្សលើការងារមហាជន ទាំងគ្រូបង្គោល និងជនបង្គោលរបស់គណបក្សរាជធានី-ខេត្ត»*។ បន្ទាប់ពីទទួលបានគោលការណ៍ណែនាំ គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល បានរៀបចំសេចក្តីសម្រេចបង្កើតក្រុមការងារទទួលបន្ទុកវគ្គបណ្តុះបណ្តាលគ្រូបង្គោលលើការងារមហាជន ដែលក្នុងនោះ រយៈពេលជាង៣ខែ ចាប់ពីថ្ងៃទី៧ ខែមីនា ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ ២៥រាជធានី-ខេត្ត ជំនាន់ទី១ ដែលមានចំនួន៥វគ្គ រួចរាល់ និងប្រកបដោយជោគជ័យ។

ដើម្បីឱ្យការបណ្តុះបណ្តាល ទទួលបានផ្លែផ្កាល្អប្រសើរ និងមានប្រសិទ្ធភាពដូចការគ្រោងទុក ការរៀបចំវគ្គបណ្តុះបណ្តាលនេះ បានគិតគូរលើទិដ្ឋភាពចំនួន២ រួមមាន លក្ខណៈសម្បត្តិបេក្ខជន និងខ្លឹមសារដែលត្រូវបណ្តុះបណ្តាល សំដៅសម្រេចគោលដៅសំខាន់៣ រួមមាន ១)លើកកម្ពស់សមត្ថភាព និងបំពេញបន្ថែមនូវចំណេះដឹងជូនមន្ត្រីបក្ស ពាក់ព័ន្ធនឹងការងារចលនាមហាជន វិធីសាស្ត្រនៃគ្រប់គ្រងសមរភូមិសតិអារម្មណ៍ វិធីសាស្ត្រនៃការផ្សព្វផ្សាយ និងសមិទ្ធផលនានានៃយុទ្ធសាស្ត្របញ្ចកោណ ដើម្បីលើកកម្ពស់ការងារសាធារណមតិនៅថ្នាក់រាជធានី-ខេត្ត និងថ្នាក់មូលដ្ឋាន ២)ពង្រឹងបណ្តាញទំនាក់ទំនងនៃជនបង្គោលគណៈចលនាមហាជនរាជធានី-ខេត្ត ជាមួយគណៈចលនាមហាជនថ្នាក់កណ្តាល ក៏ដូចជារវាងគណៈចលនាមហាជនរាជធានី-ខេត្ត តាមរយៈយន្តការគ្រូបង្គោល ៣)ជំរុញការបណ្តុះបណ្តាលបន្តដល់មន្ត្រីបក្សនៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ភូមិ ក្នុងដំណាក់កាលបន្ត។

ជាក់ស្តែង បេក្ខជនដែលត្រូវបានជ្រើសរើសមកចូលរួមវគ្គបណ្តុះបណ្តាលនេះ បានកំណត់ឱ្យមានសមាសភាពចម្រុះ រួមមាន អនុប្រធានគណៈចលនាមហាជនរាជធានី-ខេត្ត មន្ត្រីបក្សដែលបានឆ្លងកាត់វគ្គអប់រំនយោបាយរបស់គណបក្សថ្នាក់កណ្តាល និងមន្ត្រីបក្សដែលមានឧបនិស្ស័យលើការងារផ្សព្វផ្សាយ និងការងារសាធារណមតិ។ ចំណែកឯខ្លឹមសារបណ្តុះបណ្តាល ក៏ត្រូវបានផ្តោតលើមេរៀនចំនួន៤៖ ១)តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគណៈចលនាមហាជន ២)ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និងវិធីសាស្ត្រផ្សព្វផ្សាយ ៣)វិធីសាស្ត្រគោលក្នុងការប្រឈម និងគ្រប់គ្រងសមរភូមិសតិអារម្មណ៍ និង៤)យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងសមិទ្ធផលសម្រេចបានរបស់រាជរដ្ឋាភិបាល ដែលទាំងអស់នេះ ដើម្បីជាធាតុចូលបន្ថែមសម្រាប់មន្ត្រីបក្ស ក្នុងការអនុវត្តការងារមហាជនឱ្យមានប្រសិទ្ធភាព ព្រមទាំងក្លាយជាធនធានបង្គោល សម្រាប់គាំទ្រដល់ការរៀបចំវគ្គបណ្តុះបណ្តាលបន្តនៅថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ភូមិ ឱ្យប្រព្រឹត្តទៅរលូន និងមានប្រសិទ្ធភាព។

ដើម្បីបន្តលើកកម្ពស់សមត្ថភាពមន្ត្រីបក្សលើការងារមហាជន និងការងារសាធារណមតិ ក្រុមការងារនៃវគ្គបណ្ដុះបណ្ដាលក៏បានគិតគូរជាដំណាក់កាលបន្ត ក្នុងការរៀបចំតាក់តែងចងក្រងឯកសារជំនួយស្មារតីនានាពាក់ព័ន្ធនឹងស្ថានភាពនយោបាយថ្មីៗ សម្រាប់ចែកជូនគ្រូបង្គោលតាមរាជធានី-ខេត្ត ដើម្បីជាមូលដ្ឋានក្នុងការផ្សព្វផ្សាយបន្ត ក៏ដូចជាការបន្តរៀបចំវគ្គបំពាក់បំប៉នជាបន្តបន្ទាប់ថែមទៀត ជូនគ្រូបង្គោលគណៈចលនាមហាជនក្រោមប្រធានបទផ្សេងៗ ទៅតាមបរិបទ និងសភាពការណ៍នយោបាយថ្មីៗជាក់ស្ដែងនាពេលខាងមុខ សំដៅពង្រឹងការអនុវត្តការងារឱ្យកាន់តែប្រសើរជាជំហានៗ ពីថ្នាក់រាជធានី-ខេត្ត រហូតដល់ថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ដែលជាមូលដ្ឋានសំខាន់នៃការផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋ សំដៅឈានទៅអនុវត្តតួនាទីប្រកបដោយប្រសិទ្ធភាព ក្នុងការ **«អនុវត្តការងារ និងបំពេញតួនាទី ភារកិច្ច ឆ្លើយតបនឹងសំណូមពរ និងតម្រូវការជាក់ស្ដែងរបស់ប្រជាជន និងប្រទេសជាតិ នៅគ្រប់ដំណាក់កាលឱ្យបានទាន់ពេលវេលា»** ព្រមទាំង **«បម្រើប្រជាជនដោយស្មោះត្រង់»** និងអនុវត្តយុទ្ធសាស្ត្រ **«ផ្អែកលើអំពើល្អរបស់មន្ត្រីគណបក្ស គុណភាព និងបរិមាណរបស់សមាជិកបក្ស ដើម្បីបន្តឈ្នះឆ្នោត»**។

ក្នុងនាម **អគ្គលេខាធិការដ្ឋាននៃគណៈចលនាមហាជន និងក្រុមការងាររៀបចំវគ្គបណ្ដុះបណ្ដាល** ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅគោរពជូនចំពោះ **សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ប្រធានគណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាល ដែលតែងតែបានតម្រង់ទិស ផ្ដល់ការគាំទ្រ និងអនុសាសន៍ណែនាំប្រកបដោយគតិបណ្ឌិតជាប់ជាប្រចាំ ក្នុងកិច្ចដំណើរការរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលលើការងារមហាជនរាជធានី-ខេត្ត និងសូមថ្លែងអំណរគុណដល់គ្រូឧទ្ទេសដែលបានចំណាយពេលវេលាដ៏មមាញឹក ចូលរួមផ្ដល់បទឧទ្ទេសនាមក្នុងវគ្គបណ្ដុះបណ្ដាល និងបានចងក្រងជាមេរៀន សម្រាប់ផ្ដល់ជូនសិក្ខាកាមក្នុងការផ្សព្វផ្សាយបន្ត។ ទន្ទឹមនេះ ខ្ញុំក៏សូមថ្លែងការកោតសរសើរដល់ក្រុមការងារទាំងអស់ដែលបានខិតខំប្រឹងប្រែងរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលលើការងារមហាជនរាជធានី-ខេត្ត លើកទី១នេះប្រកបដោយជោគជ័យ ឈរលើស្មារតី **«ធ្វើបណ្ដើរ រៀនបណ្ដើរ កែលម្អបណ្ដើរ»** ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កម្រងមេរៀននេះ នឹងក្លាយជាឯកសារមូលដ្ឋានដ៏មានសារៈសំខាន់ សម្រាប់ទ្រទ្រង់ដល់ការបណ្ដុះបណ្ដាលបន្តដល់ជនបង្គោលលើការងារមហាជននៅតាមក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់-ភូមិ ប្រកបដោយប្រសិទ្ធភាព និងគុណភាព។

ថ្ងៃ សុក្រ ៦កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៥

**គណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាល**

**អគ្គលេខាធិការ**

**ហ៊ុន ម៉ានី**

# មេរៀនទី១
# តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ
# គណៈចលនាមហាជន

រៀបរៀងដោយៈ **ឯកឧត្តមបណ្ឌិត អ៊ុត សំហេង**

# មេរៀនទី១
# តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគណៈចលនាមហាជន

## I. បុព្វកថា

**គណបក្សប្រជាជនកម្ពុជា** ជាគណបក្សរបស់ប្រជាជន កើតឡើងស្ថិតស្ថេរនិងរីកចំរើនដោយសារប្រជាជន និងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីផលប្រយោជន៍ដ៏ឧត្តុងឧត្តមរបស់ប្រទេសជាតិ និងប្រជាជន។

**គណបក្ស** ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ (មានឈ្មោះដើមបក្សប្រជាជនបដិវត្តន៍ខ្មែរ) ដោយមានប្រភពពីចលនាស្នេហាជាតិរបស់ប្រជាជនកម្ពុជា ប្រឆាំងពួកអាណានិគមដើម្បីឯករាជ្យជាតិ។ ចាប់ពីថ្ងៃចាប់បដិសន្ធិមក គណបក្សបានប្រកាន់ខ្ជាប់នូវគោលបំណង និងឧត្តមគតិរបស់ខ្លួន គឺឈរនៅខាងប្រជាជន រួមសុខរួមទុក្ខ ជាមួយប្រជាជននៅគ្រប់កាលៈទេសៈ ពុះពារជម្នះគ្រប់ឧបសគ្គ ហ៊ានធ្វើពលីកម្មឥតរុញរាដើម្បីប្រទេសកម្ពុជាឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម។

**គណបក្សប្រជាជនកម្ពុជា** ប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស លើកកម្ពស់មនសិការស្នេហាជាតិបំរើប្រជាជន អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ និងអនុវត្តនយោបាយការបរទេសឯករាជ្យដោយផ្អែកលើច្បាប់បើកទូលាយទំនាក់ទំនងអន្តរជាតិ ជាមួយបណ្តាប្រទេសទាំងអស់លើសកលលោក ធ្វើជាមូលដ្ឋាននូវកម្មវិធីនយោបាយដោយផ្អែកលើសភាពការណ៍ជាក់ស្តែងក្នុងប្រទេស និងនិន្នាការនៃសកលលោក។

រយៈពេលកន្លងមក ទោះបីត្រូវប្រឈមនឹងភាពបត់បែន និងការប្រែប្រួលយ៉ាងស្មុគស្មាញបំផុតនៃសភាពការណ៍ជាតិ និងសភាពការណ៍អន្តរជាតិយ៉ាងណាក្តី ក៏គណបក្សប្រជាជនកម្ពុជាបាននៅតែផ្សារភ្ជាប់ខ្លួនជានិច្ចជាមួយប្រជាជន ពុះពារឆ្លងកាត់ដំណាក់កាលធំៗ នៃប្រវត្តិសាស្ត្ររបស់ជាតិ ប្រកបដោយវីរភាពគឺ÷ ការតស៊ូប្រឆាំងរបបអាណានិគម ដើម្បីឯករាជ្យជាតិពីឆ្នាំ១៩៥១-១៩៥៣, ការការពារឯករាជ្យ សន្តិភាព អព្យាក្រឹតភាពនៃព្រះរាជាណាចក្រកម្ពុជាប្រឆាំងការជ្រៀតជ្រែករបស់បរទេសពីឆ្នាំ១៩៥៤-១៩៧០, ការតស៊ូរំដោះជាតិពីរបបសាធារណរដ្ឋខ្មែរ លន់ នល់ ដែលកើតចេញពីរដ្ឋប្រហារតាមខ្សែញាក់របស់បរទេសពីឆ្នាំ១៩៧០-១៩៧៥, ការតស៊ូផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដើម្បីសង្គ្រោះអាយុជីវិតជាតិ និងប្រជាជន ពីឆ្នាំ១៩៧៥-១៩៧៩, ការការពារជាតិ ស្តារ និងកសាងប្រទេសឡើងវិញ, ការថែរក្សាសន្តិភាព ប្រឆាំងបដិវត្តន៍ពណ៌ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច លើកកម្ពស់ជីវភាពប្រជាជន។

ជាពិសេសតាំងពីដំណាក់កាលតស៊ូផ្តួលរំលំរបប ប៉ុល ពត មកដល់បច្ចុប្បន្ន គណបក្សបានសាមគ្គីប្រជាជាតិខ្មែរទាំងមូល ប្រឹងប្រែងក្រោកឈរឡើង ពុះពារគ្រប់ឧបសគ្គធ្វើដំណើរទៅមុខជានិច្ចនៅលើមាគ៌ាដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិត ភាពអង់អាច និងបត់បែនតាមការវិវត្តនៃសភាពការណ៍ជាតិ និងអន្តរជាតិសម្រេចបានជោគជ័យយ៉ាងធំធេង បង្កើតបានសមិទ្ធផលធំៗ ជាប្រវត្តិសាស្ត្រជូនជាតិគឺ÷

១-ប្រមូលកម្លាំងមហាសាមគ្គីជាតិ ក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ទទួលបានជ័យជម្នះជាប្រវត្តិសាស្រ្តនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ធ្វើអោយប្រជាជាតិបានរស់រានមានជីវិតឡើងវិញ បញ្ចប់សករាជដ៏ខ្មៅងងឹតបំផុត ហើយបើកឡើងនូវសករាជថ្មីរបស់កម្ពុជាគឺ ឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម។ គណបក្សបានការពារការរស់ឡើងវិញរបស់ប្រជាជន ដោយទប់ស្កាត់មិនអោយរបបដ៏ឃោរឃៅនេះអាចវិលត្រឡប់មកវិញបាន។

២-លើមូលដ្ឋានជ័យជម្នះ៧មករា បាននាំមកជូនប្រជាជនវិញនូវសិទ្ធិសេរីភាពគ្រប់យ៉ាងដែលត្រូវបាត់បង់ទាំងស្រុងក្នុងរបប ប៉ុល ពត ជាពិសេស សិទ្ធិនៃការមានជីវិតរស់នៅដោយកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាជន ព្រមជាមួយនោះសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើតឡើង (ដែលបន្ទាប់មកបានប្តូរឈ្មោះជារដ្ឋកម្ពុជា) ដើម្បីការពារជាតិ ស្តារ និងកសាងសង្គម-សេដ្ឋកិច្ចឡើងវិញ។

៣-ធ្វើជាកម្លាំងស្នូលនៃការផ្សះផ្សារ បង្រួបបង្រួមជាតិ រហូតសម្រេចបានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងជាកម្លាំងមិនអាចខ្វះបានក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ដែលជាមូលដ្ឋាននៃការបង្កើតឡើងនូវរដ្ឋធម្មនុញ្ញ និងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ។

៤-បញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃ បង្កើតបានសន្តិភាព និងឯកភាពជាតិពេញលេញ និងឯកភាពទឹកដីទាំងស្រុងចាប់ពីចុងឆ្នាំ១៩៩៨មក តាមរយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះ ប្រកបដោយជោគជ័យដែលបានធ្វើអោយអង្គការចាត់តាំងរបស់ពួកឧទ្ទាមកម្ពុជាប្រជាធិបតេយ្យទាំងខាងនយោបាយ និងយោធាត្រូវរលំរលាយទាំងស្រុង។

៥-ការពារ ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស អោយចាក់គ្រឹះរឹងមាំក្នុងសង្គមជាតិ ដោយដើរទន្ទឹមនឹងការពង្រឹងនីតិរដ្ឋ លើកកម្ពស់ការគោរពសិទ្ធិមនុស្ស សម្រេចបានការបោះឆ្នោតទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងសកល និងអសកលតាមការកំណត់នៃរដ្ឋធម្មនុញ្ញ និងច្បាប់ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ ដែលទទួលបានការគាំទ្រ និងការសាទរដ៏កុះករពីសំណាក់ សហគមន៍ជាតិ និងអន្តរជាតិ ព្រមទាំងដោះស្រាយបញ្ហាដែលកើតមានក្រោយការបោះឆ្នោតដោយសន្តិវិធី ផ្អែកលើរដ្ឋធម្មនុញ្ញ ច្បាប់ និងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ការពារឆន្ទៈ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ។

៦-អនុវត្តការកែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងទូលំទូលាយប្រកបដោយផ្លែផ្កា ដែលបានធានាដល់ការលើកកម្ពស់អភិបាលកិច្ចនៃគ្រប់ស្ថាប័ន គ្រប់ថ្នាក់ ការពង្រឹងយុត្តិធម៌ និងសមធម៌សង្គម, ការកសាងធនធានមនុស្សប្រកបដោយគុណភាព, ការផ្តល់សេវាសាធារណៈជូនប្រជាជនប្រកបដោយប្រសិទ្ធភាព និងការជឿទុកចិត្ត, ការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈបរិវត្តកម្មឌីជីថល, ការបង្កើតការងារ, ការផ្តល់ជូនប្រជាជននូវកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្ន, ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ, ការធានាចីរភាពផ្នែកបរិស្ថាន និងការកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកែលម្អឥតឈប់ឈរជីវភាពរបស់ប្រជាជន។

៧-ស្ពារ និងកសាងសង្គម-សេដ្ឋកិច្ច ពីស្ថានភាពត្រូវបានបំផ្លាញខ្ទេចខ្ទីដល់ឫសគល់អោយរស់ឡើងវិញ និងមានស្ថិរភាពជាជំហានៗ រហូតឈានមកដល់ដំណាក់កាលអភិវឌ្ឍលើគ្រប់វិស័យ ប្រកបដោយចីរភាព និង សមធម៌ ធ្វើអោយសង្គមជាតិ មានការផ្លាស់ប្តូរមុខមាត់ដែលពុំអាចគិតស្មានដល់។ កម្ពុជាបានស្ថិតក្នុងចំណោមប្រទេសលើពិភពលោក ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចបានវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការលើកកម្ពស់ជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ហើយបានចេញផុតពីប្រទេសមានចំណូលទាប ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប នៅឆ្នាំ២០១៥ និងត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអនុម័ត កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ អោយកម្ពុជាក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

៨-ក្នុងពេលត្រូវប្រឈមនឹងការឆ្លងរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងការកើនឡើងនៃភាពតានតឹងនៃភូមិសាស្ត្រនយោបាយ គណបក្សបានដឹកនាំប្រជាជនប្រយុទ្ធទប់ស្កាត់ជំងឺដ៏កាចសាហាវនេះ និងអនុវត្តយុទ្ធសាស្ត្រផ្តាវីក នៃការចាក់វ៉ាក់សាំងដោយជោគជ័យ ការពារអាយុជីវិតប្រជាជនមិនអោយធ្លាក់ក្នុងគ្រោះមរណៈ ពង្រឹងខឿនការពារសុខភាពប្រជាជន រក្សាបានលំនឹងសេដ្ឋកិច្ច និងលំនឹងនៃជីវភាពរបស់ប្រជាជន ជាពិសេសប្រជាជនក្រីក្រ និងជនរងគ្រោះពីជំងឺនេះ ដែលបានបង្កភាពអនុគ្រោះដល់ការរស់នៅតាមគន្លងប្រក្រតីភាពថ្មី និងការងើបឡើង នៃសេដ្ឋកិច្ចជាតិ នៅអំឡុងនិងក្រោយវិបត្តិជំងឺកូវីដ១៩។

៩-ការឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីបានគត់មត់ ប្រឆាំងការជ្រៀតជ្រែករបស់បរទេសចូលកិច្ចការផ្ទៃក្នុងកម្ពុជា ថែរក្សាសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ និងសុខសុវត្ថិភាពសង្គមបានរឹងមាំ ធ្វើអោយបរាជ័យឧបាយកលទុច្ចរិតរបស់ពួកប្រឆាំងជ្រុលនិយម និងមជ្ឈដ្ឋានអគតិនានា ដែលបានប្រើប្រាស់ចលនាបដិវត្តន៍ពណ៌ ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ការពារសង្គមជាតិមិនអោយធ្លាក់ក្នុងអស្ថិរភាព អសន្តិសុខ ការបែកបាក់ជាតិ និងសង្គមសារជាថ្មីទៀត ធ្វើអោយសង្គមជាតិបន្តដំណើរទៅមុខឥតឈប់លើមាគ៌ាសន្តិភាព ប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិវឌ្ឍន៍។

១០-ការអនុវត្តនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់បានស្តារ និងលើកកិត្តិយស កិត្យានុភាពជាតិលើឆាកអន្តរជាតិ ពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ប្រទេស និងដៃគូនានា ដែលបាននាំមកនូវការគាំទ្រ និងជំនួយឧបត្ថម្ភយ៉ាងច្រើនសម្រាប់ការអភិវឌ្ឍ ហើយបានចូលរួមយ៉ាងសកម្មជាមួយបណ្តាប្រទេសដោយស្មើភាព និងស្មើសិទ្ធិក្នុងរាល់កិច្ចការអន្តរជាតិ ដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងតាមរយៈការចរចាដោយសន្តិវិធី ដោយផ្អែកលើរដ្ឋធម្មនុញ្ញ ច្បាប់អន្តរជាតិ និងឯកសារពាក់ព័ន្ធនានាដែលបន្សល់ទុកពីសម័យអាណានិគម កសាងបានខ្សែបន្ទាត់ព្រំដែនប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍។

១១-ឆ្នាំ២០២៤ សភាពការណ៍ទូទៅមានលក្ខណៈល្អប្រសើរ ដែលធានាដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការរស់នៅដ៏សុខសាន្តរបស់ប្រជាជនក្រោមម្លប់នៃសន្តិភាព។ នៅក្នុងអំឡុងពេលនេះ ទោះបីត្រូវជួបការលំបាកជាច្រើនដែលបណ្តាលមកពីការវិវត្តដ៏ស្មុគស្មាញនៃសភាពការណ៍តំបន់ និងអន្តរជាតិ ព្រមទាំងសកម្មភាព

វិខានរបស់ពួកប្រឆាំងជ្រុលនិយមក្តី ក៏រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភាដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជារាជរដ្ឋាភិបាលបន្តវេនរបស់គណបក្សប្រជាជនកម្ពុជា បានបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន ដោយការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីបុព្វហេតុកសាង នឹងការពារមាតុភូមិ តាមរយៈការដឹកនាំអនុវត្តប្រកបដោយផ្លែផ្កានូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានឆ្លើយតបទៅនឹងសេចក្តីសង្ឃឹមជឿជាក់របស់ប្រជាជន។ ទន្ទឹមនេះការងារកសាង និងពង្រឹងគណបក្ស ក៏ត្រូវបានបន្តលើកកម្ពស់ឥតឈប់ឈរស្របតាមសំណូមពរនៃសភាពការណ៍ និងភារកិច្ចរបស់គណបក្សនៅក្នុងរយៈពេលចំពោះមុខផង និងរយៈពេលយូរអង្វែងផង។ អង្គការចាត់តាំងគណបក្ស និងមន្ត្រីគណបក្សនៅគ្រប់ថ្នាក់ គ្រប់ផ្នែកបានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដោយការទទួលខុសត្រូវខ្ពស់ ធានាបានការថែរក្សា និងពង្រីកបាននូវប្រៀបខ្លាំង និងប្រៀបឈ្នះរបស់គណបក្ស។

## II. ប្រវត្តិនៃការងារចលនាមហាជនរបស់គណបក្ស

ការងារចលនាមហាជនរបស់គណបក្សប្រជាជនកម្ពុជា ឆ្លងកាត់ដំណាក់កាលជាច្រើន ជាអាទិ៍÷

### ក. ដំណាក់កាលតស៊ូ រំដោះជាតិ

១-គណបក្សប្រជាជនកម្ពុជាកើតចេញពីចលនាស្នេហាជាតិរបស់ប្រជាជន តស៊ូប្រឆាំងពួកអាណានិគមនិយមដើម្បីដណ្តើមឯករាជ្យជាតិ។ បុព្វការីជនរបស់គណបក្សបានបង្កើតគណបក្សដោយមានឧត្តមគតិស្នេហាជាតិមាតុភូមិស្មារតីអង់អាចក្លាហាន ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិ។ ផ្តើមពីឧត្តមគតិជាតិមាតុភូមិ និងប្រជាជន បានប្រមូលកម្លាំងមហាជន ប្រជាជនពីតិចទៅច្រើនក្លាយជាចលនាមហាជនដែលមានឧត្តមគតិរួមគ្នាតស៊ូពុះពារ ឆ្លងកាត់រាល់ការលំបាក ឧបសគ្គគ្រប់បែបយ៉ាងទទួលបានជោគជ័យជាប្រវត្តិសាស្ត្រជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។

២-ក្នុងដំណាក់កាលដែលប្រទេសជាតិធ្លាក់ក្នុងគ្រោះមហន្តរាយនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត មានតែសមាជិកគណបក្សប្រជាជនកម្ពុជាដ៏បរិសុទ្ធ ដែលស្មោះត្រង់និងគោលបំណង និងឧត្តមគតិរបស់គណបក្សដែលក្រោកឈរឡើងដឹកនាំចលនាមហាជនផ្តួលរំលំរបបប្រល័យពូជសាសន៍។

ចលនាមហាជនដែលដឹកនាំដោយ សមមិត្ត **ហ៊ុន សែន** ដែលគ្រានោះជាមេបញ្ជាការកងវរសេនាធំដែលគ្រប់គ្រងបញ្ជាលើកងទ័ពជាង២០០០នាក់ ជាយុវជនដ៏អង់អាច ក្លាហាន ឈ្លាសវៃ និងមានទេពកោសល្យខ្ពស់គ្មានពីរបានសម្រេចចិត្តចាកចេញទៅប្រទេសវៀតណាម ផ្សងព្រេងប្រថុយជីវិតជាមួយនិងជម្រើសចុងក្រោយដើម្បីរំដោះជាតិអោយរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ នៅយប់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ សមមិត្ត **ហ៊ុន សែន** និងយុទ្ធមិត្ត ៤នាក់បានឆ្លងដែនទៅប្រទេសវៀតណាម ដើម្បីកសាងកម្លាំងតស៊ូ រំដោះប្រទេស ដែលជាជម្រើសល្អបំផុតជាប្រវត្តិសាស្ត្រសម្រាប់ការរស់រានពៃប្រជាជនខ្មែរ។ ចលនាមហាជនដឹកនាំដោយសមមិត្ត **ហ៊ុន សែន** មានឆន្ទៈមុតមាំ មានឧត្តមគតិដើម្បីជាតិ និងប្រជាជន ទទួលបានការគាំទ្រ និងពង្រីកកម្លាំងបានឆាប់រហ័ស ដោយបានកសាង

កម្លាំងប្រដាប់អាវុធជាង១០០០០នាក់ និងរៀបចំអង្គការរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលជាអង្គការមហាជននយោបាយ ដឹកនាំចលនាមហាជនតស៊ូផ្តួលរំលំរបបប្រល័យពូជសាសន៍។

រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចទាំងបី **សម្តេច ជា ស៊ីម, សម្តេច ហេង សំរិន** និង **សម្តេច ហ៊ុន សែន** ត្រូវបានប្រកាសជាផ្លូវការថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ដែលមានរចនាសម្ព័ន្ធចលនាមហាជនមានកសិករ កម្មករ បញ្ញវ័ន្ត យុវជន ស្ត្រី ព្រះសង្ឃ ជនជាតិ។ល។ បុព្វហេតុ និងឧត្តមគតិរបស់រណសិរ្សគឺផ្តួលរំលំរបបប្រល័យពូជសាសន៍សង្គ្រោះជាតិ និងប្រជាជន ពីការកាប់សម្លាប់ដ៏សាហាវឃោរឃៅនៃរបបប្រល័យពូជសាសន៍ ដែលមានគោលនយោបាយ១១ខ បុព្វហេតុដ៏ឧត្តុង្គឧត្តមនេះបានទទួលការគាំទ្រយ៉ាងទូលំទូលាយពីប្រជាជនគ្រប់មជ្ឈដ្ឋានក្នុងប្រទេស និងប្រទេសជាមិត្តជិតឆ្ងាយ។

អាស្រ័យដោយចលនាមហាជនចូលរួមគាំទ្រយ៉ាងទូលំទូលាយ និងស្មារតីប្រយុទ្ធដ៏អង់អាចក្លាហានរបស់កងទ័ព រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាទទួលបានជ័យជំនះជាប្រវត្តិសាស្ត្រនៅថ្ងៃ ៧មករា ឆ្នាំ១៩៧៩ ផ្តួលរំលំរបបប្រល័យពូជសាសន៍សង្គ្រោះជាតិ និងប្រជាជនអោយរស់ឡើងវិញ។

**ខ. ដំណាក់កាលដឹកនាំ ការពារ និងកសាងប្រទេស**

គណបក្សប្រជាជនបដិវត្តន៍កម្ពុជា ដឹកនាំប្រទេសលើគ្រប់វិស័យតាមរបបបក្សតែមួយដែលមានរដ្ឋាភិបាលជាស្ថាប័ននីតិប្រតិបត្តិ រដ្ឋសភា ជាស្ថាប័ននីតិបញ្ញត្តិ ដែលបង្កើតឡើងដោយការបោះឆ្នោត តុលាការ និងស្ថាប័នគណបក្ស ដែលជាស្ថាប័នសេនាធិការផ្ទាល់របស់គណបក្ស ស្ថាប័នអង្គការមហាជន ស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណបក្សសម្រាប់ការងារចលនាមហាជន។

ស្ថាប័នអង្គការមហាជនមាន ៤ រួមមាន រណសិរ្សសាមគ្គីការពារកសាងមាតុភូមិកម្ពុជាដែលមានសមមិត្ត **ជា ស៊ីម** ជាប្រធាន សមាគមនារីកម្ពុជាមានសមមិត្តនារី **មាន សំអាន** ជាប្រធាន សមាគមយុវជនមានសមមិត្ត **ឈុច ថង** ជាប្រធាន សហព័ន្ធសហជីពកម្ពុជាមានសមមិត្ត **មាស សំណាង** បន្ទាប់មកសមមិត្ត **ហេង ទៀវ** បន្ទាប់មកសមមិត្ត **ម៉ាត់ លី** បន្ទាប់មកសមមិត្តនារី **ម៉ែន សំអន** ជាប្រធាន។

សមាសភាពប្រធានអង្គការមហាជន ជាថ្នាក់ដឹកនាំដែលមានតួនាទីសំខាន់នៅក្នុងគណបក្សដូចជា សមាជិកការិយាល័យនយោបាយ និងសមាជិកគណៈកម្មាធិការកណ្តាល។ អង្គការមហាជននីមួយៗ មានឋានៈស្មើក្រសួងមួយ ប្រធានស្ថាប័នឋានៈស្មើរដ្ឋមន្ត្រី ថ្នាក់ដឹកនាំកម្មាភិបាលបុគ្គលិករបស់អង្គការមានក្របខ័ណ្ឌ មានបៀវត្សប្រាក់បំណាច់ផ្សេងៗ ដូចបុគ្គលិករដ្ឋ ស្ថាប័ននីមួយៗមានអគាររដ្ឋបាល មធ្យោបាយធ្វើការ កញ្ចប់ថវិកាដូចស្ថាប័នរដ្ឋ ដែលមានភាពងាយស្រួល និងម្ចាស់ការលើរាល់សកម្មភាពនៃការងារចលនាមហាជនតាមតួនាទី ភារកិច្ច និងមុខសញ្ញារៀងៗខ្លួន។

ក្នុងដំណាក់កាលនេះ ការងារចលនាមហាជនប្រមូលផ្តុំក្នុងភារកិច្ច ការពារ និងកសាងជាតិ ទប់ស្កាត់ការវិលត្រលប់មកវិញនៃរបបប្រល័យពូជសាសន៍ ស្តារ និងកសាងប្រទេសជាតិតាំងពីបាតដៃទទេក្នុងស្ថានភាពដែលត្រូវហ៊ុមព័ទ្ធសេដ្ឋកិច្ចពីខាងក្រៅដោយអយុត្តិធមិត្រូវប្រឈមមុខនឹងការលំបាករាប់មិនអស់។

ការងារចលនាមហាជនបានបំផុសសកម្មភាពជាច្រើនលើគ្រប់វិស័យដូចជា ចលនាស្ម័គ្រចិត្តចូលបម្រើកងទ័ពស្នេហាជាតិ ចលនាក៥ ធ្វើរបងការពារខ្សែប្រយុទ្ធជួរមុខតាមព្រំដែន ចលនាក៦ ធ្វើខ្សែក្រវ៉ាត់ការពារក្រុងភ្នំពេញ ចលនាបីមិន មួយរាយការណ៍ ចលនាគាស់រំលើងខ្មាំងបង្កប់ ចលនាកសាងពង្រឹងមូលដ្ឋានរយៈពេល ៣ខែ ទៅ៣ឆ្នាំ ចលនាលក់ស្រូវជូនរដ្ឋស្នេហាជាតិ ចលនាប្រលងប្រណាំងច្នៃប្រឌិតសន្សំសំចៃរបស់កម្មករបុគ្គលិក ។ល។

តាមរយៈការងារចលនាមហាជន កម្លាំងពិតរបស់គណបក្សប្រជាជនកម្ពុជាគ្រប់ផ្នែកបានរីកចម្រើនធំធាត់ឡើងម្ចាស់ការក្នុងការដឹកនាំប្រទេសជាតិគ្រប់វិស័យ ទាំងការងារគណបក្ស ការងាររដ្ឋ និងអង្គការមហាជន រួមនឹងការជួយឧបត្ថម្ភពីមិត្តភក្តិជិតឆ្ងាយ បានសម្រេចជោគជ័យក្នុងការរាំងស្កាត់បានការប៉ុនប៉ងវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ស្តារ និងកសាងជាតិឡើងវិញ ចេញផុតពីដំណាក់កាលដ៏សែនលំបាកបំផុត មកកាន់ដំណាក់កាល ពង្រឹងពង្រីកខ្លួនបានអោយបន្តធ្វើដំណើរទៅមុខប្រកបដោយជោគជ័យលើមាគ៌ាសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍។

### គ.ដំណាក់កាលអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស

ឆ្នាំ១៩៩១ ការងារចលនាមហាជន ត្រូវបានផ្លាស់ប្តូររចនាសម្ព័ន្ធ តួនាទី ភារកិច្ចតាមប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស។ ក្នុងដំណាក់កាលនេះ គណបក្សបន្តដឹកនាំអង្គការមហាជនលើការងារនយោបាយ សតិអារម្មណ៍ ចាត់តាំង បង្កលក្ខណៈជូនបណ្តាអង្គការមហាជនធ្វើសកម្មភាពដោយឯករាជ្យស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងស្របទៅតាមកម្មវិធីនយោបាយរបស់គណបក្ស។

តួនាទី ភារកិច្ចរបស់អង្គការមហាជនមួយចំនួន ត្រូវបានបញ្ចូលក្នុងតួនាទីភារកិច្ចរបស់ស្ថាប័នរដ្ឋ ដូចជា ការងារយុវជនមួយផ្នែកត្រូវបានបញ្ចូលទៅក្រសួងអប់រំ យុវជន និងកីឡា ការងារស្ត្រី ត្រូវបានបញ្ចូលទៅក្រសួងកិច្ចការនារី ការងារសហជីព ត្រូវបញ្ចូលទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ល។ ចរិកា មធ្យោបាយ ប្រាក់បៀវត្សរបស់បុគ្គលិកត្រូវដោះស្រាយដោយអង្គការមហាជនខ្លួនឯង។ អង្គការមហាជនរបស់គណបក្ស បានបន្តសកម្មភាពដឹកនាំ និងបំផុសចលនាមហាជនតាមមុខសញ្ញារៀងៗខ្លួនដូចជា÷ រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា សមាគមយុវជនកម្ពុជា ក្រោយមកជាសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) សមាគមនារី បច្ចុប្បន្នជាសមាគមនារីដើម្បីប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ សហព័ន្ធសហជីពកម្ពុជា បច្ចុប្បន្នសហព័ន្ធសហជីពឯករាជ្យកម្ពុជា។

អង្គការមហាជនបានខិតខំប្រឹងប្រែងធ្វើសកម្មភាពក្នុងបរិបទថ្មី ដោយត្រូវពង្រឹងចលនារបស់ខ្លួនដែលមានស្រាប់ផង និងត្រូវប្រកួតប្រជែងជាមួយអង្គការមហាជនផ្សេងៗដែលមាននិន្នាការខុសៗគ្នាដើម្បីប្រមូលកម្លាំងចលនាមហាជនគាំទ្រគណបក្ស។

ក្រៅពីអង្គការមហាជនទាំង៤ គណបក្សបានអនុវត្តគោលនយោបាយសេរីភាពក្នុងការបង្កើតសមាគមអង្គការមិនមែនរដ្ឋាភិបាល សហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ សេរីភាពសហជីពអង្គការវិជ្ជាជីវៈ ដោយជំរុញការកសាងកម្លាំងចលនាមហាជន ក្នុងបណ្តាអង្គការមហាជនតាមមជ្ឈដ្ឋានមហាជននានា អោយចូលរួមគាំទ្រកម្មវិធីនយោបាយ

របស់គណបក្ស និងទៅតាមលទ្ធភាពដែលអង្គការទាំងនោះអាចធ្វើបាន តាមរយៈនេះអង្គការមហាជនដែលគាំទ្រគណបក្សប្រជាជនកម្ពុជាបានកើនឡើងទាំងបរិមាណ និងគុណភាព រួមចំណែកក្នុងជោគជ័យនានារបស់គណបក្ស។

រចនាសម្ព័ន្ធនេះបានបន្តនិរន្តរភាព ក្នុងការកសាងពង្រឹងកម្លាំងចលនាមហាជនចូលរួមការបោះឆ្នោតគ្រប់អាណត្តិទាំងបោះឆ្នោតសកល និងបោះឆ្នោតឃុំ-សង្កាត់ ដោយបានរៀបចំយន្តការដឹកនាំការងារចលនាមហាជនចំណុះអោយគណៈបញ្ជាការបោះឆ្នោត ដើម្បីទទួលបន្ទុកការងារចលនាមហាជនចូលរួមបោះឆ្នោតជូនគណបក្ស។ អង្គការមហាជនបានទទួលភារកិច្ចបំផុសសមាជិកចូលរួមគាំទ្រយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្ស ចូលរួមសង្កេតការណ៍បោះឆ្នោត និងសកម្មភាពផ្សេងទៀត ស្របតាមច្បាប់ស្តីពីការបោះឆ្នោត រួមចំណែកក្នុងជោគជ័យរបស់គណបក្សក្នុងការបោះឆ្នោតគ្រប់អាណត្តិនាពេលកន្លងមក។

**ឃ.ដំណាក់កាលរៀបចំរចនាសម្ព័ន្ធគណៈចលនាមហាជនបច្ចុប្បន្ន**

ឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជាទទួលបានជ័យជម្នះ ៦៨អាសនៈ គណបក្សប្រឆាំងបាន៥៥អាសនៈ។

ចលនាមហាជនរបស់គណបក្សយើងបានចូលរួមបំផុសចលនាការពារ ពង្រឹងលទ្ធផលបោះឆ្នោត ការពាររាជរដ្ឋាភិបាលស្របច្បាប់ គាំទ្រដល់កម្លាំងមានសមត្ថកិច្ចទប់ស្កាត់ដោះស្រាយបញ្ហាបាតុកម្ម ហើយរៀបចំបង្កើតរាជរដ្ឋាភិបាល។

គណបក្សប្រឆាំងដែលចាញ់ឆ្នោត បានធ្វើបាតុកម្មតវ៉ាយ៉ាងអនាធិបតេយ្យប៉ុនប៉ងប្រែក្លាយជាបដិវត្តន៍ពណ៌ សំដៅផ្តួលរំលំរាជរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា តាមមធ្យោបាយមិនប្រជាធិបតេយ្យ ការតវ៉ាបាតុកម្មអូសបន្លាយរយៈពេល៦ខែ ដោយបំពុលបរិយាកាសសង្គម ធ្វើអោយសង្គមបែកបាក់ ប្រកបដោយគ្រោះថ្នាក់ចំពោះជាតិ ធ្វើអោយប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជន ធ្វើអោយរបួស និងស្លាប់ដល់កម្លាំងសមត្ថកិច្ច និងបាតុករដើម្បីទំលាក់កំហុសលើរាជរដ្ឋាភិបាល។ ពួកប្រឆាំងជ្រុលនិយមបានអនុវត្តសកម្មភាពដ៏ពិសពុលរបស់ពួកគេតាមរូបភាព ព័ត៌មានក្លែងក្លាយ បណ្តាញព័ត៌មានសង្គម មូលបង្កាច់ ញុះញង់ កំហឹងវណ្ណៈ កំហឹងជាតិសាសន៍ ផលប្រយោជន៍សេដ្ឋកិច្ច សន្យាផ្តល់ប្រាក់ឈ្នួល អត្ថប្រយោជន៍ប្រជាភិថុតិ ដើម្បីបំផុស អូសទាញយុវជន កម្មករ កសិករ ព្រះសង្ឃ កម្មករនៅសេដ្ឋកិច្ចក្រៅប្រព័ន្ធ អ្នកលក់ដូរតាមផ្សារមួយចំនួនចូលរួមសកម្មភាពជាមួយពួកគេ។

គណបក្សសង្គ្រោះជាតិ ដែលអនុវត្តនយោបាយជ្រុលនិយមបង្កអោយមានបទល្មើសខាងផ្លូវច្បាប់ធ្ងន់ធ្ងរត្រូវតុលាការកាត់ទោសរំលាយគណបក្ស និងព្យួរសិទ្ធិធ្វើនយោបាយរបស់មេដឹកនាំបក្ស ដែលធ្វើអោយគណបក្សត្រូវរលំរលាយ និរទេសខ្លួនទៅបរទេសរហូតដល់បច្ចុប្បន្ន ហើយពួកប្រឆាំងជ្រុលនិយម នៅឯបរទេសនៅបន្តសកម្មភាពកាន់តែពិសពុល ថែមទៀតតាមរយៈប្រព័ន្ធឃោសនាបរទេស បណ្តាញសង្គមប្រឆាំងរាជរដ្ឋាភិបាលស្របច្បាប់ និងគណបក្សប្រជាជនកម្ពុជា។

ផ្តើមពីបទពិសោធន៍ខាងលើ ឆ្នាំ២០១៤ គណបក្សបានបង្កើតគណៈចលនាមហាជនដែលបន្តសកម្មភាពរហូតដល់បច្ចុប្បន្ន ដូចមានរចនាសម្ព័ន្ធបង្ហាញនូវខាងក្រោម។ ការងារចលនាមហាជនត្រូវបានជំរុញកាន់តែខ្លាំងក្លានូវគ្រប់សកម្មភាព តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋាន។

ក្រុមការងារយុវជនគណបក្សបានកសាងរចនាសម្ព័ន្ធយុវជនគណបក្សគ្រប់ថ្នាក់ ដែលជាកម្លាំងឈានមុខនៃការងាររបស់គណបក្សនៅគ្រប់ថ្នាក់ និងជាស្នូលនៃការងារចលនាយុវជនរបស់គណបក្ស។

ស.ស.យ.ក បានពង្រឹងរចនាសម្ព័ន្ធរបស់ខ្លួនរហូតដល់មូលដ្ឋាន បានផ្តួចផ្តើមបង្កើតព្រឹត្តិការណ៍ថ្មីៗដូចជា អង្គរសង្ក្រាន្ត ត្បាញក្រមា សាទរកម្ពុជា ដែលបានក្លាយជាចលនាជាតិ និងសកម្មភាពស៊ីជម្រៅរបស់ ស.ស.យ.ក នៅគ្រប់ក្រសួង-ស្ថាប័ន គ្រប់មជ្ឈដ្ឋាន វិស័យឯកជន ទាំងក្នុងនិងក្រៅប្រទេស ការផ្តល់ឱកាសដល់យុវជនទទួលបាននូវតួនាទីដឹកនាំក្នុងស្ថាប័នថ្នាក់ជាតិដល់មូលដ្ឋាន បានធ្វើអោយចលនាយុវជនរបស់គណបក្សបានរីកចម្រើនរឹងមាំល្អជាងពេលណាទាំងអស់។

គណៈចលនាស្ត្រីបានបន្តពង្រឹងរចនាសម្ព័ន្ធការងារស្ត្រី ពីថ្នាក់ជាតិដល់មូលដ្ឋាន បន្តចូលរួមសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច-សង្គម ការផ្តល់តួនាទីដឹកនាំរបស់ស្ត្រីក្នុងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ និងបានពង្រឹងចលនាស្ត្រីរបស់គណបក្ស។

គណៈចលនាសហជីពបានបន្តពង្រឹងរចនាសម្ព័ន្ធដឹកនាំពីថ្នាក់ជាតិដល់មូលដ្ឋាន និងនៅក្រៅប្រទេសដែលមានពលករកម្ពុជា។ បានបន្តអនុវត្តគោលនយោបាយសេរីភាពសហជីព និងអង្គការវិជ្ជាជីវៈ ដោយអនុលោមតាមច្បាប់ស្តីពីសហជីព ស្របតាមស្មារតីអនុសញ្ញាអន្តរជាតិរបស់អង្គការអន្តរជាតិខាងការងារ (ILO) និងបរិបទនៅកម្ពុជា។ បានប្រមូលកម្លាំងសហជីពគាំទ្រគណបក្សកើនឡើង៨០% នៃសហជីពសរុប។ **សម្តេចតេជោ** បានចុះសំណេះសំណាលជាមួយកម្មករនិយោជិតចំនួន២វគ្គ វគ្គទី១ ពីឆ្នាំ២០១៧ ដល់២០១៩ ចំនួន៧៧លើក ដែលបានជួបកម្មករប្រមាណមួយលាននាក់ វគ្គទី២ ឆ្នាំ២០២៣ ចំនួន២៥លើក ដែលមានកម្មករ ៣៥ម៉ឺននាក់។ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានបន្តចុះជួបសំណេះសំណាលជាមួយកម្មករចំនួន១០លើក ប្រមាណជិត ២០ម៉ឺននាក់។ តាមរយៈកម្មវិធីសំណេះសំណាល បានដាក់ចេញនូវគោលនយោបាយ ១០ចំណុច ដែលបានទទួលការគាំទ្រពីកម្មករនិយោជិត និយោជក និងប្រជាពលរដ្ឋ។ នេះជាអច្ឆរិយៈនៃការងារចលនាកម្មករនិយោជិតដែលមិនដែលមានក្នុងប្រវត្តិសាស្ត្រ។

គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍បានកសាងរចនាសម្ព័ន្ធដឹកនាំពីថ្នាក់ជាតិដល់មូលដ្ឋាន។ បានបន្តអនុវត្តគោលនយោបាយស្តីពីសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការ សមាគម និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដោយអនុវត្តតាមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈចលនានេះ បានពង្រឹងចលនាអង្គការសមាគមរបស់គណបក្សចូលរួម ក្នុងសកម្មភាពអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស សកម្មភាពសេដ្ឋកិច្ច-សង្គម មនុស្សធម៌ តាមកម្មវិធីនយោបាយរបស់គណបក្ស។

ឆ្នាំ២០២៤ ការងារចលនាមហាជនរបស់គណបក្ស ត្រូវបានយកចិត្តទុកដាក់ជំរុញអនុវត្តកាន់តែមានសកម្មភាពខ្លាំងក្លាឡើង តាមរយៈគណៈចលនានីមួយៗ អគ្គលេខាធិការដ្ឋាន និងក្រុមការងារប្រមូលព័ត៌មាន បានវាយតម្លៃ និងឆ្លើយតបសតិអារម្មណ៍មហាជន។ គណៈចលនាមហាជនរាជធានី-ខេត្ត ក្រសួង-ស្ថាប័ន និងបណ្តាអង្គការ

មហាជននានា បានចូលជ្រៅទៅក្នុងស្រទាប់មហាជន យុវជន ស្ត្រី កម្មករ និយោជិត អង្គការសង្គម និងគ្រប់មជ្ឈដ្ឋានមហាជននានាក្នុងសង្គម ជាពិសេសការបំពាក់បំប៉នស្មារតី ការគ្រប់គ្រងសមរភូមិសតិអារម្មណ៍សាធារណៈ និងជំរុញចលនាមហាជនក្នុងបុព្វហេតុរួមរបស់គណបក្ស ដែលបានរួមចំណែកដ៏សំខាន់ដល់ជោគជ័យរបស់គណបក្សក្នុងការបោះឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងលើកកម្ពស់ការចូលរួមរបស់មហាជនក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

ជាមួយគ្នានេះ អង្គការចាត់តាំងយុវជនគ្រប់ថ្នាក់ គ្រប់ផ្នែកក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការបំផុសចលនាយុវជន អោយគាំទ្របុព្វហេតុដ៏ត្រឹមត្រូវរបស់គណបក្ស តាមរយៈការពង្រឹងពង្រីករចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបការងារ ពង្រឹងការកសាងគណបក្សទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងក្នុងជួរយុវជនដោយផ្តោតលើការងារបំពាក់បំប៉ន បណ្តុះបណ្តាល ការចូលរួមក្នុងសកម្មភាពសង្គម និងមនុស្សធម៌ និងការកសាងសមាជិកគណបក្ស ជាយុវជនទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយពង្រឹងសមត្ថភាពយុវជនបន្តវេន និងពង្រីកសមាជិកជាក្បាលម៉ាស៊ីនយុវជនគណបក្ស។

ក្នុងការងារសតិអារម្មណ៍ និងចលនាមហាជននេះដែរ គួរកត់សម្គាល់ថាការផ្តួចផ្តើមរបស់គណបក្សយើងក្នុងការដង្ហែរអង្គកឋិនទានទៅកាន់វត្ត ពោធិគីរីវង្សារាម នៅខេត្តត្រាវិញ ប្រទេសវៀតណាម បានធ្វើអោយបងប្អូនខ្មែរក្រោមមានការរំភើបរីករាយ និងកក់ក្តៅក្រៃលែង ដោយបានមើលឃើញនូវការគិតគូយកចិត្តទុកដាក់របស់គណបក្សយើង និងរាជរដ្ឋាភិបាលចំពោះសុខទុក្ខផលប្រយោជន៍របស់បងប្អូន និងការផ្សារភ្ជាប់រវាងខ្មែរនិងខ្មែរទោះនៅទីណាក៏ដោយ។ ជាមួយគ្នានេះ តាមរយៈអង្គកឋិនទាននេះក៏បានបង្ហាញនូវការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល អាជ្ញាធរនៅវៀតណាម ក្នុងការថែរក្សានូវប្រពៃណី ភាសាទំនៀមទំលាប់របស់បងប្អូនខ្មែរក្រោម។

ស្របជាមួយគ្នានេះ រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ដែលជាអង្គការមហាជនដ៏ធំទូលាយ ក៏បានធ្វើសកម្មភាពយ៉ាងសកម្មសំដៅរួមចំណែកក្នុងការបំផុសស្មារតីសាមគ្គី សុខដុមនីយកម្មសង្គម ពង្រឹងការគាំទ្រ និងជំនឿចិត្តមកលើការដឹកនាំរបស់រាជរដ្ឋាភិបាលតាមរយៈការធ្វើការងារសតិអារម្មណ៍ជាមួយអតីតយុទ្ធជន និងមហាជនសម័យក្រោយសង្គ្រាម ការផ្សារភ្ជាប់ បញ្ជ្រាបការយល់ដឹងអំពីតថភាពនៃប្រវត្តិសាស្ត្រ ការលះបង់ ស្នាដៃសំខាន់ៗរបស់គណបក្សប្រជាជនកម្ពុជា ដែលបានខិតខំស្តារ កសាង និងអភិវឌ្ឍជាតិមកដល់បច្ចុប្បន្ន និងតាមរយៈការពង្រឹងរចនាសម្ព័ន្ធ ការចុះសួរសុខទុក្ខ ការរៀបចំកម្មវិធីសំណេះសំណាល វប្បធម៌ កម្សាន្ត មនុស្សធម៌ និងពិធីបុណ្យប្រវត្តិសាស្ត្រនានា។

## III.តួនាទី ភារកិច្ច រចនាសម្ព័ន្ធគណៈចលនាមហាជន

### ១.ថ្នាក់កណ្តាល (ឧបសម្ព័ន្ធ១)




#### ក.តួនាទីៈ

ជាស្ថាប័នជំនួយការអោយគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាក្នុងការដឹកនាំ ណែនាំតម្រង់ទិស និងសម្របសម្រួលការងារចលនាមហាជនរបស់គណបក្ស ក្នុងស្រទាប់មហាជន យុវជន ស្ត្រី កម្មករនិយោជិត និង អង្គការសង្គមនានា។

#### ខ. ភារកិច្ចៈ

១-កំណត់គោលការណ៍ដឹកនាំ គ្រប់គ្រងការងារចលនាមហាជននៅតាមគ្រប់បណ្តាមូលដ្ឋានដូចជាសហគមន៍ គ្រឹះស្ថានសាធារណៈ ឯកជន អង្គការសមាគម និងសាសនានានា ក្នុងន័យក្តាប់អោយបាននូវតម្រូវការសំណូមពរ និងសតិអារម្មណ៍ ដើម្បីវិភាគរកចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាពរបស់គណបក្សដើម្បី កសាងនូវយន្តការដោះស្រាយសមស្របមួយសំដៅអនុវត្តអោយបានជោគជ័យនូវកម្មវិធីនយោបាយ និងគោល នយោបាយរបស់គណបក្ស។

២-ស្រាវជ្រាវសភាពការណ៍សតិអារម្មណ៍ក្នុងស្រទាប់យុវជន ស្ត្រី កម្មករនិយោជិត និងគ្រប់មជ្ឈដ្ឋានមហាជន ដោយសហការណ៍ជាមួយគណៈឃោសនាអប់រំនៃគណៈកម្មាធិការកណ្តាល ដើម្បីរៀបចំផែនការកម្មវិធីខ្លឹមសារអប់រំ នយោបាយ បណ្តុះបណ្តាល និងបំពាក់បំប៉ន ហើយធ្វើសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលពិនិត្យ និងសម្រេច។

៣-កសាងផែនការសកម្មភាពការងាររបស់គណៈចលនាមហាជន និងអនុម័តផែនការសកម្មភាពរបស់គណៈចលនានីមួយៗ។

៤-តាមដាន ត្រួតពិនិត្យ ធ្វើការវាយតម្លៃការអនុវត្តតួនាទី ភារកិច្ចរបស់បណ្តាគណៈចលនាចំណុះ សំដៅកែលម្អ និងពង្រឹងអោយបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

៥-តាមដាន ស្វែងយល់ វិភាគសកម្មភាព និងឧបាយកលរបស់មជ្ឈដ្ឋានអមិត្ត ដើម្បីមានវិធានការឆ្លើយតបជាក់ស្តែងអោយបានសមស្រប ទាន់ពេលវេលា តាមគ្រប់មធ្យោបាយ។

**គ. រចនាសម្ព័ន្ធ**

***១. គណៈចលនាយុវជន អក្សរកាត់ "គ.ច.យ"***

ជាសេនាធិការរបស់គណៈចលនាមហាជនរបស់គណបក្សក្នុងការប្រមូលផ្តុំ អង្គការយុវជនទាំងក្នុង និងក្រៅគណបក្សដែលមាននិន្នាការស្របនឹងគណបក្សលើមូលដ្ឋាន ទស្សនទាននយោបាយ សង្គម និងមនោគមវិជ្ជា ដើម្បីកសាងជួយយុវជន ប្រជាពលរដ្ឋ ដែលមានសមាសភាព សកម្ម និងមានការទទួលខុសត្រូវក្នុងសង្គម និងកសាងកម្លាំងគាំទ្រដ៏មានសក្តានុពលក្នុងការគាំទ្រគណបក្សប្រជាជនកម្ពុជា។

- **តួនាទី÷**

១-ដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំងយុវជនផ្សេងៗ ដែលមាននិន្នាការស្របនឹងគណបក្សក្នុងការកសាង និងគ្រប់គ្រងកម្លាំងយុវជន។

២-បង្កើនប្រសិទ្ធភាពនៃការដឹកនាំរបស់អង្គការចាត់តាំងយុវជនផ្សេងៗ ដែលមាននិន្នាការស្របនឹងគណបក្ស ដើម្បីធានាបាននូវភាពខ្លាំង និងភាពឈ្នះរបស់អង្គការចាត់តាំងយុវជននីមួយៗ ក្នុងការកសាង និងគ្រប់គ្រងកម្លាំងយុវជន ទាំងបរិមាណ និងគុណភាព និងគ្រប់កាលៈទេសៈ។

- **ភារកិច្ច÷**

១-ផ្តួចផ្តើមគំនិត និងផ្តល់យោបល់ជូនគណៈចលនាមហាជនដើម្បីកំណត់សម្រេចគោលនយោបាយ និងគោលការណ៍នានាសំដៅប្រមូលកម្លាំងគាំទ្រគណបក្ស។

២-កំណត់ដែនប្រតិបត្តិ និងការទទួលខុសត្រូវច្បាស់លាស់ទៅតាមស្ថានភាពជាក់ស្តែងព្រមទាំងមានការសម្របសម្រួលដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។

៣-អនុវត្តផែនការសកម្មភាពយុវជន ស្របតាមគោលការណ៍វិមជ្ឈការដោយសហការជាមួយក្រុមការងារថ្នាក់ខេត្ត។

៤-អនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ១២ចំនុចក្នុងការអភិវឌ្ឍយុវជនដូចខាងក្រោម÷

- អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការដើម្បីគាំទ្រការអភិវឌ្ឍគោលនយោបាយ និងផែនការនានាអោយមានប្រសិទ្ធិភាព។

- លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព។
- បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព។
- បណ្តុះស្មារតីសហគ្រិនភាព និងការយល់ដឹងអំពីទីផ្សារការងារ។
- លើកកម្ពស់កិច្ចការពារសុវត្ថិភាព សន្តិសុខ និងយុត្តិធម៌។
- បង្កើនការចូលរួមរបស់យុវជន។
- លើកកម្ពស់ការសម្រាក ការកំសាន្ត និងកីឡា។
- លើកកម្ពស់សិល្បៈ និងវប្បធម៌។
- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម និងទេសចរណ៍។
- បង្កើនការស្ម័គ្រចិត្ត។
- លើកកម្ពស់សមភាពយេនឌ័រ
- ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្ការយុវនីតិសម្បទា

៥- គ្រប់គ្រង និងពង្រឹងកម្លាំងដែលមានក្នុងដៃអោយបានច្បាស់លាស់តាមអង្គភាពនីមួយៗ។

៦- តាមដាន ឈ្វេងយល់ពីសកម្មភាពសង្គម និងយុវជន ដើម្បីមានវិធានការឆ្លើយតបជាក់ស្តែងអោយបានសមស្រប និងទាន់ពេលវេលាតាមគ្រប់រូបភាព។

៧- សហការជាមួយអង្គការចាត់តាំងបក្ស ស្ថាប័ននានាគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងសម្បុរសជនដើម្បីប្រមូលផ្តុំធនធាន និងការគាំទ្រដោយមានការស្នើសុំគោលការណ៍ពីបក្ស។

## ២. *គណៈចលនាស្ត្រី អក្សរកាត់ "គ.ច.ស"*

- **តួនាទី÷**

ជាសេនាធិការរបស់គណៈចលនាមហាជនក្នុងការដឹកនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងក្រុមការងារទាំងអស់របស់គណបក្សដែលបំពេញការងារចលនាស្ត្រី ដើម្បីធានាបាននូវសុខដុមនីយកម្មក្នុងការងារចលនាស្ត្រីក្រោមការដឹកនាំរួមរបស់គណបក្ស។

- **ភារកិច្ច÷**

១- ផ្តួចផ្តើមគំនិត និងផ្តល់យោបល់ជូនគណៈចលនាមហាជនដើម្បីកំណត់សម្រេចគោលនយោបាយ និងគោលការណ៍នានាសំដៅប្រមូលកម្លាំងគាំទ្រគណបក្ស។

២- ពង្រឹងការដឹកនាំ គ្រប់គ្រង បណ្តុះបណ្តាលសមត្ថភាព សម្របសម្រួល ណែនាំ តម្រង់ទិស ត្រួតពិនិត្យកែលម្អជាប្រចាំ ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពការងាររបស់គណៈចលនាស្ត្រី ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។

៣- កសាងផែនការសកម្មភាពរបស់គណៈចលនាស្ត្រីដើម្បីចាត់តាំងអនុវត្តតួនាទី ភារកិច្ច របស់ខ្លួន អោយបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

៤- ពិនិត្យ តាមដានសកម្មភាពសង្គមពាក់ព័ន្ធនឹងសកម្មភាពរបស់ស្ត្រីដើម្បីមានវិធានការឆ្លើយតប ជាក់ស្តែង អោយបានសមស្របទាន់ពេលវេលាតាមគ្រប់រូបភាព។

៥- សហការជាមួយគ្រប់អង្គការចាត់តាំង ស្ថាប័ននានា គ្រប់លំដាប់ថ្នាក់ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ និងសប្បុរសជនដើម្បីកៀរគរធនធាននឹងការគាំទ្រតាមមធ្យោបាយផ្សេងៗ សម្រាប់បម្រើអោយ ការអនុវត្តផែនការ និងគោលនយោបាយរបស់គណបក្ស។

៦- រៀបចំគោលការណ៍ណែនាំកំណត់តួនាទី ភារកិច្ច របៀបរបបការងារ របស់ក្រុមចលនាស្ត្រី។

### *៣. គណៈចលនាសហជីព អក្សរកាត់ "គ.ច.ស"*

- **តួនាទី÷**

ជាសេនាធិការរបស់គណៈចលនាមហាជនក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងក្រុមការងារទាំងអស់ របស់គណបក្សដែលបំពេញការងារក្នុងស្រទាប់កម្មករនិយោជិត និងនិយោជក ដើម្បីធានាបាន សុខដុមនីយកម្ម ការងារចលនាកម្មករនិយោជិត ក្រោមការដឹកនាំរួមរបស់គណបក្ស។

- **ភារកិច្ច÷**

១- រៀបចំផែនការរួម និងផែនការសកម្មភាព ដែលមានភាពស៊ីចង្វាក់ជាមួយអង្គការចាត់តាំងគណបក្ស គ្រប់ផ្នែក និងប្រតិបត្តិករនានា ដើម្បីដាក់ជូនគណៈចលនាមហាជន នៃគណៈកម្មាធិការកណ្តាល ពិនិត្យសម្រេច។

២- សហការប្រមូល និងវិភាគព័ត៌មាន សំដៅក្តាប់អោយជាប់នូវស្មារតីសតិអារម្មណ៍គោលជំហរ និង សំណូមពររបស់កម្មករនិយោជិត និយោជក សហជីព និងអង្គការវិជ្ជាជីវៈ ដើម្បីធ្វើជាមូលដ្ឋាន ក្នុងការកសាងកម្មវិធីនយោបាយរបស់គណបក្ស និងឯកសារឃោសនាអប់រំ អូសទាញកម្មករ និយោជិត និងនិយោជក អោយបន្តចូលរួមគាំទ្រ និងបោះឆ្នោតជូនគណបក្ស។

៣- សម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាបំប៉នសមត្ថភាព មន្ត្រីគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក និងប្រតិបត្តិករនានាអោយមានសិល្បៈក្នុងការពន្យល់បកស្រាយពីសិទ្ធិ និងអត្ថប្រយោជន៍ ដែលគណបក្សបាននឹងកំពុងខិតខំការពារ និងផ្តល់ជូនកម្មករនិយោជិត និយោជក សហជីព និង អង្គការវិជ្ជាជីវៈ។

៤- រំលឹកតាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក និងប្រតិបត្តិករនានាលើការងារគ្រប់គ្រង និងពង្រឹងសតិអារម្មណ៍កម្មករនិយោជិត និយោជក សហជីព និងអង្គការវិជ្ជាជីវៈ។

៥-ណែនាំ ចាត់តាំង និងផ្សារភ្ជាប់ជាមួយកម្មករនិយោជិត តាមរោងចក្រ សហគ្រាស និងតាមលំនៅដ្ឋានរបស់កម្មករនិយោជិត។

៦-សហការជាមួយបណ្តាសហជីព សមាគមនិយោជក និងអង្គការវិជ្ជាជីវៈនានា ក្នុងការកៀរគរធនធាននានាសម្រាប់បម្រើអោយការអនុវត្តផែនការសកម្មភាពរបស់គណៈចលនាសហជីព។

### *៤. គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ អក្សរកាត់ "គ.ច.អ.ស"*

- **តួនាទី៖**

ជាសេនាធិការជូនគណៈចលនាមហាជនក្នុងការតម្រង់ទិស និងសម្របសម្រួលជួយឧបត្ថម្ភ និងសហការជាមួយអង្គការ សមាគម ដៃគូអភិវឌ្ឍន៍ និងក្រុមការងារនានាដែលបំពេញការងារក្នុងស្រទាប់មហាជនក្រៅពីចលនាយុវជន ស្ត្រី កម្មករ និងនិយោជិត ដើម្បីបំផុសចលនាប្រជាជនការពារសមិទ្ធផលសង្គមជាតិ និងកសាងប្រទេសជាតិស្របតាមកម្មវិធីនយោបាយរបស់គណបក្ស។

- **ភារកិច្ច៖**

១-ស្រាវជ្រាវចងក្រងគោលការណ៍នយោបាយនៃការងារគណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ ដើម្បីដាក់ជូនគណៈចលនាមហាជន គណៈកម្មាធិការកណ្តាលពិនិត្យ សម្រេច និងតម្រង់ទិសអនុវត្ត។

២-ពិនិត្យ តាមដាន វាយតម្លៃ សកម្មភាពបណ្តាអង្គការ នៃគណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍។

៣-រៀបចំ កសាង និងអភិវឌ្ឍផែនការសកម្មភាព គំរោងសកម្មភាពនានាក្នុងគោលដៅសហការ សម្របសម្រួល ឬឆ្លើយតបជាមួយបណ្តាអង្គការសង្គម សមាគម និងដៃគូអភិវឌ្ឍន៍។

៤-ពង្រឹងភាពជាដៃគូ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាអង្គការសមាគម ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ និងដៃគូពាក់ព័ន្ធនានា ដើម្បីកៀរគរធនធាន និងការគាំទ្រតាមមធ្យោបាយផ្សេងៗទៀតសម្រាប់បម្រើអោយ ការអនុវត្តផែនការ និងគោលនយោបាយរបស់គណបក្ស។

៥-ទាក់ទង សហការការងារល្អជាមួយគណបក្សគ្រប់ថ្នាក់ និងមុខសញ្ញានានា ដើម្បីបំពេញតួនាទី ភារកិច្ចអោយបានសម្រេចជោគជ័យ និងប្រសិទ្ធភាពខ្ពស់ជូនគណបក្ស។

៦-គ្រប់គ្រង ចាត់ចែង ថែរក្សាឯកសារ លិខិតស្នាមរដ្ឋបាលរបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍អោយបានត្រឹមត្រូវ។

***៥. អគ្គលេខាធិការដ្ឋានគណៈចលនាមហាជន*** មានរចនាសម្ព័ន្ធ តួនាទី ភារកិច្ចដូចខាងក្រោម៖

- **រចនាសម្ព័ន្ធមាន ៣ផ្នែក ដូចខាងក្រោម៖**

១-ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

២-ផ្នែកសិក្សាស្រាវជ្រាវ និងគោលនយោបាយ

៣-ផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា

- **តួនាទីភារកិច្ចរបស់ផ្នែកនីមួយៗ៖**

១-ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី ភារកិច្ច÷

- ពិនិត្យ ចាត់ចែងនូវរាល់លិខិតចេញចូល ដែលស្ថាប័នជុំវិញគណៈកម្មាធិការកណ្តាលផ្ញើជូនគណៈចលនាមហាជន។
- បញ្ជូនគោលការណ៍ សេចក្តីសម្រេច សារាចរណែនាំ និងលិខិតស្នាមរដ្ឋបាលនានារបស់គណៈចលនាមហាជន។
- ទំនាក់ទំនង សហការ ពិនិត្យ ដោះស្រាយ ទទួល បញ្ជូនលិខិតស្នាមរដ្ឋបាលឯកសារផ្សេងៗទៀតពីគណៈចលនាមហាជន ទៅស្ថាប័នពាក់ព័ន្ធនានា។
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងការងារពិធីការរបស់គណៈចលនាមហាជន។
- គ្រប់គ្រងឯកសារបុគ្គលិក ភស្តុភារ និងគណនេយ្យរបស់អគ្គលេខាធិការដ្ឋាន។
- ធ្វើការបូកសរុបរបាយការណ៍នៃគណៈចលនាមហាជនថ្នាក់រាជធានី-ខេត្ត ក្រសួង-ស្ថាប័ន និងគណៈជំនាញនីមួយៗ នៃគណៈចលនាមហាជនថ្នាក់កណ្តាល។
- កៀរគរប្រភពធនធានស្របច្បាប់ ដើម្បីធ្វើជាមធ្យោបាយបំពេញភារកិច្ច អោយមានប្រសិទ្ធភាព។
- បូកសរុបរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋានជូនគណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល។
- បំពេញភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការគណៈចលនាមហាជនប្រគល់ជូន។

២.ផ្នែកសិក្សាស្រាវជ្រាវ និងគោលនយោបាយ មានតួនាទី និងភារកិច្ច÷

- ជាសេនាធិការរបស់អគ្គលេខាធិការដ្ឋាន ដើម្បីសហការជាមួយគណៈចលនាចំណុះគណៈចលនាមហាជន ក្នុងការរៀបចំសេចក្តីព្រាងផែនការសកម្មភាពការងារគណៈចលនាមហាជន ជូនគណៈចលនាមហាជនពិនិត្យនិងសម្រេច។
- សហការជាមួយផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ក្នុងការវាយតម្លៃ និងតាមដានវឌ្ឍនភាពការងាររបស់គណៈចលនាមហាជនថ្នាក់រាជធានី-ខេត្ត ក្រសួង-ស្ថាប័ន។
- សិក្សា វាយតម្លៃអំពីស្ថានភាពនយោបាយ និងសកម្មភាពរបស់មជ្ឈដ្ឋានអមិត្ត ព្រមទាំងពិនិត្យរៀបចំឯកសារវិភាគ ស្រាវជ្រាវ និងសុន្ទរកថាសំខាន់ៗពាក់ព័ន្ធនឹងគោលនយោបាយរបស់គណបក្ស និងរាជរដ្ឋាភិបាល។
- រៀបចំជាទស្សនទាន ការវិភាគនានាពាក់ព័ន្ធសតិអារម្មណ៍មហាជន និងសភាពការណ៍នយោបាយដើម្បីជាមូលដ្ឋានរៀបចំគោលនយោបាយពាក់ព័ន្ធលើការងារគណៈចលនាមហាជន។
- សហការជាមួយគណៈចលនាចំណុះគណៈចលនាមហាជន ប្រមូលព័ត៌មានពីតម្រូវការ សំណូមពរពីមហាជន នៅក្នុងស្រទាប់យុវជន ស្ត្រី កម្មករនិយោជិត។ល។
- សិក្សា និងវិភាគ លើកចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈមនានា ពាក់ព័ន្ធការងារមហាជនជូនអគ្គលេខាធិការដ្ឋានគណៈចលនាមហាជន។
- សហការជាមួយក្រុមការងារគណៈចលនាចំណុះគណៈចលនាមហាជន និងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំ ចងក្រង គោលនយោបាយពាក់ព័ន្ធនានា លើការងារចលនាមហាជន។

- បំពេញភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការគណៈចលនាមហាជនប្រគល់ជូន។

៣. ផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ច÷

- ទទួលបន្ទុកផ្សព្វផ្សាយអំពីសមិទ្ធផល បេសកកម្ម និងសកម្មភាពរបស់ថ្នាក់ដឹកនាំសមាជិក សមាជិការបស់គណៈចលនាមហាជន តាមបណ្ដាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានា។
- សិក្សា រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់អគ្គលេខាធិការដ្ឋានគណៈចលនាមហាជន។
- ស្រាវជ្រាវ ផ្ដួចផ្ដើម និងសម្របសម្រួលលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ សម្រាប់បង្កើនប្រសិទ្ធភាពការងាររបស់អគ្គលេខាធិការដ្ឋានគណៈចលនាមហាជន ក៏ដូចជាជួយសម្របសម្រួលទំនាក់ទំនងរវាងអគ្គលេខាធិការដ្ឋាន និងរចនាសម្ព័ន្ធគណៈចលនាមហាជនគ្រប់ជាន់ថ្នាក់។
- បំពេញភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការគណៈចលនាមហាជនប្រគល់ជូន។

***៦. គណៈកម្មាធិការគណបក្សក្រសួង-ស្ថាប័ននៃថ្នាក់កណ្ដាល (ឧបសម្ព័ន្ធ២)***




**រចនាសម្ព័ន្ធក្រុមការងារចលនាមហាជនតាមក្រសួង-ស្ថាប័ន រួមមាន÷**

១-ក្រុមការងារយុវជនគណបក្សដឹកនាំការងារយុវជនក្នុងស្ថាប័ន

- ស.ស.យ.ក តាមក្រសួង-ស្ថាប័ន

២-ក្រុមការងារស្ត្រីដឹកនាំការងារស្ត្រីក្នុងស្ថាប័ន

- សមាគមនារី ដើម្បីសន្តិភាព និងការអភិវឌ្ឍ

៣-ច្បាប់ស្ដីពីសហជីពមិនមានវិសាលភាពអោយមន្ត្រីសាធារណៈចូលជាសមាជិកសហជីពទេ

៤-រណសិរ្សក្រសួងស្ថាប័នដឹកនាំការងាររណសិរ្សក្នុងស្ថាប័ន

- សមាគមមូលនិធិសាមគ្គីរបស់មន្ត្រីរាជការតាមស្ថាប័ន សមាគមបុគ្គលិកសិក្សារបស់គណបក្ស

## ២. ថ្នាក់រាជធានី-ខេត្ត (ឧបសម្ព័ន្ធ៣)




### ក. អំពីតួនាទី ភារកិច្ចៈ

***១. តួនាទី÷***

គណៈចលនាមហាជនគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីជាស្ថាប័នជំនួយការរបស់គណៈកម្មាធិការគណបក្សថ្នាក់នីមួយៗ ក្នុងការដឹកនាំការងារចលនាមហាជនរបស់គណបក្សក្នុងស្រទាប់មហាជន យុវជន ស្ត្រី កម្មករនិយោជិត និងអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍នានា ដើម្បីធានាអោយបាននូវប្រសិទ្ធភាពក្នុងការងារអភិវឌ្ឍកម្មវិធីនយោបាយ និងគោលនយោបាយរបស់គណបក្ស នៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

***២. ភារកិច្ច÷***

១- ណែនាំ និងផ្សព្វផ្សាយគោលការណ៍គ្រប់គ្រងការងារចលនាមហាជននៅតាមគ្រប់មូលដ្ឋានដូចជា មន្ទីរ អង្គភាពចំណុះ សហគមន៍ គ្រឹះស្ថានសាធារណៈ ឯកជន អង្គការសមាគម និងវត្តអារាម ក្នុងន័យក្តាប់អោយបាននូវតម្រូវការសំណូមពរ និងសតិអារម្មណ៍ ដើម្បីវិភាគចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងកាលានុវត្តភាពរបស់គណបក្ស ដើម្បីកសាងយន្តការព្រមទាំងធ្វើការដោះស្រាយសមស្របមួយ សំដៅអនុវត្តអោយបានជោគជ័យនូវកម្មវិធី និងគោលនយោបាយរបស់គណបក្ស។

២- ស្រាវជ្រាវសភាពការណ៍សតិអារម្មណ៍ក្នុងស្រទាប់យុវជន ស្ត្រី កម្មករនយោជិត និងគ្រប់មជ្ឈដ្ឋានមហាជន ព្រមទាំងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងសតិអារម្មណ៍ស្រពិចស្រពិល ឬថ្នាំងថ្នាក់ជាមួយគណបក្ស ដើម្បីរៀបចំផែនការកម្មវិធីខ្លឹមសារអប់រំនយោបាយបណ្តុះបណ្តាលបំពាក់បំប៉ន និងលើកសំណើជូនគណៈអចិន្ត្រៃយ៍គណបក្សរបស់ខ្លួនដើម្បីពិនិត្យសម្រេច។

៣- កសាង និងអនុម័តផែនការសកម្មភាពរបស់ខ្លួន។

៤-តាមដាន ត្រួតពិនិត្យ វាយតម្លៃ ការអនុវត្តតួនាទី ភារកិច្ចរបស់គណៈចលនានីមួយៗសំដៅកែលម្អ ពង្រឹងអោយទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

៥-តាមដានស្វែងយល់ និងវិភាគសកម្មភាព ឧបាយកលរបស់ពួកអមិត្ត និងតាមមជ្ឈដ្ឋាននានា ដើម្បីរៀបចំវិធានការទប់ស្កាត់ព្រមទាំងផ្តល់គោលការណ៍វាយបកអោយសមស្របទាន់ពេលវេលា តាមគ្រប់មធ្យោបាយ។

៦-កៀរគរប្រភពធនធានស្របច្បាប់ដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព។

### ៣.រចនាសម្ព័ន្ធ

**រចនាសម្ព័ន្ធ** ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការគណបក្សរាជធានី-ខេត្តសាមី ត្រូវដឹកនាំដោយមន្ត្រីគណបក្ស ដែលមានតួនាទីជាអភិបាលរាជធានី-ខេត្ត។

១-គណៈចលនាយុវជននៃគណៈចលនាមហាជន នៃគណបក្សរាជធានី-ខេត្តមានតួនាទីជាសេនាធិការ របស់គណៈចលនាមហាជន គណៈកម្មាធិការគណបក្សរាជធានី-ខេត្តក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ រចនាសម្ព័ន្ធក្រុមការងារយុវជនទាំងអស់ របស់គណបក្សក្នុងមូលដ្ឋានរបស់ខ្លួននីមួយៗគ្រប់ថ្នាក់ សំដៅដល់ការគ្រប់គ្រងអោយបាននៅកម្លាំងយុវជន ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់គណបក្ស ប្រកបដោយជោគជ័យក្រោមការដឹកនាំរួមរបស់គណបក្ស។

-គណៈចលនាយុវជននៃគណៈចលនាមហាជន គណបក្សរាជធានី-ខេត្ត ត្រូវដឹកនាំដោយមន្ត្រីបក្ស ដែលមានតួនាទីជាអភិបាលនៃគណៈភិបាលរាជធានី-ខេត្ត និងមានអនុប្រធាន និងសមាជិកមួយ ចំនួនតាមការចាំបាច់។

២-ក្រុមចលនាស្ត្រីរបស់គណៈចលនាមហាជន គណៈកម្មាធិការគណបក្សរាជធានី-ខេត្តមានតួនាទីជា សេនាធិការរបស់គណៈចលនាមហាជន ក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួលការងារ ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងរចនាសម្ព័ន្ធក្រុមការងារ ស្ត្រីទាំងអស់ របស់គណបក្សក្នុងមូលដ្ឋានរបស់ខ្លួន សំដៅដល់ការគ្រប់គ្រងអោយបាននូវកម្លាំងស្ត្រី ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់គណបក្សប្រកបដោយជោគជ័យក្រោមការដឹកនាំរួមរបស់គណបក្ស។

-ក្រុមចលនាស្ត្រី គណៈចលនាមហាជន នៃគណៈកម្មាធិការគណបក្សរាជធានី-ខេត្ត ត្រូវដឹកនាំ ដោយមន្ត្រីបក្សដែលមានតួនាទីជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី-ខេត្តសាមី និងមាន អនុប្រធាន សមាជិកមួយចំនួនតាមការចាំបាច់។

៣-គណៈចលនាសហជីព នៃគណៈចលនាមហាជន គណៈកម្មាធិការគណបក្សរាជធានី-ខេត្ត មាន តួនាទីជាសេនាធិការរបស់គណៈចលនាមហាជនក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ច របស់អង្គការចាត់តាំង យន្តការ និងរចនាសម្ព័ន្ធ

ក្រុមការងារ សហជីពទាំងអស់របស់គណបក្សក្នុងមូលដ្ឋានរបស់ខ្លួននីមួយៗគ្រប់ថ្នាក់ សំដៅដល់ការគ្រប់គ្រង អោយបាននូវកម្លាំងសហជីព ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់គណបក្សប្រកបដោយជោគជ័យក្រោមការដឹកនាំរួមរបស់គណបក្ស។

-គណៈចលនាសហជីពនៃគណៈចលនាមហាជន គណបក្សរាជធានី-ខេត្ត ដឹកនាំដោយប្រធានមួយរូប អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់។

៤-គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ នៃគណៈចលនាមហាជន គណៈកម្មាធិការគណបក្សរាជធានី-ខេត្ត មានតួនាទីជាសេនាធិការរបស់គណៈចលនាមហាជនក្នុងការដឹកនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងរចនាសម្ព័ន្ធក្រុមការងារ អង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ទាំងអស់របស់គណបក្សក្នុងមូលដ្ឋានរបស់ខ្លួននីមួយៗគ្រប់ថ្នាក់ សំដៅដល់ការគ្រប់គ្រងអោយបាននូវកម្លាំងអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់គណបក្សប្រកបដោយជោគជ័យ ក្រោមការដឹកនាំរួមរបស់គណបក្ស។

-គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ នៃគណៈចលនាមហាជន គណៈកម្មាធិការគណបក្សរាជធានី-ខេត្ត មានប្រធានមួយរូប អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់។

៥-លេខាធិការដ្ឋាននៃគណៈចលនាមហាជន គណបក្សរាជធានី-ខេត្ត មានតួនាទីជាជំនួយការគ្រប់គ្រង ការងាររដ្ឋបាល ឯកសារ បុគ្គលិក ភស្តុភារ ហិរញ្ញវត្ថុ បូកសរុបរបាយការណ៍ និងដំណើរការរដ្ឋបាលប្រចាំថ្ងៃស្របតាមទិសដៅការងារចលនាមហាជននៃគណបក្សរាជធានី-ខេត្ត។

## ៣. ថ្នាក់ ក្រុង ស្រុក ខណ្ឌ (ឧបសម្ព័ន្ធ៤)



នៅថ្នាក់ ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំមន្ត្រីគណបក្សដែលជាអភិបាល ក្រុង ស្រុក ខណ្ឌ អោយទទួលបន្ទុកផ្ទាល់លើការងារចលនាមហាជន និងចលនាយុវជន។

សមាជិកមួយរូបនៃគណៈកម្មាធិការគណបក្ស ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកលើការងារចលនាស្ត្រី ។

យោងតាមសេចក្តីសម្រេចអំពីរចនាសម្ព័ន្ធគណៈចលនាមហាជន នៅថ្នាក់ ក្រុង ស្រុក ខណ្ឌ មានគណៈចលនាយុវជន និងក្រុមការងារស្ត្រី។

យោងសារាចរណែនាំលេខ១១៨ របស់គណបក្សនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ ត្រូវមានគណៈកម្មាធិការដឹកនាំការកសាងគណបក្ស កសាងអង្គការសហជីព និងចលនាកម្មករនិយោជិត តាមរោងចក្រសហគ្រាស ដែលចំណុះគណៈចលនាមហាជន ស្ថិតក្រោមការដឹកនាំរបស់គណបក្ស។ ចំពោះគណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ គណៈចលនាមហាជន ក្រុង ស្រុក ខណ្ឌ អាចបង្កើតក្រុមការងារដែលធ្វើសកម្មភាពក្នុងមហាជនក្រៅពីមុខសញ្ញានៃ គណៈចលនាទាំងបីខាងលើ ចំណុះគណៈចលនាមហាជន ក្រុង ស្រុក ខណ្ឌ និងស្ថិតក្រោមការដឹកនាំរបស់គណបក្ស ក្រុង ស្រុក ខណ្ឌ។

### ៤. ថ្នាក់ ឃុំ សង្កាត់ (ឧបសម្ព័ន្ធ៥)




នៅថ្នាក់ ឃុំ សង្កាត់ ត្រូវរៀបចំអនុប្រធានមួយរូបនៃគណៈកម្មាធិការគណបក្ស ឃុំ សង្កាត់ អោយទទួលបន្ទុកលើការងារចលនាមហាជន និងរៀបចំសមាជិកមួយរូបនៃគណៈកម្មាធិការគណបក្ស ឃុំ សង្កាត់ អោយទទួលបន្ទុកលើការងារចលនាស្ត្រី។

ចំពោះគណៈចលនាសហជីពត្រូវអនុវត្តតាម សារាចរលេខ១១៨ ហើយរៀបចំបង្កើតគណៈកម្មាធិការដឹកនាំការកសាងគណបក្ស កសាងអង្គការសហជីព និងចលនាកម្មករនិយោជិត តាមរោងចក្រ សហគ្រាស ថ្នាក់ឃុំ សង្កាត់ ដែលចំណុះគណៈចលនាមហាជន ស្ថិតក្រោមការដឹកនាំរបស់គណបក្ស ឃុំ សង្កាត់។

ចំពោះគណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ គណៈចលនាមហាជន ឃុំ សង្កាត់ អាចបង្កើតក្រុមការងារដែលធ្វើសកម្មភាពក្នុងមហាជនក្រៅពីមុខសញ្ញានៃគណៈចលនាទាំងបីខាងលើ ចំណុះគណៈចលនាមហាជន ឃុំ សង្កាត់ និងស្ថិតក្រោមការដឹកនាំរបស់គណបក្ស ឃុំ សង្កាត់។

តួនាទី ភារកិច្ចរបស់គណៈចលនាមហាជន និងគណៈចំណុះរបស់គណៈចលនាមហាជននៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានខ្លឹមសារដូចគ្នា នឹងតួនាទីភារកិច្ចគណៈចលនាមហាជនគណៈកម្មាធិការកណ្តាល គ្រាន់តែវិសាលភាព និងរង្វង់សកម្មភាពស្ថិតក្នុងមូលដ្ឋានរៀងៗខ្លួន។

## IV. របៀបរបបធ្វើការរបស់គណៈចលនាមហាជនគ្រប់ថ្នាក់

១- គណៈចលនាមហាជនគ្រប់ថ្នាក់ ត្រូវបំពេញភារកិច្ចតាមការដឹកនាំរបស់គណៈកម្មាធិការគណបក្សនៅថ្នាក់របស់ខ្លួន។

២- គណៈជំនាញនៃគណៈចលនាមហាជនធ្វើការក្រោមការដឹកនាំរបស់គណៈចលនាមហាជន។

៣- គណៈចលនាមហាជន និងគណៈចលនាចំណុះថ្នាក់នីមួយៗ ត្រូវបំពេញភារកិច្ចតាមរបបសមូហភាពដឹកនាំបុគ្គលទទួលខុសត្រូវ។

៤- គណៈចលនាមហាជន និងគណៈចលនាចំណុះនីមួយៗគ្រប់ថ្នាក់ត្រូវមានរបបប្រជុំសាមញ្ញមួយខែម្តង ហើយ មានករណីចាំបាច់អាចកោះប្រជុំវិសាមញ្ញបាន។

៥- គណៈចលនាមហាជន នៃគណបក្សគ្រប់ថ្នាក់រាជធានី-ខេត្ត ត្រូវរាយការណ៍អំពីលទ្ធផលកិច្ចប្រជុំជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សសាមីរបស់ខ្លួនយ៉ាងយូរបំផុត៧ថ្ងៃក្រោយ កិច្ចប្រជុំដើម្បីសុំយោបល់ណែនាំ និងផ្ញើជូនអគ្គលេខាធិការនៃគណៈចលនាមហាជនគណៈកម្មាធិការកណ្តាល។ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក៏ត្រូវអនុវត្តដូចគ្នា។

៦- ចំពោះគណៈចំណុះនៃគណៈចលនាមហាជនគ្រប់ថ្នាក់ត្រូវរាយការអំពីលទ្ធផលនៃកិច្ចប្រជុំជូនគណៈចលនាមហាជន នៅថ្នាក់របស់ខ្លួន ដើម្បីសុំយោបល់ដឹកនាំ និងត្រូវចម្លងជូនគណៈចលនាជំនាញថ្នាក់លើជ្រាបជារបាយការណ៍។

៧- គណៈចលនាមហាជន និងគណៈចលនាចំណុះនីមួយៗគ្រប់ថ្នាក់ត្រូវលើកផែនការសកម្មភាពកសាងបទបញ្ជាផ្ទៃក្នុង និងរៀបចំមន្ត្រីជំនួយការរបស់ខ្លួន ដើម្បីធានាអនុវត្តភារកិច្ចអោយបានល្អប្រកបដោយប្រសិទ្ធភាព ខ្ពស់ស្របតាមគោលការណ៍របស់គណបក្ស។

៨- គណៈចលនាមហាជន និងគណៈចំណុះនីមួយៗ ត្រូវអនុវត្តអោយបានត្រឹមត្រូវនូវរបបរាយការណ៍តាមការកំណត់ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ។

## V. វិធីសាស្ត្រ ចរិត អភិក្រម ការងារចលនាមហាជន

### ១.វិធីសាស្ត្រ

យោងតាមមតិដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្ស** វិធីសាស្ត្រការងារចលនាមហាជនគឺការងារនយោបាយ សតិអារម្មណ៍ ចាត់តាំង។ មានន័យថា ចលនាមហាជនជាការគួបផ្សំរវាងការងារនយោបាយ ការងារសតិអារម្មណ៍ និងការបំផុសមហាជនចូលរួម។

វិធីសាស្ត្របំផុសចលនាមហាជន គឺជាការភ្ជាប់ទំនាក់ទំនងរវាងថ្នាក់ដឹកនាំគណបក្ស ថ្នាក់ដឹកនាំគណៈចលនាមហាជន ថ្នាក់ដឹកនាំអង្គការមហាជនគ្រប់ថ្នាក់ជាមួយសមាជិក សមាជិកា ជាមួយមហាជន ប្រជាជន ដើម្បីទាក់ទាញការគាំទ្រ និងការចូលរួមរបស់មហាជន ប្រជាជន។ មានតែការចុះជាប់ជាមួយមហាជន ប្រជាជន ទើបមហាជនប្រជាជនស្គាល់ និងមានទំនាក់ទំនងជាមួយយើង ការចុះជួបមហាជន ប្រជាជន អោយបានញឹកញាប់ និងទទួលបានការគាំទ្រកាន់តែច្រើន ដូចពាក្យស្លោក "ជួបច្រើន ទទួលបានការគាំទ្រច្រើន"។

#### ក. នយោបាយ

១-ការងារចលនាមហាជនត្រូវប្រកាន់ខ្ជាប់មាគ៌ានយោបាយ និងកម្មវិធីនយោបាយរបស់គណបក្ស និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។

២-ត្រូវឈរលើទស្សនៈគ្រប់ជ្រុងជ្រោយក្រោមការវិភាគ វាយតម្លៃសភាពការណ៍ និងរៀបចំគោលការណ៍គោលនយោបាយនៃការងារចលនាមហាជនអោយបានត្រឹមត្រូវតាមមុខសញ្ញាមហាជន តាមដំណាក់កាលនិងតាមភូមិសាស្ត្រនីមួយៗ។

៣-ត្រូវស្តាប់ និងតាមដានដោយយកចិត្តទុកដាក់នូវសុន្ទរកថា និងសារនយោបាយនានាដ៏មានអត្ថន័យជ្រាលជ្រៅរបស់ **សម្តេចប្រធានគណបក្ស** និង **សម្តេចនាយករដ្ឋមន្ត្រី អនុប្រធានគណបក្ស** ដោយចាត់ទុកជាខ្លឹមសារនយោបាយ សម្រាប់ការចិញ្ចឹមការងារចលនាមហាជនជាប្រចាំ។

#### ខ. សតិអារម្មណ៍

ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការថែទាំកម្លាំងនយោបាយគាំទ្រគណបក្ស ជាពិសេសប្រជាពលរដ្ឋដែលបានគាំទ្រគណបក្ស។ បន្តពង្រឹងមន្ត្រីគណបក្សអោយមានគោលជំហររឹងមាំខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងដោយត្រូវពង្រឹងពីគោលជំហរស្នេហាជាតិ គោលជំហរគោរពស្រលាញ់ បម្រើប្រជាជនអស់ពីចិត្តពីថ្លើម និងដោយឥតលក្ខខណ្ឌ គោលជំហរប្រយុទ្ធប្រឆាំងដាច់អហង្ការចំពោះឧបាយកល និងល្បិចកលចំពោះពួកអមិត្ត ទាំងក្នុងនិងក្រៅប្រទេសដែលប៉ុនប៉ងផ្តួលរំលំគណបក្សយើងតាមគ្រប់រូបភាព។

បន្តអនុវត្តអោយបានជាប់លាប់នូវយុទ្ធសាស្ត្រសាធារណមតិប្រតិសកម្ម និងបុរេសកម្ម ដែលត្រូវតាមដានវាយតម្លៃសតិអារម្មណ៍ ការយល់ឃើញរបស់មហាជន ទាំងលើប្រព័ន្ធបណ្តាញសង្គម និងនៅតាមមូលដ្ឋានផ្ទាល់ក្រោមរូបភាពជាការអង្កេត ស្ទង់មតិពីចំណាប់អារម្មណ៍ ការរំពឹងទុក ដោយមិនត្រូវផ្តេកផ្តួលស្លឹកស្រពន់នោះឡើយព្រោះ "ជំនឿចិត្តដែលទទួលបានពីប្រជាជនត្រូវការកសាងជាប្រចាំ និងត្រូវការរយៈពេលយូរ"។

ថែរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុងអោយបានរឹងមាំតាមពាក្យស្លោក “សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់” ត្រូវចងចាំថាសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់គណបក្ស រឹងមាំទៅបានត្រូវឈរលើលក្ខន្តិកៈកម្មវិធីនយោបាយ គោលការណ៍ នយោបាយ និងសេចក្តីសម្រេចចិត្តនានារបស់គណបក្ស។

គណៈកម្មាធិការគណបក្ស គណៈចលនាមហាជន បណ្តាអង្គការមហាជន និងប្រព័ន្ធឃោសនារបស់គណបក្ស ត្រូវបន្តយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្មតាមគ្រប់រូបភាព នូវការងារអប់រំនយោបាយ សតិអារម្មណ៍ទាំងក្នុងគណបក្ស ទាំងក្នុងមហាជន។ ការងារចិញ្ចឹមចលនានៅមូលដ្ឋាន ទាំងខាងស្មារតី និងសំភារៈត្រូវបន្តអនុវត្តជាប្រចាំ។

**គ.ចាត់តាំង អនុវត្តន៍**

ពង្រឹងរចនាសម្ព័ន្ធចាត់តាំងរបស់គណៈចលនាមហាជនគ្រប់ថ្នាក់តាំងពីថ្នាក់កណ្តាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងពង្រឹងរចនាសម្ព័ន្ធចាត់តាំង អង្គការមហាជនទាំងអស់ របស់គណបក្ស ណែនាំអនុវត្តត្រឹមត្រូវ តាមលក្ខន្តិកៈ របៀបរបបការងារ និងធ្វើសកម្មភាពជាក់ស្តែងទៀងទាត់។ អង្គការមហាជននីមួយៗត្រូវមានការតាមដាន ត្រួតពិនិត្យជាប្រចាំនូវប្រសិទ្ធភាពនៃការងារ និងបញ្ហាប្រឈម ដើម្បីដាក់ចេញនូវវិធានការកែលម្អអោយទាន់ពេលវេលា។

**២.ចរិតនៃការងារចលនាមហាជន**

ការងារចលនាមហាជន មានសារៈសំខាន់ជាកត្តាកំណត់ជោគជ័យក្នុងការសម្រេចភារកិច្ចនយោបាយ របស់គណបក្សតាមដំណាក់កាលនីមួយៗ។

ការងារចលនាមហាជន ត្រូវមានភាពម៉ឺងម៉ាត់ ម៉ត់ចត់ អត់ធ្មត់ ព្យាយាម ទន់ភ្លន់ បត់បែន ទៅតាមស្ថានភាព ជាក់ស្តែង។ ត្រូវប្រកាន់ឥរិយាបទរស់រាយរាក់ទាក់ ក្នុងការទំនាក់ទំនងជាមួយមហាជន ប្រជាជនគ្រប់មជ្ឈដ្ឋានដោយ ស្នាមញញឹមចេញពីបេះដូង។

ត្រូវប្រកាន់ឥរិយាបទនិយាយស្តីស្មោះត្រង់ មិនប្រជាភិថុតហួសហេតុ មិនសន្យាហួសហេតុដែលមិនអាច ធ្វើបានដោយអនុវត្តតាមពាក្យស្លោក “ហ៊ាននិយាយ ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ”។

ចលនាមហាជន និងគណបក្សប្រៀបដូចទឹកហើយនិងទូក ទឹកអាចបណ្តែតទូក តែទឹករលកខ្លាំង ក៏អាច ពន្លិចទូក។ ត្រូវតាមដាន ទប់ស្កាត់នូវរាល់ឧបាយកល សកម្មភាពពួកប្រឆាំងតាំងពីចាប់ផ្តើមនៅតូច អនុវត្តយុទ្ធសាស្ត្រ ផើបមួយ វាយមួយ មិនត្រូវទុកអោយរីករាលដាលទៅជាធំ។ ត្រូវអនុវត្តវិធានការសរុប មធ្យោបាយសរុប ក្នុងការ គ្រប់គ្រងចលនាមហាជន ដោយអនុវត្តអោយបានល្អនូវគោលនយោបាយរបស់គណបក្សស្តីពីសេរីភាព នៃការ បង្កើតអង្គការ សមាគម សេរីភាពសហជីព អង្គការវិជ្ជាជីវៈ ស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព។

**៣.អភិក្រម**

អភិក្រមនៃការងារមហាជន ត្រូវផ្តោតលើ (១)ការស្វែងយល់ពីតម្រូវការរបស់មុខសញ្ញាមហាជននីមួយៗ (២)ការស្វែងយល់ពីសំណូមពររបស់មុខសញ្ញាមហាជននីមួយៗ (៣)ការស្វែងយល់ពីសតិអារម្មណ៍ (៤)ការតាមដាន ស្វែងយល់វិភាគពីសកម្មភាពនៃភាគីបដិបក្ស និងបញ្ហាប្រឈម ដើម្បីវាយបក និងលើកដំណោះស្រាយ។

ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃគណៈចលនាមហាជន ត្រូវស្វែងយល់ និងអនុវត្តអភិក្រមនេះក្នុងការដឹកនាំ និងអនុវត្តការងារចលនាមហាជននៅគ្រប់ថ្នាក់ ដើម្បីនិរន្តរភាព និងប្រសិទ្ធភាពនៃការងារចលនាមហាជន។

# មេរៀនទី២

# វិធីសាស្ត្រគោលក្នុងការប្រឈម និងការគ្រប់គ្រងសមរភូមិសតិអារម្មណ៍ "ព័ត៌មាន សាធារណមតិ សតិអារម្មណ៍មហាជន"

រៀបរៀងដោយៈ **ឯកឧត្តម ហ៊ុយ វណ្ណៈ**

# មេរៀនទី២
# វិធីសាស្ត្រគោលក្នុងការប្រឈម និងការគ្រប់គ្រងសមរភូមិសតិអារម្មណ៍ "ព័ត៌មាន សាធារណមតិ សតិអារម្មណ៍មហាជន"

## I- សេចក្តីផ្តើម

### ក្រុមការងារព័ត៌មាននិងសាធារណមតិចំណុះគណៈចលនាមហាជន

**១.អំពីគណៈចលនាមហាជន**

សេចក្តីសម្រេចស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់ គណៈចលនាមហាជន នៃគណៈកម្មាធិការកណ្តាល លេខ៣២៧/១៥ សស.គក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២២០១៥ នៅត្រង់÷

- ប្រការ១ បានចែងថា គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល មានតួនាទីជាស្ថាប័នជំនួយការឱ្យគណៈកម្មាធិការកណ្តាល ក្នុងការដឹកនាំ ណែនាំ តម្រង់ទិស និងសម្របសម្រួល ការងារចលនាមហាជនរបស់គណបក្សក្នុងស្រទាប់មហាជន យុវជន ស្ត្រី កម្មករ និយោជិត និងអង្គការសង្គមនានា។
- ប្រការ២ ត្រង់ចំណុចទី(៥) អំពីភារកិច្ចរបស់គណៈចលនាមហាជនពាក់ព័ន្ធកិច្ចការព័ត៌មាន និងសាធារណមតិបានចែងថា តាមដាន ស្វែងយល់ វិភាគសកម្មភាព និងឧបាយកលរបស់មជ្ឈដ្ឋានអមិត្ត ដើម្បីមានវិធានការឆ្លើយតបជាក់ស្តែង ឱ្យបានសមស្រប ទាន់ពេលវេលាតាមគ្រប់មធ្យោបាយ។
- ប្រការ៣ អំពីរចនាសម្ព័ន្ធរបស់គណៈចលនាមហាជន មានដូចតទៅ÷
  - គណៈចលនាយុវជន
  - គណៈចលនាស្ត្រី
  - គណៈចលនាសហជីព
  - គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍
  - គណៈចលនាមហាជនគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
    (សេចក្តីណែនាំលេខ០២/១៧គចម.គក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧)
  - អគ្គលេខាធិការដ្ឋាន
    - ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
    - ផ្នែកសិក្សាស្រាវជ្រាវ និងគោលនយោបាយ
    - ផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា
    (សេចក្តីសម្រេចលេខ០១/២១សស.គចម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១)

## ២.ផ្នែកផ្សព្វផ្សាយនិងព័ត៌មានវិទ្យា

ចំណុះឱ្យអគ្គលេខាធិការដ្ឋានគណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជា ត្រូវបានបង្កើតឡើងដោយ សេចក្ដីសម្រេចលេខ ០១/២១ សស.គចម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។ ផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា មានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- ទទួលបន្ទុកផ្សព្វផ្សាយអំពីសមិទ្ធផល បេសកកម្ម និងសកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា គណៈចលនាមហាជន តាមបណ្ដាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានា
- សិក្សារៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់អគ្គលេខាធិការដ្ឋានគណៈចលនាមហាជន
- ស្រាវជ្រាវ ផ្ដួចផ្ដើម និងសម្របសម្រួល លើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ សម្រាប់បង្កើន ប្រសិទ្ធភាពការងាររបស់អគ្គលេខាធិការដ្ឋានគណៈចលនាមហាជន ក៏ដូចជាជួយសម្របសម្រួល ទំនាក់ទំនងរវាងអគ្គលេខាធិការដ្ឋាន និងរចនាសម្ព័ន្ធគណៈចលនាមហាជនគ្រប់ជាន់ថ្នាក់
- បំពេញភារកិច្ចផ្សេងទៀតដែល អគ្គលេខាធិការដ្ឋានគណៈចលនាមហាជន ប្រគល់ជូន។

## ៣.ក្រុមការងារប្រមូលព័ត៌មាន វាយតម្លៃ និងឆ្លើយតបសតិអារម្មណ៍មហាជន ចំណុះគណៈចលនាមហាជន នៃគណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជា

ត្រូវបានបង្កើតឡើងដោយ សេចក្ដីសម្រេចលេខ ១០/២១ គចម.គក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១។ ក្រុមការងារ មានភារកិច្ចដូចខាងក្រោម÷

- សិក្សាស្រាវជ្រាវ ប្រមូលព័ត៌មាន ស្វែងយល់ វាយតម្លៃ អំពីសភាពការណ៍សតិអារម្មណ៍មហាជន ជាពិសេស លើបញ្ហាប្រឈម តម្រូវការ និងសំណូមពរនានា ក្នុងស្រទាប់យុវជន ស្ត្រី កម្មករនិយោជិត និងមជ្ឈដ្ឋានផ្សេងៗ ដើម្បីធ្វើសេចក្ដីរាយការណ៍ជូនគណៈចលនាមហាជន ដើម្បីពិនិត្យ និងមានវិធានការឆ្លើយតបជាក់ស្ដែង
- សិក្សាស្រាវជ្រាវ ប្រមូលព័ត៌មាន ស្វែងយល់ កំណត់មុខសញ្ញា និងតាមដានជាប្រចាំនូវសកម្មភាពរបស់មជ្ឈដ្ឋានប្រឆាំង និងអមិត្តទាំងឡាយ ព្រមទាំងវិភាគ វាយតម្លៃ អំពីឧបាយកល យុទ្ធវិធី និងភាពប្រទាក់ក្រឡានៃសកម្មភាពរបស់មជ្ឈដ្ឋានទាំងនេះ ដើម្បីធ្វើសេចក្ដីរាយការណ៍ជូនគណៈចលនាមហាជន ដើម្បីពិនិត្យ និងមានវិធានការឆ្លើយតបជាក់ស្ដែង
- សហការជាមួយយន្តការពាក់ព័ន្ធ ដើម្បីរៀបចំយន្តការ ខ្លឹមសារ និងជំរុញការពន្យល់ បកស្រាយ និងវាយបកលើព័ត៌មានបំភ្លៃផ្សេងៗ ដែលមានចរិតប៉ុនប៉ងញុះញង់ បញ្ឆេះកំហឹង បង្កចលាចល ដើម្បីផ្ដួលរំលំគណបក្សប្រជាជនកម្ពុជា
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនគណៈចលនាមហាជន នៃគណៈកម្មាធិការកណ្ដាល
- បំពេញភារកិច្ចផ្សេងទៀត ដែលគណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាល ប្រគល់ជូន។ (ក្រុមការងារប្រមូលព័ត៌មាន វាយតម្លៃ និងឆ្លើយតបសតិអារម្មណ៍មហាជន មានលេខាធិការដ្ឋាន ជាសេនាធិការ)។

## II- ភាពទាក់ទងគ្នារវាងកិច្ចការព័ត៌មាន សាធារណមតិ និងសតិអារម្មណ៍មហាជន

ការយល់ដឹងសំខាន់ៗ÷ បច្ចុប្បន្ននេះ បច្ចេកវិទ្យាព័ត៌មានវិទ្យាឌីជីថល និងបណ្តាញសង្គមបានក្លាយ ជាមធ្យោបាយដ៏សំខាន់ក្នុងការផ្សាយ ផ្សព្វផ្សាយ ចែករំលែក និងចែកចាយទស្សនៈ ព័ត៌មានគ្រប់ទម្រង់ជាសារសំឡេង រូបភាព វីដេអូ ដែលមានឥទ្ធិពលលឿនលើ កិច្ចការសង្គម សេដ្ឋកិច្ច នយោបាយហើយផ្នែកខ្លះបានបង្កើតជាសាធារណមតិ ដែលជះឥទ្ធិពលស្រួចស្រាវ លឿនរហ័ស លើសតិអារម្មណ៍មហាជន ថែមទៀតផង។ នៅក្នុងការរីកសាយភាយនៃព័ត៌មានជារៀងរាល់ថ្ងៃ គឺបានលាយឡំជាមួយនូវព័ត៌មានពិតដែលមានសារប្រយោជន៍ និងក៏មានព័ត៌មានគ្រោះថ្នាក់៤ប្រភេទទៀតផងដែរគឺរួមមាន ព័ត៌មានក្លែងក្លាយ (Fake News) ព័ត៌មានបំពុល (Disinformation) ព័ត៌មានបំភ័ន្ត Misinformation និងព័ត៌មានបំភ្លៃដោយបច្ចេកវិទ្យា (Deep Fake)។

- អ្វីជាព័ត៌មាន?
- អ្វីជាសាធារណមតិ?
- អ្វីជាសតិអារម្មណ៍មហាជន?

### ១. ការយល់ដឹងមូលដ្ឋានគន្លឹះ២យ៉ាងនៃ "ព័ត៌មាន និង ដំណឹង"

#### ក. ព័ត៌មាននិងដំណឹង ចេញមកពីប្រភពពយ៉ាង ឬហៅថា P-3 :

- មនុស្ស People ( សកម្មភាព និងសម្តី)
- ក្រដាស Paper( ខ្លឹមសារ)
- ទីកន្លែង Place( ហេតុការណ៍)

#### ខ. អ្វីជាព័ត៌មាន (NEWS)?

ជាព្រឹត្តិការណ៍ថ្មីៗដែលអ្នកសារព័ត៌មានធ្វើសេចក្តីរាយការណ៍តាមរយៈ បណ្តាញសារព័ត៌មានដែលរួមមាន÷ កាសែត ព្រឹត្តិបត្រ ទស្សនាវដ្តី ទូរទស្សន៍ វិទ្យុ និងបច្ចុប្បន្ន តាមរយៈប្រព័ន្ធឌីជីថល។ ព័ត៌មានត្រូវផលិតចេញតាមគោលការណ៍គ្រប់ជ្រុងជ្រោយ មានប្រភព ការពិត តុល្យភាព សច្ចៈភាព និងអាចផ្ទៀងផ្ទាត់បាន (5W+1H)។

#### គ. អ្វីជាដំណឹង (INFORMATION)?

គឺជាសារ (message) ដែលមានខ្លឹមសារ អត្ថន័យខុសៗគ្នាទៅតាមបរិបទ ហើយក៏មានទំនាក់ទំនងជាមួយទិន្នន័យ ការទំនាក់ទំនង ការអប់រំ និងចំណេះដឹង។ ដំណឹង មានចរិតលក្ខណៈ រំញោចអារម្មណ៍ ការយល់ឃើញផ្ទាល់ខ្លួន ហើយងាយបង្កភាពចលាចល។ ការផ្សាយដំណឹង មិនបាច់អនុវត្តតាមទម្រង់ (5W+1H) ទេ ពោលគឺមានប៉ុណ្ណាក៏ផ្សាយបាន។

#### ឃ. ក្នុងបរិបទបណ្តាញសង្គម ព័ត៌មាននិងដំណឹង ងាយក្លាយទៅជា សាធារណមតិ

នឹងជំរុញឱ្យកើតមានបញ្ហា **សតិអារម្មណ៍មហាជន** នៅពេលដែល ខ្លឹមសារ ឬរូបភាព ដែលពាក់ព័ន្ធរឿងរ៉ាវគ្រួសារ រឿងរ៉ាវផ្ទាល់ខ្លួន ឬអារម្មណ៍ផ្ទាល់ខ្លួន ត្រូវបានផ្សាយចេញនោះ មានលក្ខណៈរំញោចខ្លាំង និងស៊ីអារម្មណ៍ខ្លាំង។

#### ង. មុខងារព័ត៌មាន

បានវិវត្តន៍ជាបន្តបន្ទាប់ តាំងពីអតីតកាល រហូតបច្ចុប្បន្ន នៅលើវិស័យសំខាន់ៗ÷

- ការងារឃោសនាការ
- ការងារព័ត៌មាន

- ការងារចារកម្ម សន្តិសុខ យោធា
- ការងារទំនាក់ទំនងក្នុងសង្គម សេដ្ឋកិច្ច នយោបាយ
- បច្ចុប្បន្ននេះ ព័ត៌មានដើរតួនាទីសកម្មក្នុង ការងារសាធារណមតិ និងសតិអារម្មណ៍មហាជន។
- លើសពីនេះ កម្លាំងជំរុញកាន់តែខ្លាំងនិងមុតស្រួច នៅពេលគ្រប់យ៉ាងបានកំពុងប្រែក្លាយទៅជា÷ រដ្ឋាភិបាល ឌីជីថល សង្គមឌីជីថល សេដ្ឋកិច្ចឌីជីថល និង ពលរដ្ឋឌីជីថល។ ព័ត៌មាន ក៏បានកំពុងដើរតួយ៉ាងសកម្ម និងស្នូលនៅក្នុងកិច្ចការនយោបាយ និងការបោះឆ្នោតផងដែរ។

**ច. អ្វីទៅសេរីភាពបញ្ចេញមតិ?**

ការបញ្ចេញមតិអាចធ្វើឡើងតាមរយៈ÷

- កិច្ចប្រជុំ ឬពិធីផ្សេងៗ
- ទីសាធារណៈ
- លិខិតស្នាម សារ សំបុត្រ
- សារព័ត៌មាន
- បណ្តាញព័ត៌មានសង្គម
- រូបគំនូរ

**ឆ. មនោគមវិជ្ជា និងការឃោសនា**

## III- មធ្យោបាយនានាប្រើប្រាស់ជាឧបករណ៍ក្នុងការងារព័ត៌មាននិងសាធារណមតិ

**ការយល់ដឹងពីប្រព័ន្ធផ្សព្វផ្សាយប្រពៃណី បណ្តាញសង្គម និងឥទ្ធិពលរបស់វា**

**១. បច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយផ្លូវការនៅកម្ពុជា**






## ២. ប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គមនៅកម្ពុជា

| | | |
|---|---|---|
| • ទូរស័ព្ទដៃ | ២២លានគ្រឿង | ប្រមាណ ២-៣លានគ្រឿងភ្ជាប់ 2G |
| • Facebook | ១៣លានគណនី | ប្រមាណ៥លាននាក់ |
| • Telegram | ១០លានគណនី | ប្រមាណ៧លាននាក់ |
| • TikTok | ៧,៦លានគណនី | ប្រមាណ៩,៧លាននាក់ |
| • Instagram | ១,៨លានគណនី | |
| • X (Twitter) | ៤សែនគណនី | |
| • YouTube | | ប្រមាណ៧,៩លាននាក់ |

## ៣. សមាមាត្រានៃអ្នកប្រើប្រាស់បណ្តាញព័ត៌មានគ្រប់ទម្រង់

| | |
|---|---|
| • ៨០% | ប្រើប្រាស់ឧបករណ៍ឆ្លាតវៃភ្ជាប់ internet |
| • ៣៥% | ទស្សនា TV |
| • ១៥% | ស្តាប់វិទ្យុ |
| • ១១% | អានកាសែត និងទស្សនាវដ្តី |

## ៤. ប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គមនៅសកលលោក







## ៥. ការវាយតម្លៃប្រសិទ្ធភាពនិងឥទ្ធិពលបណ្តាញព័ត៌មានសង្គម

សារព័ត៌មានប្រពៃណីដែលរួមមានទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្តី គឺជាមធ្យោបាយបញ្ជូនសារមួយផ្លូវ (one-way communications) ត្រង់ឆ្ពោះទៅកាន់អ្នកទទួល។ ប៉ុន្តែ ប្រព័ន្ធបណ្តាញសង្គម គឺជាមធ្យោបាយទំនាក់ទំនង២ផ្លូវ (two-way communications) រីករាលដាលលឿន ពហុមុខ និងជាមធ្យោបាយដែលបង្កលទ្ធភាពឱ្យមានការ (engagement) ពង្រីកសមាជិកបន្ថែមទៀតពីភាគីផ្សេងៗ លើការផ្លាស់ប្តូរព័ត៌មាន និងការទំនាក់ទំនង៖

- បណ្តាញសង្គម មានឥទ្ធិពលខ្លាំងលើឥរិយាបថសង្គម ជាពិសេសរបស់យុវវ័យ
- ងាយប្រើប្រាស់សម្រាប់ការកៀរគរឱ្យចូលរួមក្នុងសកម្មភាពសង្គម សេដ្ឋកិច្ច នយោបាយ

- បង្កើតវេទិកាពិភាក្សាគ្រប់ទិដ្ឋភាព សង្គម សិល្បៈ វប្បធម៌ កីឡា នយោបាយ
- រំលេចប្រធានបទ និងរំលេចតួអង្គបានលឿន
- ប្រសិទ្ធភាព វិសាលភាព ការផ្ញើសារ និងការទំនាក់ទំនង ទូលំទូលាយពាសពេញពិភពលោក

ឯកសារមួយបានសរសេរថា ក្នុងកាលវេលាដ៏ខ្មៅងងឹតនៃសង្គ្រាមលោកលើកទី២ នាយករដ្ឋមន្ត្រីចក្រភពអង់គ្លេស លោក Winston Churchil បានផ្ញើសារចេញពីកន្លែងលាក់ខ្លួននៅកណ្តាលទីក្រុងឡុងដ៍ទៅកាន់ប្រជាជនរបស់ខ្លួន និងទៅពិភពលោកដើម្បីការតស៊ូក្នុងនយោបាយ និងសង្គ្រាម។

៨ ទសវត្សរ៍ក្រោយមក លោក Zelensky ប្រធានាធិបតីអ៊ុយក្រែន បានធ្វើដូចគ្នា ប៉ុន្តែតាមរយៈបណ្តាញសង្គម ដើម្បីពង្រឹងកម្លាំងចិត្តប្រជាជនអ៊ុយក្រែងនិងកងទ័ព ព្រមទាំងដើម្បីអំពាវនាវនិងទាក់ទាញ ការគាំទ្រពីអន្តរជាតិ ខណៈ លោក ពូទីន ប្រើប្រាស់ទូរទស្សន៍ជាតិរុស្ស៊ី។ តាមរយៈបណ្តាញសង្គមនេះដែរ សម្លេងប្រជាជនអ៊ុយក្រែន និងស្នូរគ្រាប់កាំភ្លើងនៃសង្គ្រាម រុស្ស៊ី-អ៊ុយក្រែនឮក្នុងទូរស័ព្ទដៃយើងគ្រប់ៗគ្នា។

ស្រដៀងគ្នា សាច់រឿងរបស់កុមារីឈ្មោះ Anne Frank ជាជនជាតិជ្វីប ដែលរងគ្រោះដោយរបបណាស៊ីនៅអាឡឺម៉ង់ ដែលកត់ត្រា សាច់រឿងក្នុងសៀវភៅកំណត់ហេតុ ស្ត្រីមានកូនខ្ចីម្នាក់ដែលបដិសេធមិនចាកចេញពីអ៊ុយក្រែន បានសរសេរសាច់រឿងប្រចាំថ្ងៃរបស់គាត់តាមប្លុកឈ្មោះថា Mum News Network។ ដូច្នេះ បណ្តាញសង្គម មិនត្រឹមជាមធ្យោបាយប្រមូលព័ត៌មានមកវិញ ប៉ុន្តែក៏ជាមធ្យោបាយបង្វែរការគិត និងការសម្រេចចិត្តរបស់ប្រជាជនក្នុងកិច្ចការសង្គម និងនយោបាយផងដែរ។

## IV- ការកំណត់វាយតម្លៃប្រធានបទសំខាន់ៗ ក្នុងការងារព័ត៌មាន និងសាធារណមតិ

**"ប្រធានបទនិងសារនយោបាយ"** ដែលក្រុមប្រឆាំងចាប់យកមកសម្រាប់ប្រើប្រាស់ សម្រាប់ចិញ្ចឹមចលនាប្រឆាំង និងពង្រីកឱ្យមានឥទ្ធិពលជាសមរភូមិសាធារណមតិ មានការប្រែប្រួល ទៅតាមសភាពការណ៍ការវិវត្តន៍កើតមាននៅក្នុង ប្រទេស តំបន់ និងសកលលោក។ ជាមួយនឹងការក្តាប់ជាប់ប្រធានបទដែលក្រុមប្រឆាំងលើកឡើង យើងក៏ត្រូវស្គាល់ឱ្យច្បាស់ពី **"មុខសញ្ញាប្រតិបត្តិករ"** របស់ក្រុមប្រឆាំង និងក្រុមមាននិន្នាការគាំទ្រក្រុមប្រឆាំងផងដែរ។ ខាងក្រោមនេះ គឺជាប្រធានបទនានា និង ប្រតិបត្តិករ របស់ក្រុមប្រឆាំង ក្នុងការងារព័ត៌មាន និងសាធារណមតិ÷

| ១. ប្រធានបទស្តីពីសន្តិសុខនយោបាយលើវិស័យដែនដី | ប្រតិបត្តិករ |
|---|---|
| **• ការរៀបចំតំបន់អង្គរ រុនតាឯក និងពាក់ស្នែង** | **(អង្គការអន្តរជាតិ)** |

ពួកប្រឆាំងបានលើកឡើងនូវបញ្ហារួមមាន÷

- ការជម្លៀសប្រជាជនចេញពីតំបន់អង្គរ
- ពលរដ្ឋមួយចំនួនត្អូញត្អែរពីការលំបាករស់នៅក្នុងតំបន់
- រុនតាឯក ក្រោយពីផ្លាស់ទីពីតំបន់អង្គរ
- ការសាងសង់ព្រលានយន្តហោះខេត្តសៀមរាបដោយលើពីតម្លៃចំណេតក្នុងព្រលាន

- បញ្ហាឧស្សាហកម្មអចលនទ្រព្យ និងការធ្វើវិជ្ជិតកម្មសេដ្ឋកិច្ច **(អង្គការអន្តរជាតិ)**
- បញ្ហាការទិញលក់ផ្ទះរបស់ បុរីអភិវឌ្ឍន៍លំនៅឋាន
- សំណង់មិនរៀបរយចំនួន១៩១ទីតាំងក្នុងរាជធានីភ្នំពេញ
- ការលុបបឹងនៅក្នុងរាជធានី
- បញ្ហាស្តុរអំពៅនៅខេត្តកំពង់ស្ពឺ កោះកុង និងព្រះវិហារ

**២. សន្តិសុខនយោបាយផ្ទៃនៅ** **(សារព័ត៌មានអន្តរជាតិអង្គការអន្តរជាតិ និងសកម្មជន)**

- បញ្ហាដែលបានលើកឡើងរួមមាន÷
  - សិទ្ធិសេរីភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ
  - ការរំលាយគណបក្សនយោបាយ
  - ការចាប់ខ្លួនសកម្មជននយោបាយ និងអ្នកការពារបរិស្ថាន
  - បញ្ហាអយុត្តិធម៌សង្គម
  - បញ្ហាកំណែទម្រង់រដ្ឋបាលសាធារណៈ
  - ភូមិសាស្ត្រនយោបាយ
    - ការកសាងកំពង់ផែរាម
    - ការកសាងព្រលានយន្តហោះនៅស្រុកបុទុមសាគរ ខេត្តកោះកុង
    - គម្រោងសង់ព្រែកជីកហ្វូណនតេជោ

**៣. សន្តិសុខសេដ្ឋកិច្ច** **(សារព័ត៌មានប្រឆាំង និងសកម្មជននយោបាយ)**

- បញ្ហាដែលបានលើកឡើង រួមមាន÷
  - បញ្ហាជីវភាពរស់នៅរបស់ប្រជាជន
  - បញ្ហាធនាគារ និងមីក្រូហិរញ្ញវត្ថុ
  - បញ្ហាប្រាក់ឈ្នួលកម្មករ
  - ការធ្វើបាតុកម្មទាមទារតម្លើងប្រាក់ខែ និងទំនាស់ការងារ
  - បញ្ហាគ្រូបង្រៀន
  - បញ្ហាសេដ្ឋកិច្ចក្រៅប្រព័ន្ធ
  - ការសម្អាតប្រាក់

**៤. សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** **(មន្ត្រីទូត សារព័ត៌មានបរទេស និងសកម្មជននយោបាយ)**

- បញ្ហាដែលបានលើកឡើង រួមមាន÷
  - ការជួញដូរមនុស្ស

- បទល្មើស Online និងបច្ចេកវិទ្យា
- បញ្ហាព្រំដែន និងជនអន្តោប្រវេសន៍
- ការធ្វើបាតុកម្មតាមទីសាធារណៈ

**៥. សន្តិសុខស្បៀង** **(សារព័ត៌មានប្រឆាំង និងសកម្មជន)**

- បញ្ហាដែលបានលើកឡើង រួមមាន៖
  - បញ្ហាបរិស្ថាន និងធនធានធម្មជាតិ
  - ការរុករករ៉ែនៅខេត្តត្បូងឃ្មុំនិងខេត្តមណ្ឌលគិរី
  - បញ្ហាខ្វះទឹក

**៦. សន្តិសុខថាមពល** **(សារព័ត៌មានប្រឆាំង និងសកម្មជន)**

- បញ្ហាដែលបានលើកឡើង រួមមាន៖
  - ការសាងសង់ទំនប់វ៉ារីអគ្គិសនី
  - ការប្រើប្រាស់ថាមពលស្អាតនៅតាមរោងចក្រ

**៧. សន្តិសុខព័ត៌មាន**

ស្ថាប័ននិងអង្គភាពសារព័ត៌មាន ដែលផ្សព្វផ្សាយដោយមានចរិតញុះញង់ក្នុងសាធារណមតិ រួមមាន RFA, The Cambodia Daily, Camboja, CCIM, VOA,VOD, The Diplomat, East Asia Forum, និង Politicoffee។ ជាមួយគ្នា ប្រធានបទដែលមានចរិតបំផុសនយោបាយ ក៏ត្រូវបានលើកឡើងដោយអង្គការ និងសមាគមដែលទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុនិងថវិកាពីបរទេសមានដូចជាពី USAID, Action Aid, Sida, Oxfam, Soros Fund, Asia-Forum ជាដើម។

**៨. បញ្ហាផ្សេងៗ**

បញ្ហានៅបឹងទន្លេសាប ទាំងការចាប់ទន្ទ្រានយកដី និងការធ្វើនេសាទ ហើយប្រធានបទដែលកើតមានជាបន្តបន្ទាប់គឺទាក់ទងវិស័យកសិកម្ម នៅពេលប្រមូលផល បញ្ហាតម្លៃលក់ចេញ និងបញ្ហាកង្វះទឹកធ្វើកសិកម្ម។ បច្ចុប្បន្ននេះ ពួកប្រឆាំងកំពុងរៀបចំ រចនាសម្ព័ន្ធអង្គការចាត់តាំង សម្រាប់ការតស៊ូទៅមុខទៀតក្នុងនោះបង្កើតឱ្យមាន «ចលនាយុវជន សកល» និង «ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ» ដឹកនាំដោយលោកស្រី មួរ សុខហួ។ ពួកប្រឆាំងនៅបន្តខិតខំបង្កើត និងចិញ្ចឹមចលនាដទៃទៀត ឱ្យធ្វើសកម្មភាពដែលមានភាពប្រទាក់ក្រឡាគ្នា។ ក្រុមប្រឆាំង ក៏នៅតែបន្តធ្វើសកម្មភាពបង្ខូចកិត្តិនាមប្រទេសកម្ពុជា និងប៉ុនប៉ងធ្វើឱ្យ កម្ពុជា មានទំនាស់ជាមួយបណ្ដាប្រទេសជិតខាងផងដែរ។

## V- សាធារណមតិ និង សតិអារម្មណ៍មហាជន

### ១. ចិត្តសាស្ត្របុគ្គល - ចិត្តសាស្ត្រហ្វូងមនុស្ស




“ហ្វូងមនុស្សមានចិត្តសាស្ត្រ មិនដូចមនុស្សម្នាក់ៗទេ។ នៅពេល មនុស្សជួបជុំគ្នា វាបង្កើតបានទឹកចិត្តមួយផ្សេង។ ការដឹកនាំប្រទេស គឺការដឹកនាំហ្វូងមនុស្ស”។

*ដកស្រង់ពីសៀវភៅ “ក្តីសង្ឃឹម ហ៊ុន ម៉ានី” ទំព័រ២២២*

**សាធារណមតិ** មានពកម្រិតគឺ÷ ពណ៌ស ពណ៌ប្រផេះ និងពណ៌ខ្មៅ ដែលមានន័យថា និន្នាការគាំទ្រ និន្នាការកណ្តាល និងនិន្នាការប្រឆាំង។

**សតិអារម្មណ៍មហាជន** មិនដូចគ្នាទេ វាអាស្រ័យទៅតាមស្ថានភាព ភូមិសាស្ត្រ ជីវភាព វ័យ និង ភេទ ហើយតែងតែមានលក្ខណៈផ្សារភ្ជាប់ជាមួយផលប្រយោជន៍ “ក្រពះ បេះដូង និងខួរក្បាល”។ ដូច្នេះ បញ្ហាសតិអារម្មណ៍ មិនចំណុះតែលើព័ត៌មាន និងសាធារណមតិ នោះទេ វាក៏មានប្រភពចេញមកពីបញ្ហា ក្រពះ បេះដូង និងខួរក្បាលដែលមានជាយូរមកហើយ ឬថ្មីៗ ហើយក្នុងនោះរួមទាំង ការជះឥទ្ធិពលនៃបញ្ហាយុត្តិធម៌សង្គមផងដែរ។

**“នៅលើសមរភូមិសាធារណមតិ**
**គ្មានទេពាក្យថា ឯករាជ្យ ឬអព្យាក្រឹត្យ**
**គឺមានតែមិត្ត និងសត្រូវ”ៗ**

### ២.ការប្រឈម និងការខិតខំដណ្តើមយកប្រៀបឈ្នះលើសាធារណមតិ និងសមរភូមិសតិអារម្មណ៍មហាជន គឺដើម្បី÷

- ពង្រឹងជំនឿចិត្ត ពង្រឹងការសាមគ្គីឯកភាពផ្ទៃក្នុង និងធ្វើស្មោះកម្មផ្ទៃក្នុង
- គ្រប់គ្រងទស្សនៈ សតិអារម្មណ៍ និងសាធារណមតិ
- ត្រួតត្រាសភាពការណ៍ បន្តរក្សាប្រក្រតីភាពសង្គម និងធានាម្ចាស់ការលើការដឹកនាំ

### ៣. យន្តការនានាពាក់ព័ន្ធការងារព័ត៌មាន និងការគ្រប់គ្រងសាធារណមតិ

ការរៀបចំយន្តការនានាខាងក្រោមនេះ ដើម្បីមានលទ្ធភាពគ្រប់គ្រង បំភ្លឺ បកស្រាយ ឆ្លើយតប និងវាយបកលើការងារព័ត៌មាន សាធារណមតិ និងសតិអារម្មណ៍មហាជន ÷

- **យន្តការគណបក្ស**
  - ក្រុមអ្នកនាំពាក្យរបស់គណបក្ស
  - ក្រុមព័ត៌មានតាមបណ្តាគណៈចលនានីមួយៗរបស់គណបក្ស
  - ក្រុមព័ត៌មានយុវជនថ្នាក់កណ្តាល
- **យន្តការថ្នាក់ជាតិ÷** រាជរដ្ឋាភិបាល នីតិកាលទី៧ បានរៀបចំឱ្យមានយន្តការគ្រប់គ្រងសាធារណមតិទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ÷
  - អ្នកនាំពាក្យរាជរដ្ឋាភិបាល
  - អ្នកនាំពាក្យតាមបណ្តាក្រសួងស្ថាប័ន
  - គណៈកម្មាធិការជាតិសម្របសម្រួលព័ត៌មាននិងសាធារណមតិ (ជាបណ្តុំសមាសភាព ក្រសួងព័ត៌មាន អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល និងអង្គភាពប្រតិកម្មរហ័ស)។
- **យន្តការថ្នាក់ក្រោមជាតិ÷** មន្ទីរព័ត៌មានរាជធានី-ខេត្ត បានរៀបចំមន្ត្រីចំនួន៥នាក់ ដើម្បីធ្វើកិច្ចការប្រមូលព័ត៌មាននិងគ្រប់គ្រងសាធារណមតិ។
- **យន្តការផ្សេងៗ រួមមាន÷**
  - អង្គភាពសារព័ត៌មាន
  - អង្គការមហាជន
  - សកម្មជន

**៤. សន្និដ្ឋាន÷ ត្រូវស្គាល់៥យ៉ាង ដើម្បីជាមូលដ្ឋានចូលក្នុងសមរភូមិសាធារណមតិ**

១- ស្គាល់តួនាទីភារកិច្ច

២- ស្គាល់រចនាសម្ព័ន្ធពាក់ព័ន្ធ

៣- ស្គាល់ខ្មាំង ស្គាល់មុខសញ្ញានៃសម្ព័ន្ធភាពខ្មាំង យល់ដឹងពីឧបាយកលខ្មាំង និងគោលបំណងរបស់ខ្មាំង

៤- ក្តាប់ឱ្យជុំប្រធានបទ និងវាយតម្លៃឱ្យច្បាស់ពីវិធីសាស្ត្រត្រូវចូលប្រយុទ្ធ

៥- ស្គាល់សមរភូមិដែលត្រូវចូលប្រយុទ្ធ និងមធ្យោបាយសម្រាប់ការប្រយុទ្ធ

## VI- វិធីសាស្ត្រគោលក្នុងការប្រឈមនិងការគ្រប់គ្រងសមរភូមិសតិអារម្មណ៍

ក្នុងប្រវត្តិសាស្ត្រនៃដំណើរនយោបាយកម្ពុជាជាបន្តបន្ទាប់ ជាការកត់សំគាល់អំពីការប្រែប្រួលនៃដំណើរនយោបាយ គឺមានពាចំណុច÷ **ឈ្នាន់នយោបាយ, កំស្ទួលនយោបាយ,** និង **របត់នយោបាយ** ឬហៅថា **ចំណុចផ្លូវបត់**។ ការក្តាប់ជាប់នូវហេតុការណ៍ សភាពការណ៍ និងដំណើរប្រែប្រួលក្នុងពាទម្រង់ខាងលើគឺជួយឱ្យគណបក្សមានការត្រៀមខ្លួន មានវិធានការទាន់ពេលវេលា ដើម្បីដោះស្រាយ ព្រមទាំងអាចការពារបាននូវប្រៀបឈ្នះ និងធានាការ

ដឹកនាំយូរអង្វែងរបស់គណបក្ស។ **សម្ដេចតេជោ ហ៊ុន សែន** ប្រធានគណបក្ស បានវាយតម្លៃថា ក្នុងរយៈពេល ២០ឆ្នាំទៅមុខ កម្ពុជា នៅមិនទាន់អាចមាន "**កំសួលនយោបាយ**" នៅឡើយទេ។ ទោះបីជាយ៉ាងណាវិធានការមុតស្រួចរបស់ **សម្ដេចតេជោ ហ៊ុន សែន** ប្រធានគណបក្ស ក្នុងការអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ចំពោះជនដែលប្រមាថបង្ខូចគណបក្ស និងករណីមានការញុះញង់ ក្នុងបទល្មើសជាក់ស្ដែងដែលបង្កចលាចលក្នុងសង្គម ជាវិធានការដ៏មានប្រសិទ្ធភាព។ ជាមួយគ្នា "**វិធានការជើបមួយ រៃមួយ**" ដោយមិនទុកឱ្យរីករាលដាល នៅតែជាវិធានការត្រូវបន្តប្រកាន់យក និងអនុវត្តឱ្យមានប្រសិទ្ធភាព។

## វិធានការឆ្លើយតបជាយុទ្ធសាស្ត្រចំពោះខ្សែបាយកលរបស់ក្រុមប្រឆាំង (យន្តការ២ និងវិធានការ២)

### ១. យន្តការធនធានមនុស្ស ÷ កសាងយន្តការប្រទាក់ក្រឡា (Cyber Troopers)

- ក្រុមព័ត៌មានផ្លូវការរបស់បក្សនិងរដ្ឋ
- ក្រុមបណ្ដាញសារព័ត៌មាន
- ក្រុមអ្នកប្រើប្រាស់បណ្ដាញសង្គម
- ក្រុមវាគ្មិន Talk-show
- ក្រុមតារា សិល្បករ និង Influencers
- ក្រុមអ្នកវិភាគឯករាជ្យ (តែបេះដូងគណបក្ស)
- ក្រុមអង្គការសង្គមស៊ីវិល
- បណ្ដាញផ្សេងៗដែលមាននិន្នាការគាំទ្រគណបក្ស

### ២. វិធីសាស្ត្របែបជឿនលឿន

#### ឥទ្ធិពលនៃការធ្វើស្ទង់មតិ

ការស្ទង់មតិ ជាវិធីសាស្ត្រមានសារៈសំខាន់សម្រាប់គាំទ្រដល់គោលបំណងនិងយុទ្ធនាការដែលចង់បាន។ ការស្ទង់មតិអាចធ្វើឡើងតាមច្រើនវិធីសាស្ត្រ ហើយលទ្ធផលការស្ទង់មតិជាទិន្នន័យវិទ្យាសាស្ត្រ ជួយដល់ការវិភាគវាយតម្លៃ គាំទ្រដល់យុទ្ធសាស្ត្ររបស់បេក្ខជន ឬគណបក្ស និងប្រើប្រាស់សម្រាប់ពង្រីកឥទ្ធិពលលើសាធារណមតិ ការសម្រេចចិត្ត និងការបោះឆ្នោតផងដែរ។ គេក៏អាច បញ្ចេញទិន្នន័យស្ទង់មតិដែលមានខ្លឹមសារទាក់ទាញ ឬជាទិន្នន័យបំភ័យអ្នកបោះឆ្នោត ផងដែរ។ នៅពេលដែល ការបោះឆ្នោតបែបគុណភាព ឬនៅពេលដែលការសម្រេចចិត្តរបស់ប្រជាជនមានកម្រិតខ្ពស់ ប្រកបដោយ « ហេតុនិងផល» នោះការធ្វើស្ទង់មតិកាន់តែដើរតួនាទីសំខាន់។

**៣. វិធីសាស្ត្រតាមរយៈបច្ចេកវិទ្យា**

**បច្ចេកវិទ្យា មានសារៈសំខាន់សម្រាប់ការគ្រប់គ្រងសាធារណមតិ និងសន្តិសុខនយោបាយ**

ការតស៊ូមតិ ប្រើរយៈពេលយូរឬឆាប់ អាស្រ័យកត្តាជាច្រើនជុំវិញហេតុការណ៍នីមួយៗ។ ដូច្នេះ ការចាប់យកការគ្រប់គ្រងផ្នែកបច្ចេកវិទ្យា រួមទាំងការគ្រប់គ្រងច្រកអ៊ីនធឺណិត និង ISP គឺជាវិធីវ៉ៃឆ្លាត និងមានប្រសិទ្ធភាពលើសមរភូមិសាធារណមតិ។ បច្ចេកវិទ្យា អាចជួយដកចេញនូវទិន្នន័យ និងអាចបង្រួមលទ្ធភាពនៃការរីកសាយភាពព័ត៌មានគ្រប់ទម្រង់នៅលើបណ្តាញសង្គម ហើយក៏ជាវិធីមានប្រសិទ្ធភាពក្នុងការពង្រីក និងដណ្តើមយកប្រៀបលើការគាំទ្រ និងប្រជាប្រិយភាពរបស់បុគ្គល បេក្ខជន និងគណបក្សផងដែរ។ ករណីនៅ សហរដ្ឋអាមេរិក ដើម្បីបន្ថយនិងទប់ស្កាត់ហឹង្សានយោបាយ លោក ដូណាល់ ត្រាំ ត្រូវបានគេបិទមិនឱ្យប្រើបណ្តាញសង្គម Twitter និង Facebook។

**៤- យន្តការច្បាប់÷** ការហៅពួកជ្រុលនិយម មកអប់រំណែនាំ ឬឈានទៅមានវិធានការច្បាប់ ក៏ជាវិធីសាស្ត្រដែលមិនអាចមើលរំលងបានទេ។ ប៉ុន្តែ គប្បីធ្វើឱ្យស្របតាមការយល់ឃើញនិងការគាំទ្រពី សាធារណមតិ។

## VII- **ឥទ្ធិពលបណ្តាញព័ត៌មានសង្គមលើការបោះឆ្នោត**

ប្រយោគថ្មី១ឃ្លា គេនិយាយថា "អ្នកនយោបាយ ត្រូវតែរៀបការជាមួយ បណ្តាញសង្គម (Social Media) ហើយការឃោសនាបោះឆ្នោតដែលមានប្រសិទ្ធភាព គឺត្រូវតែផ្សាភ្ជាប់ជាមួយបណ្តាញសង្គម"។ នៅប្រទេសកម្ពុជា ច្បាប់បោះឆ្នោតរបស់យើង មានលក្ខណៈអំណោយផល ដោយសារយើងជ្រើសយកការបោះឆ្នោតតាមប្រព័ន្ធសមាមាត្រ។ ប្រសិនបើការបោះឆ្នោតជាឯកតត្តនាម ហើយក្នុងដំណាក់កាលនៃព័ត៌មានវិទ្យាព័ត៌មានឌីជីថលជឿនលឿននេះ មធ្យោបាយរបស់បេក្ខជនឈរឈ្មោះ មានភាពងាយស្រួល។ ដូច្នេះ លទ្ធផលនៃការទទួលបានសំឡេងឆ្នោតនឹងងាយមានការប្រែប្រួល លឿនខ្លាំង ហើយចំណុចខ្លះអាចនាំដល់ការប៉ះទង្គិច។

បច្ចេកវិទ្យានិងបណ្តាញព័ត៌មានសង្គម បានផ្តល់មធ្យោបាយសម្រាប់ទាក់ទងផ្ទាល់ជាមួយបេក្ខជន ឬអ្នកនយោបាយ។ បណ្តាញសង្គមក៏ជាមធ្យោបាយ បង្កើតពាក្យចចាមអារ៉ាម ព័ត៌មានក្លែងក្លាយ ព័ត៌មានលម្អៀង ឬបង្កើតការសង្ស័យ ដើម្បីបំភ័ន្តអ្នកបោះឆ្នោត ហើយវាក៏ជាមធ្យោបាយសម្រាប់ការបំភ្លឺការពិតបានលឿនផងដែរ។ បណ្តាញសង្គមមានឥទ្ធិពលអាចប្រែក្លាយ Followers into voters and mobilize voter turnout ÷

- បញ្ចុះបញ្ចូលប្រជាជនឱ្យទៅបោះឆ្នោត
- ជះឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកបោះឆ្នោត
- អំពាវនាវប្រជាជនឱ្យពហិការមិនទៅបោះឆ្នោត ឬជំទាស់លទ្ធផលការបោះឆ្នោត
- និន្នាការចុះឈ្មោះបោះឆ្នោតតាម Online

**១. បទពិសោធន៍ពីអ្នកនយោបាយនៅក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសខ្លះ**

នៅប្រទេសកម្ពុជា ក្រុមប្រឆាំងធ្លាប់ធ្វើយុទ្ធនាការដោយអំពាវនាវប្រជាជន ឱ្យធ្វើពហិការមិនទៅបោះឆ្នោត ឬជំទាស់លទ្ធផលការបោះឆ្នោត តាមរយៈ យុទ្ធនាការម្រាមដៃស្អាត ឬដេកផ្ទះឈ្នះឯង។

ស្តាប់តាមយោបល់របស់កូនប្រុស លោក ដូណាល់ ត្រាំ បានធ្វើ Show ជាមួយ Bloggers តាមបណ្តាញសង្គម ដើម្បីទាក់ទាញការគាំទ្រពីអ្នកបោះឆ្នោតវ័យក្មេងនៅសហរដ្ឋអាមេរិក។ លោក ដូណាល់ ត្រាំ ធ្លាប់បាននិយាយថា គេបានចំណាយលុយរង្វង់៧០០លាន ដើម្បីធ្វើការផ្ទែកសាធារណមតិនៅក្នុងសង្គមអាមេរិក ដើម្បីធ្វើឱ្យមានការប្រែប្រួលលើការបោះឆ្នោត ពោលគឺសំដៅទៅក្រុមដែលមានចំណេះដឹងទាប និង Swing Voters ដើម្បីទម្លាក់លោកក្នុងការបោះឆ្នោតអាណត្តិទី២របស់លោក។

បទពិសោធន៍ការបោះឆ្នោតនៅអាមេរិក ក្នុងការប្រែក្លាយ Followers ឱ្យទៅជា Voters បេក្ខជនប្រធានាធិបតីបានជ្រើសរើសវិធីសាស្ត្រប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមផ្សេងៗគ្នា ដើម្បីភ្ជាប់ជាមួយម្ចាស់ឆ្នោតរបស់ខ្លួន។ ពួកគេ បានចំណាយលុយជាច្រើនសម្រាប់ការផលិតខ្លឹមសារ សម្រាប់ផ្សព្វផ្សាយនៅលើបណ្តាញសង្គម ដើម្បីជាមធ្យោបាយជះឥទ្ធិពលលើឥរិយាបទ និងការសម្រេចចិត្តរបស់អ្នកបោះឆ្នោត។ គេត្រូវទទួលស្គាល់ថា យុវជនខ្លះមិន share ព័ត៌មាននយោបាយ និងការបោះឆ្នោតទេ ប៉ុន្តែ ពួកគេជាអ្នកបោះឆ្នោត ដ៏មានសក្តានុពល ជាក្រុមកណ្តាលដែលមានសំឡេងសង្កត់ ហើយអាចធ្វើឱ្យសម្លេងឆ្នោតគណបក្សប្រែប្រួលឬកើនសំឡេង។

- លោក Ted Cruz ប្រើប្រាស់ Twitters
- លោកស្រី Hillary Clinton ប្រើប្រាស់ Email
- លោក Donal Trump ប្រើប្រាស់ Twitters
- លោក Ben Carson ប្រើប្រាស់ Facebook
- លោក John F. Kenndy ប្រើប្រាស់ ទូរទស្សន៍
- លោក បារ៉ាក់ អូបាម៉ា ជាបេក្ខជនដំបូងគេដែលធ្វើយុទ្ធនាការតាម Facebook និង YouTube ដើម្បីឈ្នះឆ្នោត។ លោក អូបាម៉ា ចំណាយលុយច្រើនសម្រាប់ការឃោសនាលើបណ្តាញសង្គម ដែលគេប៉ាន់ស្មានថា ពេលនោះ មនុស្សនៅអាមេរិក ៧៤% នៃអ្នកប្រើប្រាស់ Internet បានតាមដានការបោះឆ្នោតតាមនេះ ក្នុងនោះ៥៥% ជាយុវជន។ ចាប់តាំងពីពេលនោះ បណ្តាញសង្គមដើរតួនាទីកាន់តែសកម្មឡើងក្នុងការបោះឆ្នោត សូម្បីតែការបោះឆ្នោតថ្នាក់មូលដ្ឋាននៅសហរដ្ឋអាមេរិក។
- នៅឆ្នាំ២០១៦ គណៈកម្មាធិការបោះឆ្នោតអាមេរិក វាយតម្លៃថា Facebook បំផ្លាញដ៏ធ្ងន់ធ្ងរចំពោះដំណើរការប្រជាធិបតេយ្យជាប្រពៃណី។ ជាមួយគ្នា ក៏មានទស្សនៈលើកឡើងថា បណ្តាញសង្គមលម្អៀង និងប្រឆាំងទស្សនៈអភិរក្សនិយម បង្កើតឱ្យក្រុមឆ្វេងនិយម ប្រឆាំងក្រុមស្តាំនិយម។ លើសពីនេះ បណ្តាញ សង្គមបំភ័ន្តឱ្យមនុស្សពិបាកយល់អ្វីជាពិតឬក្លែងក្លាយ។

## VIII- **សេចក្តីសន្និដ្ឋាន ៖ ការត្រិះរិះពិចារណា តើអ្វីជាមធ្យោបាយអំណាច?**

យើងត្រូវចងចាំថា ពិភពលោកមានប៉ូល៣ជាប្រចាំគឺ "ប៉ូលឆ្វេង ប៉ូលស្តាំ និងប៉ូលកណ្តាលនិយម"។ ការដឹកនាំដែលមានការប្រែប្រួល ក៏អាស្រ័យលើកត្តាប្រែប្រួលនៃកម្លាំងអំណាច យ៉ាងហោច៤យ៉ាងគឺ ៖សេដ្ឋកិច្ច យោធា ប្រជាជន និងបច្ចេកវិទ្យា។ ពិភពលោកសព្វថ្ងៃ ក៏នៅតែប្រើយុទ្ធសាស្ត្រ DIFID ដើម្បីប្រជែងឥទ្ធិពលគ្នាលើការដឹកនាំ ដោយគេនៅតែប្រើយុទ្ធវិធី៖ "ឡោមព័ទ្ធ បំបែក ឯកោ បំផ្លាញ" បូករួមនឹងវិធីសាស្ត្រ "សហការផង តស៊ូផង"។

### ១. ការត្រិះរិះពិចារណាប្រកបដោយវិទ្យាសាស្ត្រ

តើយើងអាចយកមេរៀនស្តីពី "លទ្ធិសម្ភារនិយមវិចារវិទ្យា" មកពិចារណាសម្រាប់ជាមូលដ្ឋានក្នុងការប្រឈមនិងការគ្រប់គ្រងសមរភូមិសតិអារម្មណ៍តាមវិធីសាស្ត្រយ៉ាងដូចម្តេច?

អ្វីដែលបានកើតឡើងនិងត្រូវបានបង្កើតឡើង ហើយសូម្បីតែនៅក្នុងព័ត៌មាន គឺតែងតែមានហេតុ មានផល និងមានគោលបំណងទិសដៅរបស់វា។ ដូច្នេះ ក្នុងការត្រិះរិះពិចារណាអ្វីមួយក្នុងធម្មជាតិសង្គម និងមនសិការ ត្រូវតែប្រកាន់យកទស្សនៈសត្យានុម័ត(តថភាពសត្យានុម័ត ឬការពិតសត្យានុម័ត)។ ទស្សនៈសត្យានុម័ត ផ្ទុយពីទស្សនៈអត្តនោម័ត។ មនុស្សយើងគ្រប់រូបមិនត្រូវមានទស្សនៈអត្តនោម័តក្នុង ការត្រិះរិះពិចារណា និងធ្វើសេចក្តីសម្រេចចិត្តលើបញ្ហាអ្វីមួយ ដោយមិនបានស្វែងយល់ពីការពិតសត្យានុម័តរបស់វានោះទេ។ លទ្ធិសម្ភារនិយមវិចារវិទ្យា ផ្តល់ឱ្យយើងនូវទស្សនៈ៤យ៉ាងសម្រាប់ការត្រិះរិះពិចារណាដូចតទៅ÷

- ទស្សនៈសត្យានុម័ត (ក្រឹត្យក្រមឯកភាពនិងក្រឹត្យក្រមទំនាស់)
- ទស្សនៈប្រវត្តិសាស្ត្រជាក់ស្តែង (ទំនាក់ទំនងរវាងហេតុនិងផល)
- ទស្សនៈគ្រប់ជ្រុងជ្រោយ (ការពិចារណាផ្អែកលើភាពគ្រប់ជ្រុងជ្រោយជាសារវ័ន្ត)
- ទស្សនៈអភិវឌ្ឍន៍ (ការប្រែប្រួលផ្អែកបរិមាណនិងការផ្លាស់ប្តូរផ្អែកគុណភាព)

ក្នុងន័យនេះ លទ្ធិសម្ភារនិយមវិចារវិទ្យា ជួយយើងឱ្យអាចយល់ដឹងនូវហេតុការណ៍ដែលបានកើតឡើង ដំណើរវិវត្តន៍របស់វា ផលប៉ះពាល់របស់វាតាមរយៈប្រាជ្ញានិងមនសិការរបស់យើង បានយល់ច្បាស់ពីសារជាតិ និងការវិវត្តន៍ពីទាបទៅខ្ពស់ ពីសាមញ្ញទៅស្មុគស្មាញ ពីរាក់ទៅជ្រៅ ពីបាតុភូតទៅសារជាតិ និងត្រិះរិះរកវិធីសាស្ត្របានល្អប្រសើរ ក្នុងការប្រឈមដោះស្រាយ។ ដើម្បីឱ្យការប្រឈមដោះស្រាយលើ សមរភូមិសតិអារម្មណ៍មានប្រសិទ្ធភាព កិច្ចការដែលត្រូវធ្វើជាប្រចាំគឺ÷ ការងារសាធារណមតិ ការសម្របសម្រួលព័ត៌មាន និងប្រតិកម្មរហ័ស។ កិច្ចការទាំងនេះត្រូវធ្វើដោយមានយន្តការប្រទាក់ក្រឡា និងសហការពីគ្រប់ផ្នែកពាក់ព័ន្ធ ចាប់តាំងពីការដាក់ចេញខ្លឹមសារការងារបច្ចេកទេស និងសកម្មជន។ "ការជួយគ្នាទៅវិញទៅមក គឺជាក្រឹត្យក្រមនៃការរីកចម្រើនរបស់សម្ព័ហភាព"។

ក្នុងបរិបទនៃដំណើរប្រជាធិបតេយ្យសេរីពហុបក្ស មធ្យោបាយអំណាច គឺតាមរយៈការបោះឆ្នោត។ ប្រជាជន គឺជាកត្តាកំណត់ដ៏ធំមួយក្នុងចំណោមកត្តាដទៃផ្សេងទៀត។ គណបក្សបានកំណត់ថា **"ប្រជាជន នៅខាងណា ខាងនោះជាអ្នកឈ្នះ"**។ ដូច្នេះកត្តាដឹកនាំ និង **"អំពើល្អរបស់មន្ត្រីយើង"** ទាំងបក្សនិងរដ្ឋ មានសារៈសំខាន់ណាស់ក្នុងការដណ្តើម និងថែរក្សាប្រៀបឈ្នះលើការបោះឆ្នោត។

**តើការគ្រប់គ្រងបានលើសាធារណមតិ ជាការគ្រប់គ្រងជ័យជម្នះ និងធានាការកាន់អំណាចដឹកនាំ?**

បច្ចុប្បន្ននេះ ព័ត៌មានមហាជន សាធារណមតិ និងការងារសតិអារម្មណ៍មហាជន មានសារសំខាន់ណាស់ក្នុងកិច្ចការនយោបាយ ការដឹកនាំ និង ការបោះឆ្នោត។ នយោបាយ គឺជាសិល្បៈ ដើម្បីដណ្តើមយកអំណាចដឹកនាំរដ្ឋ។ ដូច្នេះ គ្រប់រចនាសម្ព័ន្ធ និងយន្តការការងារ ទាមទារនូវភាពប្រទាក់ក្រឡាគ្នា បំពេញឱ្យគ្នាក្នុងការធ្វើការងារ

ព័ត៌មាន និងសាធារណមតិ ឱ្យមានប្រសិទ្ធភាពដើម្បីអាចគ្រប់គ្រងបាននូវសតិអារម្មណ៍មហាជន។ ការបកស្រាយ បំភ្លឺ ឆ្លើយតប និងវាយបក ត្រូវតែឈរលើភាពបុរេសកម្ម និងលើមូលដ្ឋាននៃមធ្យោបាយសរុប និងកម្លាំងសរុប បម្រើ គាំទ្រ លើកតម្កើង ថែរក្សា ការពារ ការដឹកនាំរបស់បក្សនិងរដ្ឋយើង។ ក្នុងន័យនេះ ភារកិច្ចចម្បងៗដែលក្រុមការងារព័ត៌មាន និងមន្ត្រីបក្ស គប្បីបំពេញឱ្យបានល្អប្រសើរ មានដូចតទៅ÷

- ត្រូវប្រឹងប្រែងយ៉ាងណា រក្សាបមន្ត ដើម្បីបង្កើនភាពប្រទាក់ក្រឡាររវាងយន្តការបក្ស និងយន្តការរដ្ឋលើការងារ ព័ត៌មាន និងសាធារណមតិ។ នយោបាយ សតិអារម្មណ៍ និងការចាត់តាំង គឺត្រូវតែមានភាពប្រមូលផ្តុំ មានភាពប្រទាក់ក្រឡាគ្នាទាំងខ្លឹមសារ និងយន្តការអនុវត្ត ឱ្យបានទាន់ពេលវេលា មានលទ្ធផល និងប្រសិទ្ធភាព។
- បន្តតាមដាន ដកស្រង់ និងវាយតម្លៃជាប់ជាប្រចាំ អំពីសកម្មភាពរបស់ក្រុមប្រឆាំង។ ក្តាប់ឱ្យជាប់នូវប្រធានបទសំខាន់ៗ ដែលអាចកើតឡើង និងអាចរីករាលដាលលឿនក្នុងសាធារណមតិ។
- ត្រូវតាមដាន សិក្សា វិភាគ និងវាយតម្លៃ នូវចំណុចខ្លាំងនិងគុណតម្លៃនៃការដឹកនាំរបស់គណបក្សសម្រាប់ ជាមូលដ្ឋានយកមកពង្រីកការផ្សព្វផ្សាយ ដើម្បីរួមចំណែកដល់ការងារសាធារណមតិ ពង្រឹងស្មារតីកម្មាភិបាលបក្ស ចិញ្ចឹមជំនឿចិត្តមហាជន និងការគ្រប់គ្រងសតិអារម្មណ៍មហាជន។

**"លើសពីការសង្កេតនិងកត់សំគាល់ គឺត្រូវតែវាយតម្លៃជាប្រចាំ ដើម្បីចាប់យកវិធានការសមស្រប"។**

**"ទ្រឹស្តីមិនអាចកែប្រែថតភាពបានទេ គឺទាមទារសកម្មភាពអនុវត្តជាក់ស្តែង ទើបសម្រេចបានលទ្ធផល"។**

# មេរៀនទី៣
# ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និង វិធីសាស្ត្រផ្សព្វផ្សាយ

រៀបរៀងដោយ៖ **ឯកឧត្តម សោម រតនា**
**ឯកឧត្តម សុខន តារាពី**

# មេរៀនទី៣
# ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និងវិធីសាស្ត្រផ្សព្វផ្សាយ

## I. សេចក្តីផ្តើម

ការងារមហាជន ផ្នែកការបញ្ជ្រាបខ្លឹមសារទៅមហាជន ទាមទារឱ្យមានការយល់ដឹងស៊ីជម្រៅពីបរិការណ៍នៃការវិវឌ្ឍ នៃលំហូរព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដែលកំពុងតែរីកដុះដាលក្នុងសង្គមបច្ចុប្បន្នដែលទទួលឥទ្ធិពលពីការរីកចម្រើននៃវិស័យបច្ចេកវិទ្យាព័ត៌មាន។ ខណៈដែលលំហូរព័ត៌មានត្រូវការឱ្យមានការយល់ដឹងស៊ីជម្រៅពីចរិតអ្នកទទួលសារ ដូចជា ក្រុមយុវជនសម័យថ្មី ដែលជាមហាជនសក្តានុពល ហើយដែលជាស្នូលនៃការងារមហាជន ការយល់ដឹងស៊ីជម្រៅពីប្រព័ន្ធផ្សព្វផ្សាយសំដៅដល់ការយល់ដឹងការវិវឌ្ឍ នៃបច្ចេកវិទ្យាបញ្ជូនព័ត៌មាន។ ដោយឡែក បំណិនខាងលើនេះមិនកាត់ផ្តាច់ពីការយល់ជារួម អំពីការវិវឌ្ឍរបស់ប្រព័ន្ធផ្សព្វផ្សាយ ដែលកាលពីមុនស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័ន ឬអំណាចសារព័ត៌មានផ្តាច់មុខ។ តែអំណាចនោះ ក្នុងពេលបច្ចុប្បន្ន បានផ្លាស់ប្តូរទីតាំងមកស្ថិតក្នុងដៃអ្នកប្រើប្រាស់ ដោយសារកត្តាការអភិវឌ្ឍយ៉ាងលឿន និងភាពងាយស្រួលនៃបច្ចេកវិទ្យាឌីជីថល។ ជារួម ទាំងការយល់ដឹងអំពីលំហូរព័ត៌មាន ខ្លឹមសារ និងប្រព័ន្ធផ្សព្វផ្សាយគឺជាមូលដ្ឋានគ្រឹះសម្រាប់អ្នកអនុវត្តការងារមហាជន ដើម្បីគ្រប់គ្រងសមរភូមិសតិអារម្មណ៍ និងប្រើប្រាស់យន្តការនានាដើម្បីមានប្រៀបឈ្នះលើសមរភូមិដ៏ស្មុគស្មាញ និងងាយប្រែប្រួលមួយនេះ។

នៅក្នុងផ្នែកទី១ នៃមេរៀននេះ សិក្ខាកាមនឹងធ្វើការសិក្សាលើ (១) ការឈ្វេងយល់អំពីប្រព័ន្ធផ្សព្វផ្សាយដែលនឹងផ្តល់នូវទិដ្ឋភាពរួមនៃបណ្តាប្រព័ន្ធផ្សព្វផ្សាយដែលកំពុងតែមានអត្ថិភាពនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន (២) ការសិក្សាអំពីបច្ចេកវិទ្យាព័ត៌មាន និង (៣) បម្រើបម្រាស់បច្ចេកវិទ្យានោះ ដែលសិក្ខាកាមនឹងសិក្សាអំពីវិធីសាស្ត្រ និងគន្លឹះសំខាន់ៗសម្រាប់ជួយដល់ការងារបញ្ជ្រាបសារទៅកាន់មហាជន។ ដោយឡែក នៅផ្នែកទី២ មេរៀននឹងផ្តោតលើការរៀបចំខ្លឹមសារ ដែលគ្រប់ដណ្តប់លើការ (១) កំណត់ក្រុមគោលដៅ (២) ការបង្កើតសារ (៣) ការបញ្ជូនសារ (៤) ការវាយតម្លៃឥទ្ធិពលសារ និង (៥) ការវាយបក។

## II. ប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យាព័ត៌មាន

### ១. ជំពូកទី១÷ ឈ្វេងយល់ពីប្រព័ន្ធផ្សព្វផ្សាយ

ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីផ្តល់ ផ្សាយដំណឹង និងរាយការណ៍ពីព្រឹត្តិការណ៍នានាក្នុងសង្គម។ កាលណាដែលយើងនិយាយពី "សារព័ត៌មាន" វាតំណាងឱ្យអង្គវិជ្ជាជីវៈមួយ ដែលគ្រប់គ្រងដោយច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ។ ស្របតាមការវិវឌ្ឍនៃបច្ចេកវិទ្យា សារព័ត៌មានក៏បានវិវឌ្ឍខ្លួនដូចគ្នាដែរ។ ចាប់ផ្តើមពីកាសែត វិទ្យុ និងទូរទស្សន៍ (ប្រព័ន្ធ ផ្សព្វផ្សាយបែបប្រពៃណី) បច្ចុប្បន្ន សារព័ត៌មានក៏បានឈានចូលដល់យុគសម័យឌីជីថល ដែលរួមមាន÷ បណ្តាញសង្គម (ប្រព័ន្ធផ្សព្វផ្សាយសង្គម) សារព័ត៌មានអនឡាញ (បែបប្រពៃណី និងសង្គម)។

### ក. ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី

កាលណាគេនិយាយពីប្រព័ន្ធផ្សព្វផ្សាយប្រពៃណី នោះគេសំដៅដល់វិជ្ជាជីវៈសារព័ត៌មាន ដែលជាអង្គវិជ្ជាជីវៈ ដែលមានតួនាទីផ្តល់ ផ្សាយដំណឹង និងរាយការណ៍ពីព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងជីវភាពសាធារណៈរបស់សង្គម។ ក្នុងន័យនេះសារព័ត៌មានដើរតួនាទីដូចជាស្ពានដើម្បីនាំយកហេតុការណ៍ដែលបានកើតឡើង ទៅដល់អ្នកតាមដាន ឬសាធារណជន។ សារព័ត៌មានសម្រាប់មុខងារ នៃការងារផ្សព្វផ្សាយនេះ សំដៅដល់បណ្តុំនៃស្ថាប័នអង្គភាពសារព័ត៌មានវិជ្ជាជីវៈ ដែលមានវិសាលភាពផ្សព្វផ្សាយទូទៅទៅកាន់សាធារណជនក្នុងប្រទេស និងក្រៅស្រុក។

ប្រព័ន្ធផ្សព្វផ្សាយប្រពៃណីជាមធ្យោបាយ ដែលមានប្រភពចេញ ប៉ុន្តែមិនមានប្រព័ន្ធតប មិនតម្រូវឱ្យមាន បច្ចេកវិទ្យាទំនើបក្នុងការបញ្ជូនសារ។ ការបញ្ជូនសារ ធ្វើឡើងដោយប្រើប្រាស់ប្រព័ន្ធអង់តែន។ ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី រួមមានដូចជា÷ កាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍។ ក្រសួងព័ត៌មានជាអាជ្ញាធរសាធារណៈ ដែលមានអំណាចជាអាណាព្យាបាលលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីនេះ តាមរយៈការផ្តល់អាជ្ញាបណ្ណ។ សារព័ត៌មានប្រពៃណី ត្រូវស្ថិតក្រោមអំណាចក្រមសីលធម៌វិជ្ជាជីវៈនិងច្បាប់ពាក់ព័ន្ធ ដែលជាវិធានគ្រប់គ្រងការអនុវត្តការងាររបស់ខ្លួន។ សារព័ត៌មាន គឺជាស្ថាប័នឯករាជ្យ ដោយផ្អែកលើមូលដ្ឋានវិជ្ជាជីវៈ។ ក្នុងន័យនេះ សារព័ត៌មានត្រូវសរសេររាយការណ៍ ឬយកព័ត៌មានតែការពិត និងការពិតដែលទទួលបានដោយមធ្យោបាយសុចរិត។ ដើម្បីសរសេរព័ត៌មាន អ្នកសារព័ត៌មានត្រូវការទទួលដំណឹងបឋម និងត្រូវចុះទៅទីតាំងព្រឹត្តិការណ៍ ផ្តិតយករូបភាព ពិពណ៌នា ឬសម្ភាសអ្នកដែលបានឃើញហេតុការណ៍។

បច្ចុប្បន្ន គេសង្កេតឃើញមានការផុសចេញនូវសារព័ត៌មានអនឡាញ ដែលជាការច្របាច់បញ្ចូលគ្នានូវប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងសារព័ត៌មានសង្គម (បណ្តាញសង្គម)។ ខ្លឹមសារសរសេរសារព័ត៌មានអនឡាញតាមទម្រង់ប្រពៃណី ប៉ុន្តែប្រើប្រាស់បណ្តាញសង្គមជាមធ្យោបាយផ្សព្វផ្សាយ ជំនួសឱ្យការបោះពុម្ពផ្សាយ ឬការផ្សាយតាមរយៈអង់តែន ដោយប្រើប្រាស់ប្រពន្ធផ្សព្វផ្សាយសង្គមជាជំនួយ។ ទម្រង់ថ្មីនេះ អាចអនុញ្ញាតឱ្យមានការបញ្ជូនសារទៅវិញទៅមក រវាងអ្នកបង្កើតសារ និងអ្នកទទួលសារ។

ក្នុងយុគសម័យឌីជីថល ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ក៏ត្រូវវិវឌ្ឍខ្លួនទៅតាមបរិបទសង្គមដែរ។ ស្ថាប័នសារព័ត៌មានស្ទើរទាំងអស់ បានបង្កើនការផ្សាយរបស់ខ្លួនលើបណ្តាញសង្គម ដែលជួនពេលខ្លះមានការពិបាកក្នុងការកំណត់អត្តសញ្ញាណ។ ទោះជាយ៉ាងណាក្តី សារព័ត៌មានបែបប្រពៃណីនៅតែរក្សាវិជ្ជាជីវៈរបស់ខ្លួន តែត្រូវប្រឈមនឹងបញ្ហាថ្មីៗដូចជា÷ ល្បឿន និងបរិមាណនៃព័ត៌មាន ដែលប្រព័ន្ធផ្សព្វផ្សាយសង្គមអាចធ្វើបាន។

ការទទួលដំណឹងបឋម គឺជាចំណុចដែលសំខាន់ដើម្បីសារព័ត៌មានធ្វើការសម្រេចចិត្តថាគួរទៅយកព័ត៌មាន ឬចុះផ្សាយនៅលើប៉ុស្តិ៍របស់គេដែរឬទេ។ សារព័ត៌មានភាគច្រើន ចាប់អារម្មណ៍ប្រធានបទទូទៅ ពោលគឺឱ្យតែមានតម្លៃព័ត៌មានគេនឹងចុះផ្សាយ។ ដោយឡែកស្ថាប័នខ្លះ អាចមានចំណុចចាប់អារម្មណ៍ក្នុងកម្រិតមួយ ឬខ្លះទៀតជាសារព័ត៌មាន ឯកទេសតែម្តង។ ដូច្នេះការជូនដំណឹងទៅកាន់សារព័ត៌មានដើម្បីឱ្យគេចុះផ្សាយ ចាំបាច់ត្រូវដឹងថាតើព័ត៌មាននោះស្ថិតក្នុងវិស័យដែលគេចាប់អារម្មណ៍ដែរឬទេ។

ក្នុងការងារអនុវត្តជាក់ស្តែង ការធ្វើការជាមួយសារព័ត៌មានសម្រាប់បញ្ជូនសារសម្រាប់ព្រឹត្តិការណ៍ កម្មវិធី ឬផ្សព្វផ្សាយដំណឹងណាមួយ តែងត្រូវការប្រើប្រាស់សារព័ត៌មានក្នុងទម្រង់ចម្រុះគ្នា ដែលការណ៍នេះតម្រូវឱ្យក្រុមការងារត្រូវរៀបចំខ្លឹមសារ ក៏ដូចជាទម្រង់ចាំបាច់ទៅតាមប្រភេទនៃសារព័ត៌មានផងដែរ។ ការធ្វើដូចនេះ នឹងធានាបានថាសារដែលនឹងត្រូវបញ្ជូនទៅនឹងបានទៅដល់សាធារណជនប្រកបដោយប្រសិទ្ធភាព និងមិនមានការជ្រុះ ឬខ្វះខាតណាមួយបានឡើយ។ ការស្វែងយល់ពីចរិតលក្ខណៈនៃសារព័ត៌មាន ជាជំហានដំបូងនៃការធ្វើការជាមួយសារព័ត៌មាន ដែលនឹងផ្តល់ប្រយោជន៍ដល់ការលើកកម្ពស់មុខមាត់ និងកិត្តិយសរបស់ស្ថាប័ន។

### ខ. ប្រព័ន្ធផ្សព្វផ្សាយសង្គម

ដោយឡែកប្រព័ន្ធផ្សព្វផ្សាយសង្គម ឬបណ្តាញសង្គម គឺជាទម្រង់ផ្សព្វផ្សាយបែបថ្មី ដោយមិនមានប្រើប្រាស់អង់តែនធំ ប៉ុន្តែបែជាប្រើប្រាស់ App ដូចជា÷ Facebook, Instagram, Tiktok, Messenger ។ល។ ប្រព័ន្ធផ្សព្វផ្សាយសង្គមមានភាពបត់បែនខ្លាំង និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានបែបទំនើបជាមធ្យោបាយ ដោយក្នុងនោះរួមមានទូរស័ព្ទ កំព្យូទ័រ ឬអាយផេត។ ទម្រង់ព័ត៌មានមានលក្ខណៈឆ្លងឆ្លើយបាន (interactive) រវាងអ្នកបញ្ជូនសារ និងអ្នកផ្ញើសារ។ ចំពោះប្រភពបញ្ចេញព័ត៌មាន វាកាន់តែមានភាពទូលាយ ប៉ុន្តែកម្រិតស៊ីជម្រៅ គឺមិនសូវមាននោះទេ។

ឈានចូលមកដល់សតវត្សទី២១ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍កាន់តែមានភាពសម្បូរបែប ជាពិសេសកាន់តែខិតជិតទៅដល់អ្នកប្រើប្រាស់។ វត្តមាននៃបណ្តាញសង្គមបានចាប់មានឡើង នៅក្រោយពេលដែលប្រព័ន្ធសារគមនាគមន៍ថ្មីមួយបានបង្កើតឡើងនោះគឺអ៊ីនធឺណិត។ ទោះជាយ៉ាងណាក្តី រយៈពេលជាច្រើនទសវត្សរ៍មកហើយ ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធបណ្តាញអ៊ីនធឺណិតនៅមានលក្ខណៈតូចចង្អៀត ដោយសារកត្តាតម្លៃខ្ពស់។ ក្រោយពេលដែល សេវាអ៊ីនធឺណិតចាប់ផ្តើមមានតម្លៃថោក ទន្ទឹមនឹងការមកដល់នៃទូរសព្ទវៃឆ្លាតផងនោះ ការប្រើប្រាស់អ៊ីនធឺណិត និយាយជារួម និងការប្រើប្រាស់បណ្តាញសង្គមនិយាយដោយឡែក ចាប់ផ្តើមមានសំទុះកាន់តែខ្លាំងឡើង។ នៅកម្ពុជា បាតុភូតនេះ ក៏មិនសូវជាខុសគ្នាប៉ុន្មានដែរ ពីបណ្តាប្រទេសនានាក្នុងសកលលោក គឺបានទទួលឥទ្ធិពលនៃការហក់ឡើងនៃបណ្តាញសង្គម (The rise of social media)។

ជាមួយការរីកចំរើននៃបច្ចេកវិទ្យាព័ត៌មាន បណ្តាញសង្គមបានក្លាយជាវេទិកាចែករំលែកដំណឹង ឬព័ត៌មានយ៉ាងទូលំទូលាយ ហើយមានលក្ខណៈងាយស្រួល និងឆាប់រហ័ស។ បុគ្គលសាធារណៈ ឬស្ថាប័នមួយចំនួន បានប្រើប្រាស់បណ្តាញសង្គមជាយន្តការផ្សព្វផ្សាយផ្ទាល់ និងផ្លូវការរបស់ខ្លួនផងដែរ។ ប្រព័ន្ធផ្សព្វផ្សាយប្រពៃណីមួយចំនួន បានចាត់ទុកការផ្សាយចេញពីបណ្តាញសង្គមផ្លូវការរបស់ស្ថាប័នធំៗ ថាជាប្រភពផ្លូវការ ដែលមានអានុភាពជាព័ត៌មានផងដែរ។

## ២. ជំពូកទី២÷ បម្រើបម្រាស់បច្ចេកវិទ្យាព័ត៌មាន

បណ្តាញសង្គម គឺជាវេទិកានិម្មិត ដែលអនុញ្ញាតឱ្យមនុស្សធ្វើការប្រាស្រ័យទាក់ទងគ្នាបានច្រើនយ៉ាង។ ភាគច្រើននៃអន្តរកម្មនេះគឺធ្វើឡើងជាសាធារណៈ ឬពាក់កណ្តាលសាធារណៈ។ ខុសពីគេហទំព័រ (website) បណ្តាញសង្គមអនុញ្ញាតឱ្យអ្នកប្រើប្រាស់បង្កើតមាតិកាបានយ៉ាងសម្បូរបែប ឬ/និង បញ្ចេញមតិយោបល់លើមាតិកានោះវិញ។

នៅកម្ពុជា បណ្តាញសង្គមធំៗដែលមានប្រជាប្រិយភាព និងមានទំហំធំ រួមមាន÷ ហ្វេសប៊ុក (facebook) ទិកតុក (Tiktok) តេលេក្រាម (telegram)។

នៅក្នុងជំពូកនេះ សិក្ខាកាមនឹងសិក្សាពីប្រភេទ និងទម្រង់នៃការបង្កើតមាតិកាក្នុងបណ្តាញសង្គម ដែលរួមបញ្ចូលផងដែរនូវបណ្តាវិធីសាស្ត្រដែលពេញនិយម កត្តាគួរចៀសវាង និងវិធានសុវត្ថិភាពខ្លះៗផងដែរ។

**ការបង្កើតមាតិកាក្នុងបណ្តាញសង្គម**

មាតិកាក្នុងបណ្តាញសង្គមត្រូវតែអនុលោមតាមប្រភេទនៃបណ្តាញសង្គម និងទម្រង់នៃសម្ភារៈផ្សាយ។ ទម្រង់នៃសម្ភារៈផ្សាយក៏ជាកត្តាកំណត់នៃការសាយភាយ និងភាពទាក់ទាញនៃមាតិកាផងដែរ។

*ឧទាហរណ៍÷ នៅលើហ្វេសប៊ុក ការបង្ហោះដោយផ្ទាល់ (Post) មានការសាយភាយខ្ពស់ជាង ការចែករំលែកបន្ត (Sharing) ឬការបង្ហោះមាតិកាវីដេអូខ្លី មានលទ្ធភាពបង្កើនការសាយភាយខ្ពស់ជាងការបង្ហោះរូបភាព ឬអត្ថបទ។*

ទម្រង់ និងខ្លឹមសារនៃសារក្នុងបណ្តាញសង្គម អាចមានបង្កើតប្រជាប្រិយភាព និងទាក់ទាញខ្លាំងអាស្រ័យដោយកត្តាច្រើនយ៉ាង។ ទោះជាយ៉ាងណាក្តី ទំនោរមួយចំនួនត្រូវបានកត់សម្គាល់ថាកំពុងតែផ្ទុះការពេញនិយមលើបណ្តាញសង្គម។ ទម្រង់ដែលពេញនិយមលើបណ្តាញ អាចត្រូវបានប្រើប្រាស់ដើម្បីរៀបចំខ្លឹមសារដែលបម្រើឱ្យវត្ថុបំណងនៃការងារផ្សព្វផ្សាយមានដូចខាងក្រោម÷

- **ការប្រើប្រាស់សញ្ញាទ្រុងជ្រូក hashtag "#"**

  ខុសពី tag ដែលជាការដៅឈ្មោះគណនី ឬទំព័រណាមួយដើម្បីឱ្យមិត្តភក្តិ ឬអ្នកគាំទ្របានមើលឃើញសារដែលបង្ហោះនោះដែរ សញ្ញាទ្រុងជ្រូកមានមុខងារខុសពីការtag។ hashtag អនុញ្ញាតឱ្យទំព័រកំណត់ពាក្យ ឬប្រយោគជាពាក្យគន្លឹះ ឬពាក្យស្លោកដែលអាចឱ្យពាក្យ ឬប្រយោគនោះមានលក្ខណៈលេចធ្លោ អណ្តែតពីអត្ថបទដែលសរសេរក្នុងខ្លឹមសារ។

  ដោយសារពាក្យពេចន៍ខ្លី ខ្លឹម និងងាយចាំ ការប្រើប្រាស់សញ្ញាទ្រុងជ្រូកអាចត្រូវបានយកទៅប្រើតាមដោយអ្នកប្រើប្រាស់ផ្សេងៗ បង្កើតបានជាចលនា ឬយុទ្ធនាការធំមួយបាន។ ការប្រើប្រាស់សញ្ញាទ្រុងជ្រូកក៏អាចប្រើប្រាស់សម្រាប់ការបញ្ចូលពាក្យគន្លឹះដែលផ្តល់ភាពងាយស្រួលសម្រាប់ការស្វែងរកផងដែរ។

- **វីដេអូខ្លី**

  វីដេអូឃ្លីបសំដៅដល់ទម្រង់នៃឯកសារសោតទស្សន៍ ដែលមិនចាំបាច់ត្រូវជាវីដេអូសកម្មភាពនោះទេ។ ភាពច្នៃប្រឌិតនៃការធ្វើវីដេអូឃ្លីប អាស្រ័យទៅតាមប្រធានបទ និងទំនោរដែលប្រែប្រួលឆាប់រហ័ស។ តាមការសង្កេត វីដេអូដែលប្រវែងខ្លីងាយស្រួលនឹងទទួលការចាប់អារម្មណ៍ ក៏ដូចជាអាចបញ្ជោបសារមានប្រសិទ្ធភាពខ្ពស់។ ម្យ៉ាងវិញទៀត ការប្រើប្រាស់វីដេអូមានគុណសម្បត្តិលើសអត្ថបទ និងរូបភាពដោយសារភាពរស់រវើកនៃខ្លឹមសារក្នុងវីដេអូ។

ម្យ៉ាងវិញទៀត បណ្តាញសង្គមមួយកំពុងតែមានឈ្មោះបោះសំឡេងខ្លាំងក្នុងចំណោមអ្នកប្រើប្រាស់ជាយុវជន បានប្រើប្រាស់វីដេអូខ្លីជាមធ្យោបាយអន្តរកម្មក្នុងបណ្តាញរបស់ខ្លួន នោះគឺ Tik Tok។ ទោះជាយ៉ាងណាក្តី ក្នុងទំព័រផ្លូវការ ការប្រើប្រាស់វីដេអូជាមធ្យោបាយបញ្ជូនសារ ទាមទារពេលវេលា និងទាមទារកម្លាំងច្រើនដើម្បីដើរទាន់សភាពការណ៍។ ដូច្នេះ ការប្រើប្រាស់ជាលក្ខណៈបំពេញបន្ថែមគឺជាការល្អ។

- **គន្លឹះបន្ថែមខ្លះៗ**

  អ្នកប្រើប្រាស់បណ្តាញសង្គមមានទំនោរអូសមើលមាតិកាដែលបង្ហោះក្នុងល្បឿនលឿនដូច្នេះ មាតិកាដែលទាក់ទាញ ត្រូវតែមានលក្ខណៈខ្លី និងផ្តោតលើរបស់សំខាន់។ ឧទាហរណ៍÷ ក្រៅពីប្រើរូបភាពដែលស្អាត យើងអាចប្រើរូបភាពប្លង់ជិតនៃបុគ្គល ឬរូបភាពដែលច្បាស់ជាដើម។ ដោយឡែក ក្នុងហ្វេសប៊ុក គេអាចចូល ទៅក្នុងខមិន និងវាយពាក្យ @follower ឬ @highlight ដែលធ្វើដូចនេះ វានឹងជូនដំណឹងផ្ទាល់ទៅអ្នកគាំទ្រ។

## ៣. ជំពូកទី៣÷ វិធានការការពារសុវត្ថិភាព

### បញ្ហាប្រឈមក្នុងការប្រើប្រាស់បណ្តាញសង្គម

នៅលើបណ្តាញសង្គម គេតែងមានស្តង់ដារសហគមន៍ (Community Standard Regulation) ដែលកំណត់បទបញ្ញត្តិមួយចំនួនដែលហាមឃាត់មិនឱ្យអ្នកប្រើប្រាស់បង្ហោះមាតិកាដែលមិនសមរម្យដូចជា÷ រូបភាពហិង្សា រូបភាពបែបអាសអាភាស ភាសាអសុរោះ (តែមិនអាចប្រើបាន លើករណីភាសាខ្មែរទេ)។ មាតិកាមួយចំនួនដែលល្មើសបទបញ្ញត្តិអាចត្រូវបានចាប់ដោយស្វ័យប្រវត្តិ និងត្រូវបានដកចេញ។ ក្នុងករណីដែល ប្រព័ន្ធស្វ័យប្រវត្តិចាប់មិនជាប់ អ្នកប្រើប្រាស់អាចធ្វើការប្តឹង (report) ទៅក្រុមហ៊ុនដើម្បីពិនិត្យ និងចាត់វិធានការ។ ជាទូទៅ ការប្តឹងកាន់តែច្រើន លើមាតិកាជាក់លាក់មួយទើបធ្វើឱ្យក្រុមហ៊ុនបណ្តាញសង្គមចាត់វិធានការ។

ក្រៅពីវិធានស្តង់ដារសហគមន៍ (Community Standard Regulation) ដែលកំណត់ដោយបណ្តាញសង្គម ក៏នៅមានបញ្ហាប្រឈមខ្លះៗ ដែលទាមទារឱ្យមានការប្រុងប្រយ័ត្នបន្ថែមលើទិដ្ឋភាពក្រមសីលធម៌ ដូចជា÷

- ការប្រើប្រាស់រូបភាពបុគ្គល ឬរូបសម្ងាត់ដែលមិនទទួលបានការអនុញ្ញាតជាមុន ឬដែលគ្មានការសន្មតថាបានអនុញ្ញាតដោយស្ងាត់ស្ងៀមពីម្ចាស់រូបភាព
- ការ mention ដើម្បីបង្កើនការសាយភាយ ដែលមានលក្ខណៈមិនចាំបាច់ និងបង្កការរំខាន
- ការផ្សព្វផ្សាយ ឬចែករំលែកព័ត៌មានមិនច្បាស់លាស់ ឬមិនមានការបញ្ជាក់ពីភាពត្រឹមត្រូវ ដែលភាគច្រើនមកពីការប្រញាប់ផ្សាយដើម្បីបានចេញមុនគេជាដើម។

### ៤. ជំពូកទី៤÷ សុវត្ថិភាព និងការការពារពីការក្លែងបន្លំ

គណនីគឺជាគេហដ្ឋានឌីជីថលនៅក្នុងបណ្តាញសង្គម ដែលផ្ទុកនូវទិន្នន័យឯកជន និងសម្ងាត់ផងដែរ។ គណនីកំណត់នូវអត្តសញ្ញាណបុគ្គលនីមួយៗ។ ទោះជាយ៉ាងនេះក្តី បណ្តាញសង្គមភាគច្រើនមិនបានកម្រិតចំនួននៃការបង្កើតគណនីបណ្តាញសង្គមនោះទេ។ ពុំនោះសោត ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃគណនីក៏មានលក្ខណៈធូររលុងផងដែរ។ គណនីបណ្តាញសង្គមត្រូវបានបង្កើតដោយតម្រូវឱ្យមានការចុះឈ្មោះជាមួយអាសយដ្ឋានអ៊ីមែល ឬលេខទូរសព្ទ ហើយត្រូវបានការពារដោយលេខសម្ងាត់ និងការកំណត់សុវត្ថិភាព (Authentication)។ ក្រុមជនទុចរិត តែងប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីហែគ ឬលួចគណនីបណ្តាញសង្គម ដោយកេងចំណេញពីភាពខ្សោយនៃគណនីនោះ ដូចជា ឧបករណ៍ប្រើប្រាស់ លេខសម្ងាត់ ការជ្រៀតចូលតាមបណ្តាញជាដើម។

សុវត្ថិភាពគឺជាបញ្ហាប្រឈមចម្បងមួយនៅក្នុងបណ្តាញសង្គម។ ហានិភ័យមួយចំនួននៃការប្រើប្រាស់បណ្តាញសង្គមមានដូចជា ការលួចចូលក្នុងគណនីប្រើប្រាស់ ការលួចព័ត៌មានសំខាន់ ឬសំងាត់ ការលួចមើលទំនាក់ទំនង ឯកជនជាដើម។ ឆ្លងទៅដល់ការកាន់កាប់ទំព័រហ្វេសប៊ុក បញ្ហាសុវត្ថិភាពក៏ត្រូវបានចោទជាបញ្ហាសម្រាប់អ្នកកាន់កាប់ទំព័រផងដែរ។ ថ្មីៗនេះ ហ្វេសប៊ុកបានបង្កើតមុខងារដើម្បីឆ្លើយថាភ្ញាក់ទំព័រហ្វេសប៊ុក ដែលហៅសាមញ្ញថា សញ្ញាធីកពណ៌ខៀវ (Blue Badge)។

**វិធីការពារសុវត្ថិភាពពីការហែគចូលខ្លះៗ៖**

- ប្រើលេខសម្ងាត់ដែលពិបាក និងឧស្សាហ៍ប្តូរលេខសម្ងាត់។ ការកត់ត្រាលេខសម្ងាត់ គួរតែរក្សាទុកនៅក្រៅឧបករណ៍អេឡិចត្រូនិក។
- កុំចុចលើតំណមិនស្គាល់ប្រភព ឬដែលគួរឱ្យសង្ស័យ
- គួរចៀសវាងភ្ជាប់អ៊ីនធឺណិតជាមួយប្រព័ន្ធ (wi-fi) សាធារណៈ ដែលជនទុចរិតអាចឆ្លៀតឱកាសជ្រៀតចូលឧបករណ៍អេឡិចត្រូនិកបាន
- ឧស្សាហ៍ចូលពិនិត្យចំនួនឧបករណ៍ដែលចូលគណនី (log-in devices) ដើម្បីពិនិត្យភាពមិនប្រក្រតី។

## III. ការរៀបចំខ្លឹមសារ

### ១. ជំពូកទី១÷ ការកំណត់ក្រុមគោលដៅ

ការងារមហាជន (ការបញ្ជ្រាបខ្លឹមសារទៅកាន់មហាជន) ទាមទារការផ្តោតលើទស្សនិកជនគោលដៅ (ជាក់លាក់) ដើម្បីបញ្ជូនសារ និងបង្កើតការគាំទ្រស្ថាប័ន ឬគំនិតណាមួយរបស់ស្ថាប័ន។ ដោយឡែកសម្រាប់អ្នកសារព័ត៌មាន ពួកគេមិនចាំបាច់ផ្តោតខ្លាំងលើការកំណត់ទស្សនិកជនគោលដៅនោះទេពីព្រោះអ្វីដែលពួកគេ កំពុងផ្សព្វផ្សាយ គឺជាព័ត៌មាន ដែលជាចំណាប់អារម្មណ៍របស់សាធារណជន (សម្រាប់មហាជនទូទៅ)។

ដើម្បីជានាប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយ ការកំណត់ក្រុមគោលដៅ មានសារៈសំខាន់ណាស់សម្រាប់ការតាក់តែងសារ និងតម្រង់ទិសនៃការបញ្ជោបសារ។ ចង្កោមសាធារណមតិដ៏ធំ មិនមានភាពដូចគ្នាទាំងស្រុងនោះទេ ទោះបី ក្នុងសង្គមដែលមានឯកសណ្ឋានភាពស្ទើរតែឥតខ្ចោះក៏ដោយ។ តាមទ្រឹស្ដី និងការអនុវត្តកន្លងទៅ ក្រុមគោលដៅ ត្រូវបានកំណត់ដោយយោងលើកត្តា ៥ យ៉ាងធំៗ÷ កត្តាប្រជាសាស្ត្រ កត្តាផលប្រយោជន៍ កត្តាទំនោរសង្គម កត្តាចិត្តសាស្ត្រ កត្តាចរិតលក្ខណៈ។

**១. កត្តាប្រជាសាស្ត្រ**

ជាការកំណត់ ដោយយោងលើរបាយការណ៍ប្រជាសាស្ត្រទូទៅ ដែលមានដូចជា÷ ក្រុមអាយុ ភេទ ភូមិសាស្ត្រ (ទីប្រជុំជន និងជនបទ, ឬតាមភូមិភាគជាដើម)។ល។ ការបែងចែកបែបនេះ គឺមានភាពអចិន្ត្រៃយ៍ជាងគេ និងមានការប្រែប្រួល យឺតជាងប្រភេទដទៃ។

**២. កត្តាផលប្រយោជន៍ (ចំណូលចិត្ត)**

ការបែងចែកផ្អែកលើកត្តាផលប្រយោជន៍ អាស្រ័យលើការកំណត់តាមចំណូលចិត្តរួមរបស់ក្រុមមនុស្សទាំងនោះ។ ប្រយោជន៍រួម អាចកើតចេញពីប្រភេទការងារដូចគ្នា ប្រយោជន៍ក្នុងសហគមរួមគ្នា។ល។ បំណែងចែកប្រភេទនេះ មានលក្ខណៈស្មុគស្មាញ និងពិបាកចាត់ថ្នាក់ជារចនាសម្ព័ន្ធ។ ការប្រែប្រួលនៃទំនោរសង្គម ជះឥទ្ធិពលផងដែរមកលើក្រុមផលប្រយោជន៍ ដែលទាមទារឱ្យមានការសិក្សាឡើងវិញជាញឹកញាប់តាមដែលអាចធ្វើទៅបាន។

**៣. កត្តាទំនោរសង្គម**

ទំនោរសង្គមច្រើនប្រើលើបញ្ហាប្រធានបទជាក់លាក់មានកាលកំណត់ណាមួយ។ ទំនោរសង្គមច្រើនតែជាការបែងចែកបែបនិន្នាការនយោបាយ ឧ. រវាងក្រុមគាំទ្រ និងក្រុមផ្ទុយ (ឬពេលខ្លះ អាចមានក្រុមកណ្ដាល)។ ទំនោរសង្គមមានចរិតប្រែប្រួលឆាប់រហ័ស ឬមួយឆាវៗ ប៉ុន្តែអាចជះឥទ្ធិពលដល់ការប្រែប្រួលក្នុងក្រុមផលប្រយោជន៍។

*ឧទាហរណ៍÷ ការផ្ទុះការប្រឈមមុខដាក់គ្នារវាងការជជែកវែកញែកអំពីវប្បធម៌ ខ្មែរ និងថៃ បានធ្វើឱ្យសំទុះនៃការគាំទ្រសិល្បៈបុរាណបានកើនឡើង។*

**៤. កត្តាចិត្តសាស្ត្រ**

ក្រុមគោលដៅ អាចត្រូវបានកំណត់ដោយផ្អែកលើការយល់ដឹងអំពីសង្គម។ ជាធម្មតា មនុស្សម្នាក់រស់នៅក្នុងសង្គមមួយ តែងមាននូវមនោសញ្ចេតនាចំពោះសង្គមនោះ ជាអាទិ៍ មនោសញ្ចេតនាចំពោះសិល្បៈ វប្បធម៌ របៀបរបបរស់នៅ ឬធម្មជាតិនៅជុំវិញខ្លួន។ល។ ចិត្តសាស្ត្រមានលក្ខណៈផ្សារភ្ជាប់នឹងធម្មជាតិមនុស្ស ដែលត្រូវបានកំណត់ដោយការរួមចំណែកពីបរិស្ថាន ប្រវត្តិសាស្ត្រ ឬទម្លាប់របស់សង្គមមួយផងដែរ។

**៥. កត្តាឥរិយាបទ និងចរិតសង្គម**

សកម្មភាពជាក់លាក់ណាមួយ ដែលអាចឱ្យយើងកំណត់បាននូវលក្ខណៈសម្គាល់ក្រុមមនុស្សនោះបាន គឺជាកត្តាបែងចែកក្រុមគោលដៅ ក្នុងការងារមហាជនផងដែរ។ ឥរិយាបថ មានលក្ខណៈប្រាកដនិយម និងមិនពឹង

ផ្នែកលើកត្តាមនោសញ្ចេតនា ដូចកត្តាចិត្តសាស្ត្រនោះទេ។ ដូច្នេះការផ្លាស់ប្តូរបរិយាបថពីមួយទៅមួយនៅក្នុងចំណោមក្រុមមនុស្សមិនមានភាពឆាប់រហ័ស និងពិបាកព្យាករណ៍ដូចករណីទំនោរសង្គមឡើយ។

*ឧទាហរណ៍÷ យើងអាចកំណត់តាមរយៈរបៀបដែលពួកគេបង្ហាញជីវិតលើបណ្តាញសង្គម។*

## ២. ជំពូកទី២÷ ការបង្កើតសារ

សារ គឺជាពាក្យពេចន៍ ឬសកម្មភាព ដែលបង្កើតដោយមនុស្សម្នាក់ ឬក្រុមមនុស្ស ដើម្បីបង្ហាញពីបំណងទៅអ្នកទទួលសារ ដែលអាចជាមនុស្សម្នាក់ទៀត ឬក្រុមមនុស្សក្នុងស្រទាប់មហាជន។ សារល្អ ជាសារដែលមានភាពពាក់ព័ន្ធ ឬឆ្លើយតបទៅនឹងអ្វី ដែលជាតម្រូវការរបស់ក្រុមគោលដៅ។ គោលបំណងនៃការបញ្ជូនសារ គឺដើម្បីឱ្យយល់ ធ្វើសកម្មភាព ឬមិនធ្វើសកម្មភាពអ្វីមួយ។ សារដែលល្អជាសារឆ្លុះបញ្ចាំងពី÷

- ផ្ទត់គំនិត និងអារម្មណ៍របស់ប្រជាពលរដ្ឋ
- បច្ចុប្បន្នភាព និងទំនោរសង្គម - Social Trending
- ទិដ្ឋភាពមូលដ្ឋាន (ពាក់ព័ន្ធនឹងជីវភាពសង្គម)
- អនាគត (ការសម្លឹងឆ្ពោះទៅមុខ)
- មនុស្សមានអំណាច និងតារាល្បីៗក្នុងសង្គម
- ភាពចម្លែកនៃព្រឹត្តិការណ៍ ដែលជាទីចាប់អារម្មណ៍សម្រាប់មនុស្សទូទៅ

### តម្លៃនៃព័ត៌មាន

អ្នកសារព័ត៌មានតែងផ្តោតសំខាន់លើការស្វែងរកសាច់រឿងដែលមាននូវតម្លៃព័ត៌មាន។ ពាក្យថា "តម្លៃនៃព័ត៌មាន" ត្រូវបានប្រើដើម្បីរៀបរាប់សាច់រឿងមួយដែលចាត់ទុកថា មានការចាប់អារម្មណ៍ និងមានភាពពាក់ព័ន្ធគ្រប់គ្រាន់ដើម្បីធ្វើការផ្សព្វផ្សាយក្នុងប្រព័ន្ធផ្សព្វផ្សាយ។ រីឯក្នុងកិច្ចការងារទំនាក់ទំនងសាធារណៈវិញ "តម្លៃនៃព័ត៌មាន" គឺជាចំណុចពិចារណាដំបូងគេបង្អស់ មុនពេលក្រុមការងារ ចាប់ផ្តើម កំណត់ប្រធានបទ ចាប់មុំនៃសាច់រឿងសម្រាប់ការតាក់តែងខ្លឹមសារ ឬការព្រាងសេចក្តីប្រកាសព័ត៌មាន នានា។

ស្របពេលដែលស្ថាប័នព័ត៌មាននីមួយៗអាចមានវិស័យ ឬផ្នែកដែលគួរឱ្យចាប់អារម្មណ៍ (Area of interest) ផ្សេងៗដោយឡែកពីគ្នា។ សាច់រឿងដែលត្រូវយកមកផ្សព្វផ្សាយទាមទារឱ្យមាននូវលក្ខណៈមួយចំនួនដើម្បី ក្លាយជាសាច់រឿងដែលមានតម្លៃនៃព័ត៌មានគ្រប់គ្រាន់សម្រាប់ការផ្សាយ។ លក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើជាទូទៅ ដើម្បីកំណត់ តម្លៃនៃព័ត៌មានត្រូវបានគេស្គាល់ថាជាតម្លៃព័ត៌មាន (News Value)។ ខាងក្រោមនេះគឺជាតម្លៃព័ត៌មានដែលអ្នកសារព័ត៌មាន និងអ្នកទំនាក់ទំនងសារធាណៈតែងស្វែងរកមើលនៅក្នុងបណ្តាសាច់រឿងនីមួយៗ÷

| លក្ខណៈវិនិច្ឆ័យ | សេចក្តីពន្យល់ |
|---|---|
| ភាពទាន់ពេលវេលា (Timeliness) | ព្រឹត្តិការណ៍ដែលទើបតែកើតឡើងបន្ទាន់ (ភ្លាមៗ) មាននូវតម្លៃនៃ ព័ត៌មាន។ វាជាព័ត៌មានព្រោះវា " ថ្មី"។ |
| ឥទ្ធិពល (Impact) | ព្រឹត្តិការណ៍ ឬរឿងរ៉ាវដែលជះឥទ្ធិពលដល់មនុស្សជាច្រើន ត្រូវបានគេចាត់ ទុកថាមានសារៈសំខាន់ជាងរឿងដែលផលប៉ះពាល់ដល់មនុស្សតែម្នាក់ ឬ២នាក់។ |
| ភាពលេចធ្លោ (Prominence) | រឿងរ៉ាវដែលបង្ហាញពីបុគ្គលដែលមានការទទួលស្គាល់ និងមានឈ្មោះ ល្បីល្បាញ នឹងទាក់ទាញឱ្យមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ ពីសាធារណជន។ |
| ភាពជិតខ្លួន (Proximity) | ព័ត៌មាន និងព្រឹត្តិការណ៍ដែលកើតមានក្នុងស្រុក ទទួលបានការចាប់អារម្មណ៍ ខ្ពស់ពីព្រោះវាអាចប៉ះពាល់ ដល់ទស្សនិកជននៅក្នុងសហគមន៍ និងប្រទេស របស់យើង។ មនុស្សជាទូទៅ យកចិត្តទុកដាក់ខ្ពស់ អំពីអ្វីដែលកើតឡើងនៅជិត ឬជុំវិញខ្លួន។ |
| ភាពប្លែក/ចម្លែក Uniqueness/Bizarreness | ព័ត៌មាន និងព្រឹត្តិការណ៍ដែលចម្លែកពីគេ ឬធម្មតាកម្រកើតមាន។ |
| ជម្លោះ (Conflict) | សាច់រឿងអំពីហេតុការណ៍ណាមួយ នៅពេលអំពើហិង្សាកើតឡើង ឬនៅពេលមនុស្សជជែកតវ៉ា អំពីសកម្មភាព ព្រឹត្តិការណ៍ និងទស្សនៈនានា។ ទំនាស់ ឬជម្លោះនឹង ទាក់ទាញចំណាប់អារម្មណ៍របស់មនុស្ស ដោយការរំលេចឡើងនូវបញ្ហា ឬភាពខុសគ្នានៅក្នុងសហគមន៍។ |
| ចំណាប់អារម្មណ៍មនុស្ស (Human Interest) | មនុស្សគ្រប់រូបតែងចាប់អារម្មណ៍នឹងសកម្មភាពរបស់មនុស្សដ៏ទៃផ្សេងទៀត។ ធាតុសំខាន់នៃរឿងរ៉ាវដែលទាក់ទាញចំណាប់អារម្មណ៍មនុស្ស គឺថាវាមានការពាក់ព័ន្ធនឹងអារម្មណ៍ ឬមនោសញ្ចេតនា។ រឿងប្រភេទទាំងនេះច្រើនតែធ្វើឱ្យអ្នកអាន (ទស្សនិកជន) សោកសៅ ឬរីករាយ។ |

### ៣. ជំពូកទី៣៖ ការតាក់តែងខ្លឹមសារ

#### ក. ការតាក់តែងខ្លឹមសារលើបណ្តាញសង្គម (Caption)

ការតាក់តែងខ្លឹមសារសម្រាប់ទស្សនិកជនគោលដៅដែលជាអ្នកប្រើប្រាស់បណ្តាញសង្គម ក្នុងទម្រង់សង្ខេបខ្លី ទាក់ទាញការចាប់អារម្មណ៍ ដើម្បីការបញ្ចេញមតិ (Comment &Like) ការចែកចាយបន្ត (Share)។ ក្នុងន័យនេះ បណ្តាញសង្គមមានច្រើនបែប និងច្រើនប្រភេទ ដែលទាមទារទម្រង់ និងការកំណត់ខុសប្លែកពីគ្នា។ ក្នុងគោលបំណងនៃការបង្ហាញនេះ ក្រុមការងារនឹងផ្តោតលើទម្រង់ដែលតែងតែប្រើប្រាស់លើទំព័រហ្វេសប៊ុក ជាគោលនៃការពិភាក្សា។

## គន្លឹះខ្លះៗក្នុងការសរសេរ÷

- កំណត់ទស្សនិកជនគោលដៅ (មហាជនទូទៅ យុវជន ដៃគូសហការ ថ្នាក់ដឹកនាំ)
- កំណត់ខ្លឹមសារតាមប្រភេទនៃព្រឹត្តិការណ៍
- ជ្រើសរើស សេចក្តីផ្តើមដែលទាក់ទាញអ្នកអាន (Hook Lead)
- សង្ខេបខ្លឹមសារ (ដោយឆ្លើយនឹងសំនួរ 5W (អ្វីកើតឡើង? ដោយហេតុអ្វី? អ្នកណាខ្លះពាក់ ព័ន្ធ? នៅពេលណា? ទីតាំងណា? និង 1H (ដោយរបៀបណា)
- កំណត់ប្រវែងមួយដែលសមស្រប (Keep it Short and Simple)
- ខ្លឹមសារត្រូវស្របជាមួយនឹងរូបភាព ឬវីដេអូនានាដែលភ្ជាប់នឹងការបង្ហោះ

ទម្រង់នៃការសរសេរខ្លឹមសារ Caption អាចមានការបត់បែនទៅតាមស្ថានការណ៍ជាក់ស្តែង អាស្រ័យលើចំណេះដឹង និងការវាយតម្លៃរបស់អ្នកតាក់តែងថាគួរកំណត់ទម្រង់បែបណាដើម្បីសមស្រប។ ក្នុងការតាក់តែងខ្លឹមសារ បែបសង្ខេបខ្លី អ្នកសរសេរត្រូវផ្តោតសំខាន់លើសេចក្តីផ្តើមដើម្បីទាក់ចិត្តអ្នកអាន ឱ្យបន្តអានខ្លឹមសារទាំងស្រុង។ ការសរសេរសេចក្តីផ្តើម ត្រូវបានបែងចែកដូចខាងក្រោម÷

| ប្រភេទ | បម្រើបម្រាស់ |
|---|---|
| បង្ហាញអត្តសញ្ញាណ តួអង្គភ្លាមៗ<br>Immediate identification leads | នៅពេលមានវត្តមានបុគ្គលដែលមានការទទួលស្គាល់ ល្បីក្នុងសង្គម ឬអ្នកដែលមានឥទ្ធិពល |
| បង្ហាញអត្តសញ្ញាណតួអង្គបន្ទាប់<br>Delayed identification lead | នៅពេលដែលឈ្មោះនរណាម្នាក់មិនស្គាល់/មិនត្រូវបានគេទទួលស្គាល់ជាទូទៅទេ ប៉ុន្តែតួនាទី ឬស្ថាប័នសំខាន់ជាង ។ |
| បង្ហាញសង្ខេបរឿង Summary leads | បូកសរុបនូវអ្វីដែលបានកើតឡើងជាជាងបង្ហាញសកម្មភាពជាក់លាក់ |
| បង្ហាញពហុធាតុ<br>Multiple - Element Leads | ដាក់ព័ត៌មានច្រើនបញ្ចូលគ្នាក្នុងកថាខណ្ឌទី១ (១ ឬ២ ប្រយោគ) |
| បង្ហាញភាពទាក់ទាញ Leads with flair | ផ្តោតលើអ្វីដែលថ្មី / ប្លែក / មិនធម្មតា ឬកម្រកើតមាន |

## ខ. ខ្លឹមសារអត្ថបទចុះផ្សាយ (Press Article) និងខ្លឹមសារសេចក្តីប្រកាសព័ត៌មាន (Press Release)

ការសរសេរអត្ថបទចុះផ្សាយ (Press Article) និងសេចក្តីប្រកាសព័ត៌មាន (Press Release) ក៏មានភាពចាំបាច់មួយសម្រាប់អ្នកទទួលបន្ទុកការងារទំនាក់ទំនងសាធារណៈផងដែរ ព្រោះវាមានសារៈសំខាន់ក្នុងការគ្រប់គ្រងខ្លឹមសារ ឬព័ត៌មានណាមួយទៅកាន់សាធារណជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ឬស្ថាប័នព័ត៌មាន។ ជាធម្មតាប្រភេទខ្លឹមសារទាំងពីរខាងលើនេះ ត្រូវបានរៀបចំឡើងដោយស្ថាប័នមួយ រួចត្រូវបានផ្ញើខ្លឹមសារទាំងស្រុងទៅកាន់អ្នកសារព័ត៌មាន។ ចំពោះអត្ថបទចុះផ្សាយ ស្ថាប័នអាចស្នើការចុះផ្សាយទាំងស្រុងដោយ មិនចាំបាច់ ការកែសម្រួលណាមួយ។ ដោយឡែក សម្រាប់សេចក្តីប្រកាសព័ត៌មាន ខ្លឹមសារអត្ថបទនោះនឹងក្លាយជាជំនួយស្មារតីសម្រាប់អ្នកសារព័ត៌មានក្នុងការចាប់យកមុំណាមួយទៅសរសេរអត្ថបទផ្សព្វផ្សាយក្នុងទម្រង់ការផ្សាយរបស់ពួកគេ។

**គន្លឹះខ្លះៗក្នុងការសរសេរ**

- ស្វែងយល់ច្បាស់ពីស្ថាប័នព័ត៌មានដែលត្រូវស្នើឱ្យចុះផ្សាយ (ទម្រង់ការសរសេរបែបណា? ទស្សនិកជនគោលដៅប្រភេទណា?)
- ជ្រើសរើសមុំរឿងដែលជាចំណាប់អារម្មណ៍អ្នកអាន
- ចំណងជើង ដើរតួសំខាន់បំផុត
- កំណត់លំហូរខ្លឹមសារ (សេចក្តីផ្តើម តួសេចក្តី និងបញ្ចប់)
- កំណត់ប្រវែងមួយដែលសមស្រប (Keep it Short and Simple)
- ខ្លឹមសារត្រូវស្របជាមួយនឹងរូបភាព ឬវីដេអូនានាដែលផ្តល់ទៅកាន់អ្នកសារព័ត៌មាន

ការតាក់តែងខ្លឹមសារសម្រាប់អត្ថបទចុះផ្សាយ និងសេចក្តីប្រកាសព័ត៌មានមានភាពស្រដៀងគ្នាច្រើនលើទម្រង់ និងលំហូរសាច់រឿង។ ដោយឡែក ភាពខុសគ្នារវាងអត្ថបទទាំងពីរនោះ គឺប្រភេទនៃភាពលម្អិតក្នុងខ្លឹមសារ និងប្រវែងអត្ថបទ។

ក្នុងការសិក្សាផ្នែកសារព័ត៌មាន ឬការសរសេរអត្ថបទផ្សព្វផ្សាយជាទម្រង់ពីរ៉ាមីដផ្កាប់ (Inverted Pyramid) ត្រូវបានលើកយកមកបង្រៀន និងតែងត្រូវបានអនុវត្តដោយអ្នកសារព័ត៌មាន។




សង្ខេបខ្លឹមសារ (ដោយឆ្លើយនឹងសំនួរ 5W &H (អ្វីកើតឡើង? ហេតុអ្វី?អ្នកណាខ្លះពាក់ព័ន្ធ? នៅពេលណា? កន្លែងណា? និងដោយរបៀបណា?)

ប្រយោគទី១ ត្រូវគាំទ្រសេចក្តីផ្តើមដោយដកស្រង់ សម្តីប្រភពដោយផ្ទាល់ ឬដោយប្រយោល។ រក្សាតុល្យភាពនៃប្រភព។

ផ្តល់សេចក្តីពិស្តារ និងរៀបរាប់ព្រឹត្តិការណ៍ ឬហេតុការណ៍ពាក់ព័ន្ធអាចជាតួលេខ/ទិន្នន័យ

រំឭកព្រឹត្តិការណ៍កន្លងដែលពាក់ព័ន្ធ

**ចំណាំ**

**គន្លឹះខ្លះៗក្នុងការតាក់តែងខ្លឹមសារអត្ថបទផ្សាយ និងសេចក្តីប្រកាសព័ត៌មាន÷**

- 5W1H ÷ សង្ខេបខ្លឹមសារទាំងមូលដោយឆ្លើយនឹងសំនួរ 5W (អ្វីកើតឡើង? ដោយហេតុអ្វី? អ្នកណាខ្លះពាក់ព័ន្ធ? នៅពេលណា? ទីតាំងណា? និង 1H (ដោយរបៀបណា)
- ជ្រើសរើសមុំរឿងដែលចាប់អារម្មណ៍ និងឆ្លើយតបនឹងស្ថានភាពជាក់ស្តែងដែលកំពុងកើតមាន
- បញ្ជាក់ប្រភពព័ត៌មាន និងធ្វើការផ្ទៀងផ្ទាត់ពិស្តាព័ត៌មាន ឬហេតុការណ៍អោយបានច្បាស់លាស់
- ដឹងច្បាល់ពីគោលបំណងនៃការរៀបចំខ្លឹមសារ និងការកំណត់ទស្សនិកជនគោលដៅ
- តាក់តែងខ្លឹមសារ ឱ្យសមស្របទៅតាមជម្រើសនៃមធ្យោបាយផ្សព្វផ្សាយ

សម្រាប់ខ្លឹមសារសម្រាប់ការបង្ហោះលើបណ្តាញទំនាក់ទំនងសង្គម (Captions) សេចក្តីផ្តើមត្រូវឆ្លើយនឹងសំនួរ ៥W និង១H ។ ដោយឡែក សម្រាប់អត្ថបទចុះផ្សាយ (Press Article) និងសេចក្តីប្រកាសព័ត៌មាន (Press Release) សេចក្តីផ្តើមអាចឆ្លើយសំណួរ ៣ ទៅ៤ ក្នុងចំណោម៥W និង១H។

**៣. ការរៀបចំគម្រោងផ្សព្វផ្សាយ**

ដើម្បីធានាប្រសិទ្ធភាពក្នុងការបំពេញការងារប្រចាំថ្ងៃ បុគ្គលទទួលបន្ទុកការងារផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ ត្រូវមានការបែងចែក និងរៀបចំផែនការសកម្មភាពការងាររបស់ខ្លួន ឱ្យបានច្បាស់លាស់ និងទៀងទាត់ ដើម្បី តាមទាន់សភាពការណ៍ និងការវិវត្តនានារបស់ស្ថាប័ន និងសង្គម។ ទន្ទឹមនឹងការចេះរៀបចំ តាក់តែងខ្លឹមសារសម្រាប់ការផ្សាយ ការរៀបចំគម្រោង ផ្សព្វផ្សាយ គឺជាកត្តាចាំបាច់។ យុទ្ធសាស្ត្ររៀបចំផែនការប្រព័ន្ធផ្សព្វផ្សាយ ទាមទារការស្វែងយល់ពី (១)ការកំណត់ពេលវេលា (momentum) ដែលត្រឹមត្រូវ (២)ការគ្រប់គ្រងសកម្មភាពតាមផែនការដាក់ចេញ និង(៣)ការជ្រើសរើសមធ្យោបាយផ្សព្វផ្សាយ (ចំគោលដៅភ្នាក់ងារព័ត៌មាន និងទស្សនិកជនគោលដៅ)។

| សកម្មភាព | បរិយាយ |
|---|---|
| ការកំណត់ពេលវេលា | វាអាស្រ័យលើ ខ្លឹមសារ ប្រភេទសម្ភារៈ ឬឧបករណ៍ផ្សព្វផ្សាយ (PR Materials) / ទស្សនិកជនគោលដៅ / និងប្រតិទិនព្រឹត្តិការណ៍ ឬសកម្មភាព។<br>ឆ្លើយសំនួរថា÷<br>• តើពេលវេលាសមស្របសម្រាប់ការផ្សាយខ្លឹមសារ ប្រភេទនេះ ឬទេ? វាមានឥទ្ធិពលបែបណាលើសាធារណជន?<br>• តើអ្វីដែលទស្សនិកជនគោលដៅកំពុងចាប់អារម្មណ៍តាមដាន?<br>• តើវាស្របនឹងស្ថានភាព ឬព្រឹត្តិការណ៍ដែលកំពុងកើតមានក្នុងសង្គម ឬទេ? |

| | |
|---|---|
| ការគ្រប់គ្រងសកម្មភាពតាមផែនការដាក់ចេញ | • បែងចែកកាលវិភាគផ្សព្វផ្សាយ និងតួនាទីភារកិច្ចឱ្យបាន ច្បាស់លាស់<br>• ពិនិត្យ តាមដានជាប្រចាំ ថាការផ្សព្វផ្សាយត្រូវបានអនុវត្ត តាម គម្រោង<br>• ស្វែងយកពីភាពខ្លាំង និងបញ្ហាប្រឈមក្នុងដំណើរការផ្សព្វផ្សាយ |
| ការជ្រើសរើសមធ្យោបាយផ្សព្វផ្សាយ | • ការបោះពុម្ពផ្សាយ (កាសែត)<br>• ការផ្សព្វផ្សាយតាមទូរទស្សន៍ ឬវិទ្យុ<br>• ការផ្សាយតាមសារព័ត៌មានអនឡាន ឬបណ្តាញទំនាក់ទំនងសង្គម |

## ៤. ជំពូកទី៤÷ ការងារផលិតកម្ម

### ក. ការរៀបចំកិច្ចសម្ភាសន៍ និងសន្និសីទសារព័ត៌មាន

ការងារចម្បងមួយទៀតរបស់អ្នកទំនាក់ទំនងសាធារណៈរបស់ស្ថាប័នមួយ គឺការរៀបចំកិច្ចសម្ភាសន៍ និងសន្និសីទសារព័ត៌មានសម្រាប់ថ្នាក់ដឹកនាំ អ្នកនាំពាក្យស្ថាប័ន ឬបុគ្គលផ្សេងៗតាមការសម្រេចរបស់ស្ថាប័ន។ កិច្ចការងារទាំងពីរ ទាមទារការត្រៀមរៀបចំទុកជាមុនលើទិដ្ឋភាពសំខាន់ ២ គឺ÷ ខ្លឹមសារ និងបច្ចេកទេស។

**១-ដំណើរការរៀបចំកិច្ចសម្ភាសន៍÷**

- ផ្នែកខ្លឹមសារ÷
  - កំណត់ប្រធានបទនៃកិច្ចសម្ភាសន៍
  - រៀបចំជាកម្រងសំណួរត្រៀម ស្របតាមរយៈពេលនៃកិច្ចសម្ភាសន៍
  - រៀបចំខ្លឹមសារជាជំនួយស្មារតី ស្របតាមសំណួរដែលបានត្រៀម
- ផ្នែកបច្ចេកទេស÷
  - កំណត់ស្ថាប័នព័ត៌មានដែលត្រូវមកសម្ភាសន៍ ឬអ្នកសម្ភាសន៍ (ពិធីករ ឬអ្នកសារព័ត៌មាន)
  - ទម្រង់នៃការសម្ភាសន៍ (ជាក្រុម ឬមួយទល់មួយ)
  - កំណត់កាលបរិច្ឆេទ ទីតាំង និងពេលវេលា
  - តាមដានការចាក់ផ្សាយ

**២-ដំណើរការរៀបចំសន្និសីទសារព័ត៌មាន÷**

- ផ្នែកខ្លឹមសារ÷
  - ត្រៀមសេចក្តីជូនដំណឹងដល់អ្នកសារព័ត៌មាន
  - ត្រៀមសេចក្តីប្រកាសព័ត៌មាន
  - រៀបចំជាកម្រង សំណួរត្រៀម និងចម្លើយជាជំនួយស្មារតីសម្រាប់ថ្នាក់ដឹកនាំ
- ផ្នែកបច្ចេកទេស÷
  - កំណត់ចំនួនស្ថាប័នព័ត៌មានដែលត្រូវអញ្ជើញ
  - រៀបចំទីតាំងសន្និសីទ (Backdrop, កន្លែងអង្គុយ ប្រព័ន្ធសំឡេង)
  - សម្របសម្រួលអំឡុងដំណើរការកម្មវិធី ( វគ្គសំនួរចម្លើយ)
  - តាមដានការចាក់ផ្សាយ និងប្រមូលទុកនូវឯកសារផ្សព្វផ្សាយនានា

### ខ. ការងារផលិតកម្មវីដេអូ

វីដេអូ គឺជាទម្រង់នៃព័ត៌មានផ្សព្វផ្សាយមួយដែលកំពុងមានប្រជាប្រិយភាព និងមានតម្រូវការលើទីផ្សារព័ត៌មានក្នុងបណ្តាញសង្គម។ វីដេអូ គឺជាកម្រងស្នាដៃសោតទស្សន៍ ដែលមានសមត្ថភាពបញ្ជូនសារបានខ្ពស់ ព្រោះមានរូបភាព និងសំលេងដែលមានអន្តរកម្មគ្នា។ មុនការមកដល់នៃអ៊ីនធឺណិត វីដេអូត្រូវបានផ្សាយតាមរលកធាតុអាកាស ទូរទស្សន៍ដែលមានវត្តមានលើពិភពលោកជិតមួយសតវត្សទៅហើយ។ ដូច្នេះមនុស្សនៅតែមានចំណាប់អារម្មណ៍ខ្ពស់លើវីដេអូ ទោះបីជាការពេញនិយមលើទូរទស្សន៍ចាប់ផ្តើមថយចុះក្តី។ ទោះបីជាត្រូវបានជំនួសវិញដោយ អ៊ីនធើណែត ក៏វីដេអូនៅតែឈរលំដាប់កំពូល។ វីដេអូមានច្រើនបែប ច្រើនសណ្ឋានដែលមានទៅតាមសាច់រឿងប្រឌិត ឬបទយកការណ៍ តួអង្គមនុស្សពិត ឬគំនូរជីវចល និងចិរវេលាជាដើម។

វត្តមាននៃបណ្តាញសង្គមបានចាប់មានឡើង នៅក្រោយពេលដែលប្រព័ន្ធសារគមនាគមន៍ថ្មីមួយបានបង្កើតឡើង នោះគឺអ៊ីនធើណែត។ ទោះជាយ៉ាងណាក្តី រយៈពេលជាច្រើនទសវត្សមកហើយ ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធ បណ្តាញអ៊ីនធើណែតនៅមានលក្ខណៈតូចចង្អៀត ដោយសារកត្តាតម្លៃ។ ក្រោយពេលដែលសេវាអ៊ីនធឺណិតចាប់ផ្តើមមានតម្លៃថោក ទន្ទឹមនឹងការមកដល់នៃទូរសព្ទវៃឆ្លាតផងនោះ ការប្រើប្រាស់អ៊ីនធឺណិតនិយាយជារួម និងការប្រើប្រាស់បណ្តាញសង្គមនិយាយដោយឡែក ចាប់ផ្តើមមានសំទុះកាន់តែខ្លាំងឡើង។ នៅកម្ពុជា បាតុភូតនេះ ក៏មិនសូវជាខុសគ្នាប៉ុន្មានដែរ ពីបណ្តាប្រទេសនានាក្នុងសកលលោក គឺបានទទួលឥទ្ធិពលនៃការហក់ឡើងនៃបណ្តាញសង្គម (The rise of social media)។

ដោយឡែកការងារផលិតកម្ម គឺជាដំណើរការនៃការបង្កើតខ្លឹមសារវីដេអូសម្រាប់ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។ ការងារផលិតកម្មមានទម្រង់ផ្សេងៗគ្នាជាច្រើន និងជាប្រភេទនៃការផ្សព្វផ្សាយដែលមានប្រសិទ្ធភាពខ្ពស់ក្នុងពេលបច្ចុប្បន្ន។ ដើម្បីឱ្យការងារផលិតកម្មមួយដែលមានជោគជ័យ យើងត្រូវសិក្សាអំពីទម្រង់ផ្សេងៗនៃផលិតកម្ម, ការងាររៀបចំផលិត និងបច្ចេកទេសផលិតកម្ម។

#### ១- ទម្រង់ខ្លះៗវីដេអូ

ក្នុងផ្នែកនេះ យើងនឹងសិក្សាលើនិយមន័យទូទៅនិងលក្ខណៈមួយចំនួននៃប្រភេទវីដេអូដែលមានបម្រើបម្រាស់នៅក្នុងការងារផ្សព្វផ្សាយ។ នៅលើបណ្តាញសង្គម ប្រភេទវីដេអូមួយចំនួនដែលកំពុងពេញនិយមក្នុងចំណោមអ្នកប្រើប្រាស់រួមមាន៖

- **វីដេអូHighlight**

  ជាទម្រង់វីដេអូខ្លី ដែលបង្ហាញពីទិដ្ឋភាពទូទៅនៃកម្មវិធីណាមួយ ឬបរិយាយពីប្រធានបទណាមួយ។ រយៈពេលចន្លោះ ១ ទៅ៥នាទី អាចមាន ឬគ្មានអ្នកបញ្ចូលសំលេង។ ជាទូទៅ វីដេអូ highlight អាចរំលេចរូបភាពពិសេសនៅក្នុងកម្មវិធី ឬព្រឹត្តិការណ៍ណាមួយ។ ធាតុសំខាន់នៃការធ្វើវីដេអូ highlight ក្រៅពីរូបភាពវីដេអូ ការកាត់ប្លង់ និងភ្លេង គឺជាធាតុសំខាន់មួយផងដែរ។

- Voxpop

ស្រដៀងនឹងកិច្ចសម្ភាសផងដែរ Voxpop ទម្រង់វីដេអូកិច្ចសម្ភាសខ្លី ដែលបរិយាយពីប្រធានបទមួយ ហើយបង្ហាញពីមតិយោបល់ និងការយល់ឃើញពីសាធារណជន។ រយៈពេលចន្លោះពី ១ ទៅ ៥នាទី។ កិច្ចសម្ភាសបានកាន់តែច្រើនកាន់តែល្អ។ Voxpop ប្រមូលផ្តុំអ្នកផ្តល់បទសម្ភាសពីកន្លែងតែមួយឬខុសៗគ្នា។ គេអាចប្រើ Voxpop ធ្វើជាវីដេអូសារអប់រំ និងលើកទឹកចិត្តផងដែរ។

- **វីដេអូឯកសារ**

ទម្រង់វីដេអូឯកសារមាន២ប្រភេទ ខ្លី និងវែង ប៉ុន្តែទម្រង់ផលិតកម្មស្រដៀងគ្នា ដោយមានអ្នកអធិប្បាយ រួមជាមួយកិច្ចសម្ភាស និងឯកសារជំនួយច្រើនអំពីប្រធានបទនៃវីដេអូ។ ឈានចូលមកដល់សតវត្សទី២១ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍កាន់តែមានភាពសំបូរបែប ជាពិសេសកាន់តែខិតជិតទៅដល់អ្នកប្រើប្រាស់ តម្រូវការទីផ្សារវីដេអូក៏កាន់តែមានភាពសំបូរបែប និងទំហំធំ។ ភាពយន្តឯកសារផ្សារភ្ជាប់ ទៅនឹងព្រឹត្តិការណ៍ណាមួយ ឬប្រធានបទសំខាន់ណាមួយដែលពាក់ព័ន្ធនឹងស្ថាប័ន។ ទន្ទឹមនឹងការផលិតវីដេអូ ភាពយន្តឯកសារត្រូវការឧបករណ៍ផ្សព្វផ្សាយជាច្រើនទៀតដូចជា÷ poster, trailers, teaser, បដា X-stand leaflet និងកម្មវិធីសម្ពោធផងដែរ។ ជាទូទៅការផលិតវីដេអូឯកសារដែលមានទំហំវែង ត្រូវការក្រុមការងារធំ ដែលមានរចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលមួយដោយឡែកក្នុងរយៈពេលនៃការផលិតនោះ។

**២-ការងារត្រៀមផលិត**

ការត្រៀមផលិត ទាមទារនូវការរៀបចំឯកសារ ការងារ និងសំភារៈមួយចំនួនមុននឹងថ្ងៃថតមកដល់។ ក្នុងន័យនេះក្រុមការងារត្រូវមានការត្រៀមលក្ខណៈទុកជាមុននូវធាតុចាំបាច់សម្រាប់ការថត ជាពិសេស គឺការធ្វើការតួអង្គ។ ក្នុងផលិតកម្ម ក្នុងបរិបទនៃការងារផ្សព្វផ្សាយរបស់ ស.ស.យ.ក. គឺយើងផ្តោតទៅលើការងារផលិតកម្មវីដេអូដែលមិនមែនជារឿងប្រឌិត (វីដេអូពាណិជ្ជកម្ម ឬវីដេអូអប់រំ) ឡើយ។

- **ខ្លឹមសារវីដេអូ ÷**

គឺជាសម្រាយអំពីអត្ថន័យ និងគោលបំណងនៃការផលិតវីដេអូ។ ខ្លឹមសារដើរតួនាទីជាការណែនាំសម្រាប់ការបង្កើតលំហូសាច់រឿង និងអត្ថបទអត្ថាធិប្បាយ។

- **លំហូរសាច់រឿង ÷**

គឺជាគ្រោងឆ្អឹងនៃសាច់រឿង ដែលរៀបរាប់ពីលំហូរនៃសាច់រឿង ចាប់ពីសេចក្តីផ្តើមតួសេចក្តី រហូតដល់សេចក្តីបញ្ចប់។ នៅក្នុងលំហូរសាច់រឿង ក៏នឹងបញ្ជាក់អំពីតួអង្គដែលត្រូវសម្ភាស និងរូបភាពដែលត្រូវប្រើប្រាស់ផងដែរ។

- **តួអង្គ ÷**
  ត្រៀមខ្លួនជាមុនសម្រាប់កិច្ចសម្ភាសជាមួយតួអង្គ ដោយរៀបចំនូវឯកសារសំខាន់ៗមួយចំនួន ដូចជា សង្ខេបខ្លឹមសារ កម្រងសំណួរ និងលិខិតស្នើសុំសម្ភាស (ក្នុងករណីចាំបាច់)។ ដើម្បីសម្រួលដល់ការថត ផលិតករគួរធ្វើការទំនាក់ទំនងទៅតួអង្គជាមុនដើម្បីផ្តល់នូវឯកសារ និងពន្យល់ពីគោលបំណងនៃកិច្ចសម្ភាស។
- **អ្នកបញ្ចូលសំលេង÷**
  ក្នុងករណីវីដេអូមានសំលេងអត្ថាធិប្បាយ គឺត្រូវការមានអ្នកបញ្ចូលសំលេង។ អ្នកបញ្ចូលសំលេងត្រូវអានអត្ថបទអត្ថាធិប្បាយទៅតាមសិល្បវិធី និងសាច់រឿង ពណ៌សំបុរនៃវីដេអូ។
- **ទីតាំង ÷**
  ទីតាំងនៃការថតអាចខុសគ្នាយោងទៅតាមទម្រង់វីដេអូ (ស្ទូឌីយ៉ូ / Outdoor) ប៉ុន្តែគួរជ្រើសរើសទីតាំង ណាដែលនឹងផ្តល់ភាពងាយស្រួលដល់ដំណើរការផលិតដូចជា ពុំមានសម្លេងរំខាន និងមានទីតាំងរៀបចំឧបករណ៍ថត។ ការជ្រើសរើសទីតាំងមានសារៈសំខាន់ណាស់ ព្រោះវាអាចនឹងផ្តល់អត្ថន័យបន្ថែម ទៅលើសាច់រឿង។
- **ក្រុមការងារថត ÷**
  មុននឹងចុះថត ត្រូវត្រៀមក្រុមការងារ ដែលទទួលបន្ទុកនូវតួនាទីផ្សេងៗគ្នា។ ចំនួនក្រុមការងារតូច ឬធំ តាមភាពជាក់ស្តែងនៃទម្រង់វីដអូ។ ជាទូទៅ ក្រុមការងារថតមានមនុស្សសំខាន់ៗដូចជា ផលិតករ, អ្នកដឹកនាំ, អ្នកថត, អ្នកកាន់សំលេង និងអ្នកសម្រួលការងាររដ្ឋបាល។
- **ហិរញ្ញវត្ថុ÷**
  ការត្រៀមសំភារៈសម្រាប់ការថត និងការចាត់ចែងនានាទាមទារឱ្យមានការចំណាយផងដែរ។ ដូច្នេះការផលិតវីដេអូនិមួយៗ ប្រៀបបានទៅនឹងគម្រោងតូចមួយដែលត្រូវមានគម្រោងចំណាយសម្រាប់ការថត និងក្រោយការថត។

**៣- បច្ចេកទេសផលិតកម្ម**

ក្របខ័ណ្ឌបច្ចេកទេសនៃការផលិតវីដេអូ មានភាពខុសប្លែកគ្នាអាស្រ័យទៅតាមប្រភេទឧបករណ៍ប្រើប្រាស់ដូចជា កាម៉េរា ម៉ៃក្រូហ្វូន ឬភ្លើង និងកម្មវិធីកុំព្យូទ័រជាដើម។ ទោះជាយ៉ាងណាក្តី ការកំណត់មួយចំនួនមានលក្ខណៈរួម ដែលត្រូវអនុវត្តតាមដើម្បីសម្រេចបានផលិតកម្មមួយ។ ភាពច្នៃប្រឌិតក៏ជាកត្តារួមផ្សំផងដែរនៅក្នុងការផ្តល់សោភ័ណភាព ឬភាពទាក់ទាញដល់ផលិតកម្មវីដេអូ ដែលទាមទារឱ្យមានការសិក្សាស្រាវជ្រាវ និងពិភាក្សា យ៉ាងល្អិតល្អន់ក្នុងគម្រោងផលិតកម្មនិមួយៗ។ ការងារបច្ចេកទេសដែលមិនគួរត្រូវបានមើលរំលង មាន÷

- **អំឡុងពេលថត ÷**
  - ជ្រើសរើសប្លង់ថត÷ ត្រូវកំណត់ជាមុនអំពីប្លង់នៃការផ្ដិតយករូបភាព និងទីតាំងតួអង្គ (ឆ្វេង ស្ដាំ ជិត ឆ្ងាយ ឈរ ឬអង្គុយ)។ គួរជ្រើសយកប្លង់ណាដែលមានពន្លឺធម្មជាតិល្អ និងពុំមានសម្លេងរំខាន។
  - រៀបចំឧបករណ៍ថត÷ឧបករណ៍ចាំបាច់សម្រាប់ការថតមានកាមេរ៉ា ប្រដាប់ស្រូបសំលេង និងពន្លឺជំនួយ។
  - ជំនួយការថតផ្សេងៗ÷ រួមមានអ្នកតុបតែងមុខ សក់ អ្នករៀបចំសំលៀកបំពាក់ អ្នកតុបតែងឆាក និងការផ្គត់ផ្គង់ផ្សេងៗ ដូចជា (អាហារ ភេសជ្ជៈ សង្គ្រោះបឋម ជាដើម)
- **ក្រោយការថត÷**
  - ការកាត់ត÷ បន្ទាប់ពីបានទូវីដេអូថត និងកិច្ចសម្ភាស ហើយអ្នកកាត់តត្រូវប្រមូលវីដេអូទាំងនោះមកពីការកាត់ត រៀបចំទៅតាមលំហូរសាច់រឿងដែលត្រៀមរួចជាស្រេច។
  - ភ្លេង÷ ភ្លេងដែលនឹងប្រើប្រាស់ក្នុងវីដេអូ មានសារៈសំខាន់ណាស់ ព្រោះវាផ្ដល់អត្ថន័យមួយកម្រិតទៅដល់សាច់រឿងទាំងមូល។ ដូច្នេះត្រូវជ្រើសរើសភ្លេងដោយយកចិត្តទុកដាក់ ជាពិសេសភ្លេងដែលពុំមែនជា copyright ដើម្បីងាយស្រួលក្នុងការយកផ្សព្វផ្សាយតាម Social Media។
  - ពិនិត្យឡើងវិញ÷ បន្ទាប់ពីការកាត់តរួច ក្រុមការងារទាំងមូលនឹងធ្វើការពិនិត្យ និងផ្ដល់យោបល់ដើម្បីកែសម្រួលវីដេអូ។ ការពិនិត្យនេះអាចធ្វើឡើងជាច្រើនដង រហូតធ្វើយ៉ាងណា ឈានដល់ការសម្រេចយល់ព្រមជាចុងក្រោយ។ ការពិនិត្យឡើងវិញ អនុញ្ញាតឱ្យមានការជំនួសវីដេអូខ្លះៗចេញ ដូច្នេះក្នុងអំឡុងការថត ការថតច្រើនប្លង់គឺជាជំនួយក្នុងការងារពិនិត្យឡើងវិញនេះ ដើម្បីអាចចៀសវាងការថតឡើងវិញដែលនាំឱ្យប៉ះពាល់ដល់កាលវេលានៃការថត។
  - បញ្ចប់÷ ពេលដែលវីដេអូបានបញ្ចប់ និងសម្រេចជាចុងក្រោយហើយ ក្រុមការងារដែលទទួលបន្ទុកក្នុងការផ្សព្វផ្សាយនឹងទទួលយកវីដេអូ ធ្វើការចែករំលែក ផ្សព្វផ្សាយ តាមផែនការណ៍ដែលបានត្រៀមទុក។

### ៤-ប្រភពឯកសារ និងប័ណ្ណសារ

ក្នុងការផលិតវីដេអូមួយ ការប្រើប្រាស់រូបភាពអតីតកាល ឬរូបភាពសាធារណៈមួយចំនួនដែលមិនអាចធ្វើការថតបានឡើងវិញ ឬដែលការចំណាយធនធាន និងពេលវេលាមានទំហំធំខ្លាំងសម្រាប់ការថតថ្មី ការស្វែងរកធនធានដែលមានស្រាប់គឺជាជម្រើសមួយដែលមិនអាចខ្វះបាន ក្នុងការផលិតវីដេអូនានា។

នៅក្នុងប្រទេសកម្ពុជា មានមជ្ឈមណ្ឌលធនធានសោតទស្សន៍មួយចំនួនដែលដើរតួនាទីជាឃ្លាំងទុកឯកសារប្រវត្តិសាស្ត្រមានតម្លៃ ដ៏កម្រមួយចំនួន។ មជ្ឈមណ្ឌលផ្ទុកទិន្នន័យអាចអនុញ្ញាតឱ្យក្រុមការងារផលិតកម្មស្វែងរកតាមឆ្នាំព្រឹត្តិការណ៍ ទីតាំង ឬប្រភេទសកម្មភាព។ ជាទូទៅ មជ្ឈមណ្ឌលធនធានមិនមែនជាកម្មសិទ្ធករផ្ទាល់

នៃស្នាដៃទាំងអស់នោះទេ ដូច្នេះក្រុមការងារត្រូវធ្វើការស្នើសុំទៅម្ចាស់ស្នាដៃ ឬសិទ្ធិវ័ន្តដើម្បីទទួលបានអាជ្ញាប័ណ្ណប្រើប្រាស់រូបភាពនោះ។ ការទទួលបានអាជ្ញាប័ណ្ណអាចត្រូវបានតម្រូវឱ្យមានការបង់ប្រាក់តាមប្រភេទ និងទំហំនៃការប្រើប្រាស់ស្នាដៃនោះ។

ចំពោះប្រភពបរទេស (Stock footage) មានមជ្ឈមណ្ឌលធនធានជាច្រើន។ ប្រភពទាំងនោះរួមបញ្ចូលទាំងរូបភាពចាស់ៗ រូបភាពបច្ចុប្បន្នដែលមានជម្រើសសំបូរបែបផងដែរ។ ប្រភពមួយចំនួនអាចតម្រូវឱ្យប្រតិបត្តិការបង់ថ្លៃអាជ្ញាប័ណ្ណទៅតាមប្រភេទនៃការប្រើប្រាស់ ដែលមាននីតិវិធីមិនសាំញ៉ាំ គ្រាន់តែតម្រូវឱ្យមានវិធីសាស្ត្របង់ប្រាក់តាមអ៊ីនធើណែត (debit/credit card, online payment)។

ប្រភពដែលបានពីបណ្តាញសង្គម ថ្វីបើជាខ្លឹមសារបង្កើតដោយសាធារណជនទូទៅ ឬដែលមិនមានគោលដៅពាណិជ្ជកម្ម ក៏ទាមទារឱ្យមានការទទួលបានការអនុញ្ញាតជាក់លាក់មួយពីម្ចាស់ស្នាដៃផងដែរ។ ក្នុងន័យនេះ ការទាក់ទងទៅម្ចាស់ស្នាដៃដោយផ្ទាល់។ ដោយឡែក បណ្តាញសង្គមធំៗដូចជា facebook ឬ YouTube អាចចាប់បានគ្រប់ពេលបណ្តាស្នាដៃណាមួយត្រូវបានរកឃើញថាទទួលបានដោយគ្មានការអនុញ្ញាត ឬម្ចាស់ស្នាដៃដើមដាក់ពាក្យប្តឹង។ ដូច្នេះទោះជាក្រោយពេលទទួលបានអាជ្ញាប័ណ្ណពីម្ចាស់ស្នាដៃក្តី ការបង្ហោះវីដេអូលើអ៊ីនធើនែតតម្រូវឱ្យមានការបំពេញលក្ខខ័ណ្ឌមួយចំនួនដើម្បីការពារពីការចាប់។

## ៥. ជំពូកទី៥÷ វាស់វែងតម្លៃឥទ្ធិពលនៃសារ

### ក. ការវិភាគលើភាពខ្លាំង និងភាពខ្សោយដោយផ្អែកលើអន្តរកម្ម

ឥទ្ធិពលសារ អាចត្រូវបានវាយតម្លៃតាមរយៈប្រតិកម្មរបស់អ្នកទទួលសារ។ ប្រតិកម្មចេញជាច្រើនទម្រង់ តាមបែបចេញជាមតិតបនៅតាមប្រព័ន្ធផ្សព្វផ្សាយ ឬចេញជាសកម្មភាពសង្គមនានា តាម ឬមិនតាមបំណងសារ ដែលបានដាក់ចេញ។ ជាទូទៅ ឥទ្ធិពលសារអាចស្តែងចេញតាមរយៈការបញ្ចេញមតិ ការចែករំលែកសារ ការចូលចិត្ត ឬមិនចូលចិត្ត ឬការអនុវត្តតាមខ្លឹមសារ ដែលបញ្ចេញ។

### ខ. ឥទ្ធិពលសារដោយផ្អែកលើអនុលោមភាពនៃទស្សនិកជន

- ឥទ្ធិពលខ្លី ដែលបង្ហាញតាមរយៈការចូលមើល មានមតិ ឬធ្វើសកម្មភាព ហើយចប់។
- ឥទ្ធិពលមធ្យម ជាការកសាងនូវនិន្នាការ (momentum) ដើម្បីឈានឆ្ពោះទៅការទាមទារអ្វីមួយ ឬការឆ្លើយតបចាំបាច់ណាមួយ (ភាពច្រើនជាសារដែលបង្ហាញពីអំពើអសកម្មណាមួយក្នុងសង្គម អំពើពុករលួយ ឬហេតុការណ៍សង្គមសំខាន់ៗ) និង
- ឥទ្ធិពលសារ ដែលមានលក្ខណៈយូរអង្វែង ដែលមានជាអាទិ៍ សារដែលទាក់ទងនឹងរឿងវប្បធម៌ បូរណភាពទឹកដី ឬការប្រកាន់ជាតិសាសន៍។ល។

## ៦. ជំពូកទី៦÷ ការរាយបក

ការរៀបចំសារឆ្លើយតប (រាយបក) ណាមួយ ត្រូវផ្អែកលើកត្តាសត្យានុម័តមួយចំនួន ដូចជា÷

- យល់អង្គហេតុឲ្យបានច្បាស់
- យល់ស្ថានការណ៍សារ ដែលកំពុងត្រូវបានចែករំលែក
- ស្គាល់ពីតួអង្គពាក់ព័ន្ធ
- វិសាលភាពនៃសារ (ភាពពាក់ព័ន្ធ)
- យល់ពីពេលវេលា

# មេរៀនទី៤
# ឯកសារជំនួយស្មារតី ស្តីពី
# យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និង
# សមិទ្ធផលរបស់រាជរដ្ឋាភិបាល

រៀបរៀងដោយៈ **ឯកឧត្តម ឈាង វណ្ណារិទ្ធ**

# មេរៀនទី៤
# ឯកសារជំនួយស្មារតី ស្តីពីយុទ្ធសាស្ត្របញ្ចកោណ
# ដំណាក់កាលទី១ និងសមិទ្ធផលរបស់រាជរដ្ឋាភិបាល

## I. សេចក្តីផ្តើម

គណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យ និងភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា បានផ្តល់អនុសាសន៍ និងមគ្គុទ្ទេសក៍តម្រង់ទិសដល់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល ដើម្បីពង្រឹងបន្ថែមសមត្ថភាពមន្ត្រីបក្ស និងប្រសិទ្ធភាពការងារចលនាមហាជន ឱ្យឆ្លើយតបនឹងសំណូមពរ និងតម្រូវការជាក់ស្តែងរបស់ប្រជាជន។ ជាមួយគ្នានេះ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ប្រធានគណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល** ក៏បានណែនាំជាបន្តបន្ទាប់ និងផ្តល់ការអនុញ្ញាតដល់អគ្គលេខាធិការដ្ឋាននៃគណៈចលនាមហាជនគណៈកម្មាធិការកណ្តាល រៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "**គ្រូបង្គោលលើការងារមហាជន**" សម្រាប់រាជធានី- ខេត្ត។

គ្រូបង្គោលលើការងារមហាជនបានសម្រិតសម្រាំងលើប្រធានបទ សម្រាប់ការបណ្តុះបណ្តាលនេះ ដែលរួមមាន **១).**វិធីសាស្ត្របណ្តុះបណ្តាលបន្តស្តីពីការងារមហាជន **២).**តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគណៈចលនាមហាជន **៣).**វិធីសាស្ត្រគោលក្នុងការប្រឈម និងគ្រប់គ្រងសមរភូមិសតិអារម្មណ៍ **៤).**ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និងវិធីសាស្ត្រផ្សព្វផ្សាយ និង**៥).**សេចក្តីសង្ខេប និងខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងសមិទ្ធផលសម្រេចបានក្នុងរយៈពេល ១ ឆ្នាំរបស់រាជរដ្ឋាភិបាល។

ដើម្បីធានាប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលគ្រូបង្គោលលើការងារមហាជន លើប្រធានបទខាងលើនេះ គ្រូឧទ្ទេសបានរៀបចំជំនួយស្មារតីតាមប្រធានបទនីមួយៗ។ ក្នុងន័យនេះ ឯកសារជំនួយស្មារតី ស្តីពី "**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងសមិទ្ធផលដែលសម្រេចបានរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំគណបក្សប្រជាជនកម្ពុជា**" ត្រូវរៀបចំឡើងក្នុងគោលបំណងពន្យល់បន្ថែមអំពីវិធីសាស្ត្រក្នុងការចែករំលែក លើប្រធានបទទី៥ ស្តីពីយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងសមិទ្ធផលដែលសម្រេចបាន ១ឆ្នាំរបស់រាជរដ្ឋាភិបាល ដើម្បីឱ្យគ្រូបង្គោលលើការងារមហាជនប្រើប្រាស់ជាជំនួយស្មារតីក្នុងការចែករំលែកបន្តជូនសមាជិកសមាជិការបស់គណបក្សប្រជាជនកម្ពុជា ប្រជាពលរដ្ឋទូទៅ ឬមជ្ឈដ្ឋានណាមួយគោលដៅណាមួយ។

ឯកសារជំនួយស្មារតីនេះ បែងចែកជា ៥ ផ្នែក រួមមាន÷ **ផ្នែកទី១** សេចក្តីផ្តើម, **ផ្នែកទី២** អំពីយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, **ផ្នែកទី៣** សមិទ្ធផលរបស់រាជរដ្ឋាភិបាល, **ផ្នែកទី៤** ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ **និង ផ្នែកទី៥** សេចក្តីសន្និដ្ឋាន។

**១. លទ្ធផលរំពឹងទុក**

បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ គ្រូបង្គោលនឹងទទួលបានការយល់ដឹងលើចំណុចសំខាន់ៗ ដូចខាងក្រោម÷

- ដំណើរការនៃការរៀបចំយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។
- ខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។
- ការចូលរួមរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្ត យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។
- សមិទ្ធផល និងបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកន្លងមក។
- យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។
- ទិសដៅការងាររបស់គណបក្សប្រជាជនកម្ពុជា។

**២. រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានបែងចែកជា ២ (ពីរ) ផ្នែក រួមមាន÷

- **<u>ផ្នែកទី១ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១</u>** នឹងពិភាក្សាអំពី÷
  - ដំណើរការនៃការរៀបចំយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។
  - ខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។
  - ការផ្សារភ្ជាប់យុទ្ធសាស្ត្រនានា។
  - តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់-កាលទី១។
- **<u>ផ្នែកទី២ សមិទ្ធផលរបស់រាជរដ្ឋាភិបាល</u>** ផ្តោតសំខាន់អំពី÷
  - វឌ្ឍនភាពការងារសំខាន់ៗតាមវិស័យ។
  - បញ្ហាប្រឈមគន្លឹះ។
  - ទិសដៅការងារ។
- **<u>ផ្នែកទី៣ ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១</u>** បង្ហាញអំពី÷
  - គោលបំណង អភិក្រម និងគោលការណ៍។
  - យន្តការតាមដាន ត្រួតពិនិត្យយន្តការវាយតម្លៃ។
  - ការរាយការណ៍ និងការប្រើប្រាស់លទ្ធផល។
  - តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់-កាល ទី១។

## II. **អំពីយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១**

ផ្នែកនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីស្វែងយល់អំពីមូលដ្ឋានគ្រឹះ និងសារតារនៃការរៀបចំយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលនឹងផ្តល់ដល់គ្រូបង្គោលស្វែងយល់អំពី គោលគំនិតសំខាន់ៗ ក្នុងការការរៀបចំយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ នីតិវិធីនៃការរៀបចំយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ទិដ្ឋភាពរួមនៃការរៀបចំយុទ្ធសាស្រ្តនេះ គោលដៅជាយុទ្ធសាស្រ្ត ស្នូល បរិស្ថានគ្របដណ្តប់ និងបញ្ចកោណទាំង៥ នៃយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១។

### ១. **ដំណើរការនៃការរៀបចំយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១**

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដែលទទួលបានការគាំទ្រពីប្រជាជនតាមរយៈការបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាឱ្យឈ្នះភ្លូកទឹកភ្លូកដី កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ បានរៀបចំនិងដាក់ឱ្យអនុវត្ត**យុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១**។ ឯកសារយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១នេះ ត្រូវបានរៀបចំដោយផ្អែកលើ**ឯកសារកម្មវិធីគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ២០២៣-២០២៨**។

ឯកសារកម្មវិធីគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ ២០២៣-២០២៨ មានគោលដៅយុទ្ធសាស្រ្តរបស់គណបក្ស រួមមាន **១).** ការការពារសន្តិភាព ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងការពាររាល់សមិទ្ធផលនៃសង្គមជាតិឱ្យបានគង់វង្សស្ថិតស្ថេរ **២).** កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរីពហុបក្សដ៏ជឿនលឿន និងរឹងមាំដែលផ្អែកលើច្បាប់ មានសេដ្ឋកិច្ចរីកចម្រើនប្រកបដោយចីរភាព និងសមធម៌ ប្រជាជនមានជីវភាពសម្បូរសប្បាយ បានរស់នៅយ៉ាងសុខដុមរមនាប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ និងមានការគោរពសិទ្ធិមនុស្ស **៣).** កសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលធានាការផ្តល់ការគាំពារដល់ប្រជាជន ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច ហានិភ័យសុខភាពសាធារណៈ និងភាពងាយរងគ្រោះផ្សេងៗ ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌនៃការងារ និងការរស់នៅ **៤).** ជំរុញការអនុវត្ត "កម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥" និងកាត់បន្ថយគ្រាប់មិនទាន់ផ្ទុះឱ្យបានជាអតិបរមា និង **៥).** បន្តអនុវត្តនយោបាយការបរទេសឯករាជ្យដោយផ្អែកលើច្បាប់ កសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសទាំងអស់លើសាកលលោក និងអង្គការ អន្តរជាតិនានា ហើយចូលរួមយ៉ាងសកម្ម ចំពោះបុព្វហេតុសន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់ និងពិភពលោក។

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្រ្តទាំងលើនេះ គណបក្សប្រជាជនកម្ពុជា បានដាក់ចេញនូវគោលនយោបាយធំៗជាអាទិភាព រួមមាន÷ **ទី១-នយោបាយក្នុងប្រទេស** រួមមាន (ក)-ការការពារសន្តិភាព ស្ថិរភាពនយោបាយ និងរាល់សមិទ្ធផលសង្គមជាតិឱ្យរឹងមាំស្ថិតស្ថេរគង់វង្ស (ខ)-ការលើកកម្ពស់ជីវភាពរបស់ប្រជាជនគ្រប់រូបទាំងខាងសម្ភារៈនិងស្មារតីឱ្យបានសមរម្យប្រកបដោយភាពថ្លៃថ្នូរ (គ)-ការការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពរបស់ប្រជាជន និងពង្រឹងនីតិរដ្ឋ (ឃ)-ការពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់

ជារដ្ឋបាលរបស់ប្រជាជននិងបម្រើផលប្រយោជន៍របស់ប្រជាជន (ង)-ការបន្តជំរុញការកែទម្រង់ដើម្បីអភិបាលកិច្ចល្អ (ច)-ការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យមានការរីកចម្រើនប្រកបដោយចីរភាព សមធម៌ និងបរិយាបន្ន និង (ឆ)-ការការពារជាតិ ការពារសន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាពសង្គម និង **ទី២-នយោបាយការបរទេស។**

បន្ទាប់ពីទទួលបានទិសដៅគោលនយោបាយ ពីឯកសារកម្មវិធីគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ២០២៣-២០២៨ **ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ដែលជាស្ថាប័នក្នុងការតាក់តែងយុទ្ធសាស្ត្រសំខាន់ៗរបស់រាជរដ្ឋាភិបាល បានចាប់ផ្ដើមក្នុងការរៀបចំសេចក្ដីព្រាងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដោយមានមានដំណាក់កាល ដូចខាងក្រោម÷




## ២. យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

ការរៀបចំយុទ្ធសាស្ត្របញ្ចកោណ ត្រូវបានរៀបចំឡើងដោយសម្លឹងទៅមុខ ២៥ឆ្នាំ សំដៅឆ្ពោះទៅសម្រេច "**ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០**" ដោយផ្អែកលើសមិទ្ធផលសម្រេចបានក្នុងរយៈពេល ២៥ឆ្នាំកន្លងទៅ ដែលជាមូលដ្ឋានមួយរឹងមាំសម្រាប់ការអភិវឌ្ឍបន្ត។ ក្នុងន័យនេះ ២៥ឆ្នាំទៅមុខ រាជរដ្ឋាភិបាលតាមរយៈយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ មានចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមាន÷

**១-ទិដ្ឋភាពនយោបាយ÷** មានសង្គមជាតិមួយដ៏រស់រវើក ដែលមាន សុខសន្តិភាព, ស្ថិរភាពនយោបាយ, និង នីតិរដ្ឋ។

**២-ទិដ្ឋភាពសេដ្ឋកិច្ច÷** ប្រទេសមានចំណូលខ្ពស់ និងមានសេដ្ឋកិច្ចធន់រឹងមាំ។

**៣-ទិដ្ឋភាពមនុស្ស÷** ប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ ប្រកបដោយសីលធម៌ និងជំនាញមួយយ៉ាងតិច។

**៤-ទិដ្ឋភាពសង្គម÷** ប្រជាជនរស់នៅក្នុងសេចក្ដីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គមស្មើសិទ្ធិនិងឱកាស។

៥. **ទិដ្ឋភាពបរិស្ថានរូបវ័ន្ត និងធម្មជាតិ:** គឺជាប្រទេសមួយ ដែលមានតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិ ព្រមទាំងភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។

យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ មាន÷ បាវចនាចំនួន ៥ ពោលគឺ **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** អាទិភាពគន្លឹះចំនួន ៥ គឺ**មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា** និងមានគោលដៅចម្បង ក្នុងរយៈពេលវែង គឺ÷ **១).** រក្សាចលនាការនៃសុខសន្តិភាព កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម និង **២).** កសាងភាពធន់ នៃវិស័យទាំង ៥÷ វិស័យសាធារណៈ វិស័យសេដ្ឋកិច្ច វិស័យធនធានមនុស្ស និងសង្គម វិស័យហិរញ្ញវត្ថុ និងវិស័យបរិស្ថាន និងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ យុទ្ធសាស្ត្រនេះ ក៏បានកំណត់នូវគោលដៅយុទ្ធសាស្ត្រ ចំនួន៥÷

**ទី១. ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយភាពធន់។**

**ទី២. បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណភាព, ជាពិសេស សម្រាប់យុវជន។**

**ទី៣. សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រក្នុងអត្រាក្រោម ១០% និងទាញទម្លាក់ឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា។**

**ទី៤. បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័ន។**

**ទី៥. ធានាចីរភាព នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។**

ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រទាំង ៥នោះ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១នេះ បានកំណត់ នូវរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដោយបានបែងចែកជា ផ្នែកស្នូលនៃយុទ្ធសាស្ត្រ បរិស្ថានគ្របដណ្តប់ និងបញ្ចកោណយុទ្ធសាស្ត្រទាំង ៥ ដែលផ្នែកនីមួយៗ សុទ្ធតែមានមុំចំនួន៥។ ទន្ទឹមនេះ ដើម្បីសម្រេចឱ្យបានគោលដៅជាយុទ្ធសាស្ត្រនៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវកម្មវិធីអាទិភាពចំនួន៦ រួមមាន÷ ១). ការលើកកម្ពស់គុណភាព និងបង្កើនវិសាលភាពក្នុងការផ្តល់ការថែទាំសុខភាពតាមរយៈ ការដាក់ចេញ និងអនុវត្តនូវ **ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥** ២). ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ជូនដល់យុវជនមកពីក្រុមគ្រួសារក្រីក្រ និងក្រុមគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ៣). ការធ្វើស្ថាប័នីយកម្មកម្មវិធីជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ចនិងគ្រាមានគ្រោះអាសន្ន ៤). ការដាក់ចេញ និងការជំរុញអនុវត្ត **យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨** ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ ៥). ការដាក់ចេញនូវយន្តការសម្របសម្រួលនិងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ និង៦). ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ- សង្កាត់ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវ វិធានការគន្លឹះចំនួន៥ ដែលទាក់ទងនឹង ១). ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ២). ការលើកកម្ពស់គុណភាពអប់រំ ៣). ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ៤). ការពង្រឹងការអនុវត្ត គោលនយោបាយភូមិ- ឃុំ- សង្កាត់ មានសុវត្ថិភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងប្រើប្រាស់គ្រឿងញៀន និង ៥). ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

ដើម្បីធានាឱ្យការអនុវត្តយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យ រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការចំនួនបី គឺ÷ ១). យន្តការដឹកនាំសម្របសម្រួល ២). យន្តការអនុវត្ត និង៣). យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

**ទី១.** យន្តការដឹកនាំសម្របសម្រួល មាន ១).**រាជរដ្ឋាភិបាល** ដឹកនាំការអនុវត្តយុទ្ធសាស្ត្រជារួម ដោយផ្តោតលើការតម្រង់ទិសការកែសម្រួលវិធានការគោលនយោបាយនានា និងការដាក់ចេញនូវវិធានការគោលនយោបាយថ្មីៗតាមការចាំបាច់ ២).គណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ បញ្ចកោណ ដំណាក់កាលទី១ (**គ.យ.ប.**) គឺជាសេនាធិការសម្រាប់ដឹកនាំសម្របសម្រួលរួមលើការជំរុញការអនុវត្តកិច្ចការពាក់ព័ន្ធនឹងយុទ្ធសាស្ត្របញ្ចកោណរបស់ក្រុមប្រឹក្សា គណៈកម្មាធិការក្រសួង-ស្ថាប័ន និង៣).**ក្រសួងផែនការ** ដឹកនាំសម្របសម្រួលកម្រិតបច្ចេកទេសក្នុងការរៀបចំផែនការសកម្មភាព និង សូចនាករសមិទ្ធកម្មគន្លឹះរបស់ក្រសួង-ស្ថាប័ន ព្រមទាំងផ្ទួផ្គង និងតម្រឹមការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ និងផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍតាមវិស័យ។ល។

**ទី២.** យន្តការអនុវត្ត មាន ១).**ក្រសួង-ស្ថាប័ន** ជាតួអង្គស្នូលត្រូវបុរេសកម្ម សកម្ម និងមានកិច្ចសហការជិតស្និទ្ធ ជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការ ការអនុវត្ត ការបូកសរុបវឌ្ឍនភាព និងការវាយតម្លៃ ព្រមទាំងប្រកាន់ខ្ជាប់អភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់" ២). **ក្រុមប្រឹក្សា និងគណៈកម្មាធិការ** ដែលមានសមត្ថកិច្ចពាក់ព័ន្ធទទួលបន្ទុកសម្របសម្រួលលើការជំរុញការអនុវត្តការងារអាទិភាព ដែលមានចរិតអន្តរក្រសួង-ស្ថាប័ន ឬអន្តរវិស័យ និង ៣).**រដ្ឋបាលថ្នាក់ក្រោមជាតិ** ត្រូវចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ព្រមទាំងចូលរួមផ្តល់ធាតុចូលលើការបូកសរុបវឌ្ឍនភាពនិងការវាយតម្លៃ។ល។ និង

**ទី៣.** យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មាន **១).** គណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ **(គ.យ.ប.)** ដឹកនាំរៀបចំ **ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលផ្អែកលើភស្តុតាង (Evidence-based M&E Framework)** រួមទាំងសូចនាករ សមិទ្ធកម្មគន្លឹះ និងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ព្រមទាំងផ្តល់អនុសាសន៍តម្រង់ទិសកែសម្រួលគោលនយោបាយ, យុទ្ធសាស្ត្រតាមវិស័យ និងយន្តការអនុវត្ត។ល។ និង ២). **ក្រសួង-ស្ថាប័នទាំងអស់** ត្រូវរៀបចំផែនការ និងគោលការណ៍សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាព ក្នុងការអនុវត្តយុទ្ធសាស្ត្រ។

## ៣. ការផ្សារភ្ជាប់យុទ្ធសាស្ត្រនានា

ជាការគិតគូរនិងរៀបចំបច្ចុប្បន្ន ក្របខ័ណ្ឌលទ្ធផលនៃកម្រិតយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ត្រូវបានបន្ស៊ីជាមួយនឹងកម្រិតនៃលទ្ធផលផ្សេងៗ ចាប់ពីកម្រិត**ធាតុចូល សកម្មភាព/កម្មវិធី ធាតុចេញ លទ្ធផល និងកម្មវិបាក** ជាមួយនឹងឋានានុក្រមនៃយុទ្ធសាស្ត្រ ចាប់ពីផែនការយុទ្ធសាស្ត្រថវិកា ផែនការអភិវឌ្ឍន៍តាមវិស័យ ឬក្រសួង-ស្ថាប័ន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្របញ្ចកោណ។ ជាក់ស្តែង ការកំណត់ឋានានុក្រមនៃយុទ្ធសាស្ត្រត្រូវ

បានកំណត់ជា ៤កម្រិត ដែលក្នុងនោះមាន **កម្រិតទី១** គឺយុទ្ធសាស្ត្របញ្ចកោណ ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរយៈពេលវែង ឬ យុទ្ធសាស្ត្រគ្របដណ្តប់រួម (Overarching Strategy) កំណត់របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយមួយ ដើម្បីកសាងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍឱ្យកាន់តែរឹងមាំ សម្រាប់ការបន្តដំណើរឈានទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០, **កម្រិតទី២** គឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលត្រូវរៀបចំឱ្យមានសង្គតិភាព និងមានភាពប្រទាក់ក្រឡាគ្នាទៅនឹងយុទ្ធសាស្ត្របញ្ចកោណ តាមរបៀបវារៈ និងទិសដៅគោលនយោបាយសង្គម-សេដ្ឋកិច្ចដែលបានកំណត់ ព្រមទាំងផ្តល់ជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល **កម្រិតទី៣** គឺផែនការអភិវឌ្ឍន៍តាមវិស័យ ឬក្រសួង ស្ថាប័ន ដែលក្រសួង ស្ថាប័នត្រូវរៀបចំ និងសម្រេចឱ្យបាននូវសកម្មភាពតាមវិស័យរបស់ខ្លួន ស្របតាមការចង្អុលបង្ហាញនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង **កម្រិតទី៤** គឺផែនការយុទ្ធសាស្ត្រថវិកា ដែលតម្រូវឱ្យក្រសួង ស្ថាប័ន រៀបចំផែនការថវិកា ដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាព នៃផែនការអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួន។ ឈរលើមូលដ្ឋានឋានានុក្រមនេះ ការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ÷

១). យុទ្ធសាស្ត្របញ្ចកោណ នឹងផ្តោតសំខាន់លើកម្រិត កម្មវិបាក (Impacts) និង លទ្ធផល (Outcomes)
២). ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នឹងផ្តោតសំខាន់លើកម្រិត លទ្ធផល និង ធាតុចេញ (Outputs) និង
៣). ផែនការអភិវឌ្ឍន៍តាមវិស័យ និងផែនការយុទ្ធសាស្ត្រថវិកា នឹងផ្តោតសំខាន់លើកម្រិតធាតុចេញ សកម្មភាព / កម្មវិធី (Activities/ Programmes) និង ធាតុចូល (Inputs)។

### រូបភាពទី១- ការផ្សារភ្ជាប់ឋានានុក្រមយុទ្ធសាស្ត្រទៅនឹងច្រវាក់លទ្ធផល




ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រតាមវិស័យ ឬក្រសួង-ស្ថាប័ន និងផែនការយុទ្ធសាស្ត្រថវិកា ព្រមទាំងគោលនយោបាយនានា <u>ត្រូវមានភាពប្រទាក់ក្រឡានិងបំពេញគ្នាទៅវិញទៅមក</u> ដើម្បីធានាការសម្រេចបាននូវលទ្ធផលរំពឹងទុក (ដូចក្នុងរូបភាពទី២)។

នៅក្នុងរូបភាពទី២ខាងក្រោមនេះ ផ្តល់នូវទិដ្ឋភាពសំខាន់២÷ ទី១. យន្តការនៃការធ្វើសមាហរណកម្មនៃការរៀបចំ និងការអនុវត្តគោលនយោបាយ និងផែនការអភិវឌ្ឍន៍ទាំងបីកម្រិត និងទី២.ការរៀបចំក្របខ័ណ្ឌ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវមានបីកម្រិតផ្សេងៗគ្នា ពោលគឺ (១) ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ សម្រាប់ក្របខ័ណ្ឌលទ្ធផលកម្រិតយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ (២) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ក្របខ័ណ្ឌលទ្ធផលកម្រិតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង(៣) ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ក្របខ័ណ្ឌលទ្ធផលកម្រិតផែនការយុទ្ធសាស្ត្រ តាមវិស័យ ឬក្រសួង-ស្ថាប័ន។ **ក្នុងន័យនេះ ទាំងយន្តការនៃការរៀបចំ និងការអនុវត្ត និងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គោលនយោបាយ និងផែនការអភិវឌ្ឍន៍ នៅគ្រប់កម្រិត ត្រូវមានភាពប្រទាក់ក្រឡានិងសង្គតិភាពទៅវិញទៅមក។**

**រូបភាពទី២- ក្របខ័ណ្ឌសមាហរណកម្មនៃការរៀបចំផែនការនិងការអនុវត្តយុទ្ធសាស្ត្រ**




## ការរៀបចំផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត និងផែនការយុទ្ធសាស្ត្រថវិកា

ដើម្បីធានាសម្រេចចក្ខុវិស័យខាងលើ ការរៀបចំ ១).ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និង ២).ផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលរាជធានី-ខេត្ត គឺជាកិច្ចការចាំបាច់និងសំខាន់បំផុត ដែលការរៀបចំផែនការ

អភិវឌ្ឍន៍ត្រូវអនុលោមតាម**សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត ឆ្នាំ២០១៧** និងការរៀបចំផែនការយុទ្ធសាស្ត្ររបស់ខេត្តត្រូវអនុលោមតាម **គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឆ្នាំ២០២០**។

## ក-ការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត

ក្រុមការងារកសាងផែនការខេត្តត្រូវពិនិត្យក្របខ័ណ្ឌច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយ សំដៅធានានូវការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្របញ្ចកោណ និងដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត ព្រមទាំងត្រូវធ្វើការគណនាប៉ាន់ស្មានអំពីតម្រូវការថវិកាចំណាយផងដែរ។ ក្រុមការងារកសាងផែនការរាជធានី ខេត្ត ត្រូវបានបែងចែកជាក្រុមតូចក្នុងការវិភាគតាមវិស័យ, កំណត់អាទិភាព និងរៀបចំ ១).កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលខេត្ត និង ២).កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់មន្ទីរ អង្គភាព (កម្មវិធីអភិវឌ្ឍន៍មាន ក្របខ័ណ្ឌវិនិយោគរបស់រដ្ឋបាលខេត្ត, ក្របខ័ណ្ឌវិនិយោគរបស់មន្ទីរ អង្គភាព, ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលខេត្ត, ក្របខ័ណ្ឌផ្តល់សេវារដ្ឋបាលរបស់មន្ទីរ អង្គភាព និងផែនការរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលខេត្ត)។

ជាមួយគ្នានេះ ក្រុមការងារកសាងផែនការខេត្ត ក៏ត្រូវរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃ ដែលក្នុងនោះមានក្របខ័ណ្ឌពេលវេលា ការកំណត់សូចនាករ ការកំណត់អ្នកទទួលខុសត្រូវតាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត ការកំណត់វិធីសាស្ត្រតាមដាន និងវាយតម្លៃ ការកំណត់អ្នកចូលរួមដែលតារាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃមាន ១).ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ខេត្ត ២).ក្របខ័ណ្ឌតាមដាននិងវាយតម្លៃការអនុវត្តក្របខ័ណ្ឌវិនិយោគរយៈពេល៥ឆ្នាំ ៣).ក្របខ័ណ្ឌតាមដាននិងវាយតម្លៃការអនុវត្តក្របខ័ណ្ឌផ្តល់សេវារដ្ឋបាល និងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការដាក់ចេញលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលខេត្ត។ ទន្ទឹមនេះ ក្រុមប្រឹក្សាខេត្ត ត្រូវវាយតម្លៃនៅពាក់កណ្តាលអាណត្តិដោយមានក្រុមការងារកសាងផែនការខេត្តជាសេនាធិការ ដែលរដ្ឋបាលខេត្តត្រូវប្រមូលទិន្នន័យ ដោយសហការជាមួយតំណាងមន្ទីរ អង្គភាព និងទីចាត់ការនានា ដែលក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិ ត្រូវមានវឌ្ឍនភាពការងារអនុវត្តកន្លងមក ទិសដៅការងារសម្រាប់អនុវត្តបន្ត និងសេចក្តីសន្និដ្ឋាន។

## ខ- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្ត

ផែនការយុទ្ធសាស្ត្រថវិកាខេត្ត គឺជាផែនការយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំរំកិល ដោយផ្សារភ្ជាប់អាទិភាពគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងគោលដៅតាមវិស័យ និងផែនការអភិវឌ្ឍន៍ខេត្ត។ ផែនការ

យុទ្ធសាស្រ្តថវិកាខេត្ត ត្រូវរៀបចំទៅតាមគោលបំណងនយោបាយ និងរចនាសម្ព័ន្ធកម្មវិធី ដោយមានខ្លឹមសារពិពណ៌នាអំពីគោលបំណង សូចនាករសមិទ្ធកម្មគន្លឹះ(KPI) សម្រាប់ការតាមដានការអនុវត្ត និងការត្រួតពិនិត្យលទ្ធផល គោលដៅ សូចនាករសមិទ្ធកម្មគន្លឹះ(KPI Target) ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។

ការតម្រឹមផែនការ/កម្មវិធីនៃថវិការដ្ឋបាលខេត្ត ជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិសម្រាប់ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត គឺធ្វើឡើងក្នុងកម្រិតចង្កោមសកម្មភាព។ ការតម្រឹមនេះ គឺដើម្បីលុបបំបាត់ការរៀបចំផែនការត្រួតគ្នា ឬជាន់គ្នា និងដើម្បីធានាការប្រើប្រាស់ធនធានថវិកាទាំងអស់រួមចំណែកសម្រេចគោលបំណងគោលនយោបាយរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅក្នុងដំណើរការនៃការធ្វើការតម្រឹមផែនការ/កម្មវិធីនេះ ត្រូវរក្សាឡូជីកនៃរចនាសម្ព័ន្ធកម្មវិធី (Program structure logic) ដូចជា មានសកម្មភាពសម្រាប់អនុវត្តចង្កោមសកម្មភាព ចង្កោមសកម្មភាពត្រូវផលិតលទ្ធផលក្នុងឆ្នាំ(output)នៃអនុកម្មវិធី លទ្ធផលក្នុងឆ្នាំត្រូវសម្រេចលទ្ធផល ចុងក្រោយនៃកម្មវិធី លទ្ធផលចុងក្រោយ(outcome) ត្រូវសម្រេចគោលបំណងនៃកម្មវិធី គោលបំណងនៃកម្មវិធីត្រូវចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយ, ព័ត៌មានហិរញ្ញវត្ថុ។ល។

អ្នកគ្រប់គ្រងកម្មវិធី (រដ្ឋបាលថ្នាក់ក្រោមជាតិ) នឹងទទួលខុសត្រូវលើលទ្ធផលក្នុងឆ្នាំ(Output) នៃការអនុវត្ត ថវិកាកម្មវិធីតាមរយៈរបាយការណ៍(Reporting) និងការត្រួតពិនិត្យ(Monitoring) ការអនុវត្ត។ នៅក្នុងខែមីនានៃឆ្នាំនីមួយៗ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្រ្តថវិកា ដែលបានរៀបចំនៅក្នុងឆ្នាំមុន ដោយផ្តោតលើ ១).ការត្រួតពិនិត្យ និងវាយតម្លៃរចនាសម្ព័ន្ធកម្មវិធី ២).ការត្រួតពិនិត្យ និងវាយតម្លៃសូចនាករ និងគោលដៅសូចនាករ និង ៣).ការត្រួតពិនិត្យ និងវាយតម្លៃការកំណត់ធនធាន។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ ១).ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ២).រៀបចំត្រួតពិនិត្យ និងវាយតម្លៃសូចនាករ និង ៣).ត្រួតពិនិត្យ និងវាយតម្លៃគោលដៅសូចនាករ។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត ត្រូវត្រួតពិនិត្យ និងវាយតម្លៃគម្រោងចំណូល និងតម្រូវការចំណាយដោយត្រូវផ្តោតលើកត្តាដែលធ្វើឱ្យតម្រូវការចំណាយមានការផ្លាស់ប្តូរ។

## III.សមិទ្ធផលរបស់រាជរដ្ឋាភិបាល

### ១. វឌ្ឍនភាពការងារសំខាន់ៗតាមវិស័យ ឆ្នាំ ២០២៤

ផ្នែកនេះ នឹងពិភាក្សាអំពីវឌ្ឍនភាពការងារសំខាន់ៗ និងសមិទ្ធផលរបស់រាជរដ្ឋាភិបាល ដែលសម្រេចបានតាមវិស័យ ដោយបែងចែកតាមគោលដៅជាយុទ្ធសាស្រ្ត ផ្នែកស្នូល បរិស្ថានគ្របដណ្តប់ និងបញ្ចកោណទាំង៥ នៃយុទ្ធសាស្រ្តបញ្ចកោណ មានដូចខាងក្រោម÷

#### ក.គោលដៅជាយុទ្ធសាស្រ្ត

រាជរដ្ឋាភិបាលបានបន្តសម្រេចកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ២០២៤ ប្រមាណ ៦,០% ជាមួយនឹងការរំពឹងថានឹងបន្តកំណើនសេដ្ឋកិច្ចប្រមាណ ៦,៣% ជាមួយផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) សម្រាប់ប្រជាជនម្នាក់

បានកើនឡើងពី ២.៥២០ដុល្លារអាមេរិកក្នុងឆ្នាំ២០២៣ ដល់ ២.៧១៣ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤ ព្រមទាំងបានរក្សាស្ថិរភាព នៃអត្រាអតិផរណាក្នុងកម្រិតទាបមួយក្នុងតំបន់ និងនៅលើពិភពលោក។ រីឯ អត្រាគ្មានការងារធ្វើមានប្រមាណត្រឹមតែ ១,២% បើយោងតាមរបាយការណ៍អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០១៩។ ជាមួយគ្នានេះ ចំនួនគ្រួសារក្រីក្រ និងងាយរងហានិភ័យស្មើនឹង ១ ២០៥ ២១៦ គ្រួសារ ដែលស្មើនឹង ៤ ៦២៨ ៥៣៩ នាក់ ដែលក្នុងនោះគ្រួសារក្រីក្រកម្រិត១ មានចំនួន ២០៣ ០៩៣ គ្រួសារ ស្មើនឹង ៨៥៤ ៧០៦ នាក់ (ប្រមាណ ៤,៨៦% ធៀបនឹងប្រជាជនសរុប) គ្រួសារក្រីក្រ កម្រិត២ មានចំនួន ៥០០ ៥៣៧ គ្រួសារ ស្មើនឹង ២ ០៩៦ ៤០១ នាក់ (ប្រមាណ ១២,១៧% ធៀបនឹងប្រជាជនសរុប) និងគ្រួសាររងហានិភ័យមានចំនួន ៥០១ ៥៩៦ គ្រួសារស្មើនឹង ១ ៧០៤ ៤៣២ នាក់ (ប្រមាណ ៩,៨៦% ធៀបនឹងប្រជាជនសរុប)។ ដោយឡែក កម្ពុជាបានកាត់បន្ថយបរិមាណសរុបនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សម្រេចបាន ១០៥,៥% ធៀបនឹងចំណុចដៅ ដោយបានកាត់បន្ថយចំនួន ៦,៥៤ $MtCO_2e$។

**ខ-ស្នូលនៃយុទ្ធសាស្ត្រ**

រាជរដ្ឋាភិបាល មានគោលដៅក្នុងការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដោយសម្រេចបានសមិទ្ធផល ដូចខាងក្រោម÷

**ទី១.** ការពង្រឹងសមត្ថភាពនៃភាពជាអ្នកដឹកនាំ និងលើកកម្ពស់សមត្ថភាពកងកម្លាំងប្រដាប់អាវុធ ដោយបាន ក).បណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន ១,០៣៧នាក់ (ស្រី ១៧២នាក់) លើភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ និង ខ).កងកម្លាំងប្រដាប់អាវុធ ចំនួន២៤ ៧៣៤នាក់ ត្រូវបានធ្វើការហ្វឹកហ្វឺន បណ្តុះបណ្តាលនិងបំប៉នជំនាញផ្សេងៗ។

**ទី២.** ការពង្រឹងប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈដោយបាន ក).រៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចំនួន ៤១លើក ខ).រៀបចំជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល និងគ).ដំឡើងបៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភ ជូនមន្ត្រីរាជការ គ្រូបង្រៀន កម្លាំងប្រដាប់អាវុធ និងសមត្ថកិច្ច។

**ទី៣.** ការធ្វើវិចារណកម្មមុខងារ និងរចនាសម្ព័ន្ធស្ថាប័ន ដោយបានបានអនុវត្តដំណើរការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ ក្រសួង ស្ថាប័ន ចំនួន ៣១។

**ទី៤.** ការបន្តកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ដោយបាន ក).រៀបចំថវិកាសរុបចំនួនប្រមាណ ៤.០១៣.៥៥២,១២លានរៀល សមមូលប្រមាណ ១ប៊ីលានដុល្លារអាមេរិក បែងចែក និងផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០២៤ និង ខ).រដ្ឋបាលរាជធានី-ខេត្ត បានរៀបចំ និងអនុវត្តសរុបចំនួន ២២០គម្រោង ស្មើនឹងទឹកប្រាក់ប្រមាណ ៤៧៦ប៊ីលានរៀល សមមូលប្រមាណ ១១៩លានដុល្លារអាមេរិក។

**ទី៥.** ការលើកកម្ពស់ និង ការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយបាន ក)- អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បានដោះស្រាយបញ្ចប់ដោយជោគជ័យ ចំនួន ៧១ករណី នៃ ៤១២ ពាក្យបណ្តឹង ខ).មេធាវីស្ម័គ្រចិត្ត បានពិគ្រោះយោបល់ផ្នែកច្បាប់ និងការពារក្តីជូនប្រជាពលរដ្ឋ បានសរុប ៨ ៣៤៧ ករណី និងគ).បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បាននិងកំពុងផលិតធនធានមនុស្សជាចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងសារការី សរុបចំនួន ៤១៤ នាក់។

**ទី៦.** ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច ដោយ ក).យន្តការវេទិការាជរដ្ឋាភិបាល ផ្នែកឯកជនរាជរដ្ឋាភិបាល បានដាក់ចេញវិធានការជាក់លាក់សរុបចំនួន ១៨៨ ក្នុងនោះ វិធានការចំនួន ១០៨ ត្រូវបានសម្រេចពេញលេញ និងវិធានការចំនួន៨០ ស្ថិតក្នុងការអនុវត្ត និងខ).ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX។

## គ-បរិស្ថានគ្របដណ្តប់

រាជរដ្ឋាភិបាលបានពង្រឹងការរក្សាបាននូវសន្តិសុខ និងស្ថិរភាពនយោបាយ ដែលជាបុរេលក្ខខណ្ឌ ក្នុងការធានាបាននូវការអភិវឌ្ឍ, ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចបើកចំហ, ការបន្តអភិវឌ្ឍ និងការលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន, និងការពង្រឹងភាពជាម្ចាស់, ភាពជាដៃគូ និង យន្តការសម្រាប់កិច្ចសហប្រតិបត្តិការក្នុងគោលដៅកៀរគរធនធានហិរញ្ញវត្ថុ បច្ចេកទេស និង ចំណេះដឹង សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលសម្រេចនូវលទ្ធផល ដូចខាងក្រោម÷

**ទី១.** ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយបាន ក).ដោះស្រាយបញ្ហាតំបន់ព្រំដែន មួយចំនួនធំ ជាមួយភាគីថៃ វៀតណាម និងឡាវ ខ).បន្តប្រយុទ្ធប្រឆាំងបទល្មើសព្រហ្មទណ្ឌឆ្នាំ២០២៤ ដោយបទល្មើសសរុបមានចំនួន ៣.៣២៤ករណី ថយចុះ ១៨៧ករណី គ).បន្តប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ដោយបានធ្វើប្រតិបត្តិការស្រាវជ្រាវបង្ក្រាបបានចំនួន ៨.៣៣៧ករណី និងបង្ក្រាបសារធាតុញៀនសរុបចំនួន ១១តោន ឃ).កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក មកត្រឹម ៣.១៥១លើក និង ង).បានបោសសម្អាតមីនលើផ្ទៃដីទំហំ ៣៦៨គីឡូម៉ែត្រក្រឡា និងបានប្រកាសខេត្តដែលអស់មីនសរុបចំនួន ១៥ខេត្ត។

**ទី២.** នយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ និងឈ្លាសវៃ ដោយបាន ក).ដាក់ឱ្យអនុវត្តគម្រោងព្រែកជីក ហ្វូណនតេជោ ខ).ដកខ្លួនចេញពីក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) គ).ត្រូវបានទទួលស្គាល់ថាជាប្រទេស ដែលដើរលើផ្លូវត្រូវឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅឆ្នាំ២០៣០ ឃ).ទទួលការគាំទ្រជាផ្លូវការឱ្យធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ នៅឆ្នាំ២០២៦ ង).បានបញ្ជូនកងកម្លាំងចូលរួមបេសកកម្ម **ចំនួន៩.៨២១នាក់** (នារី ៨៥៦នាក់) ក្នុងក្របខ័ណ្ឌការងាររក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ (អ.ស.ប.) ទៅកាន់ ១០ប្រទេស គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤។

**ទី៣.** ការធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈ ក). អត្រាកំណើនពិត នៃ ផ.ស.ស. ឆ្នាំ ២០២៤ នឹងសម្រេចបានកំណើនក្នុងរង្វង់ ៦,០% ខ). ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) សម្រាប់ប្រជាជនម្នាក់បានកើនឡើងពី ២.៥២០ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៣ ដល់២.៧១៣ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤ គ). ស្ថានភាពបំណុលសាធារណៈនៅក្នុងឆ្នាំ ២០២៤ នៅបន្តរក្សាបាននូវចីរភាព និងហានិភ័យកម្រិតទាបជាសារវ័ន្ត ឃ). កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តរួមមាន (១). កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដែលមានអ្នកទទួលផលចំនួនប្រមាណ ៣៧ម៉ឺននាក់ (២). កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ដែលមានសិស្សក្រីក្រទទួលផលចំនួនជាង ២៦ម៉ឺននាក់ ក្នុងឆ្នាំ ២០២៤ និងត្រូវបានប៉ាន់ស្មានថានឹងកើនដល់ប្រមាណ ៤៥ ម៉ឺននាក់ ក្នុងឆ្នាំ២០២៥ (៣). កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព ដែលមានអ្នកទទួលផលប្រមាណ ២ម៉ឺន ២ពាន់នាក់ និង (៤). កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ឆ្នាំឡើង) ដែលមានអ្នកទទួលផល ប្រមាណជិត ៣០ ម៉ឺននាក់។

**ទី៤.** ការបន្តកសាងភាពជាដៃគូប្រកបដោយបរិយាបន្ន និងការបន្តធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់ និងសកលលោក តាមរយៈ ក). ជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសពី EIF ចំនួន ៩៨.៩៨០ ដុល្លារអាមេរិក សហគមន៍អឺរ៉ុប និងរដ្ឋាភិបាលអាល្លឺម៉ង់ ចំនួន ៩,៩ លានអឺរ៉ូ, IFAD ចំនួន ២០ លានដុល្លារអាមេរិក CAPRED/DFAT Australia ចំនួន ១០២.៥០០ ដុល្លារអាមេរិក និងជំនួយបច្ចេកទេសពី ADB ក្រោមអនុកម្មវិធីទី២ និងទី៣ ចំនួន ១០០ លានដុល្លារអាមេរិក, សរុបជាទឹកប្រាក់ប្រមាណ ១៣០ លានដុល្លារអាមេរិក និង ខ). បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគជាមួយសាធារណរដ្ឋកូរ៉េ និងរដ្ឋបាលស្វយ័តទីក្រុងហុងកុង។

## ឃ-បញ្ចកោណទី ១ ការអភិវឌ្ឍមូលធនមនុស្ស

រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍមូលធនមនុស្ស ដែលមានគុណភាពខ្ពស់ និងសុខភាពល្អ ក្នុងគោលដៅបង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតថ្មី សំដៅធានាចីរភាពកំណើន និងជីវភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយបានសម្រេចនូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម÷

**ទី១.** វិស័យអប់រំ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដោយបាន÷

- ទទួលស្គាល់សាលារៀនគំរូ[1] ចំនួន១២០សាលា នៅឆ្នាំ២០២៤ ដែលក្នុងនោះមានកម្រិតមត្តេយ្យសិក្សា ១០ បឋមសិក្សាចំនួន ៤០ និងមធ្យមសិក្សា ៧០គ្រឹះស្ថាន។

---

[1] ជាសាលារៀនដែលសម្រេចនូវវឌ្ឍនភាពល្អប្រសើរលើស្តង់ដារទាំង ៥ ដូចជាលទ្ធផលសិក្សារបស់សិស្ស, ការបង្រៀននិងរៀន, ការចូលរួមរបស់សហគមន៍, ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន, និងគណនេយ្យភាពរបស់សាលារៀន។

- ជំរុញឱ្យអត្រាប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិកើនឡើងពី ៩៤,៥% ដល់ ៩៦,២៧% និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកើនឡើងពី ៧២,៩% ដល់ ៧៩% រវាងឆ្នាំសិក្សា ២០២២-២០២៣ និង ២០២៣-២០២៤
- បាននិងកំពុងកែលម្អកម្មវិធីសិក្សា អភិវឌ្ឍសៀវភៅសិក្សា និងបង្កើនម៉ោងសិក្សាពី ៤ម៉ោង/១ថ្ងៃ ទៅ ៦ម៉ោង/១ថ្ងៃ ឬ ៤០ម៉ោង/១សប្ដាហ៍ សម្រាប់សាលាបឋមសិក្សាដែលមានសក្ដានុពល
- បាន និងកំពុងអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍នៅតាមសាលារៀនគោលដៅ ចំនួន ៥៥៣ សាលា ក្នុងឆ្នាំ ២០២៤ ក្នុងខេត្តចំនួន ១០ ដែលមានសិស្សទទួលផលចំនួន ១៥៣ ៥៨៦ នាក់ និង ចុងភៅចំនួន ១ ៥១៨ នាក់ និង
- បានចុះឈ្មោះសិស្សឱ្យចូលរៀនសរុបចំនួន ៧៧ ១៥០នាក់ ក្នុងនោះសិស្សកំពុងសិក្សាចំនួន ២៥ ៥៩៧នាក់ និងសិស្សបានបញ្ចប់ការសិក្សាមានចំនួន ១៦ ៦០៥នាក់ ហើយទទួលបានការងារធ្វើមានចំនួន ៦ ៨៣៩នាក់ គិតត្រឹមថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ (កម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេសចំនួនប្រមាណ ១,៥ លាននាក់)។

**ទី២.** វិស័យសុខាភិបាល បានសម្រេចនូវសមិទ្ធផល ដូចខាងក្រោម÷

- បានសម្រេចនូវសន្ទស្សន៍នៃការគ្របដណ្ដប់សេវាសុខាភិបាលសារវន្ត[2] (មាត្រាដ្ឋាន 0-១00) ឱ្យកើនឡើងពី ៥៨ នៅឆ្នាំ ២០២១ ទៅ ៦0,១ នៅឆ្នាំ២០២៤
- បានសម្រេចនូវពិន្ទុគុណភាពសេវាជាមធ្យមលើសពី ៥0% សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ (៥២,១៦%) មន្ទីរពេទ្យបង្អែកកម្រិត ២ (៥១,៣៧%) មន្ទីរពេទ្យបង្អែកកម្រិត៣ (៥៧,៨៩%) មណ្ឌលសុខភាព (៤៤,៧៤%)
- បានសម្រេចនូវពិន្ទុមធ្យមនៃការពេញចិត្តរបស់អ្នកជំងឺ ក្រុមគ្រួសារអ្នកជំងឺ និងអតិថិជនដែលបានប្រើប្រាស់សេវានៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត ១, ២, និង ៣ កើនដល់៨៣% និងមណ្ឌលសុខភាព កើនដល់ ៨0,0១% និង
- មានប្រជាជនគ្របដណ្ដប់ដោយកម្មវិធីមូលនិធិសមធម៌ចំនួន ៤ ៧៩៥ ១៧១ នាក់ ដែលក្នុងនោះការប្រើប្រាស់សេវាសុខភាពក្រោមកម្មវិធីមូលនិធិសមធម៌ចំនួន ៣ ៩៣៧ ៩២0 ករណី គិតត្រឹមខែតុលា ឆ្នាំ២០២៤។

**ទី៣.** វិស័យគាំពារសង្គម បានសម្រេចនូវសមិទ្ធផល រួមមាន÷

- បានដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ តាមរយៈការធ្វើសមាហរណកម្មកម្មវិធីជាតិជំនួយសង្គមទាំង ៤ រួមមាន÷ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារ

[2] ការផ្ដល់នូវសេវាថែទាំសុខភាពដល់ប្រជាពលរដ្ឋ មានដូចជា ១). សុខភាពបន្តពូជ មាតា ទារក និងកុមារ ២). ជំងឺឆ្លង ៣). ជំងឺមិនឆ្លង និង៤). សមត្ថភាពនិងការទទួលបានសេវា។

អាយុក្រោម ២ឆ្នាំ មានអ្នកទទួលផលសរុបប្រមាណ ៣៧ ម៉ឺននាក់ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ដោយមានសិស្សក្រីក្រទទួលផលចំនួនជាង ២៦ ម៉ឺននាក់ ក្នុងឆ្នាំ ២០២៤ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព មានអ្នកទទួលផលសរុបចំនួន ២២ ០៤៤នាក់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា អាយុ ៦០ឆ្នាំឡើង មានអ្នកទទួលផលសរុបចំនួន ២៩៩ ១៥៥ នាក់។ ដែលក្នុងនោះកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ក៏មានការឧបត្ថម្ភគោលសម្រាប់គ្រួសារក្រីក្រទាំងអស់ ដែលបច្ចុប្បន្នមានប្រមាណ ៦១០ ១៨៧ គ្រួសារ និងការឧបត្ថម្ភសមាជិកគ្រួសារក្រីក្រដែលរស់នៅជាមួយមេរោគ និងជំងឺអេដស៍ ចំនួន ១ ៩៤៧ នាក់ ផងដែរ

- របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន និងរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីការងារ មានសមាជិកសរុបចំនួន ១,៨១ លាននាក់ ក្នុងនោះមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនចំនួន១៣ ម៉ឺននាក់ និងកម្មករនិយោជិត១,៦៨ លាននាក់ និងបានបើកផ្តល់តាវកាលិករបបសន្តិសុខសង្គមផ្នែកសោធនអស់ទឹកប្រាក់ប្រមាណ ៣៥៥,៦២ លានរៀល
- របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព មានសមាជិកសកម្មសរុបចំនួន ២,៥៣ លាននាក់ ដែលក្នុងនោះមានកម្មករនិយោជិត ១,៦៨ លាននាក់ បុគ្គលនៃវិស័យសាធារណៈ ៤៨ ម៉ឺននាក់ និងបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុករបស់សមាជិក ប.ស.ស. ជាង ៣៦ ម៉ឺននាក់ និងបានផ្តល់តាវកាលិករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពក្នុងឆ្នាំ ២០២៤ អស់ប្រមាណជា ៥៣៤,៤៦ ប៊ីលានរៀល
- របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ មានសមាជិកសកម្មចំនួន ១,៩៦ លាននាក់ ក្នុងនោះកម្មករនិយោជិតចំនួន ១,៦៨ លាននាក់ និងមន្ត្រីសាធារណៈ ២៨ ម៉ឺននាក់ និងបានផ្តល់តាវកាលិកហានិភ័យការងារប្រមាណ ២៧,៣៧ ប៊ីលានរៀល និង
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំសម្រាប់សមាជិក ប.ស.ស. មានស្ត្រី និងកុមារសរុបប្រមាណ ៧៧ ម៉ឺននាក់ និងបានចំណាយថវិកាអស់ ២៨៦ ប៊ីលានរៀល គិតចាប់ពីខែសីហា ឆ្នាំ២០២៣។

**ង-បញ្ហកោណទី ២: ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង**

រាជរដ្ឋាភិបាលបានសម្រេចនូវសមិទ្ធផល ដូចខាងក្រោម÷

**ទី១.** ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម បានសម្រេចរួមមាន÷

- បានស្ថាបនាផ្លូវជាតិកម្រិត១ ប្រវែង ២,២៥៤គ.ម ផ្លូវជាតិកម្រិត២ ប្រវែង៥,១២០គ.ម និងផ្លូវខេត្តប្រវែង១២,៩៣២.៧២គ.ម, គម្រោងចំនួន៣ បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ រួមមានៈ គម្រោងការធ្វើឱ្យប្រសើរឡើងវិញកំណាត់ផ្លូវជាតិលេខ៥ (ព្រែកក្តាម-បាត់ដំបង) គម្រោងផ្លូវក្រវាត់ក្រុងទី៣ "មហាវិថី ស៊ី ជីនពីង" និងគម្រោងវិថីតេជោសន្តិភាពឆ្នេរអង្កោល តាមបណ្តោយមាត់ឆ្នេរសមុទ្រខេត្តកែប។

- បាននិងកំពុងអនុវត្តសាងសង់ ដែលមានប្រវែងសរុបចំនួន ១,០៣៥,៦៨៧គ.ម និងបាននិងកំពុងសិក្សារៀបចំគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចំនួន ៤២គម្រោង ដែលមានប្រវែងសរុបចំនួន ៣,២៨៧,០៤៥គ.ម។
- បានសម្ពោធដាក់ឱ្យប្រើប្រាស់ចំនួន ៣គម្រោង រួមមាន÷ គ្រឿងចក្រលើកដាក់ចល័តនៅតែមផែកំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែពហុបំណង ក្នុងខេត្តកំពត និងចំណតផែកុងតឺន័រ ក្នុងក្រុងព្រះសីហនុ និងបានបញ្ចប់ការសាងសង់ចំនួន ៤គម្រោង រួមមានឃ្លាំងសន្និធិគយបណ្តោះអាសន្ន ចំណតផែរណបពហុបំណង ឃ្លាំងលើកដាក់ និងស្តុកទំនិញត្រជាក់ នៅកំពង់ផែស្វយ័តភ្នំពេញ និងកំពង់ផែទេសចរណ៍អន្តរជាតិនៅខេត្តកំពត។
- បាននិងកំពុងអនុវត្តគម្រោងសាងសង់ចំនួន ៤គម្រោង ក្នុងនោះក៏មានការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ តភ្ជាប់ពីព្រែកតាកែវនៃទន្លេមេគង្គ ដល់សមុទ្រខេត្តកែប មានប្រវែង ១៨០គ.ម។
- សម្រេចបានការចុះបញ្ជីដល់នាវាផ្លូវទឹកចំនួន ៣១គ្រឿង និងផ្លូវសមុទ្រចំនួន ១៦គ្រឿង និងទទួលបានចំណូលពីការដឹកជញ្ជូនសរុបចំនួន ២,៧៩៩លានរៀល ក្នុងនោះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ទទួលបានប្រមាណ ១៣៩,៧៤លានដុល្លាអាម៉េរិក និងកំពង់ផែស្វយ័តភ្នំពេញទទួលបានប្រមាណ ៤៨,៨៣ លានដុល្លាអាម៉េរិក។
- បាននិងកំពុងកសាង អាកាសយានដ្ឋានតេជោអន្តរជាតិ និងបាននិងកំពុងរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវដែកជាច្រើន រួមមានកិច្ចព្រមព្រៀងសម្បទានផ្លូវដែកជាមួយក្រុមហ៊ុនរ៉ូយ៉ាល់រេលវេ សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងផ្លូវឆ្លងកាត់ និងដីចំណីផ្លូវដែកសិក្សាពីលទ្ធភាពលើកកម្រិតផ្លូវដែកភ្នំពេញ-ក្រុងព្រះសីហនុ ផ្លូវដែកល្បឿនលឿន ប៉ោយប៉ែតសៀមរាប ភ្នំពេញ បាវិត ផ្លូវរថភ្លើងធន់ស្រាលពីក្រុងសៀមរាប ទៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ពីរាជធានីភ្នំពេញ ទៅអាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ និងផ្លូវរថភ្លើងក្រោមដីរាជធានីភ្នំពេញ។

**ទី២.** វិស័យថាមពល សម្រេចសមិទ្ធផល ដូចខាងក្រោម÷

- បន្តអភិវឌ្ឍប្រភពថាមពលកកើតឡើងវិញចំនួន ៣៦គម្រោង ក្នុងនោះ ១៣គម្រោងបានកំពុងសាងសង់ ដែលមានអនុភាពសរុបចំនួន១,២៧៥មេហ្គាវ៉ាត់ និង២៣គម្រោងទទួលបានការអនុម័តក្នុងការអភិវឌ្ឍ ដែលមានអនុភាពសរុបចំនួន ៥,៩៥០ មេហ្គាវ៉ាត់។
- បន្តឧបត្ថម្ភធនជាង ១០០លានដុល្លាអាម៉េរិក រៀងរាល់ឆ្នាំ លើថ្លៃអគ្គិសនីផ្គត់ផ្គង់ឱ្យទៅទីតាំងប្រើប្រាស់អគ្គិសនីចំនួន ៩៩,៧៣៦%នៃទីតាំងប្រើប្រាស់អគ្គិសនីសរុបទូទាំងប្រទេសដែលស្ថិតនៅតំបន់ផ្គត់ផ្គង់របស់ប្រព័ន្ធបណ្តាញជាតិ។
- អនុគ្រោះថ្លៃ ៣៨០៛ ៤៨០៛ និង៦១០៛ សម្រាប់លំនៅឋានចំណូលទាបដែលប្រើតិច និង៤៨០៛ សម្រាប់កសិកម្មដែលប្រើពេលយប់។

- បានបន្ថយថ្លៃអគ្គិសនីនៅអនុស្ថានីយពី 0.1240$/kWh មក 0.1170$/kWh និងបានបន្ថយថ្លៃអគ្គិសនីសម្រាប់ឧស្សាហកម្មនិងកសិកម្ម ដែលទិញពីខ្សែតង់ស្យុងមធ្យមពី 0.1650$/kWh មក 0.1370$/kWh និងបានបន្ថយថ្លៃអគ្គិសនីទូទៅទិញពីខ្សែតង់ស្យុងទាបពី ៧៧០៛/kWh មក ៧៣០៛/ kWh។
- បានបញ្ចុះថ្លៃអគ្គិសនីក្នុងវិស័យទេសចរណ៍ ដែលបានភ្ជាប់ពីបណ្ដាញជាតិសម្រាប់រយៈពេល ៣ខែ ចាប់ពីខែធ្នូ ឆ្នាំ២០២៣ ដល់ខែកុម្ភៈ ឆ្នាំ២០២៤ និងអនុគ្រោះថ្លៃអគ្គិសនី ៤៨០៛/ kWh ដល់អ្នកប្រើប្រាស់ ប្រភេទម៉ាស៊ីនកិនស្រូវ និងឡសម្ងួតស្រូវសម្រាប់រយៈពេល ៤ខែ (ចាប់ពីខែតុលា ឆ្នាំ២០២៤ ដល់ខែមករា ឆ្នាំ២០២៥) និងការប្រើប្រាស់អគ្គិសនីនៅថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកបុណ្យជាតិ រយៈពេល ២៤ម៉ោងពេញ និងអនុគ្រោះថ្លៃ ៥០០៛/ kWh សម្រាប់ការប្រើប្រាស់លើសពីមធ្យមភាគគោលប្រចាំខែ។

**ទី៣.** វិស័យទេសចរណ៍អន្តរជាតិ ដោយរដ្ឋាភិបាលសម្រេចបានសមិទ្ធផល÷

- ទទួលបានទេសចរអន្តរជាតិ ៦,៧០លាននាក់ កើនឡើង ២២,៩% ធៀបនឹងឆ្នាំ២០២៣។
- ទទួលបានចំណូលពីទេសចរណ៍អន្តរជាតិ ៣,៦៣៧លានដុល្លាអាម៉េរិក កើនឡើង ១៨% ធៀបនឹងឆ្នាំ២០២៣ និងចូលរួមចំណែកក្នុងផលិតផលក្នុងស្រុកប្រមាណ ៩,៤%។
- បានបង្កើតមុខរបរ និងការងារក្នុងវិស័យទេសចរណ៍ចំនួន ៥១ម៉ឺននាក់។
- បានចូលរួមពិព័រណ៍ទេសចរណ៍ក្រៅប្រទេសចំនួន ៩លើក នៅទីផ្សារអាស៊ាន ឥណ្ឌា អ៊ឺរ៉ុប ជប៉ុន កូរ៉េ និងទីផ្សារចិន។
- បានចូលរួមសហការក្នុងការផ្សព្វផ្សាយទេសចរណ៍កម្ពុជា តាមរយៈការរៀបចំកម្មវិធី ឆ្នាំនៃការផ្លាស់ប្ដូរ រវាងប្រជាជន និងប្រជាជន កម្ពុជា-ចិន កម្មវិធីទស្សនាសៀមរាប ឆ្នាំ២០២៤, ព្រឹត្តិការណ៍ពិព័រណ៍ទេសចរណ៍វប្បធម៌ និងពាណិជ្ជកម្ម កម្មវិធី Ramadan Ba Zear Malaysia, ព្រឹត្តិការណ៍ When Shaolin Meets Bokator at Angkor, ព្រឹត្តិការណ៍សមាធិ សហការជាមួយទស្សនវិទូដ៏ល្បីល្បាញជនជាតិឥណ្ឌា, ព្រឹត្តិការណ៍ ASEAN Bazzar, កម្មវិធីការប្រកួតប្រជែងថតរូបសមរាត្រីអង្គរអច្ឆរិយ, ព្រឹត្តិការណ៍ជិះទូបយានយន្តបន្តជុំរុញទេសចរណ៍ (Car & Buke Festival), ព្រឹត្តិការណ៍រត់អបអរសាទរប្រាសាទព្រះវិហារ, ព្រឹត្តិការណ៍ ហ្គាំប៊ិល ៣០០០ រ៉ាល់លី (Gumball 3000 Rally) ជាដើម។

## ច. បញ្ហាគោលនាទី ៣៖ ការអភិវឌ្ឍវិស័យឯកជន និងការងារ

រាជរដ្ឋាភិបាលបានសម្រេចវិស័យសំខាន់ៗ ដូចខាងក្រោម÷

**ទី១.** បានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងយន្តការកំណត់ និងការអនុវត្តប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ, ស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប ដោយបន្តដំឡើងប្រាក់ឈ្នួលអប្បបរមាជារៀងរាល់ឆ្នាំពី ២០៤ដុល្លារ ក្នុងមួយខែសម្រាប់ឆ្នាំ ២០២៤ ដល់ ២០៨ដុល្លារ ក្នុងមួយខែ សម្រាប់ឆ្នាំ២០២៥។

**ទី២.** ពង្រីកវិសាលភាព ប.ស.ស. ដល់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ការបង្កើតទារកដ្ឋានសហគមន៍ ការផ្លាស់ប្តូរមធ្យោបាយធ្វើដំណើរបណ្តើរៗ និងពិនិត្យលទ្ធភាពផ្សេងទៀត ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់បងប្អូនកម្មករនិយោជិត។

**ទី៣.** បានផ្តល់សេវាសាធារណៈ ក្នុងការជួយស្វែងរកការងារ ផ្សព្វផ្សាយព័ត៌មានការងារ និងប្រឹក្សាយោបល់ ព្រមទាំងដាក់ចេញនូវរបាយការណ៍អំពីចក្ខុវិស័យការងារ ដោយបន្តយកចិត្តទុកដាក់លើការបញ្ជូន និងធានាសុខុមាលភាពរបស់ពលករ ពលការិនីកម្ពុជា ដែលធ្វើការនៅបរទេសផងដែរដោយបាន÷

- បានចុះឈ្មោះអ្នកស្វែងរកការងារធ្វើសរុបចំនួន ៦៣ ៧៦៣នាក់ (ស្រី ៣៣ ៤៩៥នាក់) បានផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក តាមរយៈយន្តការផ្គូផ្គងការងារតាមបច្ចេកវិទ្យាព័ត៌មានវិទ្យា បានចំនួន ១០៣ ៦៦៧ដង/នាក់ (ស្រី ៦១ ៦០០ដង/នាក់), អ្នកទទួលបានការងារធ្វើចំនួន ១៣ ០៧២នាក់ (ស្រី ៧ ៤៣៥នាក់)។
- បានផ្តល់ការប្រឹក្សាការងារដល់ប្រជាជនសរុបចំនួន ៤៩ ៨៧៧នាក់ (ស្រី ២៥ ៣០១នាក់)។
- បានបញ្ជូនពលករ-ពលការិនីទៅធ្វើការនៅបរទេសចំនួន ៦៣ ៦៨០នាក់ (ស្រី ២៥ ១២៩នាក់) តាមវិស័យ ដូចជា ឧស្សាហកម្ម កសិកម្ម សំណង់ ការងារផ្ទះ និងការងារផ្សេងៗ។
- បានធ្វើអង្កេត និងចេញផ្សាយរបាយការណ៍អង្កេតទីផ្សារការងារចំនួនពីរគឺ÷ "តម្រូវការជំនាញរបស់និយោជក ឆ្នាំ២០២៤" និង "ទស្សនវិស័យការងារកម្ពុជាឆមាសទី ២ ឆ្នាំ២០២៤"។

**ទី៤.** បានយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធភាពនៃការដោះស្រាយវិវាទការងារ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងសមត្ថភាពមន្ត្រីផ្សះផ្សាភាពជាដៃគូ ដែលជាលទ្ធផល ការដោះស្រាយវិវាទការងារ តាមរយៈយន្តការ នៃការផ្សះផ្សាទទួលបានអត្រាសះជាកាន់តែល្អប្រសើរជាលំដាប់ ដោយកើនពី ៤៧,២៤% នៅឆ្នាំ២០១៨ ដល់ ៨១,៩១% នៅឆ្នាំ២០២៣ និង ៨៨,៥៦% នៅឆ្នាំ២០២៤។

**ទី៥.** បានកែលម្អបរិយាកាសដំណើរការសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) និងការចាប់ផ្តើមអាជីវកម្ម តាមរយៈការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍ SMEs ក្នុងនោះ បានចុះ SMEs និងសិប្បកម្មសរុបចំនួន ១ ១៣៧មូលដ្ឋាន (កម្លាំងពលកម្ម ២៣ ២៣៧នាក់) ក្នុងឆ្នាំ២០២៤។

**ទី៦.** បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សហគ្រិនលើការងារចុះបញ្ជី SMEs តាមថ្នាលបច្ចេកវិទ្យា ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ចសង្គមកម្ពុជា ព្រមទាំងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច។

**ទី៧.** បានផ្តោតលើការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការដឹកនាំរៀបចំអនុក្រឹត្យ ស្តីពីការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងបានអនុម័តចេញវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងបានរៀបចំផែនការសកម្មភាពលម្អិត សូចនាករគន្លឹះ សម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨។

**ទី៨.** បានបន្តកែលម្អ និងលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ ការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ តាមរយៈការឃ្លាំពិនិត្យទីផ្សារ ពិនិត្យគុណភាពខ្លឹមសារអត្ថបទ និងរូបភាពស្លាកផ្សាយពាណិជ្ជកម្ម និងការចុះផ្សព្វផ្សាយការយល់ដឹងពីច្បាប់ជាដើម។

**ទី៩.** បានជំរុញការនាំចេញតាមរយៈការចរចាទីផ្សារ ការបង្កើត និងដាក់ឱ្យដំណើរការ "មជ្ឈមណ្ឌលសេវានាំចេញ (Export Service Center)" សម្រាប់ផ្តល់ព័ត៌មានទីផ្សារ នីតិវិធីនាំចេញ និងតភ្ជាប់អ្នកផ្គត់ផ្គង់ និងអ្នកបញ្ជាទិញ និងការផ្តល់ការគាំទ្រនានាទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដើម្បីសម្រួល និងពន្លឿនការនាំចេញទំនិញកម្ពុជា។

## ឆ. បញ្ហាកោណទី ៤៖ ការអភិវឌ្ឍប្រកបដោយតាពធន់ ចីរភាព និងបរិយាបន្ន

**ទី១.** ផ្នែកផលិតកម្មកសិកម្ម រាជរដ្ឋាភិបាល បានសម្រេចនូវសមិទ្ធផល ក្នុងឆ្នាំ២០២៤ រួមមាន÷

- បានផលិតផលដំណាំសរុបចំនួន ៣៩ ៥០១ ៥៧៩តោន នៅក្នុងនោះ កៅស៊ូ ៤០៧ ២០៩តោន ដំណាំសាកវប្បកម្ម ៥ ១៥២ ៧៨៩តោន ស្រូវ ១៣ ៨៨៩ ៥៦២តោន និងដំណាំឧស្សាហកម្ម ២០ ០៥២ ០១៩តោន។
- ផលិតកម្មសត្វមានចំនួនសរុប ៦៩ ៣០៣ ៦៩០ក្បាល នៅក្នុងនោះផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានចំនួន ២៩ ៥០៦ ៧៦៥ ក្បាល ហើយផលិតកម្មសត្វលក្ខណៈគ្រួសារមានចំនួន ៣៩ ៧៩៦ ៩២៥ក្បាល កើនឡើង ៤,១% បើប្រៀបធៀបជាមួយផលិតកម្មសត្វក្នុងឆ្នាំ២០២៣ ដែលមានចំនួនសរុប ៦៦ ៥៨៥ ៥២២ក្បាល។
- ផលជលផលសរុបមានចំនួន ៩២៦ ៩៣៤តោន នៅក្នុងនោះ ផលនេសាទទឹកសាបមានចំនួន ៤៦៧ ៣៤៤តោន ផលនេសាទសមុទ្រមានចំនួន ១៣៩ ៣១០តោន និងផលវារីវប្បកម្មមានចំនួន ៣២០ ២៨០តោន កើនឡើង៧% បើប្រៀបធៀបនឹងផលជលផលសរុបឆ្នាំ២០២៣ ដែលមានចំនួន ៨៦៦ ២៥០តោន។
- បានផលិតគ្រាប់ពូជស្រូវសម្រាប់ក្របខ័ណ្ឌប្រព័ន្ធស្បៀងបម្រុងកម្ពុជាមានចំនួន ២ ៨០០តោន។
- បានបង្កើតសហគមន៍កសិកម្មថ្មីចំនួន ១៨៥ ក្នុងឆ្នាំ២០២៤ ដែលធ្វើឱ្យចំនួនសហគមន៍កសិកម្មសរុបកើនដល់ ១ ៤៣០ និងមានសមាជិកភាពចំនួន ១៧០ ២០៨នាក់។
- បានបង្ក្រាបបទល្មើសនេសាទជលផលសរុបចំនួន ៣.១៩៤ករណី (សមុទ្រ ១៤៨ករណី) ធៀបឆ្នាំ២០២៣ កើន ១៤០ករណី។

**ទី២.** ការនាំចេញផលិតផលកសិកម្មសម្រេចបានការនាំចេញ <u>ផលិតផលដំណាំសរុប</u> **ចំនួន ១២ ០០២ ៣០១ តោន** ដែលមាន តម្លៃសរុបចំនួន៥,៣ពាន់លានដុល្លារអាម៉េរិក ក្នុងនោះការនាំចេញកៅស៊ូសម្រេចបាន **៣៣៨ ០០០តោន** ស្មើនឹងប្រមាណ ៥៦២លានដុល្លារអាម៉េរិក ការនាំចេញអង្ករសម្រេចបាន ៦៤៥ ៨៧២តោន ស្មើនឹងប្រមាណ ៥៥២លានដុល្លារអាម៉េរិក ការនាំចេញស្រូវសម្រេចបាន

**៤ ៦០៨ ៩៧៤តោន** ស្មើនឹងប្រមាណ ១,៣ពាន់លានដុល្លារអាម៉េរិក និងកសិផលក្រៅពីស្រូវ អង្ករ និងកៅស៊ូសម្រេចបាន **៦ ៤០៩ ៨៥៤តោន** ស្មើនឹងប្រមាណ ២,៩ពាន់លានដុល្លារអាម៉េរិក។

**ទី៣.** ទីផ្សារ និងហិរញ្ញប្បទាន សម្រាប់វិស័យកសិកម្ម រួមមាន:

- អន្តរាគមន៍ហិរញ្ញប្បទានពិសេស និងត្រៀមអន្តរាគមន៍ (លើកទី១. ២៨,៥៥លានដុល្លារអាម៉េរិក និងលើកទី២. ៤០លានដុល្លារអាម៉េរិក) សំដៅ លើកកម្ពស់ផលិតកម្ម, រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ។
- បានដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ចំនួន ១ ២៥០នាក់ (២៥០នាក់នៅឆ្នាំ២០២៣ និង ១ ០០០នាក់ នៅឆ្នាំ២០២៤) ដើម្បីអភិវឌ្ឍវិស័យកសិកម្ម។
- បានផ្តល់កិច្ចសហការលើការថែរក្សាសន្តិសុខស្បៀង និងលំនឹងថ្លៃស្រូវវស្សា ២០២៤ របស់រាជរដ្ឋាភិបាល តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មដល់រោងម៉ាស៊ីនកិនស្រូវចំនួន ២៣។
- បាននាំយកអង្ករផ្កាម្លិះ និងសែនក្រអូបលេខ១ របស់កម្ពុជាទៅប្រកួតនៅ **ប្រទេសហ្វីលីពីន និងនៅប្រទេសចិន** ដោយទទួលបានពានរង្វាន់លេខ១ នៅក្នុងព្រឹត្តិការណ៍ទាំងពីរ។

## ជ.បញ្ចកោណទី ៥៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល

រាជរដ្ឋាភិបាលបានសម្រេចវិស័យសំខាន់ៗ ដូចខាងក្រោម:

**ទី១.** បានដាក់ចេញថ្នាល និងកម្មវិធីរបស់រាជរដ្ឋាភិបាលសំខាន់ៗចំនួន រួមមាន÷

- ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh. ដែលត្រូវបានដាក់ឱ្យប្រើក្នុងគោលបំណងលុបបំបាត់ការក្លែងបន្លំឯកសារ ផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ នៃឯកសារ ផ្តល់ទំនុកចិត្ត ចំណេញពេលវេលា និងកាត់បន្ថយចំណាយនានា ព្រមទាំងជំរុញការធ្វើបរិវត្តកម្មឌីជីថល ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។
- ថ្នាលផ្ទុកឯកសារសាធារណៈផ្លូវការ go.gov.kh សម្រាប់ក្រសួង-ស្ថាប័នអាចប្រើប្រាស់ក្នុងការផ្សព្វផ្សាយព័ត៌មាន ឬឯកសារជាសាធារណៈ ដែលអាចទប់ស្កាត់ព័ត៌មាន ឯកសារក្លែងក្លាយ ឬតំណភ្ជាប់ឆបោក (Phishing)។
- ថ្នាលបញ្ជូនសារពហុទិសដៅ nomsa.gov.kh ដែលអាចជំនួសការប្រើប្រាស់ SMS ឬកម្មវិធី Twilio ដើម្បីផ្ញើសារខ្លីទៅសាធារណជន ហើយអាចដឹងថាសារខ្លីនេះចេញពីក្រសួង-ស្ថាប័ន ឬវិស័យឯកជនណាមួយពិតប្រាកដ និងមិនមានការក្លែងបន្លំ។
- ថ្នាលបង្កើតទម្រង់បែបបទអនឡាញ form.gov.kh. ដើម្បីប្រមូលព័ត៌មាន ស្ទង់មតិ ត្រួតពិនិត្យ និងវាយតម្លៃ ចុះឈ្មោះចូលរួមកម្មវិធី ឬប្រមូលមតិកែលម្អនានា។

- កម្មវិធីបញ្ញាសិប្បនិម្មិតបំប្លែងអត្ថបទទៅជាសំឡេង សារិកា "Sarika" ដំណើរការនៅលើបណ្តាញតេឡេក្រាម (Telegram Bot) បង្កើតឡើងសម្រាប់បំប្លែងអត្ថបទទៅជាសំឡេងភាសាខ្មែរ។
- បានដាក់ចេញនូវថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រព័ន្ធឃ្លាំងទិន្នន័យ និងថ្នាលទិន្នន័យ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា កម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស ប្រព័ន្ធគ្រប់គ្រងវិនិយោគកម្ពុជា (cdcIPM) ថ្នាលសេវាឌីជីថលកម្មសិទ្ធបញ្ញា ថ្នាលព័ត៌មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA Portal) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល (HRMIS) ជាដើម។
- បាននិងកំពុងអភិវឌ្ឍ និងត្រៀមដាក់ឱ្យដំណើរការថ្នាលគ្រប់គ្រងបញ្ញើប្រៃសណីយ៍ (DGPOST) ដែលជាថ្នាលជំនួយដល់ប្រជាពលរដ្ឋ ក្នុងការតាមដានស្ថានភាពនៃប្រតិបត្តិការដឹកជញ្ជូនបញ្ញើទាំងអស់ពីគ្រប់ប្រតិបត្តិករ ក្នុងប្រទេសកម្ពុជានៅលើថ្នាលតែមួយ ដែលផ្តល់ភាពងាយស្រួល និងផ្តល់ទំនុកចិត្តជូនប្រជាពលរដ្ឋពីការក្លែងបន្លំនានា ក្នុងការប្រើប្រាស់សេវាកម្មបញ្ញើក្នុងស្រុក។

**ទី២.** បានបន្តពង្រីកការដាក់ឱ្យអនុវត្តមុខងារស្នូល នៃប្រព័ន្ធ FMIS ទៅកាន់ការដ្ឋានបន្ថែមថ្មីនៅរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ ចំនួន ៤៤ ដោយប្រើប្រាស់នីតិវិធីចំណាយចរន្តតាមប្រព័ន្ធ FMIS ទាំងស្រុង, បន្តដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅអង្គភាពថវិកា អាណាប័កផ្ទេរសិទ្ធិចំនួន ៤៤ នៃក្រសួង-ស្ថាប័ន ចំនួន ១០ បន្តដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាគ្រប់មុខសញ្ញា និងចលនាឥណទានថវិកាចរន្តតាម FMIS ទាំងស្រុងនៅក្រសួង-ស្ថាប័ន ចំនួន១០ បន្ថែម បានបន្តដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកា នៅក្រសួង-ស្ថាប័ន ចំនួន១៤ ដែលនៅសល់ រួមទាំងអង្គភាពថវិកា អាណាប័កផ្ទេរសិទ្ធិ, បានបន្ថែមការផលិត របាយការណ៍ចំណាយថ្នាក់ជាតិទៅក្នុងប្រព័ន្ធ និងបានកែលម្អរបាយការណ៍ដែលបានអភិវឌ្ឍរួច ចំនួន៣៣ ដើម្បីបំពេញតម្រូវការបន្ថែមលើប្រើប្រាស់របស់អគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះ។

**ទី៣.** បានរៀបចំនូវលិខិតបទដ្ឋានគតិយុត្ត រួមមាន សេចក្តីព្រាងច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល សេចក្តីព្រាងច្បាប់ស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំង ឯកសារគោលនយោបាយគាំទ្ររួមមាន ផែនទីបង្ហាញផ្លូវសម្រាប់ការជំរុញបរិវត្តកម្មឌីជីថល ផែនទីបង្ហាញផ្លូវស្តីពីសន្តិសុខសាយប័រ គោលនយោបាយស្តីពីហេដ្ឋារចនាសម្ព័ន្ធក្លោដ ជាដើម។

**ទី៤.** បានរៀបចំហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការតភ្ជាប់អ៊ីនធឺណិត សេវាស៊េវើបករណ៍ (Server) ប្រព័ន្ធវេបសាយ និងអ៊ីមែល នៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ព្រមទាំងបានរៀបចំកម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលជូនមន្ត្រីរាជការ កម្មវិធីជំរុញការយល់ដឹង និងការចាប់យកឌីជីថលជាសាធារណៈ និងកម្មវិធីកសាងធនធានមនុស្ស និងអភិវឌ្ឍជំនាញឌីជីថល។

**ទី៥.** បានរៀបចំកម្មវិធីប្រកួតប្រជែងធុរកិច្ចថ្មីឌីជីថល កម្មវិធីជំនួបក្រុមហ៊ុនធុរកិច្ចថ្មី (Digital Startups) ជាមួយនឹងសហគ្រិនឌីជីថល និងស្ថាប័នរដ្ឋ ដើម្បីជំរុញអាជីវកម្មឌីជីថល និងបង្កើនការផ្លាស់ប្តូរយោបល់ និងពង្រឹងកិច្ចសហការរវាងរដ្ឋ និងវិស័យឯកជន។

**ជារួម សមិទ្ធផលខាងលើជាសមិទ្ធផលមួយផ្នែករបស់រាជរដ្ឋាភិបាល ដែលសម្រេចបាន ក្នុងកម្រិតក្រសួង-ស្ថាប័ន ដែលមិនទាន់បានកំណត់អំពីសមិទ្ធផលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយទេ។**

## ២. បញ្ហាប្រឈមគន្លឹះ

សន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤៥ អាណត្តិទី៥ បានកំណត់បញ្ហាប្រឈមដែលត្រូវយកចិត្តទុកដាក់ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មានដូចខាងក្រោម÷

**ក. ហានិភ័យ និងបញ្ហាប្រឈមខាងក្រៅ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ រួមមាន៖**

ទី១. ភាពតានតឹងនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងសង្គ្រាមនៅមជ្ឈិមបូពា៌ ភាពមិនច្បាស់លាស់នៃជំហរគោលនយោបាយ (ការទូត សេដ្ឋកិច្ច និងពាណិជ្ជកម្ម) របស់សហរដ្ឋអាម៉េរិកក្រោមរដ្ឋបាលរបស់ប្រធានាធិបតី ដូណាល់ ត្រាំ សង្គ្រាមពាណិជ្ជកម្ម បច្ចេកវិទ្យា និងហិរញ្ញវត្ថុ និងឯកតោភាគីនិយម។

ទី២. ស្ថានភាពផ្ទៃក្នុង និងគោលនយោបាយការបរទេសរបស់ប្រទេសនានា ក្នុងតំបន់។

ទី៣. បញ្ហាសន្តិសុខមិនប្រពៃណី ដូចជា ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ឧក្រិដ្ឋកម្មឆ្លងដែន បញ្ហាសន្តិសុខស្បៀង និងថាមពល ជាដើម។

**ខ- ហានិភ័យ និងបញ្ហាប្រឈមខាងក្នុងដែលកំពុងជួបប្រទះ និងបន្តជួបប្រទះទាំងក្នុងរយៈពេលខ្លី និងមធ្យម រួមមាន៖**

- ***ពាក់ព័ន្ធនឹងសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ***

ទី១. ការប៉ុនប៉ងជាបន្តបន្ទាប់ឥតឈប់ឈរ ពីសំណាក់ក្រុមអ្នកនយោបាយជ្រុលនិយមក្នុងការផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ តាមរយៈបដិវត្តពណ៌ ឬមធ្យោបាយមិនមែនប្រជាធិបតេយ្យ ដែលគំរាមកំហែងដល់សុខសន្តិភាពរបស់ប្រទេស និងប្រជាជន។

ទី២. ទំនាស់ដីធ្លី ការទន្ទ្រានដីរដ្ឋ និងការបំផ្លាញធនធានធម្មជាតិ នៅតែជាបញ្ហាស្មុគស្មាញដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាប្រចាំ។

ទី៣. គ្រឿងញៀន ក្មេងទំនើង ល្បែងស៊ីសង ល្បែងអនឡាញ ការជួញដូរមនុស្ស នៅតែជាបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់ការថែរក្សាសន្តិសុខ និងសុវត្ថិភាពនៅតាមមូលដ្ឋាន និងប៉ះពាល់ដល់កត្តិនាមរបស់កម្ពុជា។

ទី៤. បញ្ហាកិត្តិនាមរបស់កម្ពុជា ដែលត្រូវបានទទួលរងការវាយប្រហារ ជាបន្តបន្ទាប់ ជាពិសេសពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា បានធ្វើឱ្យប៉ះពាល់ខ្លាំងដល់ការសម្រេចចិត្តចូលមកកម្ពុជា របស់ទេសចរ និងវិនិយោគិនអន្តរជាតិ។

- ***សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងធុរកិច្ច***

ទី៥. កំណើនសេដ្ឋកិច្ចរួម សម្រេចបានលទ្ធផលល្អ ប៉ុន្តែវិស័យមួយចំនួនជាចន្ទល់នៃកំណើនរបស់កម្ពុជា មិនទាន់ងើបឡើងវិញពេញលេញនៅឡើយ ដូចជាវិស័យទេសចរណ៍ និងវិស័យសំណង់អចលនទ្រព្យជាដើម។ ម្យ៉ាងទៀត មូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ក៏មិនទាន់មានពិពិធកម្មគ្រប់គ្រាន់ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់លើការជំរុញ ទាំងប្រភពកំណើនថ្មី ដែលមានសក្តានុពលខ្ពស់ និងទាំងទីផ្សារថ្មីៗ។

ទី៦. បញ្ហាកង្វះកម្លាំងពលកម្ម និងជំនាញ បានចាប់ផ្តើមលេចជារូបរាងកាន់តែច្បាស់ ទោះបីជាកម្ពុជាមានចំនួនប្រជាជនក្នុងវ័យធ្វើការច្រើន ដោយសារមូលហេតុផ្សេងៗ រួមទាំងការធ្វើចំណាកស្រុកទៅក្រៅប្រទេស។ ករណីនេះ វិនិយោគិនតែងលើកឡើងអំពីការលំបាកក្នុងការស្វែងរកកម្លាំងពលកម្មសូម្បីកម្លាំងពលកម្មដែលមិនមានជំនាញ។

ទី៧. ការបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សា បន្តមានកម្រិតខ្ពស់ ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពមូលធនមនុស្ស ជារួម និងជាកត្តារួមចំណែកធ្វើឱ្យផលិតភាពសរុបរបស់ជាតិ បន្តមានកម្រិតទាប។

ទី៨. ប្រសិទ្ធភាពនៃយន្តការអន្តរាគមន៍របស់រដ្ឋ ក្នុងការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលថ្លៃកសិផលនៅលើទីផ្សារអន្តរជាតិនៅមានកម្រិត។

ទី៩. ការចាកចេញរបស់កម្ពុជា ពីចំណាត់ថ្នាក់ប្រទេសមានការអភិវឌ្ឍតិចតួចទាមទារឱ្យមាន ការកំណត់បញ្ហាប្រឈម និងការត្រៀមរៀបចំខ្លួនឱ្យបានច្បាស់លាស់។

ទី១០. ការកើនឡើងនូវសម្ពាធផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមូលដ្ឋានចំណូលនៅតូចចង្អៀត ទន្ទឹមនឹងភាពចាំបាច់ក្នុងការអនុវត្តវិធានការចំណាយសារពើពន្ធ (Tax Expenditure) និងការលើកទឹកចិត្តនានា ខណៈតម្រូវការចំណាយសម្រាប់ការអភិវឌ្ឍកាន់តែរីកធំ ហើយហិរញ្ញប្បទានក្រៅប្រទេសដែលមានកម្រិតសម្បទានខ្ពស់ក៏កាន់តែស្រកស្រុត។

ទី១១. បំណុលឯកជន និងបំណុលគ្រួសារបន្តស្ថិតក្នុងកម្រិតខ្ពស់ និងអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុជាទូទៅ។ ការណ៍នេះ ទាមទារឱ្យមានការដោះស្រាយ ដោយប្រយ័ត្នប្រយែង ក្នុងរយៈពេលមធ្យម។

ទី១២. បរិយាកាសធុរកិច្ចនៅមិនទាន់មានភាពប្រកួតប្រជែងខ្ពស់ ដោយសារភាពស្មុគស្មាញនៃនីតិវិធីក្នុងការស្នើសុំអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ វត្តមាននៃថ្លៃសេវាមិនផ្លូវការ តាមផ្នែកខ្លះ កិច្ចសម្រួលពាណិជ្ជកម្ម ការដឹកជញ្ជូន និងការតភ្ជាប់ នៅមិនទាន់មានភាពប្រសើរពេញលេញ នៅមានថ្លៃខ្ពស់ និងនៅមានប្រសិទ្ធភាពទាប ហើយភាពប៉ាន់ប្រមាណបាន និងតម្លាភាពជារួម សម្រាប់វិស័យឯកជននៅតែជាបញ្ហាដែលត្រូវបន្តដោះស្រាយបន្ថែមទៀត។

- ***ពាក់ព័ន្ធនឹងផ្នែកអភិបាលកិច្ច***

ទី១៣. រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របៀបរបបការងារ និងធនធានមនុស្សនៅតាមក្រសួង-ស្ថាប័នមួយចំនួន នៅមិនទាន់ឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងអាណត្តិរបស់ខ្លួន ស្របតាមការវិវត្តនៃស្ថានភាពបច្ចុប្បន្ន ដែលទាមទារឱ្យមានការធ្វើការពិនិត្យ វាយតម្លៃឡើងវិញ ព្រមទាំងការធ្វើការកែសម្រួលដើម្បីបង្កើនប្រសិទ្ធភាព។

ទី១៤. ធនធានហិរញ្ញវត្ថុសម្រាប់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត ដែលទាមទារឱ្យមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ភាពច្នៃប្រឌិត និងនវានុវត្តន៍។

ទី១៥. កិច្ចសម្របសម្រួលរវាងក្រសួង-ស្ថាប័ន និងការផ្តល់សេវាសាធារណៈនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់ ដែលតម្រូវឱ្យមានការគិតគូរបន្តដោះស្រាយ។

ទី១៦. គោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ត្រូវបានដាក់ចេញ តែប្រសិទ្ធភាពនៃការអនុវត្តនៅមានកម្រិតដោយអន្លើនៅឡើយ។

## ៣. ទិសដៅការងារ

ផ្នែកនេះ នឹងដកស្រង់ទិសដៅការងារ ដែលបានដាក់ចេញនៅក្នុងសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤៥ អាណត្តិទី៥ ដែលបានលើកឡើងដោយ ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់ដោះស្រាយបញ្ហាប្រឈមគន្លឹះ ដែលបានដាក់ចេញវិធានការជាក់លាក់ មានដូចខាងក្រោម÷

### ក. វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ទី១. បន្តរក្សាឱ្យបានដាច់ខាតនូវសន្តិភាព ឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

ទី២. បន្តជំរុញការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព បន្តបង្ក្រាបគ្រឿងញៀន ក្មេងទំនើង ល្បែងស៊ីសង ល្បែងអនឡាញ និងការជួញដូរមនុស្សតាមរយៈការអប់រំ និងពង្រឹងការអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់។

ទី៣. បង្កើតគណៈកម្មាធិការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ដែលជាយន្តការបំពេញបន្ថែម ដើម្បីសម្របសម្រួល និងគាំទ្រ ដល់ស្ថាប័នមានសមត្ថកិច្ច ប្រកបដោយសហថាមពល ក្នុងការប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

## ខ. នយោបាយការបរទេស

ទី៤. បន្តអនុវត្តគោលនយោបាយការទូតតាមគោលការណ៍ "កែទម្រង់ផ្ទៃក្នុង បង្កើនមិត្តខាងក្រៅ ដោយឈរលើស្មាតីឯករាជ្យ" និងអនុវត្ត "នយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ និងឈ្លាសវៃ" ដូចមានចែងនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

ទី៥. ពង្រឹងបន្ថែមទៀតនូវសហថាមពលរវាងការទូត គណបក្ស សភា និងរាជរដ្ឋាភិបាល ដើម្បីបង្កើនលម្អការទូត ជម្រើសគោលនយោបាយ និងភាពបត់បែនកាន់តែប្រសើរសម្រាប់នយោបាយការបរទេស។

## គ. វិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងធុរកិច្ច

ទី៦. បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាព និងបរិយាបន្ន នៃប្រព័ន្ធហិរញ្ញវត្ថុ និងពង្រឹងចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតលើការពង្រឹងការប្រមូលចំណូលឱ្យបានល្អ ការធានាវិន័យ និងប្រសិទ្ធភាពចំណាយសាធារណៈ ការកសាងឡើងវិញនូវប្រាក់សន្សំរបស់រាជរដ្ឋាភិបាល និងការធានាចីរភាពបំណុលសាធារណៈ។

ទី៧. បន្តតាមដាន និងគ្រប់គ្រងសតិអារម្មណ៍មហាជន ក៏ដូចជាដោះស្រាយនូវបញ្ហារសើបទាំងឡាយដែលកើតឡើងឱ្យបានទាន់ពេល និងមានប្រសិទ្ធផល ជាពិសេសបញ្ហាទាក់ទិនជីវភាពប្រចាំថ្ងៃរបស់ប្រជាជន រួមបញ្ចូលនូវបញ្ហាផលិតកម្ម និងតម្លៃស្រូវអង្ករ និងកសិផលសំខាន់ៗ។

ទី៨. បន្តតាមដាន និងវាយតម្លៃស្ថានភាពបំណុលឯកជន និងបំណុលគ្រួសារ ព្រមទាំងដាក់ចេញវិធានការឆ្លើយតបតាមតម្រូវការចាំបាច់ និងជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

ទី៩. ជំរុញការសាងសង់ "ព្រែកជីកហ្វូណនតេជោ" ជាមួយនឹងការរៀបចំបង្កើតតំបន់ពាណិជ្ជកម្មមជ្ឈមណ្ឌលភស្តុភារកម្ម និងផែរណបនៅសងខាងព្រែកជីកឱ្យបានសម្រេចជោគជ័យ។

ទី១០. បន្តកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ ដើម្បីលើកស្ទួយកម្រិតនៃភាពប្រកួតប្រជែងកម្ពុជាតាមរយៈការកែសម្រួលនីតិវិធីឱ្យកាន់តែសាមញ្ញ ជាមួយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ការពង្រឹងវិធាននៃច្បាប់ និងការអនុវត្តច្បាប់ ការរៀបចំក្របខ័ណ្ឌគតិយុត្តឱ្យបានពេញលេញ ការពិនិត្យកាត់បន្ថយថ្លៃសេវាផ្លូវការ ការលុបបំបាត់ថ្លៃសេវាមិនផ្លូវការ ការប្រឹក្សាយោបល់ជាទៀតទាត់ជាមួយវិស័យឯកជន និងការលើកកម្ពស់ភាពអាចប៉ាន់ប្រមាណបាន និងតម្លាភាព។

ទី១១. បន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ រួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ទាំងហេដ្ឋារចនាសម្ព័ន្ធរឹងខ្នង និងហេដ្ឋរចនាសម្ព័ន្ធមូលដ្ឋាន ដោយធ្វើអាទិភាវូបនីយកម្ម និងកំណត់ប្រភពថវិកា ឱ្យបានច្បាស់លាស់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិទាំងមូល។

ទី១២. ជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវ "កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកលដែលមានភាពមិនប្រាកដប្រជាខ្ពស់ ឆ្នាំ២០២៥-២០២៨"។

ទី១៣. ត្រៀមខ្លួនចាប់យកឱកាសឱ្យបានជាអតិបរមាពីការសើរើខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់ផ្គត់ផ្គង់ ដែលកើតចេញពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច តាមរយៈការជំរុញការរៀបចំតំបន់សេដ្ឋកិច្ចពិសេស ការសម្រួលពាណិជ្ជកម្ម ក៏ដូចជាការផ្តល់ការលើកទឹកចិត្ត និងភាពទាក់ទាញផ្សេងៗ សម្រាប់គម្រោងវិនិយោគសក្តានុពល។

ទី១៤. បន្តជំរុញការបើកទីផ្សារថ្មី តាមរយៈការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការពិចារណាលើការចូលរួមក្នុងយន្តការសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម កម្រិតតំបន់ ឬ សាកលលោក មួយចំនួន ដែលអាចផ្តល់ឱកាសឱ្យកម្ពុជាចាប់យកកាលានុវត្តភាព ដើម្បីជំរុញការអភិវឌ្ឍប្រទេសជាតិ។

ទី១៥. បន្តជំរុញការអនុវត្តកម្មវិធីពិសេសនានា រួមមានជាអាទិ៍÷ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៥", "ផែនការមេរយៈពេលវែងសំដៅប្រែក្លាយខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងអភិវឌ្ឍបណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជា ជារបៀងសេដ្ឋកិច្ចពហុបំណង និងប្រទាក់ក្រឡា" និង "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគពាយ័ព្យ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៥-២០២៨"។

## ឃ. អភិបាលកិច្ច

ទី១៦. បន្តកែទម្រង់ស្ថាប័នសាធារណៈ ជាពិសេសបន្តអនុវត្តការកែទម្រង់សំខាន់ ៣ បូក ២ រួមមាន÷ ការកែទម្រង់រដ្ឋបាលសាធារណៈ និងវិធានការគន្លឹះ, ការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់ច្បាប់ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងវិធានការគន្លឹះ។

ទី១៧. បន្តកែលម្អការផ្តល់សេវាសាធារណៈឱ្យបានលឿនរហ័សទាន់ចិត្ត មានតម្លាភាព ឆ្លើយតបបានទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន តាមរយៈការពង្រឹងសមត្ថភាពមន្ត្រី លើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ និងការអនុវត្តការងារតាមប្រព័ន្ធឌីជីថល។

ទី១៨. បន្តធានាយុត្តិធម៌សង្គមតាមរយៈការពង្រឹងការអនុវត្តច្បាប់ និងលើកកម្ពស់សិទ្ធិមនុស្ស តាមគោលការណ៍ នីតិរដ្ឋ ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទី១៩. បន្តជំរុញការអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការផ្សេងៗ ដែលបានដាក់ចេញរួចហើយ ព្រមទាំងធ្វើការតាមដាន និងវាយតម្លៃការអនុវត្ត ឱ្យបានច្បាស់លាស់ និងជាប់ជាប្រចាំ។

ទី២០. បន្តលើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ឈរលើអភិក្រម "ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ" តាមរយៈការដាក់ចេញនូវយន្តការច្បាស់លាស់ ឱ្យទទួលបន្ទុកមុខព្រួញការងារជាក់លាក់ ដោយបញ្ចៀសឱ្យបានដាច់ខាតនូវភាពត្រួតគ្នានៃសមត្ថកិច្ចស្ថាប័ន និងធានាធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលលើការងារដែលមានចរិតអន្តរក្រសួង-ស្ថាប័ន។

ទី២១. ជំរុញការអនុវត្តឱ្យសម្រេចបានប្រសិទ្ធភាពខ្ពស់នូវ "យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា" ដែលត្រូវបានដាក់ចេញ ក្នុងខែមករា ឆ្នាំ២០២៥ កន្លងទៅថ្មីៗនេះ។

### ង. វិស័យសង្គមកិច្ច

ទី២២. បន្តជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ប្រកបដោយភាពសកម្ម និងមានប្រសិទ្ធភាព ដោយក្រសួង-ស្ថាប័នទាំងអស់ ត្រូវខិតខំយកចិត្តទុកដាក់អនុវត្តនូវគោលនយោបាយ និងវិធានការនានា ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ឱ្យបានប្រសើរ និងសម្រេចបានលទ្ធផលច្បាស់លាស់។ រាជរដ្ឋាភិបាលនឹងអនុវត្តដោយម៉ត់ចត់នូវយន្តការពិនិត្យ តាមដាន និងវាយតម្លៃ (M&E) លើការអនុវត្តយុទ្ធសាស្ត្រ កម្មវិធី និងវិធានការគន្លឹះនានា ដែលត្រូវបានដាក់ចេញ។

ទី២៣. បន្តជំរុញការអនុវត្តកម្មវិធីអាទិភាពទាំង៦ និងវិធានការគន្លឹះទាំង៥ ដោយក្នុងនោះផ្តោតលើការយកចិត្តទុកដាក់បន្ថែម ដល់ការជំរុញសហថាមពលរវាងកម្មវិធីបណ្តុះបណ្តាលជំនាញ ជាមួយនឹងវិធានការគន្លឹះក្នុងវិស័យអប់រំ ព្រមទាំងតាមដាន វាយតម្លៃ និងដាក់ចេញ នូវវិធានការកែសម្រួលកម្មវិធីអាទិភាព និងវិធានការគន្លឹះនីមួយៗ តាមការចាំបាច់។

## IV. ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីពង្រឹងប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** រាជរដ្ឋាភិបាលបានផ្តោតសំខាន់លើការងារកែទម្រង់លើគ្រប់វិស័យនិងកាន់តែស៊ីជម្រៅ ដែលជាកម្លាំងស្នូលនៃការពង្រឹងនិងធានានូវលទ្ធផលជោគជ័យនៃគោលដៅអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច។ ក្នុងនោះ ការពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ជាផ្នែកមួយដ៏សំខាន់នៃការងារកែទម្រង់ ក៏ដូចជាឧបករណ៍ដ៏ចាំបាច់សម្រាប់ជំរុញ និងវាស់វែងសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ សម្រាប់២៥ឆ្នាំទៅមុខ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដោយប្រើប្រាស់អភិក្រម "**អភិវឌ្ឍ និងកែលម្អជាបន្តបន្ទាប់**" ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវការកសាង "**ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាតិ**" ដែលមានភាពប្រទាក់ក្រឡាសមាហរណកម្ម និងសុខដុមនីយកម្មប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគ្រប់កម្រិត តាមរយៈការធ្វើស្ថាប័នីយកម្មការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការពង្រឹង និងកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស និងការរៀបចំ និងកសាងលិខិតបទដ្ឋានគតិយុត្ត និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា។

ក្នុងក្របខ័ណ្ឌនៃទស្សនវិស័យនេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូន **គណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** (គ.យ.ប.) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ទទួលបន្ទុកសម្របសម្រួលរួម តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ជំរុញ តម្រង់ទិស និងផ្តល់អនុសាសន៍ដល់ការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់ក្រសួង-ស្ថាប័នទាំងអស់ ព្រមទាំងដាក់ឱ្យអនុវត្ត "**ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**" ដែលជាឧបករណ៍ដ៏សំខាន់សម្រាប់ **១).** វាស់វែង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម **២).** លើកកម្ពស់នូវគណនេយ្យភាពរបស់ក្រសួង-ស្ថាប័ន លើការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធ និង **៣).** តម្រង់ទិសដល់ការរៀបចំយុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយនានា ព្រមទាំងយន្តការអនុវត្ត ជាបន្តបន្ទាប់ឱ្យកាន់តែប្រសើរឡើង។

### ១. គោលបំណង អភិក្រម និងគោលការណ៍

ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ (M&E-PS1) នេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីគាំទ្រ និងជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ប្រកបដោយភាពជោគជ័យ តាមរយៈការដ្ឋានការងារចំនួន៣÷

- **ទី១.** ការកសាងមូលដ្ឋានគ្រឹះសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលមានជាអាទិ៍ វិធីសាស្ត្រ និងឧបករណ៍ ការកំណត់តួនាទីនិងភារកិច្ច ការពង្រឹងប្រព័ន្ធនិងសមត្ថភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ របស់ក្រសួង-ស្ថាប័ន ប្រព័ន្ធរំហូររបាយការណ៍ ប្រព័ន្ធស្ថិតិនិងព័ត៌មាន ព្រមទាំងការផ្សព្វផ្សាយលទ្ធផល នៃការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ។
- **ទី២.** ការផ្តល់ជាគោលការណ៍ណែនាំ ដើម្បីផ្សារភ្ជាប់យុទ្ធសាស្ត្របញ្ចកោណទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលជាឧបករណ៍គោលនយោបាយក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ការចង្អុលបង្ហាញ អាទិភាពគោលនយោបាយ និងជាយុទ្ធសាស្ត្រដល់ក្រសួង-ស្ថាប័ន សម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍អន្តរវិស័យ និងតាមវិស័យ និងការផ្តល់មូលដ្ឋានសម្រាប់ការរៀបចំផែនការ និងការវិភាជថវិកាជាតិ។
- **ទី៣.** ការផ្តល់អនុសាសន៍សម្រាប់តម្រង់ទិស និងកែសម្រួលគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យ ផែនការតាមវិស័យ និងយន្តការអនុវត្តរបស់គ្រប់ក្រសួង-ស្ថាប័ន។

**រូបភាពទី៣- ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**




ឈរលើមូលដ្ឋាននេះ ការរៀបចំឯកសារក្របខ័ណ្ឌនេះ ដោយប្រើប្រាស់នូវអភិក្រម ៤ គឺ ការរៀបចំក្របខ័ណ្ឌនេះ ផ្អែកលើអភិក្រមចំនួន៤ ដូចខាងក្រោម÷

**១). ស្តង់ដាអប្បបរមា (Minimum Standard)** សំដៅដល់ការប្រកាន់យកស្តង់ដាគុណភាពមួយដែលសមរម្យ និងស្ថិតក្នុងកម្រិតអាចទទួលយកបាន ធៀបនឹងឧត្តមានុវត្តអន្តរជាតិ។

**២). បរិបទភាព** (Contextuality) សំដៅដល់ភាពដែលអាចអនុវត្តបានស្របតាមបរិបទនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេស ធានាថា គ្រប់ក្រសួង-ស្ថាប័ន មានសមត្ថភាព ក្នុងការអនុវត្តកិច្ចការពាក់ព័ន្ធ។

**៣). សាមញ្ញភាព** (Simplicity) សំដៅដល់ប្រព័ន្ធមួយដែលមានលក្ខណៈទំនើប (Sophisticated) ប៉ុន្តែអាចផ្តល់ភាពងាយស្រួលដល់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធអាចអនុវត្តបានដោយរលូន និងទាន់ពេល។

**៤). សមិទ្ធិលទ្ធភាព** (Feasibility) សំដៅដល់ការកំណត់លក្ខខណ្ឌ ដែលក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធអាចអនុវត្តបានស្របតាមលទ្ធភាពនៃធនធានផ្សេងៗ ក្នុងការអនុវត្តកិច្ចការរបស់ខ្លួនដែលបានកំណត់។

ជាមួយគ្នានេះ ក្របខ័ណ្ឌនេះមានគោលការណ៍គ្រឹះនៃការអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដូចខាងក្រោម÷

**១). ប្រសិទ្ធភាព** (Efficiency) : គ្រប់ក្រសួង-ស្ថាប័នត្រូវអនុវត្តក្របខ័ណ្ឌនេះ ដោយប្រើប្រាស់ធនធានដូចជាថវិកា ពេលវេលា និងមនុស្ស ជាដើម ក្នុងកម្រិតអប្បបរមា។

**២). សក្តិសិទ្ធិភាព** (Effectiveness) : គ្រប់ក្រសួង-ស្ថាប័នត្រូវអនុវត្តក្របខ័ណ្ឌនេះ ដើម្បីសម្រេចឱ្យបាននូវចំណុចដៅដែលបានកំណត់ឱ្យទាន់ពេល។

**៣). គណនេយ្យភាព** (Accountability) : គ្រប់ក្រសួង-ស្ថាប័នត្រូវអនុវត្តក្របខ័ណ្ឌនេះ ប្រកបដោយវិជ្ជាជីវៈ និងមិនលម្អៀងលើសមិទ្ធកម្ម លទ្ធផល និងការរំពឹងទុកនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

**៤). ភាពជាម្ចាស់** (Ownership): គ្រប់ក្រសួង-ស្ថាប័នអនុវត្តក្របខ័ណ្ឌនេះ ត្រូវមានស្វយ័តភាព និងឯករាជ្យភាពលើកិច្ចការ ដែលស្ថិតក្រោមអាណត្តិកិច្ចរបស់ខ្លួន។

**៥). ជវភាពនៃប្រព័ន្ធតួអង្គតែមួយ** (Dynamics of Stakeholder System) : គ្រប់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវបំពេញតួនាទីរៀងៗខ្លួន ដោយមិនចោទប្រកាន់គ្នាទៅវិញទៅមក និងត្រូវសម្របសម្រួល និងសហការគ្នាជិតស្និទ្ធ ដើម្បីចូលរួមក្នុងដំណើរការ និងនីតិវិធីនៃការរៀបចំ និងអនុវត្តក្របខ័ណ្ឌនេះ។

## ២. យន្តការតាមដាន និងត្រួតពិនិត្យ

ដើម្បីផ្តល់ភាពងាយស្រួលដល់ក្រសួងស្ថាប័នទទួលបន្ទុកអនុវត្តក្របខ័ណ្ឌនេះ បានរំលេចនូវដំណើរការនៃការតាមដាន និងត្រួតពិនិត្យ ដែលជាវិហ្វូវនៃការរាយការណ៍វឌ្ឍនភាពការងារ ដែលត្រូវបានកំណត់ដូចនៅក្នុងរូបភាពទី៤នេះ។

## រូបភាពទី៤- យន្តការនៃការរាយការណ៍ការ តាមដាន និងត្រួតពិនិត្យ




យន្តការតាមដាន និងត្រួតពិនិត្យ គឺជាមុខងារគ្រប់គ្រង ដែលពាក់ព័ន្ធនឹងដំណើរការនៃការប្រមូល និងចងក្រងសមិទ្ធកម្ម ឬលទ្ធផលជាក់ស្ដែង នៃការអនុវត្តផែនការសកម្មភាព ដើម្បីសម្រេចបាននូវចំណុចដៅរបស់សូចនាករសមិទ្ធកម្មគន្លឹះ ដែលបានកំណត់នៅក្នុងតារាងម៉ាទ្រីសវាស់វែងសមិទ្ធកម្ម។ ក្នុងនោះ ការត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាព និងការចុះពិនិត្យដល់ទីកន្លែង ព្រមទាំងកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ អាចត្រូវបានធ្វើឡើងដើម្បីបញ្ជាក់អំពីវឌ្ឍនភាពនៃការអនុវត្ត ផ្ទៀងផ្ទាត់ និងផ្ដល់សុពលភាព ឬស្វែងរកមូលហេតុ និងភស្តុតាងឱ្យបានច្បាស់លាស់ ក្នុងករណីដែលការអនុវត្តមិនសម្រេចតាមការគ្រោងទុក ឬ មានវឌ្ឍនភាពយឺតយ៉ាវ។

វិសាលភាពនៃយន្តការតាមដាន និងត្រួតពិនិត្យនេះ គឺផ្ដោតលើវឌ្ឍនភាពការងារនៃការអនុវត្ត KPIs យុទ្ធសាស្ត្រ ដែលមានលទ្ធផលសម្រេចបាននៅក្នុងឆ្នាំនីមួយៗ ហើយចំពោះវឌ្ឍនភាពនៃសូចនាករសមិទ្ធកម្មគន្លឹះ ដែលតម្រូវឱ្យមានការអង្កេត ត្រូវធ្វើឡើងទៅតាមប្រេកង់ ឬក្របខ័ណ្ឌពេលវេលា ដែលបានកំណត់។ ក្រសួង-ស្ថាប័ន ទទួលបន្ទុកដឹកនាំ និងចូលរួមអនុវត្តដែលមានកំណត់នៅក្នុងតារាងម៉ាទ្រីសវាស់វែងសមិទ្ធកម្ម ត្រូវផ្ទៀងផ្ទាត់ និងបូកសរុបលើព័ត៌មានស្ថិតិ និងទិន្នន័យ សម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាព រួចបញ្ជូនទៅក្រសួងផែនការ។ ក្នុងករណីក្រុមប្រឹក្សា អាជ្ញាធរ និងគណៈកម្មាធិការ ឬក្រុមការងារនានា ដែលត្រូវបានប្រគល់ភារកិច្ចដោយរាជរដ្ឋាភិបាលក្នុងការធ្វើការតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ គោលនយោបាយ កម្មវិធីគោលនយោបាយអាទិភាព និងវិធានការគន្លឹះដោយឡែក ដែលមិនមែនជាស្ថាប័នទទួលបន្ទុកអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះ ដែលកំណត់ក្នុងក្របខ័ណ្ឌនេះ ហើយមានអាណត្តិកិច្ចរាយការណ៍ដោយផ្ទាល់ជូន **សម្ដេចធិបតីនាយករដ្ឋមន្ត្រី**/គណៈរដ្ឋមន្ត្រី ត្រូវចម្លងរបាយការណ៍វឌ្ឍនភាពរបស់ខ្លួនជូនក្រសួងផែនការ។ បន្ទាប់ពីទទួល

របាយការណ៍វឌ្ឍនភាព ក្រសួងផែនការ ត្រូវផ្ញើមក គ.យ.ប. ឱ្យបានឆាប់ ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើសុពលភាពលើរបាយការណ៍នោះ។ បន្ទាប់មកទៀត គ.យ.ប. ត្រូវរៀបចំរបាយការណ៍តាមដាន និងត្រួតពិនិត្យ និងលើកសំណើនូវអនុសាសន៍នានា ព្រមទាំងរាយការណ៍លទ្ធផលនៃការបូកសរុប និងវាយតម្លៃជូន ក)- **សម្តេចធិបតី នាយករដ្ឋមន្ត្រី** និង ខ)- គណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសម្រេច។

ការចាត់ថ្នាក់លទ្ធផលសម្រេចបាននៃការអនុវត្តផែនការសកម្មភាពនានាធៀបនឹងចំណុចដៅ ដើម្បីសម្រេចបានសូចនាករសមិទ្ធកម្មគន្លឹះ ត្រូវបានកំណត់ក្នុងតារាងខាងក្រោម ពោលគឺ÷ ល្អប្រសើរ ល្អ ល្អបង្គួរ មធ្យម និងមិនពេញចិត្ត ដោយផ្អែកទៅតាម "កម្រិតសម្រេចបានធៀបនឹងចំណុចដៅ" ដូចមាននៅក្នុងតារាងទី១ ខាងក្រោម÷

**តារាងទី១- ការចាត់ថ្នាក់សម្រាប់ការតាមដាននិងត្រួតពិនិត្យ**

| កម្រិតសម្រេចបានធៀបនឹងចំណុចដៅ | កម្រិតវឌ្ឍនភាព |
|---|---|
| ៩០% - ១០០% | ល្អប្រសើរ |
| ៧៦% - ៨៩% | ល្អ |
| ៦៦% - ៧៥% | ល្អបង្គួរ |
| ៥០% - ៦៥% | មធ្យម |
| តិចជាង៥០% | មិនពេញចិត្ត |

### ៣. យន្តការវាយតម្លៃ

ការវាយតម្លៃ គឺជាការពិនិត្យវិនិច្ឆ័យការវិភាគស៊ីជម្រៅ និងការស្វែងរកហេតុផលផ្អែកលើភស្តុតាងនៃការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីរបស់រាជរដ្ឋាភិបាល។ ការវាយតម្លៃនេះ មានវិសាលភាពលើទាំងការវាយតម្លៃដំណើរការ ព្រមទាំងការវាយតម្លៃលើលទ្ធផល និងកម្មវិបាក។ វិធីសាស្ត្រនៃដំណើរការនៃការវាយតម្លៃរួមមាន÷ ការពិនិត្យឯកសារ (Desk Review), សម្ភាសន៍ (Interview), ការពិភាក្សាជាក្រុម (Focus Group), ការអង្កេត (Survey), ករណីសិក្សា (Case Study) និងបេសកកម្មដល់ទីកន្លែង (Field Mission) ជាដើម។

ក្របខ័ណ្ឌ M&E-PS1 នេះ កំណត់នូវប្រភេទការវាយតម្លៃចំនួន ៣ គឺ **ទី១). ការវាយតម្លៃពាក់កណ្តាលអាណត្តិ**÷ កំណត់ការកែតម្រូវចាំបាច់ណាមួយនៅក្នុងវិធានការគោលនយោបាយ និងយន្តការអនុវត្ត ផ្តល់ឱ្យភាគីពាក់ព័ន្ធនូវការបង្ហាញដំបូងនៃលទ្ធផលសំខាន់ៗ **ទី២). ការវាយតម្លៃចុងអាណត្តិ**÷ ប្រមើលមើលនូវលទ្ធផល និងកម្មវិបាករយៈពេលមធ្យម និងវែងមកលើវឌ្ឍនភាព និងការផ្លាស់ប្តូរជារចនាសម្ព័ន្ធនៃសង្គម-សេដ្ឋកិច្ចកម្ពុជា, ផ្តល់នូវបទពិសោធនិងឧត្តមានុវត្តន៍នៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ និង**ទី៣). ការវាយតម្លៃបន្ទាន់**÷ កំណត់ឱ្យបានឆាប់រហ័សនូវឫសគល់នៃបញ្ហា ដើម្បីជៀសវាងនូវការជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរដល់ភាពជោគជ័យ នៃការអនុវត្តយុទ្ធសាស្ត្រទាំងមូល & ផ្តល់នូវអនុសាសន៍កែលម្អ និងដំណោះស្រាយទាន់ពេលវេលា ដែលអាចឱ្យភាគីពាក់ព័ន្ធធ្វើការកែតម្រូវបានឆាប់រហ័ស។

## ៤. ការរាយការណ៍ និងការប្រើប្រាស់លទ្ធផល

របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានកំណត់ក្នុងទម្រង់ជា ៤ ប្រភេទ ដូចខាងក្រោម÷

១). របាយការណ៍តាមដាន និងត្រួតពិនិត្យ ផ្តោតលើការតាមដានវឌ្ឍនភាពនៃការអនុវត្តការងាររបស់ក្រសួង-ស្ថាប័នទាំងអស់ ដើម្បីកំណត់អំពីកត្តាដែលចូលរួមចំណែក ឬបញ្ហាប្រឈមសមិទ្ធកម្ម (Performance Problems) ដើម្បីសម្រេចបាននូវលទ្ធផល (Outcomes) ដែលកំណត់នៅក្នុងក្របខ័ណ្ឌនេះ។(ត្រូវរាយការណ៍យ៉ាងយូរ ១ខែ ក្រោយការបញ្ចប់ឆមាស/ឆ្នាំនីមួយៗ ឬត្រូវរាយការណ៍យ៉ាងយូរ ២ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ)

២). របាយការណ៍វាយតម្លៃបន្ទាន់ ដែលរាជរដ្ឋាភិបាលអាចប្រគល់ភារកិច្ចជូន គ.យ.ប. ក្នុងការរៀបចំរបាយការណ៍វាយតម្លៃបន្ទាន់ពាក់ព័ន្ធនឹងបញ្ហាប្រឈមគន្លឹះអន្តរវិស័យ វិស័យ និងមុខងារស្នូល និងអាទិភាពសំខាន់ៗ។

៣).របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ផ្តោតលើការវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ដើម្បីសម្រេចនូវចំណុចដៅរបស់សូចនាករសមិទ្ធកម្មគន្លឹះ ធៀបនឹងចំណុចដៅដែលកំណត់នៅក្នុងក្របខ័ណ្ឌនេះ។ (ត្រូវរាយការណ៍យ៉ាងយូរត្រឹមខែកុម្ភៈ ឆ្នាំ២០២៦)

៤).របាយការណ៍វាយតម្លៃចុងអាណត្តិ គ្របដណ្តប់លើការវាយតម្លៃលើលទ្ធផល ធៀបនឹងចំណុចដៅដែលកំណត់នៅក្នុងក្របខ័ណ្ឌនេះ ព្រមទាំងការវាយតម្លៃតាមមូលបទ ដើម្បីធានាការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ សម្រេចបាននូវគោលដៅយុទ្ធសាស្ត្រដែលបានដាក់ចេញ។ (ត្រូវរាយការណ៍យ៉ាងយូរត្រឹមខែកុម្ភៈ ឆ្នាំ២០២៨)

បន្ថែមលើនេះ អ្នកប្រើប្រាស់លទ្ធផលសំខាន់ៗ នៃរបាយការណ៍ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមានដូចខាងក្រោម÷

១).**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** និង គណៈរដ្ឋមន្ត្រី ពិនិត្យ និងផ្តល់គោលការណ៍ ណែនាំលើសមិទ្ធផល ដែលសម្រេចបាន និងផ្តល់អនុសាសន៍សម្រាប់តម្រង់ទិស ដែលស្នើឡើងដោយ គ.យ.ប. ដើម្បីកែសម្រួលគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមវិស័យ។

២). គ.យ.ប. ពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំ ដឹកនាំពិនិត្យ និងវាយតម្លៃលើរបាយការណ៍ និងជំរុញការដោះស្រាយបញ្ហាប្រឈមបន្ទាន់នានា និងលើកអនុសាសន៍តម្រង់ទិសជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច ក្នុងករណីចាំបាច់។

៣). ក្រសួង-ស្ថាប័ន ត្រូវកែសម្រួលគោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍តាមវិស័យ និងការអនុវត្តនានា តាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ គ្រប់អង្គភាពចំណុះក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវអនុវត្តត្រូវកែសម្រួលផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រថវិកា។

៤).ភាគីពាក់ព័ន្ធដទៃទៀត មានដូចជាវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ជាដើម ជ្រាបជាព័ត៌មានអំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

## ៥. សូចនាករសមិទ្ធកម្មគន្លឹះ

សេចក្តីព្រាងក្របខ័ណ្ឌ M&E-PS1 កំណត់យកសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) យុទ្ធសាស្ត្រ និងកែទម្រង់ មានសរុប ៣៩ KPIs ដូចខាងក្រោម:

១). អត្រាកំណើនពិត នៃ ផ.ស.ស.

២). ផ.ស.ស. សម្រាប់ប្រជាជនម្នាក់

៣). អត្រាអតិផរណា

៤). អត្រាគ្មានការងារធ្វើ

៥). អត្រាកំណើនប្រាក់ឈ្នួលពិតប្រចាំឆ្នាំ

៦). សមាមាត្រនៃប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ

៧). មេគុណជីនី

៨). អនុបាតតម្លៃបាត់បង់ និងខូចខាតដោយគ្រោះមហន្តរាយធម្មជាតិធៀបនឹង ផ.ស.ស.

៩). បរិមាណសរុបនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

១០). ការយល់ឃើញរបស់ប្រជាពលរដ្ឋ លើប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងសេវារដ្ឋបាល ជូនប្រជាពលរដ្ឋ

១១). ការយល់ឃើញរបស់ធុរជន លើប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងការវិនិយោគ និងធុរកិច្ច

១២). ការយល់ឃើញរបស់ប្រជាពលរដ្ឋ និងធុរជន លើលទ្ធផលនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌

១៣). អត្រាបទល្មើសពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងចំណោមប្រជាជន ១០០ ០០០នាក់

១៤). អនុបាតតុល្យភាពថវិកាធៀបនឹង ផ.ស.ស.

១៥). អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផ.ស.ស.

១៦). ពិន្ទុនៃក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)

១៧). លទ្ធផលនៃកម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិ (PISA)

១៨). អត្រារួមនៃការសិក្សា

១៩). អត្រាបោះបង់ការសិក្សា

២០). សន្ទស្សន៍ការគ្របដណ្តប់សេវាសុខាភិបាលសារវន្ត

២១). ភាគរយនៃមូលដ្ឋានសុខាភិបាល ដែលទទួលបានពិន្ទុមធ្យមនៃគុណភាពសេវាថែទាំសុខភាពលើសពី ៥០%

២២). អត្រានៃការពេញចិត្តរបស់អ្នកជំងឺ/អតិថិជន ចំពោះសេវាថែទាំសុខភាពដែលផ្តល់ដោយមណ្ឌលសុខភាព/មន្ទីរពេទ្យបង្អែក

២៣). ភាគរយនៃក្រុមគ្រួសារក្រីក្រដែលទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គម

២៤). ចំណែកទំហំទុនវិនិយោគបរទេសក្នុងវិស័យឧស្សាហកម្មគន្លឹះថ្មីៗ ធៀបនឹងទំហំទុនវិនិយោគបរទេសសរុបក្នុងវិស័យឧស្សាហកម្ម

២៥). ពិន្ទុនៃសន្ទស្សន៍ប្រតិបត្តិការភស្តុភារកម្ម

២៦). ពិន្ទុនៃសន្ទស្សន៍ត្រៀមខ្លួនរួចរាល់សម្រាប់ធុរកិច្ច

២៧). ចំនួនទេសចរអន្តរជាតិ

២៨). អត្រាតម្លៃបន្ថែមសុទ្ធនៃវិស័យទេសចរណ៍ដែលកម្ពុជាទទួលបាន

២៩). ភាគរយនៃការអនុវត្តអភិក្រមទាំង៤វិស័យអគ្គិសនី

៣០). ចំនួនសហគ្រាសធុនតូច និងមធ្យមផ្លូវការសរុប

៣១). ចំនួនសហគ្រាសធុនតូច និងមធ្យមផ្លូវការដែលធ្វើការនាំចេញ

៣២). ចំនួនសហគ្រាសធុនតូច និងមធ្យម ផ្សារភ្ជាប់នឹងសហគ្រាសមានប្រភពទុនវិនិយោគផ្ទាល់បរទេស

៣៣). ការយល់ឃើញអំពីស្ថានភាពកម្លាំងពលកម្មកម្ពុជា

៣៤). ការយល់ឃើញរបស់ធុរជន និងសាធារណជនលើការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

៣៥). សមាមាត្រនៃផលិតផលកសិកែច្នៃធៀបនឹងផលិតផលកសិកម្មក្នុងស្រុកសរុប

៣៦). សមតុល្យពាណិជ្ជកម្មកសិកម្ម

៣៧). អនុបាតដែលអាចផ្គត់ផ្គង់ស្បៀងបានគ្រប់គ្រាន់ដោយខ្លួនឯង

៣៨). សន្ទស្សន៍នៃការកសាងមូលដ្ឋានគ្រឹះឌីជីថល

៣៩). សន្ទស្សន៍នៃការចាប់យកឌីជីថល។

## ៦. តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

ដើម្បីសម្រេចបានការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ គឺមានសារៈសំខាន់ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

១). **ការរៀបចំផែនការ÷** រដ្ឋបាលរាជធានី-ខេត្ត ត្រូវរៀបចំផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត និងផែនការយុទ្ធសាស្ត្រថវិកា ត្រូវផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការអភិវឌ្ឍន៍តាមវិស័យ។

២). **ការចូលរួម និងសហការ÷** រដ្ឋបាលរាជធានី-ខេត្តត្រូវចូលរួម និងសហការជាមួយរដ្ឋបាលថ្នាក់ជាតិក្នុងការរៀបចំអនុវត្ត និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជាពិសេសចូលរួមជាមួយក្រសួង-ស្ថាប័ន ដឹកនាំការអនុវត្តក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

៣). **ការអនុវត្ត និងការផ្តល់សេវា÷** ដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការងារដោយផ្ទាល់ជាមួយប្រជាជន ដូច្នេះក្រសួង-ស្ថាប័នត្រូវ ក).អនុវត្តផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត និងផែនការយុទ្ធសាស្ត្រថវិកា ឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងទទួលបានជោគជ័យ ខ).ពង្រឹងអភិបាលកិច្ច ការផ្គត់ផ្គង់សេវាសាធារណៈ រចនាសម្ព័ន្ធរូបវន្ត និងការការពារបរិស្ថាន និង គ).ពង្រឹងសុខុមាលភាព និងការយកចិត្តទុកដាក់លើផលប្រយោជន៍ជាតិ និងប្រជាជន។

៤). **ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** : រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវ ក).រៀបចំផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ខ).តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងគ).អនុវត្តអនុសាសន៍ពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើផែនការអភិវឌ្ឍន៍រាជធានី-ខេត្តនីមួយៗ។

## V. សេចក្តីសន្និដ្ឋាន[3]

បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ សិក្ខាកាម គួរបានយល់យ៉ាងច្បាស់អំពី ១).ដំណើរការនៃការរៀបចំយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលជាមូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គឺកម្មវិធីគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ២០២៣-២០២៨ ២).ខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានរៀបចំផ្អែកលើសមិទ្ធផលក្នុងរយៈពេល២៥ឆ្នាំកន្លងមក ជាមួយនឹងការសម្លឹងទៅមុខក្នុងរយៈពេល២៥ឆ្នាំ ជាពិសេសបានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រទាំង ៥ អាទិភាពគោលនយោបាយទាំង៦ និងកំណត់ស្ថលបរិស្ថានគ្របដណ្តប់ និងកោណទាំង៥ ៣).ការចូលរួមរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដោយមានភាពប្រទាក់ក្រឡាវាងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត និងផែនការយុទ្ធសាស្ត្រថវិកា ក្នុងនោះក៏បានសង្កត់ធ្ងន់អំពីការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ផងដែរ ៤).យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយបានរំលេចច្បាស់អំពីគោលបំណង និងយន្តការ តាមដាន និងត្រួតពិនិត្យ ក៏ដូចជាយន្តការវាយតម្លៃ ៥).សមិទ្ធផល និងបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត កន្លងមក បានបង្ហាញអំពីសមិទ្ធផលជាច្រើន ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានក្នុងឆ្នាំ២០២៤

[3] ឯកសារនេះជាឯកសាររស់ ដែលនឹងអាចកែសម្រួល និងកែលម្អបន្ថែមទៀត ដើម្បីឱ្យស្របទៅនឹងការរីកចម្រើន និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

និងបានលើកយកបញ្ហាប្រឈមគន្លឹះសម្រាប់ដោះស្រាយក្នុងរយៈពេលបន្ទាន់ ខ្លី មធ្យម និងវែងខាងមុខ និង ៦). ទិសដៅការងាររបស់គណបក្សប្រជាជនកម្ពុជា ដោយបានដកស្រង់អំពីទិសដៅការងារ ដែលជារបាយការណ៍ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អនុប្រធានគណបក្ស និងជានាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា** ជូនសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៤៥ អាណត្តិទី៥។

ជារួម សិក្ខាកាមគួរប្រើប្រាស់ឯកសារនេះ និងចំណេះដឹងផ្សេងៗដែលទទួលបានក្នុងសិក្ខាសាលា សម្រាប់បង្រៀនសមាជិក សមាជិកា របស់គណបក្សប្រជាជនកម្ពុជា ជាពិសេស រំលេចឱ្យបានច្បាស់លាស់ ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ អំពីការគិតគូររៀបចំ និងការអនុវត្តគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការនានា ខ្លឹមសាររបស់ឯកសារទាំងនោះ និងសមិទ្ធផលដែលសម្រេចបានដោយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា។ ទន្ទឹមនេះ សម្រាប់សមាជិក សមាជិកាគណបក្ស ប្រជាពលរដ្ឋទូទៅ ឬមជ្ឈដ្ឋានគោលដៅណាមួយ ដែលត្រូវទទួលការបង្រៀន ពន្យល់ ឆ្លើយតប ឬបកស្រាយនឹងសំណួរផ្សេងៗ គ្រូបង្គោលគួរចាប់យកតែខ្លឹមសារសំខាន់ៗ នៃគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការនានារបស់គណបក្ស ដែលមានភាពពាក់ព័ន្ធ និងមានភាពចាំបាច់សម្រាប់ក្រុមជនគោលដៅទាំងនោះ ដើម្បីបង្កើនការយល់ដឹង និងស្រាយបំភ្លឺឱ្យចំគោលដៅប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព៕

# បរិសិដ្ឋ

## សមិទ្ធផលធំៗរយៈពេល ២៥ ឆ្នាំកន្លងមក

ក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយ បន្ទាប់ពីការសម្រេចបាននូវ សុខសន្តិភាពពេញលេញ ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង តាមរយៈនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភា** រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល ដោយសម្រេចបានសមិទ្ធផលធំៗលើគ្រប់វិស័យ ទាំងខាងនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងទាំងខាងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ទោះបីជាត្រូវប្រឈមនឹងសភាពការណ៍ប្រែប្រួលផ្នែកនយោបាយ និងបញ្ហាប្រឈមថ្មីៗ ពាក់ព័ន្ធនឹងវិបត្តិសុខភាពសាធារណៈធ្ងន់ធ្ងរ ជម្លោះភូមិសាស្ត្រនយោបាយសកល ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល ការគំរាមចំពោះអធិបតេយ្យជាតិនិងបូរណភាពទឹកដី គ្រោះធម្មជាតិផ្ទួនៗ និងតម្រូវការដោះស្រាយសំណូមពររបស់ប្រជាជនគ្រប់ស្រទាប់។ ក្នុងការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល រយៈពេល ២៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលធំៗ ដូចខាងក្រោម÷

### ១. ផ្នែកនយោបាយ និងការទូត

តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** កម្ពុជាសម្រេច និងរក្សាបាននូវចីរភាពនៃសុខសន្តិភាពពេញលេញ ចាប់តាំងពីចុងឆ្នាំ១៩៩៨មក ក៏ដូចជារក្សាការពារបានយ៉ាងរឹងមាំនូវអធិបតេយ្យ សណ្តាប់ធ្នាប់សង្គម សន្តិសុខ សុវត្ថិភាពសង្គម និងស្ថិរភាពនយោបាយ ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការពង្រឹងសាមគ្គីភាពផ្ទៃក្នុង ការទប់ស្កាត់ដោយជោគជ័យប្រឆាំងនឹងឧបាយកលនានា ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ការការពារប្រទេសជាតិមិនឱ្យធ្លាក់ចូលក្នុងកលិយុគ ការប្រយុទ្ធប្រឆាំងនឹងវិបត្តិខាងក្រៅ និងការរក្សាបានស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច ដែលទាំងអស់នេះ គឺជាបុរេលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកិច្ចការការទូតប្រកបដោយភាពទន់ភ្លន់ និងឈ្លាសវៃផ្អែកលើមូលដ្ឋានច្បាប់និងផលប្រយោជន៍ជាតិ ស្របតាមបាវចនា "កែទម្រង់ខាងក្នុង កសាងមិត្តខាងក្រៅ ដោយឈរលើស្មារតីឯករាជ្យ"។ ក្នុងរយៈពេល ២៥ឆ្នាំកន្លងមកនេះ កម្ពុជាបានសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចជាការធ្វើជាប្រធានអាស៊ាន ចំនួន៣លើក ដោយបានដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធប្រកបដោយជោគជ័យ បានជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការរៀបចំនៃគណៈកម្មាធិការកសាងសន្តិភាព (OCPBC) សម្រាប់អាណត្តិ២០២៥-២០២៦ ការទទួលធ្វើជាប្រធានសម្របសម្រួលនៃប្រទេសមានការអភិវឌ្ឍតិចតួច ជាអនុប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ និងសមាជិកក្រុមប្រឹក្សាសង្គម-សេដ្ឋកិច្ច នៃអង្គការសហប្រជាជាតិ និងការបញ្ជូនកងកម្លាំងរក្សាសន្តិភាពសរុប ចំនួន ៨ ៦៧១ នាក់ ទៅបំពេញបេសកកម្មរក្សាសន្តិភាព នៅក្នុងប្រទេសជាច្រើន។ ជាពិសេស រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តគោលជំហរមិនចូលរួមជាមួយយន្តការតំបន់ ឬអន្តរជាតិណាមួយដែលមានចរិតនយោបាយ និងបង្កើតឡើងដើម្បីប្រឆាំងជាមួយប្រទេសណាមួយ ឬប្លុកណាមួយនោះទេ។

ជាមួយគ្នានេះ ការរក្សាបូរណភាពទឹកដី, ការងារខណ្ឌសីមា និងការបោះបង្គោលព្រំដែនជាមួយបណ្តាប្រទេសជិតខាង ក៏ដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់តាមបណ្តោយព្រំដែន ដើម្បីឱ្យតំបន់ព្រំដែនក្លាយទៅជាតំបន់នៃការអភិវឌ្ឍ នៅតែជាអាទិភាពដ៏សំខាន់បំផុតមួយរបស់រាជរដ្ឋាភិបាល។ ក្នុងបុព្វហេតុដ៏ថ្លៃថ្លានេះ កម្ពុជាបានពង្រឹងនូវយន្តការសម្រាប់ការងារខណ្ឌសីមា ជាមួយប្រទេសជិតខាងដូចជា ការរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះព្រំដែនកម្ពុជា- វៀតណាម ការរៀបចំកិច្ចប្រជុំអនុគណៈកម្មការបច្ចេកទេសចម្រុះកម្ពុជា- ថៃ និងការផ្លាស់ប្តូរលិខិតុបករណ៍សច្ចាប័នលើសន្ធិសញ្ញាកំណត់ព្រំដែនកម្ពុជា- ឡាវ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការមេសម្រាប់រយៈពេល ១០ឆ្នាំ(ឆ្នាំ២០២៤-២០៣៤) សម្រាប់ការងារបោះបង្គោលសីមា ការកសាងផ្លូវចូលទីតាំងបង្គោលព្រំដែន និងការកសាងផ្លូវ ខ្សែក្រវាត់ព្រំដែនលើដីដែលបានឯកភាពគ្នារួច ជាមួយវៀតណាម ឡាវ និងថៃ។ ជាពិសេស ក្នុងគោលបំណងការពារបូរណភាពទឹកដី ក៏ដូចជាឧត្តមប្រយោជន៍ជាតិ និងប្រជាជនខ្មែរ ក៏ដូចជាបន្តរក្សានូវខ្សែបន្ទាត់ព្រំដែនស្របតាមផែនទីដែលទទួលស្គាល់ដោយអន្តរជាតិ លិខិតផ្លូវការរបស់កម្ពុជាទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ(ICJ) ដើម្បីជួយស្វែងរកដំណោះស្រាយបញ្ហាវិវាទព្រំដែននៅតំបន់ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបី ត្រូវបាន លោកជំទាវ គឹមសួគិ សុវណ្ណារី ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសហូឡង់ ប្រគល់ដោយផ្ទាល់ដៃជូនលោកក្រឡាបញ្ជី Philippe Gautier នៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ ការបញ្ជូនសំណុំរឿងតុលាការយុត្តិធម៌អន្តរជាតិ (ICJ) គឺជាជម្រើសរបស់កម្ពុជាក្នុងការជ្រើសយកសន្តិភាព និងជម្រើសនៃការអនុវត្តច្បាប់អន្តរជាតិ។

## ២.ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្នុងការកសាងសេដ្ឋកិច្ច កម្ពុជាបានប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារតាមរយៈ÷ ១).ការបើកចំហជាបន្តបន្ទាប់នូវការធ្វើពាណិជ្ជកម្មអន្តរជាតិ ឈរលើគោលការណ៍ពហុភាគីនិយម រួមទាំងការធ្វើពិពិធកម្មទីផ្សារ និងទំនិញ ព្រមទាំងការពង្រឹង និងការពង្រីកការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងការជំរុញបន្ថែមនូវការតភ្ជាប់ក្នុងតំបន់ ២).ការជំរុញ និងការទាក់ទាញបន្ថែមនូវការវិនិយោគផ្ទាល់ពីបរទេស តាមរយៈការកែសម្រួលនូវបរិយាកាសធុរកិច្ច និងវិនិយោគ ៣).ការពង្រឹង និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរឹង ដូចជា ផ្លូវ ថ្នល់ ទឹក និងអគ្គិសនី ដើម្បីលើកកម្ពស់ការតភ្ជាប់ និងភាពប្រកួតប្រជែង ៤).ការបន្តអភិវឌ្ឍ និងការលើកកម្ពស់មូលធនមនុស្ស ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងបង្កើនផលិតភាព និង៥).ការកែទម្រង់ស្ថាប័ន និងអភិបាលកិច្ចជាប្រចាំ សម្រាប់ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ច ជាពិសេសប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធធនាគារ ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

នៅក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព ក្នុងអត្រាកំណើនជាមធ្យមប្រមាណជា ៦% ក្នុងមួយឆ្នាំ ដែលនាំឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ត្រូវបានផ្លាស់ប្តូរពីសេដ្ឋកិច្ចដែលពឹងផ្អែកជាចម្បងលើកសិកម្ម

ប្រពៃណី ទៅជាសេដ្ឋកិច្ចទំនើបដែលពឹងផ្អែកលើកសិកម្មវៃឆ្លាត ឧស្សាហកម្ម និងសេវាកម្ម និងមានការតភ្ជាប់កាន់តែខ្លាំងទៅនឹងខ្សែច្រវាក់តម្លៃ និងខ្សែច្រវាក់ផ្គត់ផ្គង់ នៅក្នុងតំបន់និងសកល រួមជាមួយនឹងការកើតមានឡើងនូវឧស្សាហកម្មថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់, ព្រមទាំងការបន្តពង្រឹង និងការពង្រីកពិពិធកម្មមូលដ្ឋានឧស្សាហកម្ម និងពាណិជ្ជកម្មអន្តរជាតិ។ ជាក់ស្តែង ទំហំនៃចំណែកវិស័យកសិកម្ម បានថយចុះពី ៣៥,៥៣% នៃផ.ស.ស នៅក្នុងឆ្នាំ២០០០ មកនៅត្រឹម ១៥,៨៥% នៃផ.ស.ស នៅក្នុងឆ្នាំ២០២៣ ខណៈទំហំនៃចំណែកវិស័យឧស្សាហកម្ម បានកើនឡើងពី ២១,៦៥% នៃផ.ស.ស ដល់ ៤០,៥២% នៃផ.ស.ស. ក្នុងរយៈពេលដូចគ្នា។ ទន្ទឹមនេះ កម្រិតជីវភាពប្រជាជនបានបន្តមានភាពប្រសើរឡើង ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃទំហំផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ប្រមាណ១២ដង គឺពីប្រមាណ ៣,៦៦ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ ២០០០ ដល់ប្រមាណ ៤៣,០៧ ប៊ីលាន ដុល្លារអាមេរិក នៅឆ្នាំ ២០២៣ ខណៈដែល ផ.ស.ស សម្រាប់មនុស្សម្នាក់ បានកើនឡើងប្រមាណ ៨ ដង គឺពីក្រោម ៣០០ ដុល្លារអាមេរិក មកដល់ ប្រមាណ ២៥០០ ដុល្លារអាមេរិក ក្នុងរយៈពេលដូចគ្នា។ ការប្រមូលចំណូលក្នុងស្រុកសរុប បានកើនឡើងពីប្រមាណ ១ ៤២២ ប៊ីលានរៀល ឬ ៩,៩៩% នៃ ផ.ស.ស ក្នុងឆ្នាំ ២០០០ ដល់ប្រមាណ ២៨ ៥៩២ ប៊ីលានរៀល ឬ១៦,១៥% នៃផ.ស.ស ក្នុងឆ្នាំ ២០២៣។ ទន្ទឹមនេះ ចំណាយសរុបបានបន្តកើនឡើងពីប្រមាណ ២ ០៣៩ ប៊ីលានរៀល ឬ ១៤,៣៣% នៃផ.ស.ស នៅឆ្នាំ២០០០ ដល់ប្រមាណ ៣៥ ៣១០ ប៊ីលានរៀល ឬ ១៩,៩៥% នៃផ.ស.ស នៅឆ្នាំ២០២៣ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអនុវត្តកម្មវិធីនយោបាយរបស់ខ្លួន បានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ខណៈដែលសន្និធិបំណុលសាធារណៈក្រៅប្រទេស ត្រូវបានគ្រប់គ្រងក្នុងកម្រិតទាប។

បន្ថែមលើនេះ វិស័យហិរញ្ញវត្ថុ ទាំងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានការរីកចម្រើនយ៉ាងរហ័សគួរឱ្យកត់សម្គាល់។ ជាក់ស្តែង នៅក្នុងឆ្នាំ២០២៣ ទ្រព្យសកម្មសរុបនៅក្នុងវិស័យធនាគារមានទំហំប្រមាណ ៣៤៥,១ ទ្រីលានរៀល (៨៤,៥ ប៊ីលានដុល្លារអាមេរិក) ឥណទានដុលមានទំហំប្រមាណ ២២១,២ ទ្រីលានរៀល (៥៤,៨ ប៊ីលានដុល្លារអាមេរិក) និងប្រាក់បញ្ញើអតិថិជនមានប្រមាណជា ១៩៧,២ ទ្រីលានរៀល (៤៨,៣ ប៊ីលានដុល្លារអាមេរិក) ហើយទុនបម្រុងអន្តរជាតិត្រូវបានគរពូនជាលំដាប់ដល់ ១៨ ប៊ីលានដុល្លារអាមេរិក។ រូបិយវត្ថុចរាចរណ៍ក្នុងទីផ្សារ និងប្រាក់បញ្ញើជារៀល បានកើនឡើងប្រមាណ៥៥ដង ខណៈការប្រើប្រាស់ប្រព័ន្ធទូទាត់ បានកើនឡើងយ៉ាងរហ័ស ដោយទឹកប្រាក់ទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក មានទំហំស្មើនឹងប្រមាណ១០ដង នៃផ.ស.ស។ ការជួញដូរមូលបត្រ សរុបគិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន៣១០,៨ លានដុល្លារអាមេរិក ខណៈដែលមូលធនូបនីយកម្មទីផ្សារ (Market Capitalization) មានទំហំប្រមាណ ១០,៣៧% នៃ ផ.ស.ស។ ក្នុងរយៈពេលដូចគ្នា ទំហំទីផ្សារធានារ៉ាប់រងរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបុព្វលាភធានារ៉ាប់រង មានចំនួន ៣៣២ លានដុល្លារអាមេរិក និងមានកំណើន ២៨% ជាមធ្យមប្រចាំឆ្នាំ។ ទន្ទឹមនេះ វិហូវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា នៅបន្តនិន្នាការកើន ក្នុងរង្វង់ប្រមាណ ៣ ៩៥៩ លានដុល្លារអាមេរិក ឬ ប្រមាណ ៩,២% នៃផ.ស.ស. ជាមួយនឹងកំណើន

ប្រមាណ ១០,៦% ធៀបនឹងឆ្នាំ ២០២២ ដែលត្រូវបានជំរុញដោយការវិនិយោគក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរដូចជា÷ ផលិតកម្មសំបកកង់រថយន្ត សូឡា ផលិតផលវេចខ្ចប់ ចំណីអាហារកែច្នៃ និងសំបកកំប៉ុង និងលោហធាតុជាដើម ស្របពេលដែលការវិនិយោគក្នុងវិស័យធនាគារនៅបន្តរក្សាបានចលនការល្អ។ ការណ៍នេះ ធ្វើឱ្យទុនបម្រុងអន្តរជាតិពូនគរ ក្នុងរង្វង់ ១៩ ៩៩៨ លានដុល្លារអាមេរិក ដែលស្មើនឹងប្រមាណ ៨,២ ខែនៃការនាំចូល។

### ៣.ផ្នែកស្ថាប័ន និងអភិបាលកិច្ច

កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការកែទម្រង់ស្ថាប័ន និងអភិបាលកិច្ច តាមរយៈប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងន័យបង្កើនភាពជឿទុកចិត្តបាននៃថវិកា ការលើកកម្ពស់គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការពង្រឹងគណនេយ្យភាព សមិទ្ធកម្ម ដែលបានរួមចំណែកដល់ការលើកកម្ពស់ប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច ដែលកំណត់ចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមមួយនោះគឺ “ការកែប្រែប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាក្លាយជាប្រព័ន្ធមួយដែលផ្តោតលើលទ្ធផល សមិទ្ធកម្ម និងវិមជ្ឈការស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានបែងចែកជា៤ដំណាក់កាលរួមមាន÷ **ដំណាក់កាលទី១** គឺ “ភាពជឿទុកចិត្តបាននៃថវិកា” ដែលរក្សាបាននូវភាពរឹងមាំ និងឆ្លុះបញ្ចាំងពីភាពធន់នៃហិរញ្ញវត្ថុសាធារណៈ ដែលការអនុវត្តថវិកា (ចំណូល-ចំណាយ) ស្ថិតក្នុងរង្វង់+/-៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបង្ហាញពីភាពរលូន និងអាចប៉ាន់ប្រមាណក្នុងការឆ្លើយតបបានតាមសភាពការណ៍។ **ដំណាក់កាលទី២** “គណនេយ្យភាពហិរញ្ញវត្ថុ” ជាដំណាក់កាលដែលពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តមាតិកាថវិកាស្តង់ដាគណនេយ្យ និងប្លង់គណនី និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)។ FMIS ត្រូវបានពង្រីកដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន និងបានពង្រីកដល់រដ្ឋបាលរាជធានី-ខេត្តទាំង២៥ជាផ្លូវការសម្រាប់ប្រតិបត្តិការឆ្នាំ២០២២។ **ដំណាក់កាលទី៣** “ការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ” ដោយផ្តោតសំខាន់លើការផ្សារភ្ជាប់រវាងគោលដៅ និងគោលបំណងនៃការរៀបចំ និងអនុវត្តថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន។ តាមរយៈការដាក់ឱ្យអនុវត្តក្របខ័ណ្ឌថវិការយៈពេលមធ្យម(MTBF) ដែលជាមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននៅកម្រិតថវិកាថ្នាក់ជាតិ ក៏ដូចជាការជំរុញការធ្វើសមាហរណកម្មផែនការថវិការវាងថវិកាចរន្ត និងមូលធន។ **ដំណាក់កាលទី៤** “គណនេយ្យភាពសមិទ្ធកម្ម” ជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានគ្រោងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២៣ដល់ឆ្នាំ២០២៧ ក្នុងគោលដៅកសាងវប្បធម៌សមិទ្ធកម្ម នៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា។

លើសពីនេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានកែសម្រួលឱ្យប្រសើរឡើង ជាពិសេស ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស ការផ្ទេរមុខងារថវិកានិងការទទួលខុសត្រូវទៅ

ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយនេះ ក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវបានកែទម្រង់ស៊ីជម្រៅ តាមរយៈការដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍តំបន់ ការលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងស្ថាប័ន នៅក្នុងវិស័យយុត្តិធម៌ ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច ការលើកកម្ពស់យន្តការផ្តល់សេវាជំនួយផ្នែកច្បាប់ ការជំរុញការដោះស្រាយការកកស្ទះសំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្ត និងការលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ កងកម្លាំងប្រដាប់អាវុធ ត្រូវបានកែទម្រង់ ជាពិសេសតាមរយៈការពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងការធ្វើទំនើបកម្មកងកម្លាំងប្រដាប់អាវុធ។ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានលើកកម្ពស់តាមរយៈការបង្កើតស្ថាប័ន ប្រឆាំងអំពើពុករលួយ និងការជំរុញអនុវត្ត វិធានការអប់រំ ការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសពុករលួយ។ អភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច ត្រូវបានពង្រឹងតាមរយៈការបង្កើតក្របខ័ណ្ឌនិយ័តកម្ម និងអភិបាលកិច្ចសាជីវកម្ម។

បន្ថែមលើនេះ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា ត្រូវបានពង្រឹងគួរឱ្យកត់សម្គាល់ ដោយបានផ្ទេរមុខងារ និងភារកិច្ចជាច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈយន្តការ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)។ គិតមកត្រឹមឆ្នាំ២០២៤ គ.ជ.អ.ប បាននិងកំពុងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដំណាក់កាលទី២ ដែលបានបន្តផ្តោតលើការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យកាន់តែមានភាពរឹងមាំ ស្អាតស្អំ មានសមត្ថភាព លទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការធ្វើទំនើបកម្ម ការលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពយន្តការ និងនីតិវិធីនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ ជាក់ស្តែង ក្នុងឆ្នាំ២០២៤ អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត បានផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋចំនួន ៥៩៩ ១៣៩ ដង ក្នុង ១៤វិស័យ ដែលទទួលបានចំណូលសរុបចំនួន ៨៥១,៩៦ប៊ីលានរៀល(ស្មើនឹង២១ ២៩៩ ២២១ ដុល្លារអាមេរិក)។ ដោយឡែក ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌទាំង២០៨ បានផ្តល់សេវារដ្ឋបាលសរុបចំនួន ២ ៥៦៥ ៥៣០ដង ក្នុង១៧វិស័យ ដែលទទួលបានចំណូលសរុបប្រមាណ ៧,១៥ ប៊ីលានរៀល(ស្មើនឹង ១ ៧៨៩ ៣៧៩ ដុល្លារអាមេរិក)។ ទន្ទឹមនេះ ពាក់ព័ន្ធនឹងការពង្រឹងវិមជ្ឈការហិរញ្ញវត្ថុទៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវអនុក្រឹត្យស្តីពី ការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក ពីឆ្នាំ២០២៤-២០២៨ ក្នុងអត្រាថេរប្រចាំឆ្នាំ ១,៦% ដែលអត្រានេះមានការកើនឡើង០,១% ធៀបទៅនឹងអត្រាផ្ទេរនៅក្នុងឆ្នាំ ២០២៣។ លើសពីនេះ ប្រព័ន្ធឌីជីថលត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ដោយបាននិងកំពុងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធផ្តល់សេវារដ្ឋបាលតាមអនឡាញនៅថ្នាក់រាជធានី-ខេត្តចំនួន១២ លើប្រភេទសេវារដ្ឋបាលចំនួន១១៧ ក្នុងវិស័យចំនួន៤ រួមមាន វិស័យទេសចរណ៍ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ វិស័យឧស្សាហកម្ម និងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៤. ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់

គិតត្រឹមឆ្នាំ២០២២ កម្ពុជាសម្រេចបានការសាងសង់ផ្លូវជាតិ និងផ្លូវតាមខេត្ត ដោយក្រាលកៅស៊ូ និងបេតុងគ្រប់ប្រភេទ ប្រវែង១១ ០៤២គីឡូម៉ែត្រ ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ប្រវែង១៨៧,៥ គីឡូម៉ែត្រ ស្ពានតូច-ធំ គ្រប់ប្រភេទ ចំនួន២ ៥៣០ ស្ពានប្រវែង ៨៦,២ គីឡូម៉ែត្រ បណ្តាញផ្លូវនាវាចរណ៍ តាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ប្រវែង ១ ៧៥០គីឡូម៉ែត្រ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានពង្រីក និងធ្វើទំនើបកម្មផងដែរ នូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗផ្សេងទៀត ជាពិសេសអាកាសយានដ្ឋាន កំពង់ផែទឹកជ្រៅ ផ្លូវនាវាចរណ៍ និងប្រព័ន្ធឡូជីស្ទីក។ បន្ថែមលើនេះ ហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ តាមរយៈការកើនឡើងនៃការតភ្ជាប់បណ្តាញខ្សែកាបអុបទិកលើគោក និងក្រោមបាតសមុទ្រ ការកើនឡើងជាគំហុកនៃការប្រើប្រាស់សេវាទូរសព្ទ និងអ៊ីនធឺណិត និងការដាក់ឱ្យប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ថ្នាលផ្ទៀងផ្ទាត់ឯកសារ ព្រមទាំងប្រព័ន្ធ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាមួយគ្នានេះ វិស័យអាកាសចរស៊ីវិល គឺជាឧស្សាហកម្មមួយប្រភេទដែលកំពុងតែមានការរីកលូតលាស់ទាំងក្នុងតំបន់ និងក្នុងពិភពលោកទាំងមូល ដោយសារតែវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ការធ្វើដំណើរ និងដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងរយៈពេលដ៏ខ្លី និងជាមធ្យោបាយក្នុងការជំរុញសកម្មភាពធុរកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ ការលើកកម្ពស់ទំនាក់ទំនងសង្គម ការចូលរួមចំណែកបង្កើនចំណូលជូនជាតិសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ តាមរយៈ "គោលនយោបាយបើកចំហជើងមេឃ" របស់រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យវិស័យអាកាសចរស៊ីវិល មានការរីកចម្រើនគួរជាទីមោទនៈ ដោយសម្រេចបាននូវស្នាដៃសមិទ្ធផលធំៗជាច្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធនាំផ្លូវហោះហើរ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប ការពង្រីកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ការកសាងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរថ្មី អាកាសយានដ្ឋានអន្តរជាតិតារាសាគរ គម្រោងសាងសង់អាកាសយានដ្ឋានខេត្តមណ្ឌលគីរី បានពង្រីកស្ថានីយអ្នកដំណើរ ព្រមទាំងការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិបច្ចេកទេស ដើម្បីរក្សាបាននូវការពង្រឹងសន្តិសុខ សុវត្ថិភាព លើវិស័យអាកាសចរស៊ីវិល ដែលមុនវិបត្តិកូវីដ-១៩ យើងរក្សាបាននូវកំណើនអ្នកដំណើរតាមផ្លូវអាកាសប្រមាណ១៨% ចាប់តាំងពីឆ្នាំ២០០៨មក និងមានចំនួនអ្នកដំណើរតាមផ្លូវអាកាសប្រមាណជាង ១១ លាននាក់ក្នុងឆ្នាំ២០១៩ ហើយបាននឹងកំពុងវិលត្រឡប់មកទៅស្ថានភាពធម្មតាវិញដោយទទួលបានសមិទ្ធផលគួរឱ្យកត់សម្គាល់ ដោយក្នុងឆ្នាំ២០២៤ មានអ្នកធ្វើដំណើរតាមផ្លូវអាកាសសរុបប្រមាណចំនួន ៦,២៤លាននាក់ ដែលមានកំណើនប្រមាណ២២% បើប្រៀបធៀបឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ អាកាសយានដ្ឋានអន្តរជាតិតេជោ ជាអាកាសយានដ្ឋានធំជាងគេនៅកម្ពុជា លំដាប់4F នឹងបើកឱ្យប្រតិបត្តិការក្នុងឆ្នាំ២០២៥ សាងសង់ឡើងលើផ្ទៃដីជាង ២ ៦០០ហិចតា ដែលអាចធ្វើឱ្យយន្តហោះខ្នាតធំចុះចតបានដូចជា ប្រភេទ Airbus A380 និងប្រភេទ Boeing 747 និងអាចទទួលអ្នកដំណើរបានរហូតដល់ ១៣លាននាក់ ក្នុង១ឆ្នាំ ក្នុងដំណាក់កាលទី១។

ពាក់ព័ន្ធនឹង ការធ្វើទំនើបកម្មវិស័យឌីជីថល កម្ពុជាបាននិងកំពុងជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំដោយផ្តោតលើការធ្វើទំនើបកម្មឌីជីថលពីប្រព័ន្ធ 4G ទៅប្រព័ន្ធ 5G ឆ្ពោះទៅកាន់ការអភិវឌ្ឍល្បឿនលឿន ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋ និងដើម្បីវិវត្តខ្លួនទៅជាសេដ្ឋកិច្ចឌីជីថល ឬឧស្សាហកម្ម៤.០។

### ៥. ផ្នែកសង្គម និងវប្បធម៌

វិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកែទម្រង់ជាប្រចាំ និងសម្រេចបានសមិទ្ធផលជាច្រើន ទាំងបរិមាណ និងគុណភាព។ ជាមួយគ្នានេះ វិស័យសុខភាពសាធារណៈ និងអាហារូបត្ថម្ភត្រូវបានកែលម្អ និងពង្រឹង ដែលធ្វើឱ្យកម្ពុជាមានសមត្ថភាពពេញលេញ ក្នុងការប្រយុទ្ធឈ្នះវិបត្តិសុខភាពសាធារណៈ ដូចជាការសម្រេចបាន ជោគជ័យខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការកាត់បន្ថយយ៉ាងខ្លាំងនូវអត្រាមរណភាព មាតា ទារក និង កុមារ អត្រាឈឺ និងស្លាប់ដោយជំងឺ និងអត្រាក្រិនរបស់កុមារអាយុក្រោម ៥ ឆ្នាំ និងការលុបបំបាត់ជំងឺចម្បងៗ ជាច្រើនទៀត។ លើសពីនេះ ប្រព័ន្ធគាំពារសង្គម ត្រូវបានពង្រឹង និងពង្រីក ដែលបានជួយរក្សានូវលំនឹងជីវភាពជាពិសេសប្រជាជននៅក្នុងគ្រាមាន គ្រោះអាសន្ន ឬវិបត្តិនានា ដូចជាការរាតត្បាតនៃជំងឺកូវីដ-១៩ ជាដើម តាមរយៈ ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ការកសាងប្រព័ន្ធគាំពារសង្គម ការបង្កើតនិយ័តករ សន្តិសុខសង្គម និងមូលនិធិជាតិជំនួយសង្គម និងការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យប្រព័ន្ធគាំពារសង្គម។ លើសពីនេះ ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតាមរាជធានី-ខេត្ត ត្រូវបានអនុវត្តទាំងនីតិវិធីអត្តសញ្ញាណគ្រួសារ ក្រីក្រនៅទីប្រជុំជន និងទាំងនីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រនៅទីជនបទ ចាប់តាំងពីឆ្នាំ២០១៦មក។ រាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលជាការធ្វើសមាហរណកម្ម កម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ កម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា ចំណេះទូទៅ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា និងបញ្ចូល បន្ថែមនូវការឧបត្ថម្ភគោលគ្រួសារ សម្រាប់គ្រួសារដែលមានបណ្ណសមធម៌ទាំងអស់ និងការឧបត្ថម្ភសមាជិកគ្រួសារ ជាអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងគោលបំណង គាំទ្រដល់កិច្ចអន្តរាគមន៍ជាបន្ទាន់ដល់ប្រជាពលរដ្ឋ ទាំងអស់ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ជាពិសេស គ្រួសារក្រីក្រនិងគ្រួសារទទួលរងផលប៉ះពាល់ខ្លាំង ជាងគេ ។ ចំពោះផ្នែកយេនឌ័រ តួនាទីរបស់ស្ត្រីកម្ពុជាត្រូវបាន លើកកម្ពស់ជាបន្តបន្ទាប់ តាមរយៈការធ្វើស្ថាប័នីយកម្ម និងការបញ្ជ្រាបយេនឌ័រដែលធ្វើឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ខ្ពស់បំផុត ជាប្រទេសផ្តល់ សេរីភាពទូលំទូលាយ សម្រាប់ស្ត្រី។

ក្នុងវិស័យវប្បធម៌ មរតកសិល្បៈវប្បធម៌ ដែលបានបាត់បង់ និង/ឬប្រឈមនឹងការបាត់បង់ត្រូវបានស្តារ ឱ្យរស់ឡើងវិញ និងលើកកម្ពស់បន្ថែមទៀតដែលបានស្នួយឱ្យខ្ពស់ត្រដែតនូវកិត្យានុភាពជាតិ ព្រមទាំងជំរុញ ទេសចរណ៍វប្បធម៌ និងការអភិវឌ្ឍសិល្បៈវប្បធម៌របស់ជាតិ។ ជាក់ស្តែង បេតិកភណ្ឌវប្បធម៌ជាតិ សរុបចំនួន១១ ត្រូវ បានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក បញ្ជីបេតិកភណ្ឌវប្បធម៌រូបិយនៃមនុស្សជាតិ និងបញ្ជីស្មារតីចងចាំពិភពលោក សំណង់បេតិកភណ្ឌសរុបចំនួន ១៩៥ ត្រូវបានជួសជុល វត្ថុបុរាណសរុបចំនួន ៦៣៤ ត្រូវបានបញ្ជូនពីបរទេស ត្រឡប់មកកម្ពុជា វត្ថុបុរាណចំនួន ៦ ១០៥ ត្រូវបានជួសជុល និងអភិរក្ស និងវត្ថុបុរាណសរុបចំនួន ១១ ៨០៤ ដែល ទទួលបានមកវិញ ត្រូវបានធ្វើបណ្ណកម្មសិទ្ធិរដ្ឋ។

## ឯកសារយោង


១- គណបក្សប្រជាជនកម្ពុជា (២០២៣) កម្មវិធីគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ការកសាង និងការពារមាតុភូមិឆ្នាំ២០២៣-២០២៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

២- គណបក្សប្រជាជនកម្ពុជា (២០២៥) របាយការណ៍ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជូនសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៤៥ អាណត្តិទី៥ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

៣- រាជរដ្ឋាភិបាលកម្ពុជា (២០២៣) យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

៤- រាជរដ្ឋាភិបាលកម្ពុជា(២០២៤) ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

៥- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១៧) សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រាជធានី រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

៦- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១៧) សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្ត រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

៧- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (២០២០) គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្ត រាជធានីភ្នំពេញ ប្រទេសកម្ពុជា។